# កម្រងមាស

## ភាគ ១

វត្តនិគ្រោធវ័ន គល់ទទឹង

និពន្ធ រៀបរៀងដោយ

ព្រះមហាសទ្ធម្មធរជោតិកៈ

សុវណ្ណជោតោ ភួង-សុវណ្ណ

ពុទ្ធសករាជ ២៥៦០

~សៀវភៅ **កម្រងមាស ភាគ ១**

~និពន្ធ រៀបរៀងដោយ **ព្រះមហាសទ្ធម្មធរជោតិកៈ**

**សុវណ្ណជោតោ គួច~សុវណ្ណ**

ជាអាចារ្យបង្រៀនព្រះវិន័យ ឧត្តមសិក្សាវត្តនិគ្រោធវ័ន

~អ្នកជួយពិនិត្យ

- ភិក្ខុ សុមេធបណ្ឌិតោ ស៊ិន ផល្លា
-សាមណេរ មុនីកោសល្យ នៅ ហៃឡុន
-ឧបាសក ដាំ កុយ

~ទីកន្លែងធ្វើ **វត្តនិគ្រោធវ័ន “គល់ទទឹង”** រាជធានីភ្នំពេញ

~សម្រាប់ជាធម្មទាន

~ពុទ្ធសករាជ ២៥៦០

# អារម្ភកថា

ទ្រព្យឯងណាមួយ ក្នុងលោកនេះក្តី និងក្នុងលោកឯទៀតក្តី រតនៈវត្ថុដ៏ឧត្តមឯណា ក្នុងឋានសួគ៌ក្តី ទ្រព្យនិងរតនៈវត្ថុទាំងនោះ ស្មើដោយព្រះតថាគតមិនមានឡើយ ។ ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលដ៏ប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ ព្រះអង្គប្រសើរឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្តែងហើយនូវធម៌ដ៏ប្រសើរ កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម ។

ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ឯណា ជាទីក្ស័យនៃកិលេស ជាទីប្រាសចាករាគៈ ជាធម៌មិនស្លាប់ ជាធម៌ដ៏ឧត្តម របស់អ្វីមួយស្មើដោយព្រះធម៌នោះមិនមានឡើយ ។

បុគ្គលទាំងឡាយឯណា ៨ ជំពូក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវ័ករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន, ទានទាំងឡាយដែលបុគ្គលឲ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំង ឡាយនោះ ជាទានមានផលច្រើន, កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន ។

សៀវភៅកម្រងមាស គឺជាកម្រងអត្ថបទធម៌ដ៏មានតម្លៃដែលបានចងក្រងនិងរៀបរៀងឡើង ដោយបានលើកយកព្រះពុទ្ធភាសិតខ្លះ ព្រះពុទ្ធគាថាខ្លះ និងកំណាព្យធម៌ផ្សេងៗ ភ្ជាប់ជាមួយព្រះពុទ្ធភាសិត ព្រះពុទ្ធគាថា ទាក់ទងនឹងថ្ងៃនក្ខត្តឫក្សរបស់ព្រះសម្មាសម្ពុទ្ធ

ជាម្ចាស់ គុណមាតាបិតា ជីវិតគ្រួសារ មិត្ត បុណ្យចូលឆ្នាំ សង្ខារធម៌ ញញឹម ពុទ្ធស្ថាន និងអត្ថបទធម៌សម្រាប់សិក្សាពិចារណា អប់រំផ្សេងៗជាច្រើន ។ អត្ថបទទាំងអស់នេះ ខ្ញុំព្រះការុណា អាត្មាភាព បានចងក្រងជាច្រើនឆ្នាំមកហើយ ដោយមានសំណូមពរពីពុទ្ធបរិស័ទផង និងព្រោះបានជួបហេតុផ្សេងៗ ក៏មានចិត្តចង់សរសេរឡើង ទុកជាបទសិក្សាអប់រំ តាមន័យព្រះធម៌ ។

ដោយមហាកុសលចេតនាដ៏ល្អបរិសុទ្ធ ប្រកបដោយសទ្ធា និងបញ្ញាបន្តិចបន្តួច ក្នុងការរៀបរៀង និពន្ធអត្ថបទធម៌ផ្សេងៗ ក្នុងទិសដៅធម្មទាន សូមបានសេចក្តីសុខ មានបញ្ញា មាន សម្មាទិដ្ឋិ និងសូមឲ្យបានសម្រេចនូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ ក្នុងសាសនារបស់ព្រះពុទ្ធ។

ម្យ៉ាងទៀត សូមបុណ្យធម្មទាននេះ បានសម្រេចដល់ញាតិទាំងឡាយ ពុទ្ធបរិស័ទទាំងឡាយ សព្វសត្វទាំងឡាយ ទាំងមនុស្សទាំងអមនុស្ស សូមអនុមោទនា សូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខ រួចផុតចាកទុក្ខទាំងពួង ។

ថ្ងៃ ១ កើត ខែមិគសិរ ពុទ្ធសករាជ២៥៦០

**ភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ**

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## កម្រងមាស

អារម្ភកថា .................................................. គ
សន្លឹកប្រាប់មាតិកា .................................................. ង
១-ថ្ងៃនក្ខត្តឫក្សរបស់ព្រះពុទ្ធ .................................................. ១
២-អាសាឍបុណ្ណមី .................................................. ២
៣-វិសាខបុណ្ណមី .................................................. ៤
៤-មាឃបុណ្ណមី .................................................. ៥
៥-មាឃបូជា .................................................. ៦
៦-ថ្ងៃទ្រង់ប្រសូត .................................................. ៨
៧-ថ្ងៃទ្រង់ត្រាស់ដឹង .................................................. ១០
៨-ថ្ងៃទ្រង់បរិនិព្វាន .................................................. ១២
៩-គប្បីយល់ដឹងពីគុណមាតាបិតា
ហឫទ័យមាតា .................................................. ១៥
១០-រលឹកដល់គុណ .................................................. ១៨
១១-ព្រហ្មសូត្រ .................................................. ២០

១២-នាមជាប់ដោយគុណ ...................................... ២២

១៣-បុណ្យចម្រើនជន្មាយុ ...................................... ២៣

១៤-កូនអើយគេងទៅ ...................................... ២៥

១៥-ស្រណោះដល់អ្នកម្ដាយ ...................................... ២៦

១៦-ផលតបស្នងសងគុណ ...................................... ២៧

១៧-កូនត្រូវទំនុកបម្រុងមាតាបិតាដោយស្ថាន ៥ យ៉ាង ....... ២៩

១៨-តួនាទីរបស់កូន ៥ យ៉ាង ...................................... ៣០

១៩-ឱ! កូនពុំងា ...................................... ៣១

២០-អាពុកគឺជាព្រះបិតា ...................................... ៣៤

២១-បុត្រ ៣ ប្រការ ...................................... ៣៦

កំណាព្យ កូន ៣ ប្រការ ...................................... ៣៦

២២-ថ្ងៃខួបកំណើត...................................... ៣៧

២៣-អ៊ោះអ៊ោ! អ្នកម្ដាយ ...................................... ៤០

២៤-ការគោរពគុណ និងខមាទោស ...................................... ៤២

២៥-កូនសម្ដែងការត្រេកអរ ...................................... ៤៣

២៦-កូនលាមាតាបិតាចេញសាងផ្នួស ........................... ៤៤

២៧-កូនសម្ដែងសេចក្ដីត្រេកអរ និងការអធិដ្ឋាន ............. ៤៥

២៨-កំណាព្យសូធ្យក្នុងពិធីបំបួស ................................ ៤៥

២៩-កូនចង់បួស .................................................... ៤៧

៣០-ហាទ័យមាតា .................................................... ៤៨

៣១-អត្ថបទទាក់ទងនឹងស្វាមីភរិយា ............................. ៤៩

៣២-ជូនពរស្វាមីភរិយា ............................................. ៤៩

៣៣-ជីវិតគ្រួសារ ..................................................... ៥០

៣៤-តួនាទីមាតាបិតា ៥ យ៉ាង ...................................... ៥២

៣៥-ថ្ងៃនេះខ្ញុំចង់និយាយប្រាប់ថា .............................. ៥២

៣៦-តួនាទីស្វាមី ៥ យ៉ាង ............................................ ៥៣

៣៧-ភាពជាបុរស ..................................................... ៥៣

៣៨-តួនាទីភរិយា ៥ យ៉ាង ........................................... ៥៦

៣៩-ភាពជាស្ត្រី ....................................................... ៥៧

៤០-ស្វាមី + ស្វាមី .................................................... ៥៩

៤១-ភរិយា ៧ ពួក ..................................................... ៦០

៤២-ឱវាទ ១០ យ៉ាង .................................................. ៦២

កំណាព្យ ឱវាទ ១០ យ៉ាង ........................................ ៦៣

៤៣-គប្បីយល់ដឹងពីមិត្រ ........................................... ៦៥

៤៤-មិត្តប្លួម ៤ ប្រការ ............................................... ៦៧

៤៥-មិត្តមានសន្តានល្អ ៤ ប្រការ .................................. ៦៨

៤៦-ការគប់មិត្ត .................................................. ៦៩

៤៧-សេពគប់មិត្តល្អត្រាស់ដឹងធម៌ពិត ........................... ៧១

៤៨-ឱវាទដ៏ល្អ ...................................................... ៧២

៤៩-និព្វានមិនស្លាប់ ............................................. ៧៣

៥០-អំពើល្អនិងអាក្រក់ ........................................... ៧៤

៥១-សាវ័កល្អ .................................................... ៧៥

៥២-ស្រឡាញ់នាំមកនូវទុក្ខ ...................................... ៧៧

៥៣-គួរយល់ដឹងពីបុណ្យចូលឆ្នាំ ................................. ៧៨

៥៤-ឱ ! បុណ្យចូលឆ្នាំ ............................................. ៧៩

៥៥-ឆ្នាំចាស់កន្លងចូលឆ្នាំថ្មី ........................................ ៨០

៥៦-ឆ្នាំចាស់ឆ្នាំថ្មី ................................................. ៨០

៥៧-ជូនពរឆ្នាំថ្មី .................................................. ៨១

៥៨-មមីមមៃ ជូនពរ! ............................................... ៨២

៥៩-ចូលឆ្នាំដែលល្អមានស្មារតី .................................... ៨៣

៦០-លោកិយ៍សួគ៌ា ................................................. ៨៤

៦១-គប្បីយល់ដឹងពីដំណើររបស់សង្ខារធម៌ ....................... ៨៦

៦២-គន់មើលថ្ងៃលិច ............................................... ៨៦

៦៣-ច្បាប់ធម្មជាតិ ........................................ ៨៧
៦៤-ធម្មជាតិ ........................................ ៨៨
៦៥-ធម្មជាតិ ន័យម្យ៉ាងទៀត ........................................ ៩០
៦៦-សង្ខារទាំងឡាយមិនទៀង ........................................ ៩១
៦៧-ជីវិតមិនទៀង ........................................ ៩២
៦៨-ជីវិតត្រូវស្លាប់ ........................................ ៩៣
៦៩-វេលាកន្លងយ៉ាងរហ័ស ........................................ ៩៤
៧០-មាគ៌ារំលត់ទុក្ខ ........................................ ៩៥
៧១-ដំណើរមិនទៀងនៃសង្ខារ ........................................ ៩៦
៧២-រសៀលគងភ្នំ ........................................ ៩៧
៧៣-ព្រះសាស្តា ទ្រង់មានព្រះបន្ទូលថា : ........................................ ៩៧
៧៤-សុខាជាអមតៈ ........................................ ៩៨
៧៥-ត្រូវសន្សំបុណ្យ ........................................ ៩៩
៧៦-ធ្វើបុណ្យភ្ជុំបិណ្ឌ ........................................ ១០០
៧៧-អនុមោទនានាំឱ្យបានសុខ ........................................ ១០០
៧៨-ឃ្លាតទុក្ខជួបសុខ ........................................ ១០១
៧៩-ចង់ឆ្លងផុតលោក ត្រូវប្រព្រឹត្តធម៌ ........................................ ១០២

៨០-ទេវទូត ........................................................ ១០៤

៨១-វាចាសុភាសិត ................................................ ១០៧

វាចាសុភាសិត (កំណាព្យ) ................................ ១០៧

៨២-អារាធនាធម៌ (ទី១)......................................... ១០៨

៨៣-អារាធនាធម៌ទេសនា (ទី២) ............................... ១០៩

៨៤-អារាធនាធម៌ទេសនា (ទី៣) .............................. ១១០

៨៥-សូធ្យក្រោយស្តាប់ធម៌ ......................................... ១១២

៨៦-អានិសង្សនៃការស្តាប់ព្រះសទ្ធម្ម ៥ យ៉ាង ................ ១១៤

អានិសង្សស្តាប់ធម៌ ៥ យ៉ាង (កំណាព្យ) ........... ១១៥

៨៧-ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម សាបសូន្យ ១១៦

ព្រះសទ្ធម្មសាបសូន្យដោយហេតុ ៥ យ៉ាង ......... ១១៧

៨៨-ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីញ៉ាំងព្រះសទ្ធម្ម

ឱ្យឋិតថេរ មិនសាបសូន្យ មិនអន្តរធាន .................... ១១៨

ព្រះសទ្ធម្មឋិតថេរដោយហេតុ ៥ យ៉ាង ............ ១១៨

៨៩-ចិត្តអើយចិត្តនឹក ............................................ ១២០

៩០-សីលគុណ ...................................................... ១២១

៩១-គុណសីលដ៏ល្អ .................................................. ១២២

៩២-សីលមានគុណពិត .......................................... ១២៥

៩៣-ឧបោសថសីលល្អវិសេសណាស់ ............................ ១២៦

៩៤-អ្នកមានសទ្ធាជាដើម ............................ ១២៧

៩៥-រស់ដោយបញ្ញា ............................ ១២៨

៩៦-ទសបុញ្ញកិរិយាវត្ថុ ............................ ១២៩

៩៧-ល្អអើយល្អណាស់ ............................ ១៣០

៩៨-ល្អអ្វីល្អម្លេះ ............................ ១៣១

៩៩-ល្អព្រោះប្រតិបត្តិ ............................ ១៣២

១០០-ការចេះស្គាល់ខ្លួន ............................ ១៣៣

១០១-ស្គាល់ពីធម្មជាតិ ............................ ១៣៣

១០២-មេឃភ្លៀងមិនស្រាក់ ............................ ១៣៥

១០៣-សិក្សាពីការញញឹម ............................ ១៣៦

១០៤-ញញឹមយកជ័យលើកិលេស ............................ ១៣៦

១០៥-ញញឹមបវរញញឹមស្ងប់ ............................ ១៣៧

១០៦-ញញឹមប្រាកដទទួលពរ ............................ ១៣៨

១០៧-ញញឹមសូមលាចាកភពបី ............................ ១៣៩

១០៨-ញញឹមបានដល់ត្រើយសុខសាន្ត ............................ ១៤០

១០៩-ញញឹមធ្វើទានរក្សាសីល ............................ ១៤១

១១០-ញញឹមលះបង់អកុសល ............................ ១៤១

១១១-ញញឹមប្រាថ្នារួចចាកទុក្ខ .................................. ១៤២

១១២-ញញឹមបូជាដោយបរិសុទ្ធ .............................. ១៤២

១១៣-ញញឹមសុខាជាអមត: .................................. ១៤២

១១៤-ញញឹមប្រាថ្នាព្រះនិព្វាន ................................ ១៤៣

១១៥-ញញឹមសុខាជានិរន្តរ៍ .................................... ១៤៣

១១៦-ញញឹមសេពគប់តែសប្បុរស .......................... ១៤៤

១១៧-ញញឹមកម្ចាត់អវិជ្ជា ........................................ ១៤៤

១១៨-ញញឹមសង្គ្រោះតាមវិន័យ ............................. ១៤៥

១១៩-ញញឹមទូន្មានដោយព្រះធម៌ .......................... ១៤៥

១២០-ញញឹមសន្តោសជាមង្គល ............................... ១៤៥

១២១- សួស្តីបវរល្អប្រសើរ ......................................... ១៤៦

១២២-សួស្តីប្រាំវេលា ................................................. ១៤៧

១២៣-សួស្តីបួនពេល .................................................. ១៤៧

១២៤-ចិត្តអើយចិត្តនឹក .................. ............................ ១៤៨

១២៥-សំវេជនីយដ្ឋាន .................. ............................ ១៥០

១២៦-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (១) .................. ១៥២

១២៧-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (២) .................. ១៥៣

១២៨-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៣) .................. ១៥៤

១២៩-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៤) .................. ១៥៥

១៣០-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៥) .................. ១៥៦

១៣១-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៦) .................. ១៥៦

១៣២-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៧) .................. ១៥៦

១៣៣-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៨) .................. ១៥៨

១៣៤-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៩) .................. ១៥៩

៧ សប្ដាហ៍ក្រោយការត្រាស់ដឹង ......................... ១៥៩

១៣៥-ស្ថានទីត្រាស់ដឹងពោធិព្រឹក្ស .............................. ១៦០

១៣៦-អាទិត្តបរិយាយសូត្រ .......................................... ១៦១

១៣៧-ឥន្ទសាលគុហា .................................................... ១៦១

១៣៨-ហែព្រះបរមសារីរិកធាតុនៅពារាណសី .............. ១៦២

១៣៩-ស្ទួនធម្មចក្ក ......................................................... ១៦៣

១៤០-ក្រុងកោសម្ពីឃោសិតារាម ................................ ១៦៤

១៤១-វាំងចាស់ព្រះបាទស្ដេចឧទេន ............................. ១៦៤

១៤២-ព្រះពាកុលៈ ......................................................... ១៦៥

១៤៣-ដែនសង្កស្សអចលចេតិយ ................................... ១៦៦

១៤៤-សតិប្បដ្ឋានព្រះធម្មី ............................................ ១៦៧

១៤៥-ស្ថានទីព្រះពុទ្ធមិនលះបង់ ................................... ១៦៧

១៤៦-ព្រះធាតុព្រះសម្មាសម្ពុទ្ធ ..................................... ១៦៨

១៤៧-បូជាព្រះបរមសារីរិកធាតុ .................................. ១៦៩

១៤៨-ព្រះពុទ្ធសម្តែងជយបរិត្ត ..................................... ១៧០

១៤៩-សេនាបតីសារីបុត្ត ............................................. ១៧២

១៥០-អង្គុលិមាល ........................................................ ១៧២

១៥១-ឯករាជសព្វសត្វតែងប្រាថ្នា................................. ១៧៣

១៥២-វិហារផ្កាឈូក ..................................................... ១៧៣

១៥៣-ប្រវត្តិកោះលង្កា ជាប់ទាក់ទងនឹងព្រះពុទ្ធ ........ ១៧៤

១៥៤-តម្ពបណ្ណិទ្វីប .................. ................................. ១៧៦

១៥៥-មហាអធិដ្ឋាន៥ប្រការរបស់ព្រះមានព្រះភាគ ... ១៧៧

១៥៦-ព្រះពុទ្ធធ្លាប់យាងទៅកោះលង្កា ...................... ១៧៩

១៥៧-ថូបារាមចេតិយ .................. ............................. ១៨១

១៥៨-សុមនកូដ .................. ..................................... ១៨២

១៥៩-សូមជូនបុណ្យ ................................................... ១៨៤

១៦០-សាធុ សាធុ ចិត្តត្រេកអរ ..................................... ១៨៤

១៦១-សាធុសាធុ ........................................................ ១៨៥

១៦២-សាធុសាធុ, ប្រពៃណាស់ ................................. ១៨៥

១៦៣-សាធុសាធុ, ល្អប្រពៃ ......................................... ១៨៦

១៦៤-ពាក្យសាធុការ .................................................... ១៨៧

១៦៥-បុណ្យប្ញូកនិងបុណ្យ............................................ ១៨៧

១៦៦-ចូលវិហារ ........................................................... ១៨៨

១៦៧-ការចម្រើនមេត្តាចិត្ត ........................................... ១៨៩

១៦៨-អានិសង្សមេត្តាមាន ១១ ប្រការ ........................ ១៩០

១៦៩-បីតិក្នុងធម៌ ........................................................ ១៩១

១៧០-ជីវិតរស់នៅដោយបញ្ញា .................. ................ ១៩១

១៧១-ព្រះពុទ្ធវចនៈគ្មានអ្វីស្មើ .................. ................ ១៩២

១៧២-សិក្ខាគាថា ......................................................... ១៩២

១៧៣-វិសុទ្ធិមគ្គ ........................................................... ១៩៣

១៧៤-អស្សុសូត្រ ......................................................... ១៩៥

១៧៥-វដ្តសង្សារជាផ្លូវឆ្ងាយ ........................................ ១៩៦

១៧៦-មគ្គអង្គប្រាំបីដ៏ប្រពៃ ......................................... ១៩៨

១៧៧-ឆ្លងសង្សារ ......................................................... ១៩៨

១៧៨-សមុទ្រ ៤ ប្រការ .................. ........................... ១៩៩

១៧៩-សមុទ្រ ១៦ ប្រការ .................. ....................... ២០០

១៨០-ឆ្លងសមុទ្រ .................. .................. .............. ២០១

១៨១-ចង់ឆ្លងសមុទ្រត្រូវខំប្រឹង .............................. ២០២

១៨២-រឿងក្នុងវដ្តៈគួរនឿយណាយ ......................... ២០២

១៨៣-សប្បុរិសធម៌៧យ៉ាង ...................................... ២០៣

កំណាព្យ សប្បុរិសធម៌ .................................... ២០៣

១៨៤-លោកធម៌ ជាអនត្តា ....................................... ២០៤

១៨៥-កាយប្រែប្រួល ................................................ ២០៥

១៨៦-ជំងឺឈឺថ្កាត់ពិតរំខាន ..................................... ២០៦

១៨៧-ត្រូវការពរជ័យពីញាតិមិត្រ ............................. ២០៧

១៨៨-ការចាយទ្រព្យដោយកម្មដ៏សមគួរ ៤ យ៉ាង ..... ២០៧

១៨៩-មានទ្រព្យត្រូវប្រើដោយបញ្ញា ......................... ២១០

១៩០-អ្នកមានសទ្ធាទឹកចិត្តបវរ ................................ ២១១

១៩១-ថ្វាយទានដល់សង្ឃឧទ្ទិសផល ...................... ២១១

១៩២-ឱកម្មវាសនា ................................................... ២១២

១៩៣-កម្មតាក់តែង ................................................... ២១៣

១៩៤-រឿងរ៉ាវកំបាំង ................................ ............. ២១៤

១៩៥-លោកីយ៍មហាជនងងឹតណាស់ ....................... ២១៦

១៩៦-សុរាមានរសមិនធម្មតា .................. ............... ២១៧

១៩៧-សុរាមានទោសច្រើន .................. .................. ២១៩

១៩៨-កុំដែលប្រពៃគឺកុំផឹក .................. .................. ២០០

១៩៩-តើយំព្រោះអ្វី ? ......... .................. ............... ២២២

២០០-ទឹកភ្នែកហូរស្រក់ចាកនេត្រា .......................... ២២២

២០១-តើអ្នកស្តាយអ្វី .................. .......................... ២២៣

២០២-តើចង់បានអ្វី .................. ............................ ២២៥

២០៣-ចង់បានចិត្តស្មោះ .................. ...................... ២២៦

២០៤-សលាកភត្ត ..................................................... ២២៧

២០៥-ធ្វើបុណ្យភ្ជុំបិណ្ឌ .............................................. ២២៧

២០៦-អស្សុជ ១៥ កើត (១) ....................................... ២២៨

២០៧-អស្សុជ ១៥ កើត (២) ...................................... ២២៨

២០៨-ព្រះសង្ឃស្រែបុណ្យ .......................................... ២២៩

២០៩-ថ្ងៃកឋិនកាល .................................................. ២៣០

២១០-ឧទ្ទិសបុណ្យនិងសច្ចាធិដ្ឋាន ................................ ២៣១

២១១-ជូនកុសល ....................................................... ២៣២

២១២-សូមបានពរជ័យ ............................................... ២៣២

២១៣-សំណាងល្អបវរសុខស្ស៊ី ................................ ២៣៣
២១៤-ដូចបានសង្ឃឹម ............................................ ២៣៤
២១៥-ដឹងសព្វដឹងគ្រប់ ............................................ ២៣៥
២១៦-កុំចង់តែឆ្ងាញ់ ............................................ ២៣៦
២១៧-លះបាបដោយកម្មកល្យាណ ........................ ២៣៧
២១៨-ឱត្រីអើយត្រី ............................................ ២៣៨
២១៩-អ្នកបួស ...................................................... ២៣៩
២២០-ក ខ ...! ...................................................... ២៤០
២២១-កុំ ១២ យ៉ាង ............................................ ២៤១
២២២-ឱ! មនុស្សលោក........................................... ២៤១
២២៣-ពរជ័យស្រីសុខសាន្ត.................................... ២៤២
២២៤-ពាក្យកុហក ពាក្យពិត.................................. ២៤៣
២២៥-ដីនៅតែដីមនុស្សស្លាប់អស់............................ ២៤៣
២២៦-សូមផ្តល់ក្តីសុខដល់មនុស្សសត្វផង................ ២៤៤
២២៧-ឈ្នះដែលប្រសើរឈ្នះខ្លួនឯង........................ ២៤៥
២២៨-ធ្វើជាមនុស្សត្រូវចេះគិត................................ ២៤៦
២២៩-នជីវតិសូត្រ ............................................... ២៤៧
២៣០-រូបចាស់ រូបថ្មី............................................... ២៤៨

២៣១-ចម្រើននូវផ្លូវសន្តិភាព.................................... ២៤៩
២៣២-សុរិយារះពីទិសខាងកើត............................... ២៥១
២៣៣-រដូវត្រជាក់ ................................................. ២៥១
២៣៤-វត្តនិគ្រោធវ័ន ............................................. ២៥២
២៣៥-និគ្រោធវ័នទីជម្រក ....................................... ២៥៤
២៣៦-វិសុទ្ធិមគ្គ .................................................... ២៥៥
២៣៧-អារាមវិសុទ្ធិមគ្គ ........................................... ២៥៦
២៣៨-អារាមវិសុទ្ធិមគ្គ ព្រៃតបោវ័ន ........................ ២៥៧
២៣៩-វិសុទ្ធិមគ្គទីជម្រក ........................................ ២៥៨
២៤០-នឹកឃើញទាំងអស់ ....................................... ២៥៩
២៤១-ឱគិរីរម្យជំរំចិត្ត............................................ ២៦០
២៤២-ក្រោយពេលភ្លៀងមេឃក៏ស្រឡះ ................ ២៦១
២៤៣-គិរីរម្យចាស់ .................................................. ២៦២
២៤៤-តំបន់ព្រៃភ្នំរមណីយដ្ឋាន ............................ ២៦៣
២៤៥-ស្ងួស្តីគិរីរម្យចាស់......................................... ២៦៣
២៤៦-អារាមព្រះសង្ឃគិរីរម្យចាស់......................... ២៦៤
២៤៧-ស្ពានកាត់អាល័យ........................................ ២៦៥
២៤៨-បុណ្យបូជាព្រះរតនត្រ័យ .............................. ២៦៥

២៤៩-បុណ្យដង្ហែព្រះធាតុ .......................................... ២៦៧

២៥០-បុណ្យនៅភ្នំបូកគោ .......................................... ២៧០

២៥១-បុណ្យប្រតិស្ឋានពោធិព្រឹក្ស ................................ ២៧៣

២៥២-បុណ្យដង្ហែអដ្ឋកថាទៅមណ្ឌលគិរី ........................ ២៧៨

២៥៣-កឋិនទានទៅមណ្ឌលគិរី .................................... ២៨៣

២៥៤-កៀនស្វាយជាស្រុកកំណើត (ទី១).................. ២៨៦

២៥៥-កៀនស្វាយជាស្រុកកំណើត (ទី២).................. ២៨៧

២៥៦-មិនគួរប្រាថ្នានូវកាមលោកីយ៍ ........................ ២៨៧

២៥៧-ទឹកដីសៀមរាប ............................................... ២៨៨


# ញញឹមទទួលនូវធម្មទាន

* ញញឹមទទួលនូវធម្មទាន ញញឹមប្រឹងរៀនដោយគោរព
ញញឹមធ្វើល្អទាំងថ្ងៃយប់ ញញឹមសូមឈប់សាងវេរា ។

* ញញឹមព្រោះស្គាល់នូវការពិត ញញឹមប្រព្រឹត្តព្រះធម្មា
ញញឹមជានិច្ចគ្រប់វេលា ញញឹមចិត្តជាបានសុខសាន្ត ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការ ចំពោះព្រះមានព្រះភាគ

ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

# ភាគ១មាស

## ១_ថ្ងៃនក្ខត្តឫក្សរបស់ព្រះពុទ្ធ

ព្រះមានព្រះភាគ មានកិរិយាត្រាច់ទៅនៃព្រះញាណ មិនមានទើសទាល់ក្នុងធមិទាំងពួងទាំងឡាយ ព្រះអង្គជាទេវតា ប្រសើរលើសជាងទេវតាទាំងឡាយ ព្រះអង្គជាព្រះឥន្ទ ប្រសើរលើសជាងព្រះឥន្ទទាំងឡាយ ព្រះអង្គជាព្រះព្រហ្ម ប្រសើរលើសជាងព្រហ្មទាំងឡាយ ព្រះអង្គមានសេចក្ដីក្លៀវក្លាដោយចតុវេសារជ្ជញ្ញាណ ព្រះអង្គទ្រទ្រង់នូវទសពលញ្ញាណ ព្រះអង្គមានព្រះញាណមិនទើសទាល់ ព្រះអង្គមានសមន្តចក្ខុ គឺសព្វញ្ញុតញ្ញាណ ។

ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ព្រះមហាបុរស ទ្រង់យាងចុះកាន់ព្រះគភិព្រះជននី ១ ទ្រង់ចេញមហាភិនិស្រ្កមណ៍ ១ ទ្រង់ប្រកាសព្រះធម្មចក្ក ១ ទ្រង់សម្ដែងយមកបាដិហារ្យ ១។

ក្នុងថ្ងៃ ១៥ កើត ខែវិសាខ ទ្រង់ប្រសូត (ក្នុងចន្លោះព្រះនគរទាំងពីរ គឺនគរកបិលវត្ថុ និងទេវទហៈ ក្នុងមង្គលសាលវ័នឈ្មោះលុម្ពិនី) ១ ទ្រង់ត្រាស់ដឹង (ក្រោមដើមពោធិព្រឹក្ស លើរតនបល្ល័ង្ក កម្ពស់ ១៤ ហត្ថ) ១ ទ្រង់បរិនិព្វាន (នៅនគរកុសិនារាក្នុងសាលវ័នរបស់ពួកមល្លក្សត្រ) ១ ។

ក្នុងថ្ងៃ ១៥ កើត ខែមាឃ ព្រះអង្គទ្រង់ប្រជុំព្រះសាវ័ក (សាវកសន្និបាត) ក្នុងវត្តវេឡុវ័ន ១ ទ្រង់ដាក់អាយុសង្ខារ (នៅបាវាលចេតិយ) ១ ។ ក្នុងថ្ងៃ ១៥ កើត ខែអស្សុជ ទ្រង់ចុះចាកទេវលោក (ជាន់តាវត្តិង្ស) ទៀបនគរសង្កស្ស ។

## ២_អាសាឍបុណ្ណមី

( បទពាក្យ ៨ )

អាសាឍបុណ្ណមី ថ្ងៃនក្ខត្តឫក្ស ធ្វើបុណ្យរំលឹកហេតុ ៥ ប្រការ
ដែលព្រះសម្ពុទ្ធវិសុទ្ធអស្ចារ្យ មានករុណាសត្វលោកកោតក្រែង ។
អាសាឍបុណ្ណមីទ្រង់ចុះកាន់គភ៌ លោកធាតុញាប់ញ័រគួរឱ្យស្ញប់ស្ញែង
ពន្លឺភ្លឺស្វាងប្រាកដជាក់ស្តែង ភ្លឺជាងសូរ្យសែង មារ ព្រហ្ម ទេព្តា។
អាសាឍបុណ្ណមី ទ្រង់សាងព្រះផ្នួស ផ្ចង់ចិត្តចំពោះដោយមានប្រាថ្នា

ឱ្យបានត្រាស់ដឹងជាព្រះសម្មា- សម្ពុទ្ធនោះណា សង្គ្រោះសព្វសត្វ ។
អាសាឍបុណ្ណមី សម្ដែងធម្មចក្រ ច្បាស់យ៉ាងប្រចក្ស ដើម្បីកម្ចាត់
នូវអកុសលឱ្យខ្ចាត់ខ្ចាយបាត់ រសាយរសាត់ពីចិត្តសន្ដាន ។
អាសាឍបុណ្ណមី ថ្ងៃកំណើតធម៌ សច្ចៈបវរ ដែលមានប៉ុន្មាន
ទ្រង់ត្រាស់ទេសនាមិនបានខកខាន ប្រសើរថ្កើងថ្កានដ៏មានលំអ ។
អាសាឍបុណ្ណមីថ្ងៃកំណើតសង្ឃ ជាបុត្រព្រះអង្គ អ្នកស្ដាប់ដោយល្អ
ត្រាស់ដឹងសច្ចៈមានចិត្តស្មោះសរ សាងផ្នួសបន្ត ក្នុងមួយរំពេច ។
អាសាឍបុណ្ណមី ធ្វើបាដិហារ្យ យមកអស្ចារ្យនិគ្រន្ថរត់គេច
នៅសាវត្ថីប្រុសស្រី មិនតិច រួចហើយទើបស្ដេចទៅតាវត្តិង្ស ។
អាសាឍបុណ្ណមីថ្ងៃ ១៥ កើត ជាប៉ែកខាងខ្នើតល្អណាស់យ៉ាងហ្នឹង
ថ្ងៃដ៏វិសេសបរិស័ទត្រូវដឹង គួរយើងរំពឹង កបដោយបញ្ញា ។
អាសាឍបុណ្ណមី មានហេតុប្លែកៗ អស្ចារ្យចម្លែកក្នុងពុទ្ធសាសនា
ជាប់ដោយព្រះគុណនៃព្រះសម្មា- សម្ពុទ្ធនោះណាករុណាក្រៃលែង ។
អាសាឍបុណ្ណមី ចម្រើនកុសល លះកាត់កង្វល់ ហើយខំប្រឹងប្រែង
ប្រព្រឹត្តធម្មាដោយការកោតក្រែង តាមព្រះសម្ដែងនឹងបានផុតទុក្ខ ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ៣_វិសាខបុណ្ណមី

( បទពាក្យ ៨ )

វិសាខបុណ្ណមី គួរឱ្យជ្រះថ្លា ថ្ងៃព្រះសាស្តាសម្មាសម្ពុទ្ធ
ប្រសូតចាកគភ៌ ស្អាតបរិសុទ្ធ វិសេសបំផុតនៅក្នុងលោកា ។
វិសាខបុណ្ណមី ថ្ងៃទ្រង់ត្រាស់ដឹង ដែលទ្រង់រំពឹងបច្ចយាការ
បច្ចូសសម័យព្រះទ័យស្រស់ថ្លា ត្រាស់ជាសម្មាសម្ពុទ្ធក្នុងលោក ។
វិសាខបុណ្ណមី ថ្ងៃទ្រង់និព្វាន សត្វសែនកោដិលានមកច្រើនគរគោក
ក្រាស់ក្រៃលត្រៀបត្រាភក្ត្រទទឹកជោក នាំគ្នាសោយសោកស្តាយព្រះសាស្តា ។
វិសាខបុណ្ណមី ថ្ងៃព្រះទ្រង់ត្រាស់ បញ្ជាក់យ៉ាងច្បាស់បច្ឆិមវាចា
ថាកុំប្រមាទ រៀងរាល់រូបា ចម្រើនបុញ្ញា តាមព្រះមុនី ។
វិសាខបុណ្ណមី មានន័យខ្លាំងណាស់ បរិស័ទក្មេងចាស់គួរខំសម្ដី
ស្រូតរូតស្រុះស្រួលស្ដាប់ព្រះធម្មី ក្រុមពួកសង្ឃជីបានពោលសម្ដែង ។
វិសាខបុណ្ណមី កម្ចាត់ងងឹត ដែលមានក្នុងចិត្តឱ្យភ្លឺចិញ្ចែង
លោភៈទោសៈមោហៈស្តែងៗ ពន្លឺស្វស្បសែងប្រទីបបញ្ញា ។
វិសាខបុណ្ណមី ឋិតក្នុងទានសីល ដើម្បីផ្ដាច់ផ្ដិលកិលេសតណ្ហា
ត្រាស់ដឹងសច្ចៈផុតចាកទុក្ខា សម្រេចអមតាឥតមានប្រែក្លាយ ។
វិសាខបុណ្ណមី អប់រំវិជ្ជា យល់ដឹងគ្រប់គ្នាមានចិត្តនឿយណាយ

ប្រាជ្ញាយល់ត្រូវងងឹតខ្ចាត់ខ្ចាយ ផុតចាកអន្តរាយកាយចិត្តស្រស់ថ្លា ។
ព្រះអង្គប្រសូត និងបានត្រាស់ដឹង និព្វានថ្ងៃហ្នឹងគួរពិចារណា
សង្ខារទាំងឡាយមិនទៀងឡើយណា គ្រប់រូបអាត្មាកើតចាស់ឈឺស្លាប់ ។
ចូរកុំប្រមាទនៅក្នុងទានសីល លះចិត្តខ្ជូចខិលរួតរះប្រញាប់
សម្មាទិដ្ឋិ ដែលទ្រង់បានប្រាប់ ឆ្ការគាស់កាយកាប់កិលេសតណ្ហា ។
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៤.មាឃបុណ្ណមី

( បទពាក្យ ៨ )

-មាឃបុណ្ណមី ថ្ងៃនក្ខត្តឫក្ស ធ្វើបុណ្យរំលឹកហេតុពីរប្រការ
ដែលព្រះសម្ពុទ្ធវិសុទ្ធអស្ចារ្យ មានករុណាសង្គ្រោះសត្វលោក ។
-មាឃបុណ្ណមី ប្រជុំសាវ័ក សន្និបាតជាក់នៃព្រះមានជោគ
អង្គ៤នោះឯងសង្ឃច្រើនគរគោក ឆ្លងផុតចាកលោកឥតមានមោះមៃ ។
-មាឃបុណ្ណមី ថ្ងៃព្រះសាស្តា ទ្រង់ត្រាស់វាចាមិនមានទុក្ខភ័យ
ដាក់នូវអាយុសង្ខារនោះនៃ កក្រើកផែនដីមួយម៉ឺនចក្រវាល ។
-មាឃបុណ្ណមី មានហេតុផ្លែក២ អស្ចារ្យចម្លែកក្នុងពុទ្ធសាសនា
ជាប់ដោយព្រះគុណនៃព្រះសម្មា- សម្ពុទ្ធនោះណាករុណាក្រៃលែង ។

-មាឃបុណ្ណមី មានចិត្តសទ្ធា ជ្រះថ្លាគ្រប់គ្នាគោរពកោតក្រែង
បូជាព្រះពុទ្ធនិងសង្ឃតម្កើង មានចិត្តស្ងប់ស្ញែងរលឹកដល់គុណ ។
-មាឃបុណ្ណមី ក្រុមពួកសង្ឃជី បរិស័ទមូលមីរប្រសើរពេកពន់
ឱនកាយសំពះវន្ទាបន្ទន់ ទឹកចិត្តទន់ភ្លន់ ដ៏ល្អប្រពៃ ។
-មាឃបុណ្ណមី ចម្រើនកុសល លះកាត់កង្វល់ ខំប្រឹងលកលៃ
ធ្វើពេលវេលាឱ្យមានតម្លៃ ពីព្រឹកដល់ថ្ងៃដោយមិនប្រមាទ ។
-មាឃបុណ្ណមី មានន័យខ្លាំងណាស់ ព្រះអង្គទ្រង់ត្រាស់នូវព្រះឱវាទ
ប្រាប់បេះដូងធម៌ក្នុងសន្និបាត បរិសុទ្ធស្អាតវិសេសវិសិដ្ឋ ។
-អាសាឍេ វិសាខ មាឃបុណ្ណមី សាវ័កប្រុសស្រី ប្រឹងទូន្មានចិត្ត
ឱ្យបានផូរផង់ផុតចាកទុច្ចរិត មិនមានវិបរិត នឹងបានសុខស្ងប់ ។

ថ្ងៃ ១១ រោច ខែកត្តិក ព.ស.២៥៥៦

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៥_មាឃបូជា

-ថ្ងៃ ១៥ កើតខែ្មតមាឃបូជា សាវ័កគ្រប់គ្នាមកច្រើនត្រៀបត្រា
រៀបចំចាត់ចែងធូបទៀនភ្ញីផ្កា បូជាសាស្តារលឹកដល់គុណ ។
-ប្រារព្ធហេតុធំទាំងពីរប្រការ វិសេសថ្លៃថ្លាប្រសើរពេកពន់
ឧត្តមត្រកាលករុណាលើសលន់ ដែលជាព្រះគុណមានក្នុងពុទ្ធអង្គ ។

-ទី១ ជាថ្ងៃប្រជុំសាវ័ក សន្និបាតជាក់ប្រសើរផ្លូវផង់
ចតុរង្គ-សន្និបាតសង្ឃ ប្រកបដោយអង្គទាំង ៤ ប្រការ ។
-ថ្ងៃ ១៥ កើត មាឃនក្សត្រ ជុំមិនបានណាត់ មកតាមធម្មតា
ភិក្ខុទាំងមួយពាន់ពីររយហា- សិប គួរច្រេះថ្លាគ្រប់៧អង្គា ។
-ភិក្ខុទាំងអស់ជាខីណាស្រព ឥទ្ធិប្រកប ធំមហិមា
ព្រោះលោកសម្រេចនូវអភិញ្ញា មកជួបជុំគ្នា វត្តវេឡុវ័ន ។
-សុទ្ធជាឯហិភិក្ខុទាំងអស់ ព្រះភក្ត្រស្រស់បស់ឥតមានជាប់ព័ន្ធ
កិលេសតណ្ហារាប់រយសែនពាន់ ឥតមានជាប់ព័ន្ធនៅក្នុងសន្តាន ។
-ព្រះមានព្រះភាគទ្រង់ត្រាស់ឱវាទ បាតិមោក្ខស្អាតប្រសើរថ្កើងថ្កាន
ឱ្យវៀរចាកបាបតិចច្រើនប៉ុន្មាន ជាហេតុឱ្យបានសេចក្ដីសុខជា ។
-រីកុសលធម៌ ត្រូវខំចម្រើន ឱ្យបានកើតកើន ដើរតាមមាគ៌ា
ជាផ្លូវដ៏ត្រង់ដែលព្រះភគវា ផ្លូវនោះគឺជាមគ្គអង្គប្រាំបី ។
-ម្យ៉ាងទៀតត្រូវខំទូន្មាននូវចិត្ត សន្សំសុចរិតឱ្យបានប្រពៃ
សតិប្បដ្ឋានចម្រើនគិតលកលៃ នាំឱ្យផុតភ័យផុតចាកទុក្ខា ។
-ទីពីរ ជាថ្ងៃដែលព្រះភគវា ត្រាស់ចំពោះមារ មានចិត្តប្ញស្យា
ទ្រង់បានដាក់ចុះអាយុសង្ខារ មិនយូរឡើយណានៅសល់ ៣ ខែ ។

-បាវាលចេតិយនោះឯងប្រាកដ ទ្រង់បានកំណត់ ឥតមានកែប្រែ
មិនលើសមិនខ្វះនៅត្រឹមបីខែ ចិត្តឥតប្រួលប្រែទ្រង់នឹងនិព្វាន ។

ថ្ងៃ ១១ រោច ខែកត្តិក ព.ស.២៥៥៦

និពន្ធដោយភិក្ខុ ភួង-សុវណ្ណ

## ៦-ថ្ងៃទ្រង់ប្រសូត

ថ្ងៃ ១៥ កើតវិសាខបុណ្ណមី ថ្ងៃមានសិរីប្រសើរបវរ
ដែលពោធិសត្វបរិសុទ្ធល្អ ប្រសូតចាកគភ៌នៃព្រះមាតា ។
នៅក្នុងចន្លោះនគរទាំងពីរ សួនលុម្ពិនីដេរដាសដោយផ្កា
ដែលគួររីករាយនៃមនុស្សទេព្តា មានចិត្តជ្រះថ្លាត្រេកអរកន្លង ។
នៅក្នុងកាលនោះព្រះនាងស្រស់ស្រាយ ព្រះទ័យសប្បាយទ្រង់ប្រាប់អ្នកផង
ចុះចាកគ្រែស្នែងមាសថ្មីតែម្តង ដើរតាមគន្លងដ៏ស្រស់ថ្លៃថ្លា ។
ស្តេចយាងទៅដល់ទៀបគល់សាលព្រឹក្ស ប្រដាប់ដោយស្លឹកមានផ្លែមានផ្កា
ព្រះនាងទេវីមានព្រះប្រាថ្នា ចាប់នូវមែកណាមែកនោះឱនមក ។
ខ្យល់កម្មជ្ជវាតកើតឡើងគ្រានោះ ប្រាកដចំពោះ ថាកូនពន្លក
នៅក្នុងគព្ភានឹងប្រសូតមក ឱកូនពន្លកតើល្អយ៉ាងណា ។
ទ្រង់បានសណ្តូកព្រះហស្តទាំងពីរ ព្រះបាទទាំងពីរចាគគភ៌មាតា

បរិសុទ្ធក្រៃលែងឥតមានអ្នកណា ទោះមនុស្សទេព្តាមិនប្រាកដស្មើ ។
នៅក្នុងទីនោះសូម្បីព្រះព្រហ្ម មានយសដ៏ធំ គង់មិនប្រសើរ
ដូចព្រះពោធិសត្វអ្នកមានដំណើរ វិសេសប្រសើរជាងមនុស្សទេព្តា ។
មានការញាប់ញ័រនូវផ្ទៃផែនដី ពន្លឺស្វាងស្វៃទាំងម៉ឺនចក្រវាល
ធ្វើឱ្យហប្ញទ័យនៃព្រះមាតា មានសោមនស្សរាពន់ពេកកន្លង ។
ចំណែកព្រះបរមពោធិសត្វ ផុតចាកពីហត្ថានៃមនុស្សផង
ទ្រង់ក្រឡេកមើលទិសទាំងដប់ហោង មិនឃើញអ្នកផងប្រាកដដូចឡើយ ។
ទើបបែរព្រះភក្រ្តទៅទិសឧត្តរ ស្តេចទៅដោយល្អមិនបានកន្តើយ
ឈានដោយព្រះបាទបានប្រាំពីរហើយ មិនបង្អង់ឡើយបន្លឺសីហនាទ ។
អគ្គោហមស្មិ លោកស្ស ជាដើមសច្ចៈ មិនបានឃ្លៀងឃ្លាត
ប្រសើរក្រៃលែងជាងអ្នកឯទៀត បញ្ជាក់ថាជាតិព្រះអង្គអស់ហើយ ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៧_ថ្ងៃទ្រង់ត្រាស់ដឹង

វិសាខបុណ្ណមី នាឆ្នាំរកា ថ្ងៃព្រះសាស្តាទ្រង់បានត្រាស់ដឹង
សម្មាសម្ពោធិញ្ញាណថ្ងៃហ្នឹង ថ្ងៃទ្រង់ត្រាស់ដឹងជាព្រះពុទ្ធច្បាស់ ។
ក្នុងវេលាបុព្វណ្ហសម័យ ពោធិសត្វថ្ងៃទទួលបាយាស

ដែលនាងសុជាតាដាក់ក្នុងថាស- មាសដ៏ត្រចះហើយថ្វាយបូជា ។
ព្រះពោធិសត្វទទួលរួចស្រេច ទ្រង់ញុំាងភត្តកិច្ច នាដែនគយា-
សីសៈ ទៀបស្ទឹងនេរញ្ជរា ដែលទ្រង់ពូតជាដុំពំនូតសោយ ។
ក្នុងពេលមជ្ឈន្តិកសម័យ សម្រាកពេលថ្ងៃ ព្រះទ័យបានស្បើយ
នៅក្នុងសាលវ័នទៀបមាត់ស្ទឹងហើយ ដែលជាខាងក្រោយអំពីភត្តកិច្ច ។
ក្នុងវេលាល្ងាចស្ដេចយាងសំដៅ និមន្តឆ្ពោះទៅក្នុងមួយរំពេច
ជួបសោត្ថិយៈគាត់បានដឹងកិច្ច ថ្វាយស្មៅដល់ស្ដេចមានប្រាំបីក្ដាប់ ។
ព្រះពោធិសត្វទទួលស្មៅហើយ មិនបង្អង់ឡើយយាងតាមលំដាប់
ទៅតាមមាគ៌ាទេវតាប្រដាប់ ក្រអូបចំណាប់ពាសពេញដងព្រៃ ។
លុះទ្រង់ទៅដល់គល់អស្សត្ថព្រឹក្ស ហៅពោធិព្រឹក្សដែលជាវិជ័យ
ដ៏រុងរឿងណាស់ជាងឈើដទៃ ប្រសើរពេកក្រៃផ្ដល់ក្ដីសុខសាន្ត ។
ទ្រង់ប្រទក្សិណដើមពោធិ៍បីជុំ គួរអភិរម្យរួចហើយទ្រង់បាន
ស្ដេចសណ្ឋិតឈរនាទិសឦសាន ដែលជាទីឋាន ស្អាតបរិសុទ្ធ ។
រំពេចនោះឯងបល្ល័ង្ក ១៤ ហត្ថ ព្រះមហាសត្វ ទ្រង់មិនរន្ធត់
កើតដោយបារមីវិសេសបំផុត ដែលព្រះសម្ពុទ្ធសន្សំមកហើយ ។
គង់អធិដ្ឋានប្រកបដោយអង្គ ៤ ដ៏ផ្ចិតផ្ចង់ ទ្រង់មិនថយក្រោយ
មិនបានត្រាស់ដឹងទ្រង់មិនក្រោកឡើយ ផ្ដងទុកស្រេចហើយមិនដាក់ធុរៈ ។

ស្បែកសរសៃឆ្អឹង ឱ្យសល់នៅចុះ ឈាមនិងសាច់នោះ ក្នុងសរីរៈ
ចូរហួតហែងទៅនេះយ៉ាងប្រចក្ស ប្រាកដជាក់លាក់ទ្រង់អធិដ្ឋាន ។
កាលពោធិសត្វគង់លើបល្ល័ង្ក មារមកតតាំងចង់ឱ្យចាកឋាន
កែនកម្លាំងមារដែលមានប៉ុន្មាន មកពីសព្វឋានក្រាស់ក្រែលពេកក្រៃ ។
បានព្នមកថាខាងមុខនៃមារ មានគ្នីមានគ្នា ១២ យោជន៍នៃ
ខាងស្ដាំខាងឆ្វេងចូលមកប្រល័យ ក៏ច្រើនពេកក្រៃ១២យោជន៍ណា ។
អំពីខាងក្រោយគួរឱ្យតក់ស្លុត តាំងនៅបំផុតនៃផ្ទៃចក្រវាល
ចំណែកខាងលើផ្ទៃអាកាសា មារច្រើនពេកណាមានប្រាំបួនយោជន៍ ។
ហេតុដ៏អាក្រក់មានច្រើនប្រការ ដែលមារបណ្ដាលមិនមែនតិចតួច
រកមហាក្សត្រដោយកិលេសផ្ដួច មិនចង់ឱ្យរួចពីវិស័យខ្លួន ។
ចំណែកពោធិសត្វនៅតែម្នាក់ឯង មើលមារសម្ដែងដោយចិត្តខ្ជាប់ខ្ជួន
ដោយហេតុច្រើនយ៉ាងឫទ្ធិមារប្រាំបួន បណ្ដាលផ្ទួន៧មករកពោធិសត្វ ។
ខ្យល់ ភ្លៀង ដុំថ្ម និងគ្រឿងប្រហារ សំដៅក្សត្រា តែរសាយបាត់
មិនបានពាល់ត្រូវកាយព្រះពោធិសត្វ វិនាសខ្ចាយខ្ចាត់រសាត់ទៅឯង ។
បណ្ដាលរងើកភ្លើង ភ្លើងនរក ដីខ្សាច់និងភក់ ដែលមារសម្ដែង
ភាពងងឹតឈឹងសូន្យចាកសូរ្យសែង គួរខ្លាចក្រៃលែងទ្រង់មិនញាប់ញ័រ ។
មារមានចិត្តក្រោធ អ្នកមានប្រាថ្នា ចង់ឱ្យក្សត្រាដែលឋិតក្នុងធមិ

ឃ្លាតចាកបល្ល័ង្កដ៏វិចិត្រល្អ និងឃ្លាតចាកធមិដែលត្រូវត្រាស់ដឹង ។
ព្រះមហាក្សត្រ ទ្រង់បានកម្ចាត់ មារឱ្យខ្ចាយខ្ចាត់ រួចទ្រង់រំពឹង
ក្នុងបឋមយាមរាត្រីថ្ងៃហ្នឹង ទ្រង់បានត្រាស់ដឹង បុព្វេនិវាស ។
ក្នុងមជ្ឈិមយាមជាយាមកណ្ដាល ដែលព្រះមហាក្សត្របានជម្រះ
ទិព្វចក្ខុវិសេសល្អល្អះ ទ្រង់អាចឃើញច្បាស់សព្វសត្វលោកា ។
ក្នុងបច្ឆិមយាមជាយាមចុងក្រោយ បារមីគ្រប់ហើយនៃព្រះក្សត្រា
ទ្រង់បញ្ជូនញាណវិសុទ្ធថ្លៃថ្លា ក្នុងបច្ចយាការហើយបានត្រាស់ដឹង ។
នៅក្នុងវេលាបច្ចូសសម័យ ក៏គឺជាថ្ងៃ ១៥ កើតហ្នឹង
ដែលព្រះមានបុណ្យទ្រង់បានត្រាស់ដឹង ១៥កើតហ្នឹងក្នុងខែវិសាខ ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៨-ថ្ងៃទ្រង់បរិនិព្វាន

( បទពាក្យ ៨ )

ថ្ងៃ ១៥ កើតវិសាខបុណ្ណមី ឆ្នាំម្សាញ់ប្រុសស្រីគួរឱ្យសង្វេគ
បរិស័ទត្រៀបត្រាច្រើនអនេក ទោមនស្សពេកស្ដាយព្រះសាស្ដា ។
ព្រោះថាជាថ្ងៃដែលព្រះទ្រង់ញាណ បរិនិព្វាន ក្រុងកុសិនារា
នៅក្នុងសាលវ៉ែនរបស់ក្សត្រា គ្រប់គ្រងរក្សាដោយស្ដេចមល្លក្សត្រ ។

ព្រះសាស្តាទ្រង់អស់កម្លាំង សែនល្ហិតល្ហៃខ្លាំង ស្មើរតែសូន្យបាត់
ទ្រង់បានចូលកាន់សាលវិនមល្លក្សត្រ មិនសូន្យមិនស្ងាត់ភិក្ខុភិក្ខុនី ។
ព្រះមានព្រះភាគព្រះអង្គទ្រង់ផ្ទំ លើគ្រែឧត្តមទ្រង់បានសម្ងី
នៅក្នុងចន្លោះសាលព្រឹក្សទាំងពីរ ទេវតាមូលមីរបូជាសរីរៈ ។
ដើម្បីបូជាដល់ព្រះសម្ពុទ្ធ ប្រសើរបំផុត ផ្កាមន្ទារវៈ
លំអិតខ្លឹមចន្ទន៍ ជាដើមបានធ្លាក់ លើព្រះសរីរៈព្រះតថាគត ។
វិគ្រឿងបូជាហួសពីរៀបរាប់ ប្រសើរគួរគាប់ដ៏ច្រើនបំផុត
បូជាសាស្តាសម្មាសម្ពុទ្ធ ទ្រង់ស្អាតបរិសុទ្ធជាព្រះមុនី ។
ភិក្ខុជាព្រះ-អរហន្តា និងសាវិកា ជួបជុំមូលមីរ
ខ្លះជាសេក្ខៈ អនាគាមី មកពីគ្រប់ទីតំបន់ផ្សេងៗ ។
សកទាគាមី សោតាបន្នៈ សទ្ធាស្មោះស្ម័គ្រមិនបានវង្វេង
នៅក្នុងភពនេះ ឬក្នុងភពផ្សេង មិនបានវង្វេងក្នុងវដ្តសង្សារ ។
ទោះបុថុជ្ជនអ្នកមានកិលេស ស្មុគស្មាញចាក់ស្រែះនៅក្នុងអាត្មា
មិនថាជាមនុស្ស ឬជាទេវតា ដោយចិត្តជ្រះថ្លា ក្នុងព្រះសម្ពុទ្ធ ។
ខ្លះសោកខ្សឹកខ្សួលរំជួលហឫទ័យ គួរសង្វេគក្រៃ ចិត្តសែនរន្ធត់
ព្រោះតែព្រាត់ចាកព្រះតថាគត ប្រសើរបំផុតជាងមនុស្សទេវតា ។

ក្នុងកាលនោះឯងព្រះដ៏មានបុណ្យ ប្រសើរដោយគុណធ្ងន់ក្រៃពេកណា
ទ្រង់បានត្រាស់នូវបច្ឆិមវាចា ដែលមានពាក្យថា ចូរកុំប្រមាទ ។
ទ្រង់ត្រាស់ប៉ុណ្ណេះជាការបញ្ជាក់ ដល់ពួកសាវ័កចូរខំសង្វាត
ចម្រើនដោយគុណតាមពុទ្ធឱវាទ ចូរកុំប្រមាទក្នុងកិច្ចទាំងឡាយ ។
មុននឹងនិព្វានទ្រង់បានចូលឈាន ចំនួនពីរលានបួនសែនកោដិប្លាយ
ទ្រង់មិនស្រណោះមិនបានសោកស្តាយ បរិស័ទទាំងឡាយធ្វើការបូជា ។
ព្រះមានព្រះភាគបរិនិព្វាន ហេតុចម្លែកមានពេលដំណាលគ្នា
កក្រើកញាប់ញ័រផ្ទៃពសុធា មនុស្សសត្វគ្រប់គ្នាមានចិត្តសង្វេគ ។
សាវ័កទាំងឡាយគប្បីញ៉ាំងគុណ ប្រសើរពេកពន់ជាច្រើនអនេក
ដើរតាមផ្លូវមគ្គកុំនៅរារែក ញ៉ាំងគុណប្លែកៗឱ្យសម្រេចហោង ។

វត្តនិគ្រោធវ័ន ថ្ងៃ ១៥ កើត ខែវិសាខ ព.ស.២៥៥២

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ៩.គប្បីយល់ដឹងពីគុណមាតាបិតា ហឫទ័យមាតា

(សុត្តន្តបិដក លេខ៦១ ទំព័រ៩៣-៩៦)

ព្រះពុទ្ធគាថា ក្នុងសោណនន្ទជាតក ជាសេចក្តីប្រែ ថា :

មាតាកាលប្រាថ្នាចង់បានផ្លែ គឺកូន តែងនមស្ការទេវតា សួរនក្ខត្តឫក្សទាំងឡាយផង សួររដូវនិងឆ្នាំទាំងឡាយផង ។ កាលមាតានោះមានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌សិប់ ដោយហេតុនោះ មាតាជាស្ត្រីមានសេចក្តីចាញ់ផ្ទៃ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **សុហទា** (មានដួងហឫទ័យល្អ) ។ មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយទើបប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា **ជនយន្តីផង ជនេត្តីផង** (អ្នកបង្កើតកូន) ។ មាតាញ៉ាំងកូនដែលកំពុងយំ ឱ្យត្រេកអរដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **តោសេន្តី** (អ្នកញ៉ាំងកូនឱ្យត្រេកអរ)។ តអំពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អានហើយក្រឡេកមើលទារកដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **បោសេន្តី** (អ្នកចិញ្ចឹមកូន) ។

ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាគ្រប់គ្រងទ្រព្យទាំងពីរចំណែកនុ៎ះ ដើម្បីកូននោះ (ដោយបំណងថា) ទ្រព្យនេះត្រូវមានដល់បុត្ររបស់យើង ។ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូន ដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាទក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ)ឯណោះ ។ កាលបើកូនមានវ័យចម្រើនឡើងហើយ មាតាបានដឹងថា កូនប្រមាទក្នុងប្រពន្ធនៃអ្នកដទៃ ក្នុងពេលអធ្រាត្រហើយមិនត្រឡប់មក ក្នុងពេលល្ងាចក៏រមែងលំបាកចិត្ត ដូច្នេះ ។

សត្វដែលមាតា ចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះហើយមិនបម្រើមាតា ប្រព្រឹត្តខុសក្នុងមាតានោះ តែងទៅកើតក្នុងនរក ។ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើក្នុងបិតា ប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាក ព្រោះមិនបម្រើមាតា ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាក ព្រោះមិនបម្រើបិតា ។

បណ្ឌិតបម្រើមាតា គប្បីបាននូវសុខនុ៎ះ គឺសេចក្ដីត្រេកអរ

រីករាយ ការសើចលេងសព្វៗ កាល ។ បណ្ឌិតបម្រើបិតា គប្បីបាននូវសុខទាំង៦ គឺសេចក្ដីត្រេកអររីករាយ ការសើចលេងសព្វៗកាល ។

ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តិជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១ ។ សង្គហធម៌ទាំង៤នេះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្លៅនៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំង៤នេះមិនមានទេ មាតាមិនត្រូវបានសេចក្ដីរាប់អាន និងការបូជាព្រោះហេតុនៃកូន ទាំងបិតាក៏មិនត្រូវបាននូវសេចក្ដីរាប់អាននិងការបូជា ព្រោះហេតុនៃកូន ។ ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំង៤នេះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះរមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។

មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្រ បណ្ឌិតហៅថាព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូត និងការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែ

ការបម្រើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។

## ១០~រលឹកដល់គុណ

( បទកាកគតិ )

១-ថ្ងៃនេះថ្ងៃល្អ ចិត្តខ្ញុំត្រេកអរ រលឹកដល់គុណ
អ្នកម្តាយដ៏ល្អ លោកមានគុណធ្ងន់ សង្គ្រោះពេកពន់
លើកូនប្រុសស្រី ។

២-នាម**សុហទា** ទឹកចិត្តល្អជា រក្សាថ្នមបី
ប្រយ័ត្នប្រយែង ហូបបាយចំណី មិនចេះតែធី
គិតកូនក្នុងផ្ទៃ ។

៣-អ្នកផ្តល់កំណើត ញ៉ាំងកូនឱ្យកើត ទាំងចិត្តព្រួយភ័យ
បណ្ឌិតហៅថា **ជនយន្តី** និង**ជនេត្តី**
នៃបុត្តបវរ ។

៤-នាម**តោសេន្តី** ញ៉ាំងកូនប្រុសស្រី ឱ្យបានត្រេកអរ
ដោយបំបៅដោះ ជាដើមដោយល្អ មានចិត្តអំណរ
នឹងកូនជីវ៉ា ។

៥-នាម**ហោសេដ្ឋី** ឱ្យបាយចំណី ចិញ្ចឹមរក្សា
ឱ្យបានរស់រាន ដោយចិត្តមេត្តា និងករុណា
ស្រឡាញ់រាប់អាន ។
៦-លោកតែងខ្វល់ខ្វាយ គ្រប់កិច្ចទាំងឡាយ នៅសព្វទីឋាន
បង្ហាត់បង្រៀន ដល់កូនកល្យាណ ផ្តល់ក្តីសុខសាន្ត
ដល់កូនពុំងា ។
៧-ព្រះពុទ្ធជាម្ចាស់ បញ្ជាក់យ៉ាងច្បាស់ ថាជា**ព្រហ្មា**
រាប់អានអាណិត ដោយព្រហ្មវិហារ ដល់កូនស្ងួនភ្ជា
ចិត្តមុទិតា ។
៨-គួរឱ្យកោតក្រែង ព្រះអង្គសម្តែង ជា**បុព្វាចារ្យ**
អប់រំទូន្មាន ម្យ៉ាងជា**ទេវតា** **ទក្ខិណេយ្យា**
ប្រសើរខ្ពង់ខ្ពស់ ។
៩-នាមទាំងប៉ុន្មាន ព្រះសម្ពុទ្ធបាន ត្រាស់ដោយចំពោះ
នាមជាប់ដោយគុណ ប្រសើរខ្ពង់ខ្ពស់ មានពិតចំពោះ
មាតាបិតា ។
១០-លោកមានគុណធ្ងន់ គុណច្រើនលើសលន់ មិនអាចឧបមា
ប្រៀបធៀបឱ្យស្មើ នូវគុណឧបការ ទោះពោលយ៉ាងណា

អស់កាលជានិច្ច ។

១១-ទឹកចិត្តដ៏ល្អ មានជាបន្ត កូនមិនអាចភ្លេច
កូនសូមចងចាំ ក្នុងចិត្តជានិច្ច លំបាកដូចម្តេច
កូនត្រូវតបស្នង ។

១២-ថ្ងៃនេះថ្ងៃក្រោយ កូនមិនតោះតើយ ធ្វើតាមបំណង
ប្រព្រឹត្តតាមធម៌ ដ៏ល្អកន្លង ដើម្បីតបស្នង
មាតាបិតា ។

ថ្ងៃ ១០ កើត ខែមិគសិរ ព.ស. ២៥៥៤

ដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ១១-ព្រហ្មសូត្រ

(សុត្តន្តបិដក លេខ៥៣ ទំព័រ១៤២)

ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងព្រហ្ម ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វទេវតា (ទេវតាដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូល

ទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងបុព្វាចារ្យ (អាចារ្យដើម) ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណា ដែលកូនបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងឡាយនោះ ឈ្មោះថា នៅរួមជាមួយនឹងអាហុនេយ្យបុគ្គល (បុគ្គលគួរបូជា) ។

ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មន៍ុះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វទេវាន៍ុះ ជាឈ្មោះរបស់មាតាបិតា ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុនេយ្យន៍ុះ ជាឈ្មោះរបស់មាតាបិតា ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះ) មាតាបិតាមានឧបការៈច្រើន ជាអ្នកបីបាច់ (ឱ្យគង់ជីវិត) ជាអ្នកចិញ្ចឹម (ឱ្យធំដឹងក្ដី) ទាំងជាអ្នកបង្ហាញនូវលោកនេះដល់កូនទាំងឡាយ ។

> មាតាបិតាទាំងឡាយ ដែលហៅថា ព្រហ្មក្តី បុព្វាចារ្យក្តី
> អាហុនេយ្យក្តី (សុទ្ធតែ) ជាអ្នកអនុគ្រោះដល់ពួកសត្វ គឺកូន ។
> ព្រោះហេតុនោះឯង អ្នកប្រាជ្ញ គួរនមស្ការ គួរធ្វើសក្ការៈដល់
> មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ គ្រឿងដេក
> គ្រឿងអប់ គ្រឿងផ្ងូតទឹក និងទឹកសម្រាប់លាងជើង ។ ព្រោះ

ការដែលបានទំនុកបម្រុងមាតាបិតានោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយសរសើរនូវបុគ្គលនោះ ក្នុងលោកនេះឯង បុគ្គលនោះលុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌ ។

## ១២_នាមជាប់ដោយគុណ

( បទពាក្យ ៨ )

នាមជាប់ដោយគុណមានច្រើនបែបយ៉ាង ខ្ញុំមានសំណាងសិក្សាធម៌អាថ៌
យល់ក្នុងព្រះគុណមាតាបិតា គុណច្រើនណាស់ណាប្រសើរលើសលន់ ។
ក្នុងព្រះធម្មាបានប្រាប់ច្បាស់ថា មាតាបិតាលោកមានគុណធ្ងន់
ឱ្យកូនបានរស់សង្គ្រោះពេកពន់ ដូចចន្ទ្រស្រទន់ទឹកចិត្តថ្លៃថ្លា ។
ព្រះពុទ្ធត្រាស់ថាមានព្រហ្មវិហារ ព្រះទ័យល្អជាមេត្តាករុណា
រាប់អានអាណិត ចិត្តមុទិតា និងឧបេក្ខា លើកូនប្រុសស្រី ។
ម្យ៉ាងវិញទៀតនោះ គាត់ជាទេព្តា ជាបុព្វាចារ្យ ទឹកចិត្តប្រណី
ណែនាំសព្វគ្រប់ ជានិច្ចរាល់ថ្ងៃ ខំប្រឹងកែខៃមិនគិតនឿយហត់ ។
អាហុនេយ្យបុគ្គលមែនពិត កូនត្រូវចូលជិតដោយចិត្តអំណត់
គោរពបូជាឱ្យបានហ្មត់ចត់ បានបុណ្យប្រាកដក្រៃលែងណាស់ណា ។

បើកូនទាំងឡាយប្រព្រឹត្តតបគុណ ឱ្យបានលើសលន់នឹងបានផលា
បានជាបារមីប្រសើរថ្លៃថ្លា ដែលព្រះសម្មាសម្ពុទ្ធសរសើរ ។
អ្នកដឹងគុណហើយបើបានធ្វើតប តែងបានប្រកបទៅតាមដំណើរ
ដែលព្រះសាស្ដាព្រះអង្គធ្លាប់ដើរ រីងបានប្រសើរត្រាស់ដឹងសច្ចៈ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣-បុណ្យចម្រើនជន្មាយុ

១-ថ្ងៃនេះថ្ងៃល្អ ចិត្តខ្ញុំត្រេកអរ រលឹកដល់គុណ
ធ្វើបុណ្យកុសល ចម្រើនព្រះជន្ម ជូនអ្នកមានគុណ
ប្រសើរថ្កើងថ្កាន ។

២-ប្រារព្ធពិធី ជួបជុំមូលមីរ កូនចៅគ្រប់ប្រាណ
សូមខមាទោស នឹងម្ដាយកល្យាណ ខុសឆ្គងប៉ុន្មាន
សូមលោកអភ័យ ។

៣-កូនសូមស្រោចស្រព ទឹកលាយទឹកអប់ ផ្កាល្អប្រពៃ
និងផ្កាស្រស់ស្អាត ដែលបានលកលៃ សូមលោកអភ័យ
ដល់កូនទាំងឡាយ ។

៤-ជូនគ្រឿងស្លៀកពាក់ ទាំងនេះដល់អ្នក ជាឪពុកម្ដាយ

ដោយទឹកចិត្តល្អ នៃកូនទាំងឡាយ កូនសូមខ្វល់ខ្វាយ

បម្រើតបគុណ ។

៥-លោកមានឧបការ មិនអាចឧបមា ប្រៀបដោយទម្ងន់

មេត្តាករុណា ទឹកចិត្តទោរទន់ សង្គ្រោះពេកពន់

លើកូនប្រុសស្រី ។

៦-ចិត្តមុទិតា និងឧបេក្ខា សន្ដោសប្រណី

ទោះជារូបកូន ខុសឆ្គងម្ដេចក្ដី អត់ទោសប្រណី

ដល់កូនជានិច្ច ។

៧-ទឹកចិត្តដ៏ល្អ មានជាបន្ត កូនមិនអាចភ្លេច

កូនសូមចងចាំ ក្នុងចិត្តជានិច្ច លំបាកដូចម្ដេច

កូនត្រូវតបស្នង ។

៨-ថ្ងៃនេះថ្ងៃក្រោយ កូនមិនតោះតើយ ធ្វើតាមបំណង

ប្រព្រឹត្តតាមធម៌ ដ៏ល្អកន្លង ដើម្បីតបស្នង

មាតាបិតា ។

វត្តនិគ្រោធវ័ន ថ្ងៃ ១៥ រោច ខែកត្តិក ព.ស.២៥៥៦

និពន្ធដោយភិក្ខុ ភួង សុវណ្ណ

# ១៤-កូនអើយគេងទៅ

-កូនអើយគេងទៅគេងឱ្យលក់ស្រួល គេងកុំប្រែប្រួលប្រយ័ត្នមូសខាំ
នាំឱ្យកើតរោគត្រូវទៅចាក់ថ្នាំ ព្រោះតែមូសខាំលំបាកដល់ម៉ែ ។
-កូនអើយគេងទៅកុំយំឡូឡា ក្រឡាប់ផ្កាប់ផ្ងារគឺត្រឡប់ប្រែ
បើកូនមិនគេងម្ដាយទុក្ខឥតល្ហែ ឱណាកូនម៉ែចូរអ្នកស្ងប់ស្ងាត់ ។
-កូនអើយគេងទៅកុំយំរៀបរាប់ រឿងមិនគួរគាប់អ្នកខំបំបាត់
ព្រោះជាធម្មជាតិដូចវាយោផាត់ រសាយរសាត់ទៅតាមធម្មតា ។
-កូនអើយគេងទៅគេងឱ្យលង់លក់ គេងកុំទ្រមក់ត្រូវក្រោកធ្វើការ
ភ្ញាក់ពីព្រលឹមសំអាតកាយា រួចទៅសិក្សាវិជ្ជាសិល្បៈ ។
-កូនអើយគេងទៅគេងតាមចំណាំ គេងផ្អៀងខាងស្ដាំដូចសត្វសីហៈ
មិនជាប់ក្នុងកាមមិនដាមប្រឡាក់ ពិតមិនអួលអាក់ប្រសើរថ្លៃថ្លា ។
-កូនអើយគេងទៅគេងដោយស្មារតី មុនគេងប្រុសស្រីត្រូវផ្សាយមេត្តា
គេងរលឹកគុណនៃព្រះសម្មា- សម្ពុទ្ធសាស្ដាទើបគេងជាសុខ ។

ថ្ងៃ ១៤កើត ខែបុស្ស ពុទ្ធសករាជ ២៥៥៨
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៥-ស្រណោះដល់អ្នកម្តាយ

( បទគោព័ទ្ធស្ទឹង មេពាក្យ ៧ )

-អោះឱ!ស្រណោះដល់អ្នកម្តាយ ម្តាយតែងខ្វល់ខ្វាយដល់រូបកូន
កូនទុក្ខលំបាកម្តាយស្មើរសូន្យ សូន្យអាណិតកូនពៅពុំងា ។
-ពុំងាបានសុខម្តាយត្រេកអរ អរសែនអំណរឥតគណនា
នាកាលថ្ងៃយប់ម្តាយម្ទីម្ទា ម្ទារកទ្រព្យាចិញ្ចឹមអ្នក ។
-អ្នកទៅសិក្សាម្តាយខំប្រឹង ប្រឹងគ្មានតានតឹងគ្មានស្មើរស្មាក់
ស្មាក់មួយវេលាព្រោះតែអ្នក អ្នកដឹងឱ្យជាក់ណាពៅណា ។
-ណាកិច្ចការងារច្រើនបែបយ៉ាង យ៉ាងមិនតែម្យ៉ាងទេជីវ៉ា
ជីវ៉ាដឹងចុះម្តាយមិនថា ថាទេករុណាស៊ូអត់ទ្រាំ ។
-ទ្រាំទ្រនឹងរងទុក្ខវេទនា នាស្ងួនពុំងាបានរឹងមាំ
មាំដោយវិជ្ជាអាចដឹកនាំ នាំកុំឱ្យខ្ទាំដួងចិត្តម៉ែ ។
-ម៉ែមានគុណធ្ងន់កូនត្រូវដឹង ដឹងហើយត្រូវប្រឹងបីបាច់ថែ
ថែដោយគោរពរាល់ថ្ងៃខែ ខែកន្លងតែសុខចម្រើន ។
-ចម្រើនព្រោះដឹងនិងតបគុណ គុណដ៏លើសលន់តែងកើតកើន
កើនរៀងរាល់ថ្ងៃកាន់តែច្រើន ច្រើនដោយក្តីសុខនិងកេរ្តិ៍ឈ្មោះ ។
-ឈ្មោះដ៏ពីរោះឮបានឆ្ងាយ ឆ្ងាយឱ្យសប្បាយឥតមានមោះ

មោះហ្មងគ្មានទេបានខ្ពង់ខ្ពស់ ខ្ពស់ដោយកិត្តិយសបានថ្កុំថ្កើង ។
-ថ្កើងក្នុងបច្ចុប្បន្ននិងបរលោក លោកនឹងមានជោគក្រៃលែងឡើង
ឡើងដោយគុណធម៌ព្រោះមិនឆ្មើង ឆ្មើងមិនកើតឡើងព្រោះគុណពិត ។
-ពិតណាស់ទាំងនេះកូនត្រូវដឹង ដឹងហើយសម្លឹងគួររិះគិត
គិតគួរតបគុណដ៏ល្អពិត ពិតខំប្រព្រឹត្តកុសលធម៌ ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ០៩រោច ខែមិគសិរ ព.ស.២៥៥៨
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

* អ្វីដែលកូនត្រូវដឹងនោះគឺថា ៖

មាតាបិតា ច្រើនណាស់លំបាកព្រោះកូនហើយ ត្រូវលំបាកនឹងចៅទៀត, ពេលខ្លះត្រូវកូនគំហក ស្តីបន្ទោសឲ្យទៀតក៏មាន ។ សូមកុំធ្វើយ៉ាងនេះអី អ្នកធ្វើអ្វី សូមគិតដល់មាតាបិតាផង កុំធ្វើឲ្យគាត់គ្រាំគ្រាចិត្ត យំបង្ហូរទឹកភ្នែក មិនល្អសោះឡើយ គប្បីយកចិត្តទុកដាក់បម្រើ មើលថែរក្សាគាត់ឲ្យបានល្អ តាមដែលអាចធ្វើបាន។ ការបម្រើមាតាបិតា ជាមង្គលដ៏ឧត្តម ។

## ១៦-ផលតបស្នងសងគុណ

-ក្នុងពុទ្ធសាសនាបានថែងច្បាស់ថា មាតាបិតាលោកមានគុណធ្ងន់
បើកូនប្រុសស្រីដឹងនិងតបគុណ នឹងបានជាទុនសោយផលខាងក្រោយ ។

-ព្រោះគាត់ជាព្រហ្មជាបុព្វាចារ្យ និងជាទេវតាឱ្យកូនបានស្បើយ
ផ្ទាក់ផ្ទមថៃទាំឥតមានកន្ដើយ មិនបានបណ្ដោយទៅតាមវាសនា ។
-វិសុទ្ធិទេព ពិតប្រាកដណាស់ ព្រះអង្គទ្រង់ត្រាស់ មានក្នុងដីកា
អភ័យជានិច្ចឥតយកទោសា ដល់បុត្តធីតាដោយចិត្តល្អពិត ។
-លោកគួរទទួលវត្ថុទាំងឡាយ ទោះទឹកឬបាយ មកពីឆ្ងាយជិត
ដែលកូនបូជាដល់គាត់ពិតៗ ចូរអ្នកកុំគិតខ្លាចក្រែងថាអស់ ។
-ទោះជានឿយហត់លំបាកម្ដេចម្ដា កូនត្រូវឧស្សាហ៍ដោយចិត្តស្ម័គ្រស្មោះ
លះពេលវេលាព្រមទាំងរបស់ មិនមែនសូន្យសោះទទេឡើយណា ។
-ផលការតបគុណកូនត្រូវចងចាំ សិក្សាចំណាំតាមច្បាប់តម្រា
បណ្ឌិតសរសើរនៅក្នុងលោកា ចុតិពេលណា ឋានសួគ៌ប្រាកដ ។
-ម្យ៉ាងបច្ចុប្បន្នតែងបានសុខជា ចម្រើនភោគាច្រើនលើលកំណត់
ព្រោះផលតបគុណដ៏យ៉ាងម៉ត់ចត់ នឹងមិនក្រខ្សត់ទុគ៌តសោកា ។
-ម្យ៉ាងឈ្មោះថាបានសាងជាបារមី តាមព្រះជិនស្រីជាព្រះសាស្ដា
ប្រសើរពេកក្រៃនៅក្នុងលោកា មកពីផលាតបស្នងសងគុណ ។

ថ្ងៃ ០២ កើត ខែមាឃ ពុទ្ធសករាជ ២៥៥៩

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ( ភួង-សុវណ្ណ)

# ១៧_កូនត្រូវទំនុកបម្រុងមាតាបិតាដោយស្ថាន ៥ យ៉ាង

(សុត្តន្តបិដក លេខ១៩ ទំព័រ៨៤)

ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់គហបតីបុត្ត ឈ្មោះសិង្គាលកៈ ទើបទ្រង់ត្រាស់សម្តែងថា ម្នាលគហបតីបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាង គឺ

**១_ភតោ នេសំ ភរិស្សាមិ :** អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាហើយ នឹងចិញ្ចឹមមាតាបិតាវិញ

**២_កិច្ចំ នេសំ ករិស្សាមិ :** អាត្មាអញ នឹងជួយធ្វើកិច្ចការងាររបស់មាតាបិតា

**៣_កុលវំសំ ថបេស្សាមិ :** អាត្មាអញ នឹងតម្កល់វង្សត្រកូល

**៤_ទាយជ្ជំ បដិបជ្ជាមិ :** អាត្មាអញ នឹងប្រព្រឹត្តឱ្យជាអ្នកសមគួរទទួលទ្រព្យមរតកបាន

**៥_អថវា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមិ**

ម្យ៉ាងទៀត អាត្មាអញនឹងឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់លោកខាងមុខហើយ ។

## ១៨-តួនាទីរបស់កូន ៥ យ៉ាង

-កូនមានជីវិតរស់បានក្នុងលោក មានជ័យមានជោគនៅក្នុងលោកា
អ្នកត្រូវដឹងចុះដោយគុណករុណា មាតាបិតាពិតណាស់ជាក់ស្ដែង ។
-ដូច្នេះអ្នកត្រូវគិតគួរពិចារណ៍ កបដោយបញ្ញាគោរពកោតក្រែង
ដល់អ្នកមានគុណតាមព្រះសម្ដែង រៀបចំចាត់ចែងតាមតួនាទី ។
-ត្រូវចិញ្ចឹមគាត់ដោយបច្ច័យបួន រក្សាថែថ្នួនសង្វាតសម្ដី
យកចិត្តទុកដាក់នៅគ្រប់ទិសទី នេះជាពលីដែលជាបឋម ។
-ជួយធ្វើកិច្ចការមាតាបិតា ស្រាលធ្ងន់យ៉ាងណាព្យាយាមខិតខំ
ស្គាល់ការរាក់ជ្រៅលៃលកផ្សែផ្សំ ប្រសើរឧត្ដមថ្កើងយសសម្បត្តិ ។
-តម្កល់វង្សត្រកូលដែលបវរ ត្រូវប្រព្រឹត្តល្អដោយប្រុងប្រយ័ត្ន
បាបអកុសលគប្បីលះកាត់ ខំប្រតិបត្តិចម្រើនកុសល ។
-ប្រព្រឹត្តខ្លួនឱ្យជាអ្នកសមគួរ ក្នុងការទទួលទ្រព្យនៅសល់
នៃឪពុកម្ដាយដែលគាត់ត្រូវផ្ដល់ ប្រគល់ឱ្យដល់កូនៗគ្រប់ប្រាណ ។
-មួយទៀតឧទ្ទិសទក្ខិណាទាន តាមព្រះទូន្មានក្រោយលោកចែកឋាន
គិតធ្វើយ៉ាងណាសូមឱ្យលោកបាន រស់ដោយសុខសាន្តឥតមានទុក្ខភ័យ ។
-ជាពិសេសនោះពេលគាត់នៅរស់ កុំឱ្យមានមោះត្រូវតែលកលៃ
ប្រតិបត្តិបូជាឱ្យបានប្រពៃ ញុំាងដួងហឫទ័យលោកឱ្យសប្បាយ ។

-មើលសំពត់អាវសម្រាប់ស្លៀកពាក់ ទឹកក្តៅត្រជាក់លាងជម្រះកាយ
ផ្លែឈើតូចធំម្ហូបចំណីបាយ ឱ្យឪពុកម្តាយគាត់បានសុខស្រួល ។
-រៀបចំទីនៅនិងទីសម្រាន្ត ឱ្យបានថ្មើងថ្កានត្រូវរៀបសម្រួល
សំអាតជូតលាងដោយការទទួល ភារៈដូចឈ្នួលក៏ត្រូវឃ្នាតខ្មី ។
-ពេលមានជំងឺគិតគូរព្យាបាល ទោះទាំងកណ្តាលយប់អធ្រាត្រក្តី
ត្រូវនាំទៅពេទ្យមិនត្រូវពោលស្តី លំបាកម្តេចក្តីឱ្យបានស័ក្តិសម ។
-ទោះអស់ប្រាក់ខែកម្លាំងកាយចិត្ត កូនអើយកុំគិតថាមិនសំណំ
ត្រូវប្រឹងតស៊ូស្មារតីរួមផ្សំ អ្នកនឹងឧត្តមវិសេសវិសាល ។

ថ្ងៃ ០២ កើត ខែមាឃ ពុទ្ធសករាជ ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ( ភួង-សុវណ្ណ)

## ១៩-ឱ ! កូនពុំងា

( បទគោព័ទ្ធស្នឹង មេពាក្យ ៤ )

១-ឱ! កូនពុំងា ពុំងាម្ទីម្នា ម្ទីម្នានឹងម្តាយ
ម្តាយមានគុណធ្ងន់ ធ្ងន់ហួសបរិយាយ បរិយាយវែងឆ្ងាយ
ឆ្ងាយដូចម្តេចម្តា ។
២-ទ្រាំទ្រពផ្ទៃ ផ្ទៃធំចិត្តមៃ មៃគិតជីវា
ជីវាម្តាយធន់ ធន់ទុក្ខឈឺផ្សា ផ្សាក្តៅយ៉ាងណា

ណាចិត្តភ័យអរ ។

៣-ពេលកូនកើតមក មកម្ដាយលៃលក លៃលកដោយល្អ

ល្អនោះមែនពិត ពិតម្ដាយត្រេកអរ អរចិត្តបវរ

បវររក្សា ។

៤-ម្ដាយមើលម្ដាយថៃ ថៃឥតមានល្ហែ ល្ហែមួយពេលណា

ណាចិញ្ចឹមស្នោះ ស្នោះនឹងជីវ៉ា ជីវ៉ាដឹងថា

ថាម្ដាយថ្នាក់ថ្នម ។

៥-ម្ដាយតែងគយគន់ គន់ចិត្តទោរទន់ ទន់ចង់បីបម

បីបមរូបអ្នក អ្នកត្រូវតែថ្នម ថ្នមជាដើមចម

ចមដោយស្នេហា ។

៦-កូនចម្រើនវ័យ វ័យកើនម្ដាយលៃ លៃឱ្យសិក្សា

សិក្សាវិជ្ជា វិជ្ជាថ្លៃថ្លា ថ្លាដោយបញ្ញា

បញ្ញាដ៏ល្អ ។

៧-កូនបានខ្ពង់ខ្ពស់ ខ្ពស់ដោយកិត្តិយស យសដ៏បវរ

បវរសែនល្អ ល្អចិត្តស្មោះសរ ស្មោះសរម្ដាយអរ

អរជាមួយអ្នក ។

៨-បើកូនយល់ត្រូវ ត្រូវដើរតាមផ្លូវ ផ្លូវអរិយមគ្គ

មគ្គដ៏ប្រសើរ  ប្រសើរនេះជាក់  ជាក់ណាស់មិនធ្លាក់
ធ្លាក់អបាយទេ ។
៩-ម្ដាយតែងផ្ដែផ្ដាំ  ផ្ដាំអ្នកត្រូវចាំ  ចាំចុះមាសមេ
មាសមេធ្វើអ្វី  អ្វីគួររិះរេ  រិះរេគិតគ្នេរ
គ្នេរឱ្យឃើញច្បាស់ ។
១០-ត្រូវវៀរចាកបាប  បាបមានក្លិនឆ្អាប  ឆ្អាបឆ្អេះខ្លាំងណាស់
ណាស់នាំទុក្ខសោក  សោកមិនស្រឡះ  ស្រឡះត្រចះ
ត្រចះទេណា ។
១១-ត្រូវសាងកុសល  កុសលនាំផល  ផលដ៏ថ្លៃថ្លា
ថ្លាបានរុងរឿង  រុងរឿងអស្ចារ្យ  អស្ចារ្យដោយសារ
ដោយសារធ្វើល្អ ។
១២-ខំជម្រះចិត្ត  ចិត្តមានសុចរិត  សុចរិតបវរ
បវរផូរផង់  ផូរផង់ស្រស់ល្អ  ល្អអើយសែនល្អ
ល្អណាស់ណាកូន ។

ថ្ងៃ ០១ រោច ខែវិសាខ ពុទ្ធសករាជ ២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២០-អាពុកគឺជាព្រះបិតា

១-អាពុកគឺជាព្រះបិតា ញ៉ាំងកូនសង្សារឲ្យបានកើត
បូកផ្សំមាតាផ្តល់កំណើត ដូចខែខាងខ្នើតជាពន្លឺ ។
២-លោកគិតខ្វល់ខ្វាយថែរក្សា ជាមួយមាតាតាមបានឮ
ទោះយប់ឬថ្ងៃជាឬឈឺ ដូចជាពន្លឺដល់កូនស្ងួន ។
៣-ខំប្រឹងធ្វើការសព្វទីឋាន ទុក្ខលំបាកប្រាណទ្រុឌទ្រោមខ្លួន
គិតធ្វើយ៉ាងណាឲ្យកូនស្ងួន រស់ដោយមាំមួនបានសុខសាន្ត ។
៤-រ៉ាប់រងសព្វគ្រប់ក្នុងគ្រួសារ នឿយហត់ចិន្តាចង់ឲ្យបាន
ប្រសើរខ្ពង់ខ្ពស់ក្នុងភូមិឋាន មិនស្រួលប៉ុន្មានទេមាសមេ ។
៥-កិច្ចការតូចធំផងទាំងឡាយ អាពុកខ្វល់ខ្វាយមិនទំនេរ
ជួនការងារម្តាយនោះឯងទេ តែពុកគ្មាន់គ្មេរធ្វើទាំងអស់ ។
៦-ទទួលខុសត្រូវសព្វបែបយ៉ាង មិនមែនតែម្យ៉ាងកូនដឹងចុះ
រៀបរាប់ប៉ុណ្ណោះមិនបានអស់ នៃចិត្តល្អស្មោះលោកអាពុក ។
៧-កូនគប្បីដឹងគុណដ៏ល្អ មានចិត្តបវរជាប្រមុខ
តបស្នងសងគុណដល់អាពុក ពីនេះទៅមុខកើតមង្គល ។
៨-ចូរកុំគិតថាគាត់មិនល្អ គ្មានចិត្តបវរណានិមល
ទោះគាត់មិនសូវបានរវល់ នឹងកូននិមលក៏ដោយណា ។
៩-កូនគួរតែដឹងអធ្យាស្រ័យ រស់នៅរាល់ថ្ងៃជាធម្មតា
ពេលខ្លះគាត់នឿយហត់កាយា ដូច្នេះជីវាគិតគាត់ផង ។

១០-ពេលកូនធំហើយបានរឹងប៉ឹង កូនអើយត្រូវដឹងត្រូវតបស្នង
អាពុកកល្យាណកុំឲ្យហ្មង នេះល្អកន្លងកើតសួស្តី ។
១១-បើកូនមិនដឹងប្រព្រឹត្តខុស នោះជាកំហុសណាប្រុសស្រី
នាំធ្លាក់សោយទុក្ខក្នុងអវីចី ឬប្រេតគ្មានអ្វីបរិភោគ ។
១២-គុណទោសឲ្យផលផ្សេងខុសគ្នា ប្រសិនពុំងាចង់មានជោគ
លាភយសសិរីសម្បត្តិភោគ មានជ័យមានជោគត្រូវដឹងគុណ ។

វត្តនិគ្រោធវ័ន ថ្ងៃ ៣ កើត ខែបុស្ស ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

ធម្មតាមាតាបិតាគ្រប់រូប តែងតែស្រឡាញ់កូន ប្រសិនបើគាត់មិនបានស្រឡាញ់ ថ្នាក់ថ្នមថែទាំយើងបានល្អដោយប្រការណា ក៏ព្រោះតែយើងខ្លួនឯង មិនមានបុណ្យបានធ្វើទុកមកយើងខ្វះបុណ្យ ឬព្រោះការឆ្គាំឆ្គងរបស់យើងក្នុងបច្ចុប្បន្ន, ព្រោះដូច្នោះ ត្រូវមានស្មារតីសន្សំបុណ្យ មានអាកប្បកិរិយាសមរម្យល្អសុភាពទន់ភ្លន់ កុំមានចិត្តប្រទូស្តចំពោះមាតាបិតាឲ្យសោះ គប្បីព្យាយាមសាងសេចក្តីល្អចំពោះគាត់ឲ្យបានច្រើន តាមដែលអាចធ្វើបាន ។ សេចក្តីល្អ នឹងឈ្នះសេចក្តីមិនល្អ ។ កិរិយាសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ។

## ២១-បុត្ត ៣ ប្រការ

១-អតិជាតបុត្ត (កូនដែលល្អជាងមាតាបិតាផ្នែកខាងគុណធម៌ មានសីលគុណជាដើម)

២-អនុជាតបុត្ត (កូនដែលល្អតាមមាតាបិតា)

៣-អវជាតបុត្ត (កូនដែលអន់ទន់ទាបជាងមាតាបិតា)។

គ្រប់យ៉ាងកើតពីហេតុ មិនមែនចេះតែមានបានតាមដែលយើងចង់នោះទេ ។ ត្រូវស្គាល់ការពិត គប្បីសង្គ្រោះកូនដោយធម៌ អប់រំដោយធម៌ ដឹកនាំដោយធម៌ បើបានល្អជាការប្រពៃ, បើមិនបានទេ ត្រូវទូន្មានខ្លួនដោយធម៌ ប្រព្រឹត្តធម៌ រក្សាខ្លួនទុកក្នុងកុសលធម៌ដោយប្រពៃ ។

## កំណាព្យ កូន ៣ ប្រការ

-ខ្ញុំម្ចាស់សូមក្រាបថ្វាយបង្គំ ចំពោះព្រះបរមត្រៃរតនា
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃថ្លា សូមលើកហត្ថាចារតាក់តែង ។
-អ្នកចង់ដឹងទេកូនក្នុងលោកា មាន ៣ ប្រការព្រះពុទ្ធសម្តែង
កូនល្អអាក្រក់មានជាក់ស្តែង កូនចេះកោតក្រែងស្តាប់ពុកម៉ែ ។
-អតិជាតបុត្តៗល្អពិត គឺជាបណ្ឌិតឆ្លាតពូកែ
សីលាចារវត្តប្រសើរដែរ ល្អជាងពុកម៉ែផ្នែកគុណធម៌ ។
-អនុជាតបុត្តៗល្អដូច មិនចេះខិលខូចមិនញាប់ញ័រ

ធ្វើតាមពុកម៉ែដែលមានធម៌ ពិតមិនញាប់ញ័រស្តាប់បង្គាប់ ។
-អវជាតបុត្តៗមិនល្អ គ្មានចិត្តបវរតាមទម្លាប់
ល្មើសគុណពុកម៉ែមិនគួរគាប់ ឥតស្តាប់បង្គាប់អាក្រក់ក្រៃ ។
-កូនល្អអាក្រក់ដូចបញ្ឆោក ខាតលក្ខណ៍គ្រប់លក្ខណ៍ឥតកាឡៃ
មាតាបិតាត្រូវកែខៃ គិតនឹកស្រមៃដោយប្រាជ្ញា ។
- ចិញ្ចឹមអប់រំជួយសង្គ្រោះ កុំឲ្យមានមោះតាមធម៌អាថ៌
តាមតួនាទីដ៏ថ្លៃថ្លា អត់ធន់មេត្តាជាប្រក្រតី ។
- កុំឡើយលំអៀងចិត្តមិនស្មើ ដែលជាដំណើរនាំប្រុសស្រី
អាក់អន់ឈ្លោះទាស់មិនគប្បី នេះមកពីអ្វី? ព្រោះខ្វះធម៌ ។
- បើបានសង្គ្រោះទូន្មានហើយ តែកូននោះអើយចិត្តញាប់ញ័រ
ឥតស្គាល់គុណទោសកុសលធម៌ ជាប់ក្នុងភ្លើងពណ៌ត្រូវគ្មេរគ្មាន់។
- សត្វលោកមានកម្មរៀងៗខ្លួន កម្មដ៏មាំមួនជាប់ពាក់ព័ន្ធ
កម្មយើងកម្មកូនមកតាមទាន់ ដូច្នេះរួសរាន់រកធម្មៈ ។

ថ្ងៃ ៦ កើត ខែទុតិយាសាឍ ពុទ្ធសករាជ២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២២-ថ្ងៃខួបកំណើត

១-ថ្ងៃខួបកំណើត ថ្ងៃដែលកូនកើត ចេញចាកផ្ទៃម្តាយ
ថ្ងៃម្តាយមានទុក្ខ សែនលំបាកកាយ គួរអាសូរម្តាយ
ឱណាកូនណា ។

២-ម្ដាយផ្ដល់កំណើត ញ៉ាំងកូនឲ្យកើត មានចិត្តស្នេហា
មើលថែថ្នាក់ថ្នម ចិញ្ចឹមរក្សា ផ្ដេកលើឱរា
ដោយចិត្តបវរ ។
៣-ទឹកចិត្តប្រណី ញ៉ាំងកូនប្រុសស្រី ឲ្យបានត្រេកអរ
ដោយបំបៅដោះ ជាដើមដោយល្អ មានចិត្តអំណរ
នឹងកូនជីវា ។
៤-សង្គ្រោះអាណិត អស់ពីដួងចិត្ត ចិញ្ចឹមរក្សា
ឲ្យបានរស់រាន ដោយចិត្តមេត្តា និងករុណា
ស្រឡាញ់រាប់អាន ។
៥-ម្ដាយតែងខ្វល់ខ្វាយ គ្រប់កិច្ចទាំងឡាយ នៅសព្វទីឋាន
ណាជួយបង្រៀន ដល់កូនកល្យាណ ផ្ដល់ក្ដីសុខសាន្ត
ដល់កូនពុំងា ។
៦-លះបង់គ្រប់យ៉ាង មិនមែនតែម្យ៉ាង ដឹងចុះស្ងួនភ្ងា
តាំងពីជីវិត ព្រមទាំងទ្រព្យា និងពេលវេលា
ព្រោះបុត្រធីតា ។
៧-លោកមានគុណធ្ងន់ គុណដ៏លើសលន់ មិនអាចឧបមា
ប្រៀបធៀបឲ្យស្មើ នូវគុណឧបការ ទោះពោលយ៉ាងណា
អស់កាលជានិច្ច ។
៨-ដួងចិត្តដ៏ល្អ មានជាបន្ត កូនកុំបំភ្លេច
កូនត្រូវចងចាំ ក្នុងចិត្តជានិច្ច លំបាកដូចម្ដេច

ត្រូវតែតបស្នង ។
៩-ថ្ងៃនេះថ្ងៃក្រោយ កូនកុំកន្តើយ ធ្វើតាមបំណង
ប្រព្រឹត្តតាមធម៌ ដ៏ល្អកន្លង ដើម្បីតបស្នង
មាតាបិតា ។
១០-បើអ្នកតបគុណ គុណដ៏លើសលន់ នេះព្រះសាស្តា
ត្រាស់ថាមង្គល ឧត្តមអស្ចារ្យ នាំបានសុខា
ជាស្រីសួស្តី ។
១១-កំណើតដែលល្អ ប្រសើរបវរ គួរណាស់ប្រុសស្រី
ធ្វើកុសលកម្ម ទានក្តីសីលក្តី ដោយការឃ្មាតខ្មី
ចម្រើនភាវនា ។
១២-ធ្វើបានដូច្នេះ ពិតជាពិសេស គឺជាមាគ៌ា
នៃពួកសប្បុរស ទាំងឡាយគ្រប់គ្នា រហូតបានជា
ព្រះអរិយៈ ។

វត្តនិគ្រោធវ័ន ថ្ងៃ១៤កើត ខែមិគសិរ ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ (ភួងសុវណ្ណ)

ថ្ងៃដែលកូនកើតចេញចាកផ្ទៃម្តាយ គឺជាថ្ងៃដែលម្តាយមានសេចក្តីទុក្ខដ៏សែនលំបាកកាយខ្លាំងណាស់ ដូច្នេះកូនទាំងឡាយគួរអាសូរដល់ម្តាយផង ។ ម្យ៉ាងទៀត ត្រូវរលឹកដល់សេចក្តីល្អដែលមាតាបិតាបានចិញ្ចឹម មើលថែរហូតមកហើយ ត្រូវតបស្នងសងគុណគាត់វិញឲ្យបានស័ក្តិសម ។

# ២៣_អោះអោ! អ្នកម្ដាយ

១-អ្នកម្ដាយកល្យាណ មានចិត្តប្រោសប្រាណ លើកូនពន្លក
មេត្តាអាណិត តែងបង្ហូរមក ផ្ដល់ជាជម្រក
កូនបានសុខា ។

២-កូននៅក្នុងផ្ទៃ ចិត្តម្ដាយព្រួយភ័យ ដល់កូនសង្ស័រ
ខ្លាចកូនលំបាក កើតទុក្ខឈឺផ្សា ម្ដាយមានមេត្តា
ដល់កូនពុំងា ។

៣-ម្ដាយសែនលំបាក មានទុក្ខឥតស្រាក គ្រុនក្ដៅរងា
ដេកដើរមិនស្រួល រាល់ពេលវេលា ព្រោះតែស្នេហា
ម្ដាយក៏មិនថា ។

៤-ពេលកូនកើតមក ឱកូនពន្លក ម្ដាយទុក្ខឈឺផ្សា
ស្ទើរក្ស័យជីវិត ចាកចោលលោកា ឱណាកូនណា
ចិត្តម្ដាយភ័យអរ ។

៥-កូននៅទារក ទឹកមូត្រលាមក កខ្វក់កករ
ម្ដាយដុះម្ដាយលាង ឱ្យបានស្អាតល្អ ដោយចិត្តស្មោះសរ
ព្រោះតែស្នេហា ។

៦-កូននៅក្មេងខ្ចី មិនទាន់ដឹងក្ដី ស្រែកយំឡូឡា

ម្តាយនៅមើលថែ បីបាច់រក្សា ថ្នាក់ថ្នមជីវា
ដោយបំបៅដោះ ។
៧-កូនធំដឹងក្តី ផុតពីក្មេងខ្ចី រូបរាងល្អស្រស់
ម្តាយតែងគយគន់ សោភ័ណសម្រស់ ស្រឡាញ់ដោយស្មោះ
ចិត្តមុទិតា ។
៨-ម្តាយបានលកលៃ ឱ្យកូនប្រុសស្រី បានទៅសិក្សា
ចំណេះវិជ្ជា នឹងគ្រូអាចារ្យ នៅតាមសាលា
តាមដែលម្តាយមាន ។
៩-ម្តាយមើលរំពៃ ខិតខំលកលៃ ផ្តល់ដំបូន្មាន
នាំសុខចម្រើន ផុតការស្រេកឃ្លាន ឱ្យកូនប្រឹងរៀន
ប្រឹងប្រព្រឹត្តល្អ ។
១០-កូនស្គាល់ខុសត្រូវ បានដើរតាមផ្លូវ មគ្គដ៏បវរ
សម្មាទិដ្ឋិ យល់ឃើញត្រូវល្អ ចិត្តម្តាយត្រេកអរ
ទឹកចិត្តទោរទន់ ។
១១-ពេលកូនពិសី មានប្រពន្ធប្តី សង្គ្រោះពេកពន់
ផ្តល់នូវរបស់ មាសប្រាក់ទ្រព្យធន ប្រសើរលើសលន់
ជួយបុត្តធីតា ។

១២-កូនសុខសប្បាយ ស្រុះស្រួលស្រស់ស្រាយ ទៅតាមប្រាថ្នា
ម្តាយសប្បាយចិត្ត មិនអាចឧបមា ទឹកចិត្តស្រស់ថ្លា
អ៉ោះអ៉ោ! អ្នកម្តាយ ។

ថ្ងៃ ១០ កើត ខែមិគសិរ ព.ស. ២៥៥៤
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៤-ការគោរពគុណ និងខមាទោស

-បពិត្រលោកអ្នកមាតាបិតា កូននមស្ការដោយការគោរព
រូបលោកទាំងពីរពិតបានជាម្លប់ រាល់ពេលថ្ងៃយប់កូនតែងបានជ្រក ។
-កូនសូមគោរពរលឹកដល់គុណ ដ៏មានទម្ងន់តែងបង្ហូរមក
រាល់ពេលវេលាដូចទឹករលក ផ្សព្វផ្សាយចូលមកដូចចន្ទ្រស្រទន់ ។
-ក្នុងព្រះធម្មាបានប្រាប់ច្បាស់ថា មាតាបិតាលោកមានគុណធ្ងន់
ឱ្យកូនបានរស់សង្គ្រោះពេកពន់ ប្រសើរលើសលន់ទឹកចិត្តថ្លៃថ្លា ។
-ព្រះពុទ្ធត្រាស់ថាមានព្រហ្មវិហារ ព្រះទ័យល្អជាមេត្តាករុណា
រាប់អានអាណិត ចិត្តមុទិតា និងឧបេក្ខា លើកូនប្រុសស្រី ។
-ម្យ៉ាងវិញទៀតនោះលោកជាទេព្តា ជាបុព្វាចារ្យ ទឹកចិត្តប្រណី
ណែនាំសព្វគ្រប់ ជានិច្ចរាល់ថ្ងៃ ខំប្រឹងកែខៃមិនគិតនឿយហត់ ។

-អាហុនេយ្យបុគ្គលមែនពិត កូនសូមចូលជិតដោយចិត្តអំណត់
តាំងចិត្តបូជា រូបលោកប្រាកដ ធ្វើដោយហ្មត់ចត់តាមពុទ្ធឱវាទ ។
-ឥឡូវនេះកូនសូមខមាទោស រាល់ការឆ្គងខុសព្រោះល្ងង់មិនឆ្លាត
ដោយកាយវាចាចិត្តមិនល្អស្អាត ដេរវាយប្រមាថជាដើមដល់លោក ។
-សូមលោកលើកលែងនូវទោសទាំងឡាយ ឱ្យកូនសប្បាយមានជ័យមានជោគ
ប្រព្រឹត្តធម្មៈពិតឆ្លងចាកលោក ដែលព្រះមានជោគទ្រង់ត្រាស់ទុកហើយ ។

ថ្ងៃ ០៧ កើត ខែផល្គុន ព.ស.២៥៥៥

និពន្ធដោយភិក្ខុ ភួង-សុវណ្ណ

## ២៥-កូនសម្តែងការត្រេកអរ

-សាធុ!សាធុ!កូនត្រេកអរណាស់ ព្រោះឮយ៉ាងច្បាស់ពាក្យពេចន៍វាចា
លោកលើកលែងទោសសព្វគ្រប់ប្រការ ឱ្យកូនសង្ខារបានសុខសប្បាយ ។
-ទឹកចិត្តទាំងនេះកូនសូមចងចាំ ទោះច្រើនខែឆ្នាំតទៅវែងឆ្ងាយ
កូនចាំជានិច្ចគុណឪពុកម្តាយ កូនសូមខ្វល់ខ្វាយតបស្នងសងគុណ ។

ថ្ងៃ ០៧ កើត ខែផល្គុន ព.ស.២៥៥៥

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៦-កូនលាមាតាបិតាចេញសាងផ្នួស

( បទពាក្យ ៨ )

-កូនសូមក្រាបវន្ទានមស្ការ បាទាមាតាបិតាប្រពៃ
ឱនកាយវាចាព្រមទាំងហឫទ័យ ឥតមានមោះមៃចេញពីសន្តាន ។
-មាតាបិតាមានគុណធ្ងន់ក្រៃ មិនអាចឧបមេយ្យឱ្យប្រៀបស្មើបាន
មេត្តាករុណាមានចិត្តប្រោសប្រាណ ប្រសើរថ្កើងថ្កានមកលើបុត្រា ។
-បណ្ឌិតពោលថាលោកគឺជាព្រហ្ម ប្រាប់កិច្ចតូចធំ ជាបុព្វាចារ្យ
សន្តានស្អាតល្អ និងជាទេវតា ផ្តល់ក្តីសុខាឱ្យដល់បុត្រស្ងួន ។
-កូនសូមលាលោកអ្នកមានព្រះទ័យ តែងឱ្យអភ័យសទ្ធាមាំមួន
កូនលាទៅបួសដើម្បីសាងខ្លួន ប្រព្រឹត្តខ្ជាប់ខ្ជួនក្នុងពុទ្ធសាសនា ។
-សូមលោកមេត្តាដោយអនុគ្រោះ ឱ្យកូនសាងផ្នួសសិក្សាសិក្ខា
ក្នុងធម៌វិន័យនៃព្រះសាស្តា ទ្រង់ត្រាស់ទេសនា ដែលមានលំអ ។
-សូមលោកទាំងពីរបានអនុញ្ញាត ដោយចិត្តថ្លាស្អាតមិនល្អក់កករ
ញុំាងសទ្ធាកូនដ៏ល្អបវរ ជ្រះថ្លាក្នុងធម៌អស់កាលយូរហើយ ។
-ឥឡូវថ្ងៃនេះ កូនសូមទទូច ដែលចិត្តកូនផ្តួច លោកកុំកន្តើយ
មេត្តាអនុញ្ញាតឱ្យកូនបានស្បើយ កូនសូមលាហើយលាបួសថ្ងៃនេះ ។

និពន្ធដោយភិក្ខុ ភួង-សុវណ្ណ

## ២៧-កូនសម្ដែងសេចក្ដីត្រេកអរ និងការអធិដ្ឋាន

-សាធុ សាធុ គួរត្រេកអរក្រៃ អ្នកមានគុណថ្លៃបានអនុគ្រោះ
មានចិត្តសទ្ធាឱ្យកូនសាងផ្នួស ប្រសើរខ្ពង់ខ្ពស់ក្នុងពុទ្ធសាសនា ។
-កូនសូមតាំងចិត្តធ្វើអធិដ្ឋាន ទូន្មានសន្ដានឱ្យល្អថ្លៃថ្លា
ចម្រើនសីលសមាធិបញ្ញា ដែលព្រះសាស្ដាទ្រង់ត្រាស់ទុកហើយ ។
-ញ៉ាំងសទ្ធាហិរិឱត្តប្បៈ វិរិយៈសុត្តៈមិនកន្ដើយ
សតិសព្វកាលនាំផ្លូវដល់ត្រើយ មិនទម្រន់ឡើយតាមព្រះសាស្ដា ។
-ចូលប្រាស្រ័យសេពគប់កល្យាណមិត្រ អង្គប្រាំពីរពិតមានគុណក្រៃណា
ចម្រើនសីលសមាធិបញ្ញា ជាគុណអស្ចារ្យនាំដល់និព្វាន ។

និពន្ធដោយ ភិក្ខុ ភួង-សុវណ្ណ

## ២៨-កំណាព្យសូធ្យក្នុងពិធីបំបួស

### ក-សូធ្យពេលកោរសក់ ឬពេលដង្ហែនាគ

-សុរិយាបំភ្លឺទ្វីបលោកា មាតាបិតាបំភ្លឺបុត្រ
ដោយដួងហឫទ័យល្អបរិសុទ្ធ ឱ្យកូនរួចផុតបានខ្ពង់ខ្ពស់ ។
-មានចិត្តសទ្ធាក្នុងសាសនា មាតាបិតាអនុគ្រោះ
ព្រមអនុញ្ញាតឥតមានមោះ ឱ្យកូនសាងផ្នួសតាមវិន័យ ។

-ឃើញសេចក្ដីល្អគួរប្រព្រឹត្ត សន្សំសុចរិតក្នុងកែវបី
ព្រះពុទ្ធព្រះធម៌ព្រះសង្ឃថ្លៃ នាំបានសិរីក្ដីសុខា ។
-ឃើញទោសទុច្ចរិតនាំលិចលង់ ធ្លាក់ក្នុងអន្លង់បួនប្រការ
កើតចាស់ឈឺស្លាប់គ្រប់រូបា មិនដឹងថ្ងៃណាបានរួចខ្លួន ។
-ឱ្យកូនលះផ្ទះលះពួកញាតិ សង្វាតខ្មីឃ្មាតយ៉ាងមាំមួន
សិក្សាអប់រំទូន្មានខ្លួន សតិខ្ជាប់ខ្ជួនមិនប្រមាទ ។

## ខ-ស្មូធ្យក្រោយពេលមាតាបិតាអនុញ្ញាតឱ្យបួស

-សុរិយារះពីទិសខាងកើត រស្មីល្អឆើតដ៏បវរ
មាតាបិតាមានចិត្តល្អ សាទរត្រេកអរនឹងកូនស្ងួន ។
-យល់ព្រមឱ្យបួសក្នុងសាសនា សិក្សាធម៌អាចិទូន្មានខ្លួន
ប្រព្រឹត្តបដិបត្តិឱ្យមាំមួន ដើម្បីដោះខ្លួនចេញចាកទុក្ខ ។

## គ-ស្មូធ្យពេលកូនអធិដ្ឋានចិត្តរួចហើយ

-សាធុ សាធុ គួរជ្រះថ្លា កុលបុត្រសទ្ធាដោយប្រពៃ
តាំងអធិដ្ឋានក្នុងហឫទ័យ ចង់ឆ្លងភពបីដល់និព្វាន ។
-និព្វានជាទីបរមសុខ សទ្ធានាំមុខ សីលជាស្ពាន
វិសមាធិក៏កើតមាន បញ្ញាជាយាននាំផុតទុក្ខ ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៩-កូនចង់បួស

១-ខ្ញុំសូមរៀបរាប់ពិពណ៌នា អ្នកមានសទ្ធាចង់សាងផ្នួស
នៅក្នុងសាសនាឥតមានមោះ ចិត្តស្ម័គ្រចំពោះធម៌បវរ ។
២-ព្រោះអាស្រ័យឃើញសេចក្តីទុក្ខ បណ្តាញស្មាញស្មុគល្អក់កករ
តណ្ហាចាក់ស្រែះជាប់បន្ត ញាំងសត្វនិករឱ្យលិចលង់ ។
៣-ឃើញថាបព្វជ្ជានេះប្រសើរ គឺជាដំណើរឆ្លងអន្លង់
អាចកាត់មោហៈក្តីល្ងិតល្ងង់ ហើយឆ្លងអន្លង់អវិជ្ជា ។
៤-តែគួរសង្វេគពន់ពេកណា ចិត្តកូនប្រាថ្នាដោយសទ្ធា
មាតាបិតាត្រឡប់ជា ហាមកូនពុំងាមិនឱ្យបួស ។
៥-កូនចង់បព្វជ្ជាក្រៃលែងក្រៃ អ្នកមានគុណថ្លៃមិនសង្គ្រោះ
ឱ្យកូនបានចេញសាងព្រះផ្នួស ប្រសើរខ្ពង់ខ្ពស់ក្នុងសាសនា ។
៦-តើហេតុអ្វីទៅណាអ្នកម្តាយ លោកធ្វើអន្តរាយក្តីប្រាថ្នា
ដែលកូនតាំងចិត្តល្អថ្លៃថ្លា បួសក្នុងសាសនាព្រះសម្ពុទ្ធ ។
៧-សូមលោកបានយល់ពីបំណង ដ៏ល្អកន្លងចិត្តមោះមុត
រៀនធម៌វិន័យព្រះសុគត ជាព្រះសម្ពុទ្ធនាំរួចទុក្ខ ។

វត្តនិគ្រោធវ័ន ថ្ងៃ ១០ រោច ខែកត្តិក ព.ស. ២៥៥២

និពន្ធដោយភិក្ខុ ភួង សុវណ្ណ

ព្រះពុទ្ធ ទ្រង់ត្រាស់ថា ៖

ការចេញបួសបានដោយក្រ ការត្រេកអរត្រូវ បានដោយក្រ ផ្ទះទាំងឡាយមានការនៅគ្រប់គ្រងដោយលំបាក ជាការក្រ ការនៅរួមដោយជនស្មើគ្នា (ដែលមិនមានសេចក្ដីកោតក្រែង) ជាការក្រ ជនអ្នកដើរផ្លូវឆ្ងាយគឺវដ្ដៈ តែងត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាម ព្រោះហេតុនោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយផង មិនគប្បីជាអ្នក ត្រូវសេចក្ដីទុក្ខធ្លាក់ជាប់តាមផង ។ (គាថាធម្មបទ)

## ៣០-ហាទ័យមាតា

-ក្នុងខែអាសាឍ ១៤ កើត ជាប៉ែកខាងខ្នើតដ៏បវរ
មាតាបិតាមានចិត្តល្អ សាទរត្រេកអរនឹងកូនស្ងួន ។
-យល់ព្រមឲ្យបួសក្នុងសាសនា សិក្សាធម៌អាចទូន្មានខ្លួន
តែម្ដាយស្រណោះដល់មាសស្ងួន ក្រែងមិនមាំមួនតាមប្រក្រតី។
-ម្ដាយជ្រះថ្លាហើយក្នុងសាសនា តែគិតជីវានៅក្មេងខ្ចី
ម្ដាយភ័យម្ដាយព្រួយក្នុងហាទ័យ ម្ដាយនឹកមមៃដល់ជីវា ។
-សូមបុណ្យបារមីសេចក្ដីល្អ ជួយកូនបវរបានសុខា
បួសដោយសទ្ធាក្នុងសាសនា ប្រតិបត្តិធម៌អាចរួចចាកទុក្ខ ។

ថ្ងៃ ១៤ កើត ខែទុតិយាសាឍ ព.ស.២៥៥៩

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៣១-អត្ថបទទាក់ទងនឹងស្វាមីភរិយា

ពរជ័យ គឺជាវត្ថុបំណងរបស់សត្វលោកគ្រប់គ្នា ដូច្នេះ ដើម្បីទទួលបានពរជ័យ សិរីសួស្តី ស្វាមីភរិយា ត្រូវតែមានភក្តី គឺ សេចក្តីស្រឡាញ់ស្មោះ សេចក្តីស្មោះត្រង់ដល់គ្នានិងគ្នា នេះជា តួនាទីដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា អនតិចរិយាយ ឬ អនតិចារិនី ដែលប្រែថា ដោយមិនប្រព្រឹត្តក្បត់ចិត្ត និងត្រូវ ប្រព្រឹត្តក្នុងគោលធម៌ផ្សេងៗទៀត មានមេត្តា មានករុណា សេចក្តីអត់ធន់ និងសង្គហធម៌ជាដើម ។

អ្នកត្រូវដឹងថា ៖ ម្សិលមិញផ្សេង ថ្ងៃនេះផ្សេង ឆ្នាំមុនផ្សេង ឆ្នាំនេះផ្សេង ធ្វើម៉េចនឹងដូចគ្នា គ្រប់យ៉ាងមានការប្រែប្រួល, តែ ភរិយាស្វាមី មិនអាចម្សិលមិញផ្សេង ថ្ងៃនេះផ្សេង ឆ្នាំនេះផ្សេង ឆ្នាំមុនផ្សេងបានទេ ត្រូវតែមានភក្តីជាមួយគ្នារហូត ។

## ៣២-ជូនពរស្វាមីភរិយា

ត្រូវចាំជានិច្ច ដើម្បីគ្រួសារមានសុភមង្គល

-អាយុវណ្ណៈសុខៈពលៈ ចូរមានដល់អ្នកទាំងប្រពន្ធប្តី
តែសូមផ្តាំថាត្រូវមានភក្តី ប្រពន្ធស្មោះប្តីៗស្មោះប្រពន្ធ ។
-រស់ជាមួយត្រូវមានមេត្តា មានករុណានិងចេះអត់ធន់
ស្វាមីភរិយាមានភារៈធ្ងន់ សូមចិត្តទោរទន់ចេះសង្គ្រោះគ្នា ។

-ចិញ្ចឹមជីវិតក៏ដោយសម្មា ខំធ្វើកិច្ចការស្វែងរកទ្រព្យា
តែត្រូវសន្តោសកុំឈ្លោះទាស់គ្នា ព្រោះរឿងលាភាមិនដូចបំណង។
-ត្រូវប្រព្រឹត្តធម៌ឲ្យបានជានិច្ច ចូរកុំបំភ្លេចហើយកុំកន្លង
មាតាបិតាអ្នកត្រូវតបស្នង ឲ្យបានហ្មត់ហ្មង់អ្នកនឹងថ្កុំថ្កើង ។
-សង្គ្រោះពួកញាតិទាំងឡាយដោយល្អ មានចិត្តបវរមិនឆ្មើងកន្ទ្រើង
លាភយសសិរីនឹងប្រសើរឡើង ព្រោះមិនចើងម៉ើងរាប់រកពួកញាតិ។
-ត្រូវមានសទ្ធាសីលាចាគា បញ្ញាស្មើគ្នា លុះកាយបែកឃ្លាត
លះពីលោកនេះជួបបរលោកទៀត ពិតមិនឃ្លៀងឃ្លាតរហូតនិព្វាន ។

ថ្ងៃ ៣ កើត ខែបុស្ស ពុទ្ធសករាជ២៥៥៨
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៣៣-ជីវិតគ្រួសារ

-ជីវិតគ្រួសារស្វាមីភរិយា រស់ជួបជុំគ្នាដឹងចុះកល្យាណ
តែងមានបញ្ហាតិចច្រើនមិនខាន ដូច្នេះគ្រប់ប្រាណត្រូវចេះមេត្តា។
-ធ្វើម្ដេចបានគ្នាជាប្ដីប្រពន្ធ គួរចេះអត់ធន់ដោះស្រាយបញ្ហា
ដោះតាមផ្លូវធម៌ដោះដោយបញ្ញា សូមចិត្តមេត្តាអាណិតដល់កូន។
-គ្រួសារបែកបាក់មានអ្វីល្អទៅ តែងតែអាស្រូវដល់ញាតិបងប្អូន
ប្រៀបដូចបាក់ស្ពានជីវិតស្ទើរសូន្យ ជាពិសេសកូនរងទុក្ខខ្លោចផ្សា។
-ដូច្នេះគប្បីគិតឲ្យល្អិតល្អ មានចិត្តស្មោះសរកុំឡើយសាវា
ចេះស្រឡាញ់គ្នាដោយចិត្តមេត្តា រស់ដោយបញ្ញាជីវិតឧត្តម ។

-សាងគុណសម្បត្តិឲ្យបានស្មើគ្នា គ្រប់ពេលវេលាដោយការខិតខំ លះបាបធ្វើបុណ្យប្រឹងប្រែងសន្សំ បូករួមផ្សំផ្សំនឹងបានផុតទុក្ខ៕

រាត្រីថ្ងៃ ០៦ កើត ខែជេស្ឋ ព.ស.២៥៥៩

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

=> គ្រួសារដែលមានសុភមង្គល មានសិរីសួស្តីពិតប្រាកដ ទាល់តែគ្រួសារដែលមានធម៌ ប្រព្រឹត្តធម៌ ។ល។ ដូច្នេះ មាតាបិតា ត្រូវជាអ្នកអាស្រ័យនូវធម៌ ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ រាប់អាន ធម៌ បូជាធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាស្ពាន យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកប ដោយធម៌ ។ ម្យ៉ាងទៀត ត្រូវចេះណែនាំកូនឲ្យស្គាល់ល្អអាក្រក់ ហាម ឃាត់កូនចាកអំពើបាប បបួលកូនឲ្យធ្វើអំពើល្អ ។ បើណែនាំខ្លួនឯង មិនបានទេ ត្រូវឲ្យអ្នកដទៃជួយណែនាំ ឆ្លៀតពេលកូនមិនទៅសិក្សា នៅសាលា គួរនាំកូនទៅវត្ត មានឱកាសបានធ្វើសេចក្តីល្អ ដូចជាបូជា ព្រះរតនត្រ័យ ស្តាប់ព្រះធម៌ ថ្វាយទាន រក្សាសីលជាដើម ។ បើមិន ដូច្នោះទេ មាតាបិតានឹងអាចមានផលលំបាកនៅពេលអនាគត ព្រោះ តែកូនមិនយល់ធម៌ មិនអាចប្រព្រឹត្តធម៌ គឺសេចក្តីល្អបាន ។

=> ការប្រព្រឹត្តធ្វើខ្លួនឲ្យល្អ គឺជាសំខាន់ណាស់ គឺថាជាទីពឹង សម្រាប់ខ្លួនផង និងជាគំរូល្អសម្រាប់កូនសិក្សា ប្រព្រឹត្តតាមផង ។

=> **ធម្មោ ហវេ រក្ខតិ ធម្មចារឹ** : ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្ត ធម៌ ។

## ៣៤_តួនាទីមាតាបិតា ៥ យ៉ាង

**១_បាបា និវារេន្តិ** ហាមឃាត់កូនចាកអំពើអាក្រក់

**២_កល្យាណេ និវេសេន្តិ** ឱ្យកូនតម្កល់នៅតែក្នុងអំពើល្អ

**៣_សិប្បំ សិក្ខាបេន្តិ** ឱ្យកូនរៀនសូត្រសិល្បសាស្ត្រ

**៤_បដិរូបេន ទារេន សញ្ញោជេន្តិ** ដណ្ដឹងភរិយាស្វាមីសមគួរឱ្យ

**៥_សមយេ ទាយជ្ជំ និយ្យាទេន្តិ** ចែកទ្រព្យឱ្យកូនក្នុងសម័យគួរ ។

## ៣៥-ថ្ងៃនេះខ្ញុំចង់និយាយប្រាប់ថា

>ថ្ងៃនេះខ្ញុំចង់និយាយប្រាប់ថា មាតាបិតាគឺជាគ្រូដើម
មែនពិតយ៉ាងច្បាស់ជាគ្រូដ៏ឆ្នើម ផ្ដល់នូវដង្ហើមចំណេះវិជ្ជា។
>ឲ្យបុត្តធីតាចេះនិយាយស្ដី ហូបនំចំណីបាយទឹកភោជនា
ឲ្យចេះស្លៀកពាក់ដេកដើរនានា ឲ្យកូនពុំងាចេះដឹងទាំងអស់។
>ចរិយាមារយាទអាកប្បកិរិយា កូនបានសិក្សាតាមគ្មានចន្លោះ
តាំងពីប្រើប្រាស់នូវទ្រព្យរបស់ និងការឈ្លោះទាស់ក៏កូនដឹងដែរ។
>ព្រោះហេតុដូច្នោះសូមចិត្តមេត្តា មាតាបិតាគប្បីកែប្រែ
អំពើអាក្រក់ពាលាប៉ោឡែ នាំទុក្ខឥតល្ហែដល់ក្រុមគ្រួសារ។

>គួរអាសូរចិត្តអាណិតដល់កូន ប្រៀបដូចជាក្បូននៅក្នុងជលសា
អណ្តែតរសាត់ទៅកាន់ទីណា មាតាបិតាគឺជាចម្បង។
>ធ្វើអ្វីគ្រប់យ៉ាងឲ្យចេះគ្នាន់គ្នេរ លៃលករិះរេឲ្យបានហ្មត់ហ្មង
ផ្តល់ជាចំណេះដ៏ល្អកន្លង ដល់កូនៗផងធ្វើជាបន្ត។
>ជួយផ្តល់ឱវាទអប់រំទូន្មាន ឲ្យកូនអាចហ៊ានសាងសេចក្តីល្អ
លះបង់ធម៌ខ្មៅចម្រើនធម៌ស ប្រសើរបវរបានសុខក្សេមក្សាន្ត៕

ព្រឹកថ្ងៃ ០៨ កើត ខែជេស្ឋ ព.ស. ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៣៦_តួនាទីស្វាមី ៥ យ៉ាង

**១_សម្មាននាយ** ដោយការរាប់អានជាភរិយាពេញទី
**២_អវិមាននាយ** ដោយមិនមើលងាយ
**៣_អនតិចរិយាយ** ដោយមិនប្រព្រឹត្តក្បត់ចិត្ត
**៤_ឥស្សរិយវោស្សគ្គេន** ដោយប្រគល់ឱ្យជាធំ (ក្នុងការផ្ទះ)
**៥_អលង្ការានុប្បទានេន** ដោយការឱ្យគ្រឿងតែងខ្លួន។

## ៣៧-ភាពជាបុរស

-ភាពជាបុរសដ៏ឧត្តម ធ្វើឲ្យស័ក្តិសមណាកល្យាណ
វៀរចាកបាបកម្មខាងតែបាន ផ្តល់ក្តីសុខសាន្តក្នុងលោកា ។

-កុំតាមចំណង់តាមតែចិត្ត នាំក្តីវិបរិតក្នុងគ្រួសារ
សង្គមភូមិស្រុកក្នុងរដ្ឋា ជួបតែទុក្ខាគ្មានពេលស្ងៃ ។
-ភាពជាបុរសជាបិតា ជាមេគ្រួសារត្រូវពូកែ
ស្មារតីរឹងមាំកុំប្រួលប្រែ ទៅជាប់នឹងស្នេហ៍ស្រីខាងក្រៅ ។
-មានមួយមិនស្កប់រកមួយទៀត ឲ្យខូចមារយាទពូជពង្សផៅ
ត្រូវគេតិះដៀលពោលសំដៅ ត្រកូលញាតិផៅអាក្រក់ពិត ។
-បាត់បង់កិត្តិយសនិងសិរី ធ្វើកិច្ចការអ្វីអស់ញាតិមិត្រ
គេលែងជឿជាក់មិនចង់ជិត ព្រោះតែប្រព្រឹត្តធ្វើមិនល្អ ។
-ភរិយាកូនចៅទុក្ខចំបែង គិតគ្នេរគាក់តែងកម្មខ្មៅស
មិនសុខមិនស្រួលល្អក់កករ ជាប់ជាបន្តសោយសោកា ។
-ខ្លះប៉ុណ្ណឹងហើយនៅមិនភ្ញាក់ ទៅលបលួចលាក់មានស្នេហា
នឹងស្រីផ្សេងទៀតតាមតណ្ហា ប្រាថ្នាត្រូវការមិនចេះស្កប់ ។
-កិត្តិយសកេរ្តិ៍ឈ្មោះកាន់តែអាប់ សំឡេងស្ងួរសព្ទឮសាយសព្វ
ទៅគ្រប់ទីឋានមិនត្រឡប់ ស្អុយដូចសាកសពអសោចក្រៃ ។
-មានតែចំណេះឥតបញ្ញា គិតពិចារណាលៃកែខៃ
ធ្វើឲ្យបាត់បង់គុណតម្លៃ រស់នៅរាល់ថ្ងៃដើម្បីអ្វី ។
-ហេតុនេះកុំឡើយធ្វើដូច្នេះ ត្រូវមានតម្រិះដោយស្មារតី
ដើរតាមផ្លូវធម៌ដោយឃ្មាតខ្មី គិតធ្វើពោលស្តីដោយសុចរិត ។
-ត្រូវផ្តល់ក្តីសុខដល់ខ្លួនផង និងគ្រួសារផងបានស្កប់ចិត្ត
រួមរស់ជួបជុំដោយស្នេហ៍ស្និទ្ធ មេត្តាអាណិតគិតកោតក្រែង ។

-បំពេញនាទីជាស្វាមី សង្គ្រោះប្រណីលៃចាត់ចែង
តាមគន្លងធម៌ព្រះសម្តែង ទាំងនេះនោះឯងកើតមង្គល ។

ថ្ងៃ ០៤ កើត ខែស្រាពណ៍ ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ភាពជាបុរស ជាស្វាមី ត្រូវប្រតិបត្តិតាមតួនាទីរបស់ខ្លួនឲ្យបានល្អ មានសង្គហធម៌ ប្រព្រឹត្តធម៌ សាងជីវិតគ្រួសារប្រកបដោយធម៌ដ៏ប្រសើរ ទើបមានសុភមង្គល ។ កុំចេះតែលុះទៅតាមអំណាចតណ្ហា ប្រព្រឹត្តបាបធម៌ ធ្វើឲ្យមោះហ្មងក្នុងគ្រួសារ បង្កឲ្យមានភាពក្តៅក្រហាយដល់ភរិយា ឬស្វាមី កូនចៅជាដើម មិនល្អសោះឡើយ ។ ការប្រព្រឹត្តធម៌ ជាមង្គលដ៏ឧត្តម ។

ភាពជាបុរស ត្រូវធ្វើជាបុរសល្អ មនុស្សល្អ កូនល្អ ស្វាមីល្អ ឪពុកល្អ ។ គ្រួសារដែលមានវិបត្តិ បើពិចារណាតាមព្រះធម៌ គឺមកពីខ្វះកត្តាជាច្រើន ដូចជា ៖

១.ខ្វះចំណេះដឹង

២.ខ្វះបញ្ញា ស្មារតី ក្នុងការទទួលខុសត្រូវ តាមកិច្ចតួនាទីរបស់ខ្លួន

៣.ខ្វះភក្តីភាព គឺភាពស្មោះត្រង់ មិនប្រព្រឹត្តក្បត់ចិត្តគ្នា

៤.ខ្វះសេចក្តីសន្តោស

៥.ខ្វះសង្គហធម៌ ៦.ខ្វះគុណធម៌ ។

ទាំងនេះ សុទ្ធតែជាមូលហេតុនាំឲ្យមានវិបត្តិក្នុងគ្រួសារ ដែលបុគ្គលត្រូវតែចៀសវាង ។ គ្រួសារដែលមានចំណេះដឹង មានបញ្ញា មានស្មារតី ក្នុងការទទួលខុសត្រូវ តាមកិច្ចតួនាទី របស់ខ្លួន មានភក្តីភាព មានសេចក្តីសន្តោស មានសង្គហធម៌ និងមានការរស់នៅប្រកបដោយគុណធម៌ គឺជាគ្រួសារដែល មានសុភមង្គល មានសិរីសួស្តីពិតប្រាកដ ។

ធម្មោ សុចិណ្ណោ សុខមាវហាតិ : ធម៌ដែលបុគ្គល ប្រព្រឹត្ត ល្អហើយ តែងនាំសេចក្តីសុខមកឲ្យ ។

## ៣៨_តួនាទីភរិយា ៥ យ៉ាង

(សុត្តន្តបិដក លេខ១៩ ទំព័រ៨៧)

**១_សុសំវិហិតកម្មន្តា** ចាត់ចែងការងារដោយល្អ

**២_សុសង្គហិតបរិជនា** សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ

**៣_អនតិចារិនី** មិនប្រព្រឹត្តក្បត់ចិត្ត

**៤_សម្ភតញ្ច អនុរក្ខតិ** ថែទាំទ្រព្យដែលស្វាមីរកបាន

**៥_ទក្ខា ហោតិ អនលសា សព្វកិច្ចេសុ**

ឈ្លាស មិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ។

# ៣៩-ភាពជាស្ត្រី

-ភាពជាស្ត្រីជាធីតា ត្រូវមានចរិយាដ៏បវរ
កុំឡើយឡេះឡោះធ្វើមិនល្អ នាំល្អក់កករខូចខ្លួនប្រាណ ។
-ភាពជាស្ត្រីជាភរិយា ត្រូវមានឫកពាប្រសើរថ្កាន
បំពេញនាទីកុំខកខាន គឺធ្វើឲ្យបានកុំរំលង ។
-ចាត់ចែងការងារឲ្យបានល្អ ធ្វើដោយអំណារតាមទំនង
សង្គ្រោះពូកញាតិមិនឲ្យឆ្គង ទៅតាមគន្លងធម៌សប្បុរស ។
-មិនក្បត់ស្វាមីជាដាច់ខាត ទឹកចិត្តល្អស្អាតតែងស្ម័គ្រស្មោះ
មិនលបលួចលាក់អ្វីទាំងអស់ លុះដល់សូន្យសោះបាត់រូបរាង។
-បើមិនដូច្នោះបែរជាក្បត់ ពិតជាកម្បត់ណានួននាង
កុំឃើញលាភយសក៏លំអៀង សង្ខារមិនទៀងប្រាកដទេ ។
-ទំនាស់គ្រួសារប្រពន្ធប្តី គ្មានការគប្បីឡើយមាសមេ
ទោះជារូបយើងឬរូបគេ ត្រូវតែរិះរប្រៀបឧបមា ។
-លំបាកដល់ញាតិផៅបងប្អូន ជាពិសេសកូនតើយ៉ាងណា
បើម្តាយឪពុកត្រូវប្រេះឆា រងទុក្ខខ្លោចផ្សាពេកកន្លង ។
-កិត្តិយសកេរ្តិ៍ឈ្មោះត្រូវបាត់បង់ រស់មិនផូរផង់រៃងសៅហ្មង
រងការតិះដៀលនៃអ្នកផង ព្រោះតែស្នេហ៍ស្មងគ្មានភក្តី ។
-ស្លាប់ទៅបរលោកទុក្ខខ្លាំងក្រៃ មិនអាចឧបមេយ្យនឹងពោលស្តី
នេះព្រោះតែទោសក្បត់ស្វាមី ថាតើមានអ្វីគួរស្នេហា ។

-ទោសកាមច្រើនពិតហួសរៀបរាប់ ដូច្នេះកុំគាប់តាមតណ្ហា
រស់ចេះសន្ដោសក្នុងកាមា ជីវិតស្រស់ថ្លាជួបមង្គល ។
-ថៃទាំទ្រព្យាដែលស្វាមី បានដោយឃ្មាតខ្មីណានិមល
កុំឲ្យបាត់បង់នាំអំពល់ រករឿងរកគល់ល្អក់កករ ។
-មិនខ្ជិលច្រអូសក្នុងកិច្ចការ ក្នុងក្រៅយ៉ាងណាធ្វើដោយល្អ
ឆ្លាតឈ្លាសសព្វគ្រប់ជាបន្ត មានចិត្តស្មោះសរចេះចាត់ចែង ។
-ភាពជាស្ត្រីជាមាតា មើលបុត្តធីតាជួយតាក់តែង
ថៃទាំរក្សាគ្រប់កន្លែង ប្រយ័ត្នប្រយែងលៃគិតគូរ ។
-ភាពជាស្ត្រីជាទេវតា ជាបុព្វាចារ្យផ្តល់គំរូ
តែងប្រៀនប្រដៅមិនបន្ធូរ មិនឲ្យយឺតយូរតាមវេលា ។
-គ្រប់យ៉ាងនឹងល្អសម្រាប់អ្នក ចូរដឹងឲ្យជាក់ណាពុំងា
បើអ្នកធ្វើល្អជាប់តគ្នា នេះជាមាគ៌ាសុខសិរី ។
-ម្យ៉ាងទៀតមកពីបុណ្យបុព្វ ដែលអ្នកគ្នាន់គ្នេរខំឃ្មាតខ្មី
អប់រំសន្សំបុណ្យបារមី ដោយចិត្តមេត្រីក្នុងកុសល ។
-ដូច្នេះកុំឡើយធ្វេសប្រហែស ត្រូវមានតម្រិះហើយតម្កល់
កាយកម្មជាដើមក្នុងកុសល អ្នកនឹងបានដល់ក្ដីសុខសាន្ត ។

ថ្ងៃ ០៦ កើត ខែស្រាពណ៍ ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ៤០-ស្វាមី + ស្វាមី

ស្វាមីជាខ្មោច ស្វាមីទេវតា ស្វាមីបិតា ស្វាមីជាម្ចាស់
ស្វាមីជាបង ស្វាមីផ្ដេសផ្ដាស ស្វាមីកម្មក្រាស់ជួបប្រពន្ធខូច ។
ស្វាមីដ៏ល្អស្វាមីចិត្តជា សង្គ្រោះភរិយារាល់កិច្ចធំតូច
ព្រោះមានចិត្តធម៌គ្មានអ្វីប្រៀបដូច ឥតមានខិលខូចស្មោះស្ម័គ្រមេត្រី។
ស្វាមីមិនល្អហេតុតែខ្វះធម៌ មានចិត្តញាប់ញ័រក្នុងកាមលោកីយ៍
លុះតាមតណ្ហាមិនចេះគ្រប់អី បានច្រើនម្ដេចក្ដីនៅតែមិនគ្រាន់។
ស្វាមីក្នុងលោកពិតមានច្រើនយ៉ាង ស្រីមានសំណាងហេតុចេះគ្នេរគ្នាន់
ផ្សំបុណ្យបុព្វបាបតាមមិនទាន់ នេះហៅពាក់ព័ន្ធជាមួយប្រយោគ ។

ថ្ងៃ ០៧ រោច ខែស្រាពណ៍ ព.ស.២៥៥៩
ដោយភិក្ខុ ភួង-សុវណ្ណ

ក្នុងអត្ថបទនេះ ចង់និយាយពីស្វាមី ៧ ប្រភេទ ឬ ៩ ប្រភេទ, គឺ ស្វាមីជាខ្មោច ១ ស្វាមីទេវតា ១ ស្វាមីបិតា ១ ស្វាមីជាម្ចាស់ ១ ស្វាមីជាបង ១ ស្វាមីផ្ដេសផ្ដាស ១ ស្វាមីកម្មក្រាស់ ១ ។ រាប់យក ២ ទៀតក៏បាន គឺ ស្វាមីដ៏ល្អ ១ ស្វាមីមិនល្អ ១ ។

ស្វាមីជាខ្មោច សំដៅដល់ ស្វាមីជាអ្នកគ្មានសទ្ធា គ្មានសីល មានមិច្ឆាទិដ្ឋិ គ្មានកល្យាណធម៌ ។

ស្វាមីទេវតា សំដៅដល់ ស្វាមីជាអ្នកមានសទ្ធា មានសីល មានសម្មាទិដ្ឋិ មានកល្យាណធម៌ ។

## ៤១_ភរិយា ៧ ពួក

**១-វធសមាភរិយា** ភរិយាស្មើដោយអ្នកសំលាប់

**២-ចោរីសមាភរិយា** ភរិយាស្មើដោយចោរ

**៣-អយ្យសមាភរិយា** ភរិយាស្មើដោយម្ចាស់

**៤-មាតុសមាភរិយា** ភរិយាស្មើដោយមាតា

**៥-ភគិនីសមាភរិយា** ភរិយាស្មើដោយប្អូនស្រី

**៦-សខីសមាភរិយា** ភរិយាស្មើដោយសំឡាញ់

**៧-ទាសីសមាភរិយា** ភរិយាស្មើដោយខ្ញុំស្រី ។

## កំណាព្យ ភរិយា ៧ ពួក

-ព្រះមានព្រះភាគទ្រង់ជាសាស្តា ហៅកូនប្រសារបស់សេដ្ឋី
ឈ្មោះសុជាតា មិនគោរពប្តី ចេះតែស្រដីកញ្ច្រៀវខ្ញុរខ្ញារ ។
-ព្រះអង្គទ្រង់ត្រាស់បញ្ជាក់ប្រាប់ថា នែសុជាតា រីភរិយា
មានប្រាំពីរពួក ចូរនាងម្ចីម្នា មានចិត្តល្អជាស្តាប់ដោយប្រពៃ ។
-ភរិយា ១ ជាអ្នកសម្លាប់ មិនឋិតក្នុងច្បាប់ រកប្រុសដទៃ
មានចិត្តប្រទូស្តគយគន់រំពៃ ខ្វល់ខ្វាយលកលៃសម្លាប់ប្តីឯង ។
-ភរិយា ១ ទុកស្មើដោយចោរ មានចិត្តរហោ ឥតក្រែងរអែង
លួចកិបយកប្រាក់ប្រាកដជាក់ស្តែង ទ្រព្យស្វាមីឯងទុកធ្វើកិច្ចការ ។

-ភរិយា ១ ទុកស្មើដោយម្ចាស់ រឹងរូសកាចឆ្នាស ជួនស្រែកឡូឡា
ពោលពាក្យអាក្រក់ឥតខ្លាចរអា នឹងស្វាមីណាព្យាយាមប្រឹងប្រែង ។
-ភរិយា ១ ស្មើដោយមាតា ចេះថែរក្សាជួយរៀបចាត់ចែង
ចេះអនុគ្រោះដល់ស្វាមីឯង ដោយការសម្តែងខ្លួនដូចមាតា ។
-ភរិយា ១ ស្មើដោយប្អូនស្រី គោរពស្វាមីដែលជាភស្តា
ធ្វើខ្លួនដូចប្អូន គោរពបងណា មានចរិយាមានការអៀនខ្មាស ។
-ភរិយា ១ ស្មើដោយសម្លាញ់ មានចិត្តស្រឡាញ់ ក្នុងប្តីពេកណាស់
មានសីលធម៌ប្រពៃល្អល្អះ ធ្វើវត្តឥតខ្វះតាមតួនាទី ។
-ភរិយា ១ ស្មើដោយខ្ញុំស្រី ទោះត្រូវជេរស្តី គំរាមញក់ញី
មិនប្រទូស្តវិញ អត់ធន់គ្រប់ទី មានចិត្តសម្ពីលុះតាមភស្តា ។
-ទី ១ ទី ២ ទី ៣ នេះជា ហៅភរិយាមិនល្អឡើយណា
ជាស្ត្រីទ្រុស្តសីលរឹងរូសហានក្លា បែកធ្លាយកាយាតែងទៅអបាយ ។
-ទី ៤ ជាដើម ហៅភរិយា ហទ័យសម្ភារ ព្យាយាមខ្វល់ខ្វាយ
ជាស្ត្រីសង្រួមក្នុងសីលទាំងឡាយ លុះបែកធ្លាយកាយកើតជាទេព្តា ។
-ភរិយានេះ មានពិតប្រាកដ ដែលទ្រង់កំណត់ទៅតាមហេតុការណ៍
តាមការប្រព្រឹត្ត ជាចរិយា សត្វក្នុងលោកាសន្សំខុសគ្នា ។
-រៀបរាប់ប៉ុណ្ណោះបានជាបណ្តាំ ត្រូវអ្នកចងចាំណាកូនពុំងា

គួរខំប្រព្រឹត្តតាមព្រះធម្មា នឹងបានផុតពៀរផុតចាកទុក្ខហោង ។

និពន្ធដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

## ៤២-ឱវាទ ១០ យ៉ាង

(ធនញ្ជ័យសេដ្ឋី ទូន្មានកូនស្រីឈ្មោះវិសាខា)

**១-អន្តោអគ្គិ ពហិ ន នីហរិតព្វោ** មិនគួរនាំភ្លើងខាងក្នុងចេញទៅខាងក្រៅ

**២-ពហិអគ្គិ អន្តោ ន បវេសេតព្វោ** មិនគួរនាំភ្លើងខាងក្រៅចូលមកខាងក្នុង

**៣-ទទន្តស្សេវ ទាតព្វំ** គប្បីឱ្យដល់អ្នកដែលឱ្យប៉ុណ្ណោះ

**៤-អទទន្តស្ស ន ទាតព្វំ** មិនគប្បីឱ្យដល់អ្នកដែលមិនឱ្យ

**៥-ទទន្តស្សាបិ អទទន្តស្សាបិ ទាតព្វំ** គប្បីឱ្យដល់អ្នកទាំងដែលឱ្យទាំងដែលមិនឱ្យ

**៦-សុខំ និសីទិតព្វំ** គប្បីអង្គុយឱ្យជាសុខ

**៧-សុខំ ភុញ្ជិតព្វំ** គប្បីបរិភោគឱ្យជាសុខ

**៨-សុខំ និបជ្ជិតព្វំ** គប្បីដេកឱ្យជាសុខ

**៩-អគ្គិ បរិចរិតព្វោ** គប្បីបម្រើភ្លើង

**១០-អន្តោទេវតា នមស្សិតព្វា** គប្បីនមស្ការទេវតាខាងក្នុង ។

# កំណាព្យ ឱវាទ ១០ យ៉ាង

( បទពាក្យ ៨ )

-ឱវាទ ១០ យ៉ាងគួរកូនចងចាំ កំណត់ចំណាំទុកដោយប្រពៃ
ព្រោះជាឱវាទដែលធនញ្ជ័យ ទូន្មានកូនស្រីឈ្មោះវិសាខា ។
-កុំនាំភ្លើងក្នុងចេញទៅខាងក្រៅ នេះលោកសំដៅយករាល់ទោសា
របស់ស្វាមី មាតាបិតា កុំពោលចរចាខាងក្រៅផ្ទះឡើយ ។
-កុំនាំភ្លើងក្រៅចូលមកខាងក្នុង កូនអើយត្រូវប្រុងអ្នកនឹងបានស្បើយ
បើឮគេពោលទោសឪពុកហើយ កុំនាំមកឡើយពោលក្នុងផ្ទះឯង ។
-មាតា ស្វាមី ក៏ន័យដូចគ្នា សូមកូនពុំងាចេះគិតកោតក្រែង
កុំចេះតែស្តីនាំឱ្យចំបែង ត្រូវចេះថ្លាថ្លែង គ្រប់ពេលវេលា ។
-ភ្លើងទាំងពីរនេះក្លាខ្លាំងណាស់ណា កូនត្រូវរក្សាឱ្យបានល្អជា
តែមិនប្រយ័ត្នកើតទាស់ទែងគ្នា មានកម្មវេរាឆេះក្នុងអបាយ ។
-រីឯទី ៣ កូនត្រូវចាំជាក់ គួរឱ្យដល់អ្នកដែលឱ្យទាំងឡាយ
នេះសំដៅយកអ្នកជិតឬឆ្ងាយ ខ្ចីទ្រព្យទាំងឡាយសងវិញសឹមឱ្យ ។
-ចំណែកទី ៤ កូនអើយកុំឆ្ងល់ មិនគួរឱ្យដល់អ្នកដែលមិនឱ្យ
នេះសំដៅយកអ្នកខ្ចីទ្រព្យហើយ មិនសងវិញឡើយចេះតែមកខ្ចី ។
-រីឯទី ៥ លោកបានបញ្ជាក់ គួរឱ្យដល់អ្នកដែលឱ្យវិញក្តី
និងអ្នកនោះឯងមិនឱ្យវិញក្តី នេះលោកស្រដី សំដៅយកញាតិ ។

-ប្រាំមួយ គប្បីអង្គុយជាសុខ កូនកុំសំកុកមានចិត្តចង្អៀត
ឃើញម្តាយឪពុកស្វាមីត្រូវឃ្លាត កូនគួរវវាតក្រោកចាកទីឋាន ។
-ប្រាំពីរ បរិភោគជាសុខណា នៅក្នុងន័យថា នៃកូនកល្យាណ
បម្រើស្វាមីពុកម្តាយថ្កើងថ្កាន រួចហើយទើបបានខ្លួនឯងហូបក្រោយ ។
-ប្រាំបី គប្បីដេកជាសុខស្រួល កូនគួរសម្រួលធ្វើវត្តឱ្យហើយ
ចំពោះឪពុកមិនត្រូវតោះតើយ រៀបភួយមុងខ្នើយមើលទីសម្រាន្ត ។
-ស្វាមីនិងម្តាយក៏ន័យដូចគ្នា កូនត្រូវម្ទីម្ទា ប្រឹងធ្វើឱ្យបាន
កុំខ្លាចនឿយហត់ត្រូវអ្នកក្លាហាន រួចហើយសឹមបានអ្នកដេកខាងក្រោយ ។
-ប្រាំបួន គប្បីបម្រើនូវភ្លើង កូនអើយត្រូវយើងកុំនៅកន្តើយ
ព្រោះឪពុកម្តាយស្វាមីហ្នឹងហើយ អ្នកនឹងបានស្បើយព្រោះការបម្រើ ។
-រីឯទី ១០ គួរនមស្ការ- នូវទេវតាខាងក្នុង ប្រសើរ
ព្រោះឪពុកម្តាយ ទៅតាមដំណើរ កូនគួរបម្រើឱ្យបានប្រពៃ ។
-ចំណែកស្វាមី ក៏ន័យដូចគ្នា ដែលភរិយា ត្រូវតែលកលៃ
ឃើញដូចទេវតា ចិត្តល្អប្រពៃ បម្រើតាមន័យ គោរពបូជា ។
-ឱវាទ ១០ យ៉ាងកូនចូរដឹងចុះ អ្នកត្រូវបណ្តុះ ដោយចិត្តសម្មារ
ប្រព្រឹត្តកោតក្រែងគ្រប់ពេលវេលា នឹងបានផុតពៀរផុតចាកទុក្ខហោង ។

វត្តនិគ្រោធវ័ន ថ្ងៃ ១៤ កើត ខែមិគសិរ ព.ស.២៥៥៤

ដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

# ៤៣-គប្បីយល់ដឹងពីមិត្ត

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ៖

**សចេ លភេថ និបកំ សហាយំ ។ល។**

បើបុគ្គលបានសម្លាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា បុគ្គលនោះអាចគ្របសង្កត់នូវសេចក្ដីអន្តរាយទាំងពួងបាន ហើយជាអ្នកមានសេចក្ដីត្រេកអរ មានស្មារតី គប្បីត្រាច់ទៅជាមួយនឹងសម្លាញ់នោះចុះ ។

បើបុគ្គលមិនបានសម្លាញ់មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះ គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាស្ដេចលះបង់ដែនដែលខ្លួនឈ្នះហើយ ត្រាច់ទៅតែម្នាក់ឯង (ពុំនោះសោត) ប្រៀបដូចជាស្ដេចដំរីដ៏ប្រសើរ ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

កាលដែលបុគ្គលត្រាច់ទៅតែម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាល គ្មានសហាយតាគុណទេ, ម្យ៉ាងទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង មិនគួរធ្វើអំពើលាមកឡើយ ប្រៀបដូចជាដំរីដ៏ប្រសើរ មានសេចក្ដីខ្វល់ខ្វាយតិច ត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ ។

អដ្ឋកថាធម្មបទ ពន្យល់ពាក្យថា < សហាយតាគុណា > បានដល់ ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន ហៅថា សហាយតាគុណ ។

ក្នុងសិង្គាលកសូត្រ ព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងនឹងសិង្គាលកបុត្ត ថា មិត្តប្លម មាន ៤ ប្រការ មិត្តមានសន្តានល្អ មាន ៤ ប្រការ ។

ម្នាលគហបតីបុត្ត អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ៤ ពួកនេះ គឺអ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួន ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១, អ្នកត្រូវស្គាល់មនុស្សល្អតែសំដី ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១, អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្តោយឱ្យគាប់ចិត្ត ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១, អ្នកត្រូវស្គាល់មនុស្សជាសម្លាញ់ក្នុងការដឹកនាំឱ្យវិនាសភោគៈទាំងឡាយ ថាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ១ ។

ម្នាលគហបតីបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ គឺ មិត្តមានឧបការៈ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១, មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១,

មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថាជាមិត្តមានសន្តានល្អ ១, មិត្តមានសេចក្ដីឈឺឆ្អាល អ្នកត្រូវដឹងថាជាមិត្ត មានសន្តានល្អ ១ ។

## ៤៤-មិត្តបួម ៤ ប្រការ

-អ្នកត្រូវស្គាល់មិត្តបួម៤ ប្រការ ដែលព្រះសាស្ដាទ្រង់បានត្រាស់ទុក
វាតែងនាំព្រួយនាំឱ្យស្មាញស្មុគ នាំឱ្យសោយទុក្ខនៅក្នុងអបាយ ។
-ទី១ មិត្តគិតតែប្រយោជន៍ខ្លួន ដឹងចុះណាស្ងួនគួរវៀរឱ្យឆ្ងាយ
យកច្រើនឱ្យតិចពេលភ័យអន្តរាយ ទើបជួយខ្វល់ខ្វាយធ្វើកិច្ចការមិត្ត ។
-ទី២ មិត្តនោះល្អតែសម្ដី ទទួលអ្វីៗដែលកន្លងពិត
កាលកិច្ចទាំងឡាយកើតឡើងដល់មិត្ត របស់ខូចពិតទើបសម្ដែងអាង ។
-ទី៣ មិត្តនិយាយចាក់បណ្ដោយ ខុសត្រូវក៏ដោយព្រមតាមគ្រប់យ៉ាង
ពោលគុណនៅមុខឬនៅជិតខាង ពោលទោសច្រើនយ៉ាងក្នុងទីកំបាំង ។
-ទី៤ ជាមិត្តក្នុងផ្លូវវិនាស បើអ្នកមិនជៀសនឹងរងទុក្ខខ្លាំង
ធ្លាក់ក្នុងការល្បែងដ៏មានកម្លាំង ដែលជាទីតាំងនៃក្ដីប្រមាទ ។
-ល្បែងស្រាល្បែងភ្នាល់និងល្បែងច្រើនទៀត កុំយកខ្លួនបៀតវានាំខូចខាត
ត្រូវមានស្មារតីព្យាយាមសង្វាត ដោយមិនប្រមាទដើរតាមបណ្ឌិត ។
-មិត្តទាំង ៤ នេះអ្នកចូរចាំចុះ ជាមិត្តបួមសោះអ្នកត្រូវចេះគិត

មុននឹងសេពគប់គួរតែពិនិត្យ ថានេះជាមិត្តប្លមឬមិត្តល្អ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ៤៥-មិត្តមានសន្តានល្អ ៤ ប្រការ

-មិត្តមានសន្តានល្អ៤ ប្រការ ដែលព្រះសាស្ដាទ្រង់សម្ដែងហើយ

ចូរយើងរាល់គ្នាកុំបីកន្តើយ កុំធ្វើតោះតើយសិក្សាឱ្យចេះ ។

-ទី១មិត្តមានឧបការៈ មានចិត្តស្មោះស្ម័គ្រពិតដោយវិសេស

ជួយរក្សាមិត្តដែលធ្វេសប្រហែស ជួយផ្ដល់ចំណេះនិងភោគៈផង ។

-ទី២ នោះគឺមិត្តរួមសុខទុក្ខ នៅចំពោះមុខឬនៅក្រោយខ្នង

មានភ័យអន្តរាយចិត្តឥតមានហ្មង លះជីវិតផងជាមួយនឹងមិត្ត ។

-ទី៣នោះមិញមិត្តប្រាប់ប្រយោជន៍ តិចច្រើនដោយហោចមានចិត្តស្មោះពិត

ឱ្យវៀរចាកបាបហើយឱ្យប្រព្រឹត្ត អំពើសុចរិតប្រាប់សួគ៌និព្វាន ។

-ទី៤ មិត្តមានសេចក្ដីឈឺឆ្អាល ចិត្តស្រស់ត្រកាលឥតមានលាក់លៀម

ជួយព្រួយជួយអរអ្វីដែលមិត្តមាន ឥតមានទាក់ទាមសរសើរគុណមិត្ត ។

-មិត្តទាំង ៤ នេះ សែនមានឧបការ សន្តានថ្លៃថ្លាគួរចូលទៅជិត

ស្និទ្ធស្នាលជាមួយនឹងរុងរឿងពិត ដែលពួកបណ្ឌិតស្គាល់ថាមិត្តល្អ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ក្នុងមនោជជាតក ព្រះពុទ្ធទ្រង់ត្រាស់ថា ៖

និហីយតិ បុរិសោ និហីនសេវី
ន ច ហាយេថ កទាចិ តុល្យសេវី
សេដ្ឋនុបគមញ្ច ឧទេតិ ខិប្បំ
តស្មា អត្តនោ ឧត្តរំ ភជេថ ។

បុរសអ្នកគប់នូវជនថោកទាប រមែងសាបសូន្យ, បុគ្គលគប់នូវជនស្មើៗគ្នា រមែងមិនសាបសូន្យ ក្នុងកាលណាឡើយ, គប់រកនូវជនដែលប្រសើរជាង រមែងចម្រើនឆាប់រួសរាន់ ព្រោះហេតុនោះ បុគ្គលគួរតែគប់រកនូវបុគ្គលដែលប្រសើរជាង ។

## ៤៦-ការគប់មិត្ត

-អហំ រីខ្ញុំនាម ភួង-សុវណ្ណ សូមលើកប៊ិកកាន់ចារអក្ខរា
និយាយរៀបរាប់បានជាធម៌អាថិ គ្រាន់គិតពិចារទុកជាគំនិត ។
-នៅក្នុងសាសនានៃព្រះសម្ពុទ្ធ ជាព្រះសុគតទ្រង់ត្រាស់ពីមិត្ត
នេះជាសំខាន់ក្នុងការប្រព្រឹត្ត នឹងបានសុខពិតព្រោះសេពគប់ត្រូវ ។
-មិត្តមានច្រើនយ៉ាងដែលព្រះទ្រង់ត្រាស់ ជាក់ប្រាកដណាស់យើងកុំស្រងូវ
មិត្តបាបមិនល្អមានច្រើនពេកកូវ យល់ឱ្យត្រឹមត្រូវគួរវៀរបាបមិត្ត ។
-គប់ពាលនឹងនាំឱ្យយើងលិចលង់ ធ្លាក់ក្នុងអន្លង់នៃសង្សារពិត

តែប្រសិនបើគប់នឹងបណ្ឌិត រួចចាកទុក្ខពិតមិនមានអន្តរាយ ។
-គប់ជនថោកទាបនឹងសាបសូន្យឆាប់ នាំឱ្យយ៉ាកយ៉ាប់អស់កាលវែងឆ្ងាយ
នឹងសោយទុក្ខធំនៅក្នុងអបាយ ស្រេកទឹកឃ្លានបាយខ្លោចផ្សាខ្លាំងណាស់ ។
-គប់រកនូវជនដែលស្មើៗគ្នា អង្គព្រះភគវាព្រះអង្គបានត្រាស់
តែងមិនសាបសូន្យពិតប្រាកដណាស់ ព្រោះធ្វើឱ្យច្បាស់នូវសីលជាអាទិ៍ ។
-បើគប់នូវជនដែលប្រសើរជាង ពិតជាមិនឃ្លាងចាកពុទ្ធោវាទ
តែងចម្រើនឆាប់ព្រោះមិនប្រមាទ ខំប្រឹងសង្វាតប្រព្រឹត្តធម្មា ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ក្នុងសខាសូត្រ ព្រះពុទ្ធទ្រង់ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការ បុគ្គលអ្នកស្វែងមិត្ត ទោះបីលោកបណ្តេញ បំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រក ចូលទៅអង្គុយជិត ។

ប្រកបដោយធម៌ ៧ ប្រការ តើដូចម្តេចខ្លះ ? គឺ

ភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ និងជាទីគាប់ចិត្ត ១ គួរគោរព ១ គួរសរសើរ ១ ឧស្សាហ៍ប្រៀនប្រដៅ ១ អត់ធន់ចំពោះពាក្យ ១ ជាអ្នកនិយាយពាក្យជ្រៅ ១ មិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។

# ៤៧-សេពគប់មិត្តល្អត្រាស់ដឹងធម៌ពិត

-មិត្តសម្លាញ់ល្អប្រកបដោយអង្គ មែនពិតព្រះអង្គទ្រង់ជាភគវា
បានសម្តែងប្រាប់ក្នុងសូត្រនានា មានគុណមហិមាប្រាំពីរប្រការ ។
-មិត្តធ្វើខ្លួនគួរឱ្យស្រឡាញ់ផង គួរគោរពផងដ៏មានឧបការ
គួរសរសើរផង និងលោកឧស្សាហ៍ ប្រដៅផងណានូវធម៌វិន័យ ។
-អត់ធន់ចំពោះពាក្យសម្តីផង លោកឥតមានហ្មងកាយចិត្តប្រពៃ
វាចាក៏ល្អលោកចេះលកលៃ សម្លឹងរំពៃដោយចិត្តដ៏ល្អ ។
-ជាអ្នកនិយាយពាក្យជ្រាលជ្រៅផង សម្តីហ្មត់ហ្មងដ៏មានលំអ
ពន្យល់សច្ចធម៌ពិតបវរ វែកញែកល្អិតល្អតាមពុទ្ធដីកា ។
-មិនដឹកនាំក្នុងហេតុមិនគួរផង នេះល្អកន្លងវិសេសអស្ចារ្យ
ឱ្យវៀរចាកបាបសព្វគ្រប់ប្រការ ចម្រើនបញ្ញាត្រាស់ដឹងធម៌ពិត ។

ដោយភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

នៅក្នុងសុត្តបិដក លេខ ៥២ ក្នុងឱវាទបាតិមោក្ខ ក្នុងគាថាទី ១ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា :

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

ការមិនធ្វើបាបទាំងពួង ការញ៉ាំងកុសលឱ្យកើតឡើង ការធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

## ៤៨-ឱវាទដ៏ល្អ

-កិរិយាមិនធ្វើនូវបាបទាំងឡាយ ទោះតាមផ្លូវកាយវាចានិងចិត្ត
សន្សំកុសលសាងតែសុចរិត ខំជម្រះចិត្តឱ្យបានផូរផង់ ។
-ឱវាទទាំងនេះល្អប្រសើរណាស់ ដែលព្រះពុទ្ធម្ចាស់ទ្រង់បានតម្រង់
គួរយើងគ្រប់គ្នាមានទិដ្ឋិត្រង់ ធ្វើតាមព្រះអង្គនឹងបានសុខស្ងប់ ។
-គង្វាលគោក្បៀងគោទាំងឡាយ ទៅទីជិតឆ្ងាយតាមការប្រសប់
វាយដោយរំពាត់មិនឱ្យត្រឡប់ ដល់ទីបញ្ចប់ដែលខ្លួនប្រាថ្នា ។
-ជរាមរណៈតែងក្បៀងសព្វសត្វ ទៅយ៉ាងស្ងៀមស្ងាត់គ្មានការឡូឡា
ក្បៀងយកទាំងអស់មិនវៀរសត្វណា ឱ្យអនិច្ចាត្រូវរកទីពឹង ។
-ធ្វើទានកាន់សីលចម្រើនភាវនា រាល់ពេលវេលាបានជាពំនឹង
ដោយមិនប្រមាទចេះគិតជញ្ជឹង ធ្វើបានយ៉ាងហ្នឹងល្អប្រសើរណាស់ ។

ថ្ងៃ ០៦រោច ខែបុស្ស ពុទ្ធសករាជ ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ក្នុងមួយសែននាក់ មានតែម្នាក់ប៉ុណ្ណោះដែលកាន់យកធម៌ជាប្រមាណ ។ ចំណែកឯ ៩៩,៩៩៩ នាក់ទៀត មិនបានកាន់យកធម៌ជាប្រមាណទេ ។ កិលេសចេះតែចម្រើន គុណធម៌ចេះតែថយចុះ ការសិក្សាព្រះធម៌ និងការប្រតិបត្តិល្អត្រឹមត្រូវ ក៏ចេះតែអន់ថយទៅ។ ដូច្នេះ ដែលយើងមានឱកាសបានសិក្សា ស្តាប់បានយល់ដឹងព្រះធម៌ខ្លះៗហើយ គប្បីប្រឹងប្រែងបន្តទៀត ដើម្បីបានគេចផុតពីភាពមិនចេះដឹង អសីលធម៌ ភាពខ្មៅងងឹត គឺអវិជ្ជា ឲ្យបានជាឧបនិស្ស័យនៃបញ្ញា មានសម្មាទិដ្ឋិ និងប្រតិបត្តិល្អ រួចផុតចាកទុក្ខទាំងពួង ។

## ៤៩_និព្វានមិនស្លាប់

( បទពាក្យ ៧ )

១-សង្ខារទាំងឡាយមិនទៀងពិត គឺតែងវិបរិតតែងប្រាសព្រាត់
ទោះបីស្រស់ល្អតូចធំធាត់ គ្មានអ្វីអាចឃាត់ជាធម្មជាតិ ។
២-ម្តងសើចម្តងយំផ្លាស់ប្តូរគ្នា គ្រប់ពេលវេលាគួរឆ្លាសឆ្លៀត
សាងសេចក្តីល្អកុំឱ្យឃ្លាត ធ្វើហើយធ្វើទៀតនាំសុខៈ ។
៣-អ្វីដែលបច្ច័យបានតាក់តែង ព្រះអង្គសម្តែងគ្មានអមតៈ
តែងតែធ្លុះធ្លាយប្រេះបែកបាក់ នេះជាសច្ចៈតាមបច្ច័យ ។

៤-ឯព្រះនិព្វានពិតមិនស្លាប់ តាមដែលទ្រង់ប្រាប់អស់អាល័យ
លះបង់តណ្ហាជាបច្ច័យ ជាក់ច្បាស់ធម៌ថ្លៃជាអមតៈ ។

ថ្ងៃ ០៧រោច ខែបុស្ស ពុទ្ធសករាជ ២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

នៅក្នុងវិនយបិដក ភាគ១១ និងសុត្តបិដក លេខ ៥២ ទំព័រ ២៦១ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៈ

**សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ**
**បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករំ។**

អំពើល្អ មនុស្សសប្បុរសធ្វើបានដោយងាយ អំពើល្អ មនុស្សបាបធ្វើបានដោយក្រ អំពើបាប មនុស្សបាបធ្វើបានដោយងាយ អំពើបាបព្រះអរិយៈទាំងឡាយ ធ្វើបានដោយក្រ ។

## ៥០-អំពើល្អនិងអាក្រក់

-អំពើល្អមនុស្សល្អធ្វើបានងាយ ដោយមិនខ្វះខ្វាយមានចិត្តស័គ្រស្មោះ
គ្មានការលំបាកគ្រប់កិច្ចទាំងអស់ ធ្វើបានឥតខ្ចោះឥតមានរួញរា ។
-អំពើល្អឯមនុស្សបាបវិញ មិនអាចបំពេញព្រោះគ្មានសទ្ធា
ទោះមានទ្រព្យធនមាសប្រាក់ហូរហៀរ គ្មានទេចិត្តជាសាងសេចក្ដីល្អ។

-អំពើបាបមនុស្សបាបតែងធ្វើ គ្មានការស្ទាក់ស្ទើរពេញចិត្តត្រេកអរ
ឋិតក្នុងធម៌ខ្មៅលះបង់ធម៌ស ចិត្តល្អក់កករមានភាពសៅហ្មង ។
-អំពើបាបឯព្រះអរិយៈ កាត់ផ្តាច់ដោយមគ្គមិនធ្វើតែម្តង
លោកត្រាស់ដឹងធម៌ចិត្តលោកឥតហ្មង បានឆ្លងកន្លងអបាយភូមិហើយ ។

ថ្ងៃ ០៦កើត ខែមាឃ ពុទ្ធសករាជ ២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៥១_សាវ័កល្អ

( បទពាក្យ ៨ )

១-ព្រះមានព្រះភាគមានករុណា ទ្រង់ត្រាស់ទេសនាផ្តល់ជាឱវាទ
ឱ្យបរិស័ទខំប្រឹងសង្វាត ចូរកុំប្រមាទទាំងប្រុសទាំងស្រី ។
២-នាមជាសាវ័កព្រះភគវា ប្រព្រឹត្តធម្មាជាប្រក្រតី
ឱ្យបរិបូរ សរណៈបី ចិត្តល្អប្រពៃព្រមដោយសទ្ធា ។
៣-រក្សាសីល ៥ និងសីលប្រាំបី សម្អិតលំអៃដោយការម្នីម្នា
ពេញចិត្តប្រព្រឹត្តគ្រប់ពេលវេលា បូជាមាលា ដល់ព្រះត្រៃរ័ត្ន ។
៤-បរិច្ចាគទាន ទំនុកបម្រុង ចំពោះព្រះសង្ឃ ឱ្យបានហ្មត់ចត់
តាមធម៌វិន័យដែលទ្រង់កំណត់ ឱ្យបានប្រាកដលើកស្ទួយសាសនា ។
៥-ខ្វល់ខ្វាយឧស្សាហ៍ក្នុងកិច្ចទាំងឡាយ បម្រើពុកម្តាយចម្រើនបុញ្ញា

ចិញ្ចឹមជីវិតក៏ដោយសម្មា ប្រពៃថ្លៃថ្លា រស់មិនប្រមាទ ។
៦-ប្រតិបត្តិធម៌សមគួរដល់ធម៌ ដោយមិនញាប់ញ័រ ធ្វើចិត្តឱ្យស្អាត
មិនចេះតែជឿខុសពុទ្ធឱវាទ ជាអ្នកឆ្លាសឆ្លាត ក្នុងព្រះធម្មា ។
៧-មគ្គអង្គប្រាំបីជាផ្លូវដ៏ត្រង់ ដែលព្រះពុទ្ធអង្គ នាមភគវា
ទ្រង់សម្តែងប្រាប់ទុកជាមាគ៌ា គួរយើងគ្រប់គ្នាប្រព្រឹត្តឱ្យល្អ ។
៨-សម្មាទិដ្ឋិបុរេជវំ ធម៌មានកម្លាំងដ៏មានលំអ
ស្ទុះទៅខាងមុខប្រពៃបវរ អ្នកប្រព្រឹត្តល្អនឹងរួចចាកទុក្ខ ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ការធ្វើខ្លួនឲ្យបានជាសាវ័កល្អ មិនមែនងាយ ហើយក៏មិនមែនលំបាកដែរ, ដើម្បីបានជាសាវ័កល្អ សម្រាប់បព្វជិត ត្រូវមាននូវសេចក្តីគោរព (គារវៈ ៦ ប្រការ) មិនប្រព្រឹត្តកន្លងសិក្ខាបទដែលព្រះជិនស្រីទ្រង់បញ្ញត្តដល់ខ្លួន ។

សម្រាប់គ្រហស្ថ ប្រតិបត្តិឲ្យបរិបូរក្នុងសរណៈ ៣ សីល ៥ សីល ១០ រក្សាឧបោសថសីលមួយខែ ៨ ដង ថ្វាយទាន បូជារបស់ក្រអូប បូជាមាលា ទំនុកបម្រុងមាតាបិតា ទំនុកបម្រុងសមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ។

(ចាកអដ្ឋកថា សុមង្គលវិលាសិនី)

## ៥២-ស្រឡាញ់នាំមកនូវទុក្ខ

ព្រះពុទ្ធ ទ្រង់ត្រាស់ថា ៖

**បិយតោ ជាយតី សោកោ បិយតោ ជាយតី ភយំ**

**បិយតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។**

សេចក្ដីសោក កើតពីសេចក្ដីស្រឡាញ់ ភ័យ កើតពីសេចក្ដីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្ដីស្រឡាញ់ហើយ សេចក្ដីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

## កំណាព្យ ស្រឡាញ់នាំមកនូវទុក្ខ

(បទពាក្យ ៧)

១-ស្រឡាញ់រូបៗនាំមកនូវទុក្ខ គ្រប់បែបគ្រប់មុខគ្មានទំនេរ
ស្រឡាញ់ខន្ធៗមិនទៀងទេ ខន្ធយើងខន្ធគេតែងបែកធ្លាយ ។
២-ស្រឡាញ់ធម៌ៗតែងរក្សា ក្នុងលោកនេះណានិងលោកនាយ
បានជាសម្បត្តិខ្ជាប់វេចស្ពាយ ទៅបរលោកនាយសុខចម្រើន ។

ថ្ងៃ ០៦កើត ខែមាឃ ពុទ្ធសករាជ ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៥៣_គួរយល់ដឹងពីបុណ្យចូលឆ្នាំ

អ្វីដែលអ្នកត្រូវដឹងនោះគឺថា ថ្ងៃ-ខែ-ឆ្នាំ កាលវេលា រាត្រី មិនកន្លងទៅទទេៗនោះទេ តែងតែនាំយកនូវអាយុជីវិតរបស់សត្វទាំងឡាយទៅផង ដូច្នេះ ដែលល្អគប្បីមានស្មារតីប្រព្រឹត្តធ្វើសេចក្តីល្អ ។

នៅក្នុងអច្ចេន្តិសូត្រ ព្រះមានព្រះភាគ ត្រាស់ថា :

**អច្ចេន្តិ កាលា តរយន្តិ រត្តិយោ**

**វយោគុណា អនុបុព្វំ ជហន្តិ**

**ឯតំ ភយំ មរណេ បេក្ខមានោ**

**លោកាមិសំ បជហេ សន្តិបេក្ខោ ៕**

កាលទាំងឡាយតែងកន្លងផុតទៅ រាត្រីទាំងឡាយ តែងឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយ តែងលះបង់នូវលំដាប់ កាលបើបុគ្គលបានសម្លឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្លាប់ហើយ ជាអ្នកសម្លឹងយកសេចក្តីស្ងប់ គួរតែលះបង់អាមិសៈក្នុងលោកចេញ ។

ក្នុងមូលបរិយាយជាតក ព្រះពុទ្ធ ទ្រង់ត្រាស់ថា :

**កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា**

**យោ ច កាលឃសោ ភូតោ ស ភូតបចនឹ បចិ ៕**

កាលរមែងស៊ីនូវពួកសត្វទាំងអស់ ព្រមទាំងខ្លួនឯង ចំណែកសត្វណាជាអ្នកស៊ីនូវកាល សត្វនោះ ឈ្មោះថាដុតនូវតណ្ហា ដែលជាធម្មជាតិដុតសត្វ ។ (បិដក លេខ៥៨ ទំព័រ១៣៣)

## ៥៤-ឱ! បុណ្យចូលឆ្នាំ

( បទពាក្យ ៧ )

១-ឱ! បុណ្យចូលឆ្នាំមានច្រើនណាស់ ទាំងក្មេងទាំងចាស់គិតសប្បាយ
តែប្រពៃណីត្រូវប្រែក្លាយ ចង់តែសប្បាយគ្មានស្គាល់អ្វី ។
២-មិនយូរប៉ុន្មានថាចូលឆ្នាំ ចិត្តគិតរង់ចាំយកសួស្តី
តែសាងបាបកម្មគ្មានប្រណី តើឱ្យសិរីកើតពីណា ។
៣-ចំណែកជីវិតក៏អស់ទៅ មិនអាចឋិតនៅតាមធម្មតា
ត្រូវចាស់គ្រាំគ្រាចូលមរណា គួរចេះពិចារណាដោយឧបាយ ។
៤-កុំឃើញតែសុខចង់តែស្រួល គ្រប់យ៉ាងប្រែប្រួលគួរនឿយណាយ
បាបអកុសលវៀរឱ្យឆ្ងាយ នឹងផុតអបាយបានសុខស្ងប់ ។

វត្តនិគ្រោធវ័ន ថ្ងៃ១១កើត ខែបុស្ស ព.ស.២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៥៥-ឆ្នាំចាស់កន្លងចូលឆ្នាំថ្មី

១-ឆ្នាំចាស់កន្លងចូលឆ្នាំថ្មី ថាតើមានអ្វីគួរសប្បាយ
ជីវិតអស់ទៅកាយប្រែក្លាយ ចិត្តសែនខ្វល់ខ្វាយកែលំអ ។
២-អស់លុយប៉ុន្មានក៏អស់ចុះ ឱសែនស្រណោះហេតុចង់ល្អ
វះកាត់បកស្បែកផាត់ឱ្យស ធ្វើឱ្យស្រស់ល្អបង្អួតគេ ។
៣-ដូចមិនបានដឹងសត្វសង្ខារ មិនទៀងឡើយណាទាំងយើងគេ
ប្រែប្រួលរាល់ថ្ងៃមិនឈប់ទេ ត្រូវចេះរិះរេដោយឧបាយ ។
៤-ធ្វើទានកាន់សីលឱ្យខ្ជាប់ខ្ជួន ឱ្យបានមាំមួនញ៉ាំងចិត្តកាយ
ឱ្យបរិសុទ្ធចិត្តនឿយណាយ លែងជាប់នឹងកាយអស់កង្វល់ ។

ថ្ងៃ ០៦រោច ខែមាឃ ពុទ្ធសករាជ ២៥៥៨
កែសម្រួលកំណាព្យ ឧបាសិកា វរលក្ខណ៍

## ៥៦-ឆ្នាំចាស់ឆ្នាំថ្មី

១-ឆ្នាំចាស់ផុតទៅឈានចូលឆ្នាំថ្មី មានចិត្តអរភ័យទៅតាមវេលា
រូបរាងក៏ផ្លាស់ទ្រុឌទ្រោមគ្រាំគ្រា តើចិត្តទាមទារចង់បានអ្វីទៀត ។
២-កាលកន្លងទៅយកអ្វីបានខ្លះ ម៉េចនៅផ្ដេសផ្ដាសមិនគិតប្រឹងឆ្លៀត
សាងសេចក្ដីល្អកុំឱ្យឃ្លៀងឃ្លាត កុំឱ្យវង្វាតឆ្ងាយពីកុសល ។

៣-អាយុជីវិតចេះតែអស់ទៅ គប្បីរកផ្លូវកុំនៅសល់វល់
គួរចេះសង្វេគហើយត្រូវតម្កល់ ខ្លួនក្នុងកុសលផុតទុក្ខវេទនា ។
៤-កុំបណ្តោយចិត្តលិចចុះក្នុងកាម រហេមរហាមរាល់ពេលវេលា
ត្រូវរៀរល្បែងពាលនិងកម្មវេរា ចម្រើនវិជ្ជាមោហៈឃ្លាតឆ្ងាយ ។
៥-លោភៈទោសៈមោហៈនេះណា ញ៉ាំងសត្វលោកាធ្លាក់ក្នុងអបាយ
បើនៅឡេះឡោះពិតជាអន្តរាយ សង្សារវែងឆ្ងាយអ្នកនឹងសោយទុក្ខ។
៦-កុំចេះតែលុះទៅតាមចំណង់ ត្រូវចេះតម្រង់ខំឆ្ពោះទៅមុខ
ធ្វើកុសលកម្មសាងសន្សំទុក នឹងរួចចាកទុក្ខបានសេចក្តីស្ងប់ ។

ថ្ងៃ ០៦រោច ខែមាឃ ពុទ្ធសករាជ ២៥៥៨
កែសម្រួលកំណាព្យ ឧបាសិកា វរលក្ខណ៍

## ៥៧-ជូនពរឆ្នាំថ្មី

១-អាយុវណ្ណៈសុខៈពលៈ ចូរមានដល់អ្នកពេលចូលឆ្នាំថ្មី
តែសូមផ្តាំថាអស់ជនប្រុសស្រី ចូរអ្នកឃ្លាតខ្ចីថ្វាយបង្គំព្រះ ។
២-ការឱនលំទោនគោរពវន្ទា កុសលនេះជានាំឱ្យបានឈ្នះ
អស់មារសត្រូវទិដ្ឋិមានះ ពិតមានតេជះមានយសសិរី ។
៣-បើតាមពិតទៅខ្ញុំគ្មានអំណាច ឥទ្ធិអង់អាចផ្តល់គ្រប់អ្វីៗ
ផ្តល់នូវអាយុផ្តល់សុខសិរី ដល់ជនប្រុសស្រីតិចតួចបានឡើយ ។

៤-អ្វីៗគ្រប់យ៉ាងបើអ្នកត្រូវការ គួរមានបញ្ញា ចូរកុំកន្តើយ
ខំសន្សំបុណ្យកុសលនេះហើយ ឱ្យអ្នកបានស្បើយរស់ដោយសុខសាន្ត ។
៥-ធ្វើទានកាន់សីលចម្រើនភាវនា តាមពេលវេលាត្រូវធ្វើឱ្យបាន
អត់ធន់ព្យាយាមកុំឱ្យខកខាន បើអ្នកចង់បានសេចក្ដីសុខស្ងប់ ។

វត្តនិគ្រោធវ័ន ថ្ងៃ១០ កើត ខែចែត្រ ព.ស.២៥៥៧

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៥៨-មមីមមែ ជូនពរ

១-មមែចូលដល់មមីកន្លង សូមចិត្តសៅហ្មងទាំងឡាយនានា
វិនាសចេញឆ្ងាយកុំនៅវេរា សព្វសត្វគ្រប់គ្នាសូមជួបសុខា ។
២-អាយុវណ្ណៈសុខៈពលៈ ចូរមានដល់អ្នកកុំខានឡើយណា
មានលាភមានយសមានតេជសក្ដា មានឫទ្ធិអស្ចារ្យតាមដែលចិត្តប៉ង ។
៣-តែសូមផ្ដាំថាអស់ជនប្រុសស្រី ចូរអ្នកឃ្លាតខ្ចីថ្វាយបង្គំផង
ដល់ព្រះត្រៃរ័ត្នប្រសើរឥតហ្មង ត្រកូលរៀមច្បងមាតាបិតា ។
៤-ការថ្វាយបង្គំគោរពជាដើម កុសលដ៏ឆ្នើមបុញ្ញកិរិយា
នាំសម្រេចពរប្រសើរថ្លៃថ្លា បើអ្នកប្រាថ្នាសូមយកទៅចុះ ។

ថ្ងៃ ០១ រោច ខែវិសាខ ពុទ្ធសករាជ ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ៖

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**

**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។**

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចម្រើនដល់អ្នកដែលមានសេចក្ដីឱនកាយ ថ្វាយបង្គំជាប្រក្រតី មានសេចក្ដីគោរព កោតក្រែងដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។

## ៥៩-ចូលឆ្នាំដែលល្អមានស្មារតី

-ឆ្នាំចាស់កន្លងចូលឆ្នាំថ្មី គ្រប់រូបប្រុសស្រីកាន់តែចាស់
កុំឡើយសប្បាយធ្វើផ្ដេសផ្ដាស ក្រែងលោទៅប៉ះជួបទុក្ខព្រួយ។
-នាំអស់ទ្រព្យធនខូចខ្លួនប្រាណ ទាំងញាតិសន្ដានមិនអាចជួយ
ព្រោះវាជ្រុលជ្រួសស្អុយរលួយ គ្រប់គ្នាត្រូវព្រួយព្រោះចូលឆ្នាំ។
-ចូលឆ្នាំដែលល្អមានស្មារតី ទាំងប្រុសទាំងស្រីខ្ញុំសូមផ្ដាំ
ត្រូវតែសន្សំកល្យាណកម្ម ធ្វើជាប្រចាំកុំរំលង ។
-គោរពបូជាត្រៃរតនា មាតាបិតាដោយទំនង
ធ្វើទានកាន់សីលតាមគន្លង កុំឲ្យរំលងសេចក្ដីល្អ ។
-អ្នកនឹងបានជួបសុខសួស្ដី ទៅតាមប្រក្រតីដ៏បវរ
ព្រោះអ្នកបានធ្វើសេចក្ដីល្អ ដោយចិត្តស្មោះសរដ៏បរិសុទ្ធ ។

ថ្ងៃ ០៦ រោច ខែមិគសិរ ពុទ្ធសករាជ២៥៥៩

ដោយ សុវណ្ណជោតោ ភួង សុវណ្ណ

# ៦០-លោកីយ៍ស្ងួតា

១-លោកីយ៍ស្ងួតា សត្វលោកច្រើនគ្នា មានចិត្តត្រេកអរ
សេពសោយកាមគុណ ផ្អែមណាស់ដូចស្ករ ជាប់ជាបន្ត
មិនចង់ទៅណា ។
២-ភ្លេចអស់ហាត់នឿយ ធ្វើការរឿយៗ យ៉ាកយ៉ាប់អាត្មា
បានការល្ងួងលោម អំពីកាមា គ្មានចង់ទៅណា
ចង់នៅនេះឯង ។
៣-ប្រឹងប្រែងសន្សំ ដោយការខិតខំ សព្វទីកន្លែង
ទោះត្រូវឈ្លោះទាស់ ញាតិបងប្អូនឯង ឬសង្ឃគម្តែង
ក៏គ្មានប្រណី ។
៤-សាងតែបាបកម្ម រាល់ថ្ងៃខែឆ្នាំ ឥតមានស្គាល់អ្វី
បុណ្យបាបគុណទោស វក់កាមលោកីយ៍ នាំធ្លាក់អវីចី
រងទុក្ខខ្លោចផ្សា ។
៥-ស៊ីតែមួយពោះ កុំឲ្យមានមោះ ខំសាងកុសលា
ធ្វើទានកាន់សីល ចម្រើនមេត្តា ព្យាយាមឧស្សាហ៍
ដូរយកមគ្គផល ។
៦-មានចិត្តត្រេកអរ ក្នុងធម៌បវរ ដោយការតម្កល់
កាយកម្មជាដើម តែក្នុងកុសល នឹងទទួលផល

រស់ដោយសុខសាន្ត ។

ថ្ងៃ ០៩ រោច ខែមិគសិរ ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង សុវណ្ណ

អ្នកគប្បីដឹងថា ៖

សេចក្តីត្រេកអរ សប្បាយរីករាយក្នុងកាមគុណ វាទៅទល់គ្នាត្រឹមសេចក្តីទុក្ខ, តែសេចក្តីត្រេកអរ សប្បាយរីករាយក្នុងព្រះធម៌ វាទៅទល់គ្នា ត្រឹមអស់សេចក្តីទុក្ខ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

**សមន្តមសារោ លោកោ ទិសា សព្វា សមេរិតា**
**ឥច្ឆំ ភវនមត្តនោ នាទ្ទសាសឹ អនោសិតំ ៕**

លោកមិនមានខ្លឹមដោយជុំវិញ សង្ខារក្នុងទិសទាំងអស់ញាប់ញ័រ តថាគតកាលប្រាថ្នាសេចក្តីចម្រើនដើម្បីខ្លួន មិនបានឃើញនូវទីណាមួយ ដែលទុក្ខមិនញាំញីឡើយ ។

## ៦១_គប្បីយល់ដឹងពីដំណើររបស់សង្ខារធម៌

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលអានន្ទ តថាគតប្រាប់អ្នកជាមុនហើយយ៉ាងនេះថា សេចក្តីព្រាត់ប្រាស សេចក្តីវិនាស សេចក្តីប្រែប្រួលចាកសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់តែងមានជាធម្មតា ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ មិនព្រាត់ប្រាសក្នុងខន្ធប្រវត្តិនេះអំពីណា ធម្មជាតិណាកើតឡើងហើយ មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្តីវិនាសទៅជាធម្មតា ធម្មជាតិនោះឯង បុគ្គលនឹងពោលឃាត់ថាកុំវិនាសដូច្នេះ (ដោយហេតុណា) ហេតុនុ៎ះមិនមានឡើយ" ។

## ៦២_គន់មើលថ្ងៃលិច

-ខ្ញុំឈរសម្លឹងគន់មើលថ្ងៃលិច ចាំងពណ៌រំលេចលើផ្ទៃមេឃា
វិងមនុស្សសត្វទាំងឡាយគ្រប់គ្នា ស្រូតរូតម្នីម្នាចូលកាន់ទ្រនំ ។
-ថ្ងៃកន្លងទៅយប់ចូលមកដល់ ខ្លះសែនខ្វាយខ្វល់ស្មើរតែស្រែកយំ
នឿយហត់លំបាកការងារតូចធំ ដល់ផ្ទះជួបជុំប្រពន្ធកូនស្ងួន ។
-តើសុខពិតនោះវានៅត្រង់ណា ទុក្ខព្រួយខ្លោចផ្សាម្តេចមិនដឹងខ្លួន
គិតថាបានសុខទុក្ខមកផ្ទួនៗ អ៊ោះឱ!មាសស្ងួនព្រឹកទល់ព្រលប់ ។

-អ្នកចូរដឹងចុះជីវិតសង្ខារ នៃសត្វលោកាអស់ទៅមិនឈប់
ទិវារាត្រី ថ្ងៃហើយក៏យប់ យើងកុំងល់ងប់ ត្រូវមានស្មារតី ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

* បុគ្គលគប្បីដឹងថា ៖

មិនមានបុគ្គលណាម្នាក់ បានដល់នូវភាពជាធំលើជរា ព្យាធិ មរណៈ ការព្រាត់ប្រាស និងកម្ម គឺថាអាចមានសិទ្ធិសម្រេច បង្គាប់ថា <កុំចាស់ កុំឈឺ កុំស្លាប់ កុំព្រាត់ប្រាស បានឡើយ> និងហាមនូវកម្មដែលឲ្យផល ថា <ចូរជាយ៉ាងនេះវិញទៅ កុំជាយ៉ាងនេះឡើយ> ដូច្នេះបានឡើយ។ បុគ្គលគប្បីកំណត់ដល់ភាវៈមិនទៀងនៃសង្ខាររបស់សត្វទាំងឡាយ ចូរជាអ្នកមិនប្រមាទក្នុងកុសលធម៌ ទាំងពេលយប់ ទាំងពេលថ្ងៃ ។

## ៦៣_ច្បាប់ធម្មជាតិ

-កើតចាស់ឈឺស្លាប់ជាច្បាប់ធម្មជាតិ ពិតមិនឃ្លៀងឃ្លាតទៅជាដទៃ
ព្រោះហេតុដូច្នោះយើងត្រូវលកលៃ រវៀសរវៃប្រព្រឹត្តធម៌អាថ៌ ។
-ឱជីវិតនេះតិចតួចពេកណាស់ អស់ទៅរហ័សមិនយូរឡើយណា
ព្រះអង្គបានត្រាស់ជាពុទ្ធដីកា ស្លាប់ចោលកាយាត្រាច់ទៅតាមកម្ម។
-បុគ្គលធ្វើបាបតែងតែសោយទុក្ខ នៅលោកខាងមុខរាប់ម៉ឺនសែនឆ្នាំ
ស្រេកទឹកឃ្លានបាយភ្លើងឆេះប្រចាំ រងទុក្ខតាមកម្មមិនងាយរួចខ្លួន។

-ឯអ្នកធ្វើល្អតែងបានសុខា តាមចិត្តប្រាថ្នាដឹងចុះមាសស្ងួន
នាំបាននិព្វានក្តីសុខមាំមួន នេះទើបរួចខ្លួនពីចាស់ឈឺស្លាប់ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ក្នុងជរាសូត្រ ព្រះមានព្រះភាគ ត្រាស់ថា ៖

ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយទាំងអស់ មានការបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ, ពួកជនណា ទាំងក្មេង ទាំងចាស់ ទាំងពាល ទាំងបណ្ឌិត ពួកជនទាំងអស់នោះ រមែងលុះអំណាចនៃមច្ចុ ពួកជនទាំងអស់ មានមច្ចុប្រព្រឹត្តទៅខាងមុខ, កាលពួកជនទាំងនោះដែលមច្ចុគ្របសង្កត់ ទៅកាន់បរលោក បិតាពឹងបុត្តមិនបាន ឬថាពួកញាតិពឹងពួកញាតិក៏មិនបាន អ្នកចូរមើលចុះ កាលពួកញាតិកំពុងសម្លឹងមើល កំពុងយំរៀបរាប់ច្រើន សត្វលោកដែលត្រូវមច្ចុនិងជរាបំផ្លាញហើយ ដូចជាបណ្តាសត្វទាំងឡាយ គោ ១ ៗ ដែលគេត្រូវនាំទៅសម្លាប់ ។

## ៦៤-ធម្មជាតិ

១-កើតចាស់ឈឺស្លាប់ នេះឯងជាច្បាប់ ធម្មជាតិមែនពិត
ទោះក្មេងឬចាស់ ពាលឬបណ្ឌិត មិនអាចប្រព្រឹត្ត
កន្លងបានអ៊ី ។

២-ទោះមានឬក្រ អាក្រក់ឬល្អ ទោះប្រុសឬស្រី
ទោះស្គមឬធាត់ ឬស្រស់ប្រិមប្រិយ យ៉ាងដូចម្ដេចក្ដី
ស្លាប់ឥតសល់ឡើយ ។

៣-ទោះមានកម្លាំង ឥទ្ធិក្លាខ្លាំង យ៉ាងណាក៏ដោយ
តស៊ូម្ដេចម្ដា មិនអាចឈ្នះឡើយ ហេតុដូច្នេះហើយ
ត្រូវតែធ្វើល្អ ។

៤-ទានសីលភាវនា គួរយើងគ្រប់គ្នា មានចិត្តបវរ
អប់រំចម្រើន ឱ្យបានល្អិតល្អ បិតក្នុងធម៌ស
សន្សំសុចរិត ។

៥-មាតាបិតា និងព្រាហ្មណា គួរអ្នកតាំងចិត្ត
បម្រើឱ្យល្អ ឱ្យបានប្រណីត នេះជាសុចរិត
នាំបានសុខា ។

៦-កុំខ្លាចនឿយហត់ ធ្វើឱ្យហ្មត់ចត់ ចិត្តជាសម្មា
ព្រមដោយសទ្ធា កបដោយបញ្ញា នេះហៅកុសលា
នាំបានសុខស្ងប់ ។

## ៦៥_ធម្មជាតិ ន័យម្យ៉ាងទៀត

១-កើតចាស់ឈឺស្លាប់ នេះឯងជាច្បាប់ ធម្មជាតិមែនពិត
ទោះក្មេងឬចាស់ ពាលឬបណ្ឌិត មិនអាចប្រព្រឹត្ត
កន្លងបានអ្វី ។

២-ទោះមានឬក្រ អាក្រក់ឬល្អ ទោះប្រុសឬស្រី
ទោះស្គមឬធាត់ ឬស្រស់ប្រិមប្រិយ នេះដូចម្ដេចក្ដី
ស្លាប់ឥតសល់ឡើយ ។

៣-ទោះមានកម្លាំង ឥទ្ធិក្លាខ្លាំង យ៉ាងណាក៏ដោយ
តស៊ូម្ដេចម្ដា មិនអាចឈ្នះឡើយ ហេតុដូច្នេះហើយ
ត្រូវតែធ្វើល្អ ។

៤-កាន់សីលធ្វើទាន ភាវនាជាឈាន ទឹកចិត្តបវរ
អប់រំចម្រើន ឱ្យបានល្អិតល្អ បិតក្នុងធម៌ស
មគ្គអង្គប្រាំបី ។

៥-ផ្លូវត្រង់នេះណា ដែលព្រះសម្មា- សម្ពុទ្ធជិនស្រី
ទ្រង់បានត្រាស់ប្រាប់ គួរយើងឃ្នាតខ្មី ទោះដូចម្ដេចក្ដី
បានសុខខាងក្រោយ ។

ថ្ងៃ ១០ កើត ខែអស្សុជ ព.ស.២៥៥៦
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៦៦-សង្ខារទាំងឡាយមិនទៀង

>សង្ខារទាំងឡាយមិនទៀងពិត គឺតែងវិបរិតតែងប្រាសព្រាត់
ទោះបីស្រស់ល្អតូចធំធាត់ គ្មានអ្វីហាមឃាត់ជាធម្មជាតិ ។
>ម្តងសើចម្តងយំផ្លាស់ប្តូរគ្នា គ្រប់ពេលវេលាគួរឆ្លាសឆ្លៀត
សាងសេចក្តីល្អកុំឲ្យឃ្លាត ធ្វើហើយធ្វើទៀតនាំសុខៈ ។
>អ្វីដែលបច្ច័យបានតាក់តែង ព្រះអង្គសម្តែងគ្មានអមតៈ
មានការបែកធ្លាយតែងបែកបាក់ នេះជាសច្ចៈតាមបច្ច័យ ។
>ឯព្រះនិព្វានពិតមិនស្លាប់ តាមដែលទ្រង់ប្រាប់អស់អាល័យ
លះបង់តណ្ហាជាបច្ច័យ ជាក់ច្បាស់ធម៌ថ្លៃជាអមតៈ ៕

រាត្រីថ្ងៃ ០៦ កើត ខែជេស្ឋ ព.ស.២៥៥៩
ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

អ្នកគប្បីដឹងថា ៖

ជីវិត មានតែការរលត់ អស់ទៅ សូន្យទៅជានិច្ច គ្មានថ្ងៃត្រឡប់ក្រោយទេ, ព្រោះថា សង្ខារធម៌ទាំងឡាយ គឺខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនទៀង ។

សង្ខារទាំងពួងទាំងឡាយមិនទៀងទេ, លោកមិនមានខ្លឹមដោយជុំវិញ សង្ខារក្នុងទិសទាំងពួងញាប់ញ័រ មិនមានទីណាមួយដែលទុក្ខមិនញាំញីនោះទេ ។

## ៦៧-ជីវិតមិនទៀង

-ជីវិតមិនទៀងត្រូវចាស់គ្រាំគ្រា គ្រប់ពេលវេលាដង្ហើមចេញចូល
មិនយូរប៉ុន្មានពិតត្រូវផ្លាស់ប្តូរ បើមិនដេកផ្ទូរក៏ត្រូវដុតដែរ ។
-ជីវិតមានតិចរស់មិនបានយូរ គួរតែគិតគូររក្សាស្ងួនថៃ
ធ្វើទានកាន់សីលចិញ្ចឹមពុកម៉ែ រៀងរាល់ថ្ងៃខែគោរពបូជា។
-កុំឡើយវង្វេងក្នុងកាមលោកីយ៍ មានចិត្តអប្រិយឈ្លោះទាស់ទែងគ្នា
ប្រកាន់តួខ្លួនឥតស្គាល់ធម្មា ពេលដុតបូជាមានខ្លួនអីទៀត ។
-រស់ជួបជុំគ្នាគួរមានមេត្តា មិនដឹងថ្ងៃណានឹងត្រូវបែកឃ្លាត
ជីវិតមិនទៀងគប្បីឆ្លាសឆ្លៀត ធ្វើហើយធ្វើទៀតនូវបុញ្ញកិរិយា ។
-កុសលដែលសត្វសន្សំដោយល្អ ប្រសើរបវរនាំបានសុខា
បាននូវសម្បត្តិមនុស្សទេវតា សម្រេចអមតានិព្វាននោះហោង ៕

 រាត្រីថ្ងៃ ០៥ រោ ខែភទ្របទ ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

ព្រះមានព្រះភាគ ត្រាស់ថា ៖

**វុត្តំ ហេតំ ភគវា អប្បមិទំ ភិក្ខវេ មនុស្សានំ អាយុ គមនីយោ សម្បរាយោ មន្តាយ ផោដ្ឋព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ ។** សមដូចពាក្យនេះដែលព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់ពួកមនុស្សនេះតិច បរលោកពួក

សត្វត្រូវទៅដោយពិត បុគ្គលគប្បីប៉ះពាល់ដោយបញ្ញា គប្បីធ្វើកុសល គប្បីប្រព្រឹត្តព្រហ្មចរិយៈ (ព្រោះថា) សត្វដែលកើតហើយមិនមែនជាមិនស្លាប់ទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលណារស់នៅអស់កាលយូរ បុគ្គលនោះ គប្បីរស់នៅ ១០០ ឆ្នាំ តិចពីមួយរយឆ្នាំ ឬច្រើនជាងមួយរយឆ្នាំ ។

## ៦៨-ជីវិតត្រូវស្លាប់

ជីវិតត្រូវស្លាប់កាយដេកស្តូកស្តឹង ឥតមានបានដឹងនូវជននានា
មកអភិវន្ទន៍គោរពបូជា យំសោកពណ៌នាសរសើររៀបរាប់ ។
រូបកាយត្រូវដុតផ្សេងហុយខ្ទួលខ្មាញ់ អស់គេអស់អញអស់ការគួរគាប់
លះញាតិបងប្អូនសម្បត្តិភោគទ្រព្យ គ្មានអ្វីអាចជាប់តាមខ្លួនបានឡើយ។
ទោះខំប្រកាន់ថាអញយ៉ាងណា ដឹងចុះជីវាពិតលះចោលហើយ
ជីវិតត្រូវស្លាប់គ្មានសល់អ្វីឡើយ ជាតិនេះជាក្រោយគ្រាន់ជាសង្ខារ ។
បើអ្នកមិនព្រមយល់ពីធម្មៈ មានប្រាជកជាក់បានត្រឹមសោកា
នឹងត្រូវរងទុក្ខក្នុងវដ្តសង្សារ មិនដឹងថ្ងៃណានឹងបានរួចខ្លួន ។
បើអ្នកបានយល់ពីហេតុបច្ច័យ លះក្តីអាល័យគំនុំគុំកួន
រស់មិនប្រកាន់បុគ្គលតួខ្លួន សតិមាំមួននឹងបានផុតទុក្ខ ។

រាត្រីថ្ងៃ ០៥ រោ ខែភទ្របទ ពុទ្ធសករាជ២៥៥៩

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

# ៦៩-វេលាកន្លងយ៉ាងរហ័ស

-វេលាកន្លងយ៉ាងរហ័ស កាយត្រូវប្តូរផ្លាស់ចាស់ជរា
ស្បែកជ្រួញសក់ស្កូវមានរោគា កើតទុក្ខវេទនាគេចមិនបាន ។
-រូបកាយប្រែប្រួលជាលំដាប់ ទីបំផុតស្លាប់តែគ្រប់ប្រាណ
លះញាតិបងប្អូនយសថ្កើងថ្កាន សម្បត្តិប៉ុន្មានចោលទាំងអស់។
-ក្រោយពីស្លាប់ទៅមិនយូរទេ ដឹងចុះមាសមេគេអាឡោះ
អាល័យសោកស្តាយនឹកស្រណោះ តែកាយខ្ទួរខ្ទោះទុកមិនបាន។
-គេយកទៅកប់ឬបូជា ក្នុងទីនានាព្រៃស្មសាន
ឬទីប៉ាឆាឈាបនដ្ឋាន ដឹងចុះកល្យាណទៅតែឯង ។
-ពួកញាតិកូនចៅនៅឯអាយ នាំគ្នាចែកចាយផ្ទះសំបែង
មាសប្រាក់ទ្រព្យធនគ្រឿងតុបតែង ដែលខ្លួនស្វះស្វែងសន្សំទុក។
-ចំណែកខ្លួនឯងទៅបរលោក ឥតមានបានយកអ្វីគ្រប់មុខ
គ្រប់យ៉ាងបានត្រឹមសន្សំទុក ឯលោកខាងមុខទៅតាមកម្ម ។
-កម្មជារបស់ខ្លួនមែនពិត អ្នកត្រូវចេះគិតត្រូវចងចាំ
បើអ្នកសន្សំតែបាបកម្ម អ្នកសោយផលកម្មទុក្ខខ្លោចផ្សា។
-បើអ្នកសន្សំកល្យាណកម្ម នេះអ្នកត្រូវចាំល្អថ្លៃថ្លា
នាំបានក្តីសុខស្រីសុខា តាមចិត្តប្រាថ្នាជាប្រាកដ ។
-ព្រោះហេតុដូច្នោះកុំប្រមាទ គប្បីសង្វាតចិត្តអំណត់
សន្សំកុសលឲ្យហ្មត់ចត់ ផលល្អប្រាកដបានសុខស្ងប់ ។

រាត្រីថ្ងៃ ០៣ កើត ខែអស្សុជ ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

ព្រះមានព្រះភាគ ត្រាស់ថា ៖

ន សន្តិ បុត្តា តាណាយ  ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស  នត្ថិ ញាតីសុ តាណតា,
ឯតមត្ថវសំ ញត្វា  បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ  ខិប្បមេវ វិសោធយេ ។

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយមិនមានដើម្បីជាទីពឹង បិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន, បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

## ៧០-មាគ៌ារំលត់ទុក្ខ

-រូបកាយត្រូវដុតឆេះសាយសុស អស់ស្រីអស់ប្រុសអស់អញឯង
នៅសល់តែឆ្អឹងគេចាត់ចែង  រើសដាក់កញ្រ្ចែងមួយដោយឡែក ។
-មិនយូរប៉ុន្មានត្រូវខ្ចាត់ខ្ចាយ  ទៅទីជិតឆ្ងាយគ្មានអ្វីប្លែក
វិនាសបាត់បង់ជាចំណែក  គឺគ្មានអ្វីប្លែកទៅជាដី ។
-ត្រង់ណាទៅសត្វនិងតួខ្លួន  អស់ឱមាសសួនគួរលកលៃ
សិក្សាព្រះធម៌ព្រះវិន័យ  ប្រតិបត្តិប្រពៃតាមធម្មា ។
-បើអ្នកឃើញធម៌អ្នកនឹងអាច  អស់ការភ័យខ្លាចផងនានា

លះការប្រកាន់លះគ្រឹហា នេះជាមាគ៌ារំលត់ទុក្ខ ។

វត្តនិគ្រោធនៃថ្ងៃ ០៩ កើត ខែអស្សុជ ពុទ្ធសករាជ២៥៥៩

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ៧១-ដំណើរមិនទៀងនៃសង្ខារ

-ដំណើរមិនទៀងនៃសង្ខារ រាល់រូបសត្តាគ្រប់តែគ្នា
កើតហើយតែងតែចាស់ជរា ជំងឺរោគាគេចមិនបាន ។
-ខ្លះក៏រស់យូរខ្លះក៏ឆាប់ លំបាកយ៉ាកយ៉ាប់ស្រណុកប្រាណ
តែទោះយ៉ាងណាគេចមិនបាន ត្រូវក្ស័យពុំខានចោលកាយា ។
-បើបានស្គាល់គ្នាត្រូវធ្វើល្អ ទឹកចិត្តបវរដោយមេត្តា
កុំឡើយច្រណែនចិត្តឥស្សា សំដីវាចាមិនសមរម្យ ។
-ជួបគ្នាថ្ងៃនេះលុះថ្ងៃស្អែក អាចប្រែជាបែកលែងជួបជុំ
កុំឲ្យស្តាយក្រោយទ្រហោយំ ដូច្នេះជួបជុំដោយមេត្រី ។

ថ្ងៃ ០៧ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

អ្នកគប្បីដឹងថា ៖ ទីបំផុតត្រូវតែចាកចេញ ! ទោះជាទៅដល់ទីណា នៅទីណា បើទុកជាទីនោះល្អក្តី មិនល្អក្តី សប្បាយក្តី មិនសប្បាយក្តី ទីបំផុតត្រូវតែចាកចេញ គ្មានទីណាមួយទៀងទាត់ ឋិតថេរ សម្រាប់ជាទីនៅរបស់យើងនោះទេ ។

ព្រោះហេតុនោះ មិនគួរមានចិត្តជាប់ជំពាក់ ប្រកាន់ហ្មងហែង នោះទេ ។

## ៧២-រសៀលគងភ្នំ

រសៀលគងភ្នំសូរិយាទៀបលិច រស្មីរំលេចពណ៌ក្រហមច្រាល
ជះលើដងព្រៃអាកាសបព្វតា បក្សីបក្សាចូលកាន់ទ្រនំ ។
អ្នកខ្លះនឹកដល់រឿងរ៉ាវទាំងឡាយ ចិន្តាខ្វល់ខ្វាយចង់តែស្រែកយំ
រឿងក្នុងរឿងក្រៅទាំងតូចទាំងធំ ចង់តែស្រែកយំឲ្យធូរចិន្តា ។
អ្នកចូរដឹងចុះជីវិតសព្វសត្វ តែងមានវិបត្តិនេះជាធម្មតា
តែការរស់នៅត្រូវមានបញ្ញា ដោះស្រាយបញ្ហាតាមព្រះធម្មា។
សេចក្តីត្រិះរិះដោយមានស្មារតី ធ្វើកិច្ចការអ្វីធ្វើដោយចិត្តជា
ប្រព្រឹត្តសុចរិតមិនសាងវេរា ផុតទុក្ខវេទនាព្រោះដឹងធម្មៈ ។
គ្រប់យ៉ាងកើតឡើងមានហេតុបច្ច័យ រស់នៅរាល់ថ្ងៃដឹងឲ្យបានជាក់
ស្គាល់ពីធម្មជាតិឲ្យបានជាក់លាក់ ឱណាឱអ្នកកុំឡើយទោមនស្ស។

ថ្ងៃ ១៤ កើត ខែមិគសិរ ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៧៣-ព្រះសាស្តា ទ្រង់មានព្រះបន្ទូលថា :

**បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ**
**បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ ។**

វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយហើយទៅ ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ
សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយៗចុះ។

យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហស្សតិ
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។ (សុត្តន្តបិដក ១៦, ២៥៣-២៥៧)

## ៧៤-សុខាជាអមតៈ

-វ័យកាន់តែចាស់ដល់ជរា ជីវិតគ្រប់គ្នាក៏តិចណាស់
ទ្រុឌទ្រោមគ្រាំគ្រាមិនស្រឡះ អ្នកបានអ្វីខ្លះជាទីពឹង ។
-ចូរកុំប្រមាទមានស្មារតី ទាំងប្រុសទាំងស្រីគិតជញ្ជឹង
ត្រូវមានសីលល្អចិត្តនឹងធឹង តម្រិះរំពឹងក៏ឲ្យល្អ ។

-ឯភិក្ខុណាមិនប្រមាទ ខំប្រឹងសង្វាតចិត្តបវរ
ក្នុងធម៌វិន័យមានលម្អ ដោយចិត្តស្មោះសរក្នុងសាសនា ។
-បានជម្រះចិត្តឲ្យផូរផង់ នឹងអាចលះបង់ជាតិសង្សារ
ឃើញព្រះនិព្វានផុតទុក្ខា បានក្តីសុខាជាអមត ។

ថ្ងៃ ០៤ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួងសុវណ្ណ

## ៧៥~ត្រូវសន្សំបុណ្យ

-ភទ្របទរនោចរដូវបិណ្ឌភ្ជុំ យើងមកជួបជុំមានចិត្តតម្រង់
រៀបចំចង្ហាន់ប្រណីតផ្ចិតផ្ចង់ ប្រគេនព្រះសង្ឃរួចឧទ្ទិសទាន ។
-សូមឱ្យញាតិមិត្តដែលស្លាប់ទៅហើយ ចូរអ្នកបានស្បើយផុតចាកស្រែកឃ្លាន
អនុមោទនាកុសលផ្ទាក់ទាន ឱ្យបានជាយានឆ្ពោះទៅសុខសួគ៌ ។
-អ្នកចូរដឹងចុះវិការជ្រះថ្លា កបដោយបញ្ញាតាមកាលដ៏គួរ
ដោយចិត្តចេតនានេះពិតជាតួ កុសលនាំសួគ៌និព្វានមកឱ្យ ។
-វីធមិទាំងឡាយមានចិត្តជាធំ រដូវបិណ្ឌភ្ជុំអ្នកកុំកន្តើយ
បើអ្នកប្រមាទមិនបានសុខឡើយ ហេតុដូច្នេះហើយត្រូវសន្សំបុណ្យ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៧៦-ធ្វើបុណ្យភ្ជុំបិណ្ឌ

-វេលាកាន់បិណ្ឌមាន ១៤ ថ្ងៃ ពិតល្អពេកក្រៃសាងបុញ្ញកិរិយា
ឥឡូវ ១៥ ប្រសើរថ្លៃថ្លា បងប្អូនយាយតាធ្វើបុណ្យភ្ជុំបិណ្ឌ ។
-ចាស់ទុំបូរាណលោកបានលៃលក ប្រព្រឹត្តធ្វើមកលោកប្រសប់ប៉ិន
ឲ្យរាស្ត្រប្រជាធ្វើបុណ្យភ្ជុំបិណ្ឌ ផ្អាកកិច្ចការសិនចូលវត្តធ្វើល្អ ។
-កាមគុណឲ្យសត្វរវល់ពេកណាស់ ពីក្មេងដល់ចាស់ឲ្យល្អក់កករ
គ្មានពេលធ្វើបុណ្យសាងសេចក្ដីល្អ នេះហៅកម្រកើតចិត្តសទ្ធា។
-ហេតុនេះបរិស័ទទាំងឡាយអើយ ឱកាសមានហើយព្យាយាមម្ទីម្ទា
ធ្វើទានកាន់សីលគោរពបូជា តាមពេលវេលាកុំបីខកខាន ។
-ឱកាសធ្វើបុណ្យរកបានដោយក្រ ព្រោះទឹកចិត្តល្អមិនងាយរកបាន
សទ្ធាកើតហើយក្នុងចិត្តសន្ដាន សាងក្ដីសុខសាន្តដោយមិនប្រមាទ។

ថ្ងៃ ១៥ រោច ខែភទ្របទ ពុទ្ធសករា២៥៥៩

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៧៧-អនុមោទនានាំឱ្យបានសុខ

១-ភ្លៀងធ្លាក់សស្រិច ខ្យល់បក់តិចៗ នារដូវភ្ជុំ
តាយាយមាមីង បងប្អូនតូចធំ បានមកជួបជុំ
តាមវត្តអារាម ។

២-ខ្លះមានបាយទឹក ដ៏ច្រើនសន្ធឹក ចិត្តឥតជិតដាម
ដោយអកុសល រសេមរសាម ឥតមានម៉េមម៉ាម
មានតែជ្រះថ្លា ។
៣-ខ្លះមានចំណី បង្អែមថ្មីៗ ព្រមដោយភ្ញីផ្កា
ផ្លែឈើតូចធំ គួរចង់ពិសា ចូលកាន់សាលា
ប្រគេនព្រះសង្ឃ ។
៤-មានចិត្តសង្គ្រោះ ឧទ្ទិសទាននោះ ឱ្យព្រមដោយអង្គ
នៃទក្ខិណា ប្រណីតផ្ចិតផ្ចង់ អាស្រ័យព្រះសង្ឃ
ដល់ព្រមដោយគុណ ។
៥-សូមឱ្យពួកញាតិ ដែលស្លាប់បែកឃ្លាត មានចិត្តទោរទន់
អនុមោទនា វាចាទន់ភ្លន់ នឹងបានជាគុណ
នាំឱ្យបានសុខ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៧៨-ឃ្លាតទុក្ខជួបសុខ

១-មេឃខ្មៅងងឹត ហាក់ប្រាកដពិត ថានឹងធ្លាក់ភ្លៀង
តែទោះយ៉ាងណា ធម្មជាតិមិនទៀង អាចប្រែជាឃ្វាង

ទៅជាស្រឡះ ។

២-វិរឿងជីវិត អ្នកមានគំនិត បញ្ញាច្បងច្បាស់
មានចិត្តអំណត់ ព្យាយាមឱ្យណាស់ អ្នកនឹងត្រចះ
ព្រោះប្រព្រឹត្តល្អ ។

៣-ចម្រើនយ៉ាងណា អ្នកគួរពិចារណ៍ គំនិតបវរ
អ្វីៗមិនទៀង កុំឃើញតែល្អ ទ្រុឌទ្រោមបន្ត
ជានិច្ចរាល់ថ្ងៃ ។

៤-គួរមានបញ្ញា ស្មារតីភ្លឺថ្លា ត្រិះរិះកែខៃ
សិក្សាប្រព្រឹត្ត នូវព្រះធម៌ថ្លៃ ពិតមានតម្លៃ
ឃ្លាតទុក្ខជួបសុខ ។

ថ្ងៃ ០៦ រោច ខែភទ្របទ ព.ស. ២៥៥៦
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៧៩_ចង់ឆ្លងផុតលោក ត្រូវប្រព្រឹត្តធម៌

១-ផ្ទៃមេឃស្រឡះ ហាក់ប្រាកដណាស់ ថាមិនធ្លាក់ភ្លៀង
តែទោះយ៉ាងណា ធម្មជាតិមិនទៀង អាចប្រែជាឃ្វាង
ទៅជាភ្លៀងបាន ។

២-វីវឿងជីវិត មិនប្រាកដពិត ថានៅតែថ្កាន
ព្រោះរឿងលាភយស ឬក្ដីសុខសាន្ត ព្រះសម្ពុទ្ធបាន
ត្រាស់ថាមិនទៀង ។
៣-បើអ្នកប្រមាទ មិនប្រឹងសង្វាត នោះអ្នកនឹងឃ្វាង
ឃ្លាតចាកលាភយស ចិត្តក៏លំអៀង នេះហៅមិនទៀង
នៃធម៌ក្នុងលោក ។
៤-ហេតុដូច្នេះហើយ អ្នកកុំតោះតើយ បើចង់មានជោគ
ចង់បានក្ដីសុខ មានភ័ព្វមានភោគ ចង់ឆ្លងផុតលោក
ត្រូវប្រព្រឹត្តធម៌ ។

ថ្ងៃ ០៦រោច ខែភទ្របទ ព.ស.២៥
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

មានលាភ ឥតលាភ មានយស ឥតយស សរសើរ និន្ទា សុខ ទុក្ខ ទាំងអស់នេះជាលោកធម៌, លោកធម៌នេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា មិនទៀងទេ ។ ព្រោះហេតុនោះ ដើម្បីបាននូវយស ត្រូវមានការព្យាយាម មានស្មារតី មានការងារស្អាត មានការពិចារណា រស់នៅដោយធម៌ មានបញ្ញា មិនប្រមាទ ។

ព្រះពុទ្ធគាថា ទ្រង់សម្តែងប្រារព្ធ ព្រះបាទសិរីសុទ្ធោទនៈ

ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិច ។

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះ ឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

## ៨០~ទេវទូត

( បទពាក្យ ៧ )

១-ទេវទូតទាំងឡាយប្រាំប្រការ ដែលព្រះសាស្តាទ្រង់សម្តែង
រឿងនេះមានពិតយ៉ាងជាក់ស្តែង ហេតុដូច្នេះឯងយើងត្រូវដឹង ។
២-គឺត្រូវតែយល់ត្រូវសិក្សា គិតពិចារណាហើយត្រូវប្រឹង
ត្រូវចេះប្រៀបធៀបពេលសម្លឹង នោះអ្នកនឹងដឹងរូបកាយា ។
៣-ទី១ ក៏គឺ**ទារកខ្ចី** មិនទាន់ដឹងក្តីអ្វីឡើយណា
មិនអាចក្រោករួចដោយអាត្មា គួរពិចារណាដោយឧបាយ ។
៤-ទី២ **ជរា** ចាស់គ្រាំគ្រា សោយទុក្ខវេទនាតាមផ្លូវកាយ
ខ្នងកោងញាប់ញ័រសៃនខ្វល់ខ្វាយ រស់មិនសប្បាយខ្លួនសៅហ្មង ។
៥-ទី៣ **ព្យាធិ** រោគឈឺចាប់ លំបាកយ៉ាកយ៉ាប់ពេកកន្លង

សព្វសរីរៈនោះតែម្តង មិនអាចអ្នកផងជួយរក្សា ។
៦-ទី៤ **កម្មករណ៍ ៣២** នេះតែងញាំញីដល់ជនណា
ប្រព្រឹត្តអាក្រក់ត្រូវរាជការ ដាក់ទោសប្រហារទៅតាមកម្ម ។
៧-ទី៥ **អ្នកស្លាប់**អស់មួយថ្ងៃ អស់ពីរបីថ្ងៃ បែកខន្ធប្រាំ
កាយនេះហើមប៉ោងត្រូវប្រេះស្រាំ វិនាសតាមកម្មគួរនឿយណាយ ។
៨-ទាំងនេះបើអ្នកចេះសម្លឹង អ្នកនឹងបានដឹងដោយឧបាយ
ខន្ធប្រាំមិនទៀងតែងប្រែក្លាយ មានភ័យអន្តរាយច្រើនប្រការ ។
៩-រូបគេយ៉ាងណាយើងយ៉ាងហ្នឹង គប្បីរំពឹងដោយបញ្ញា
កាត់អវិជ្ជានិងតណ្ហា តាំងក្នុងសម្មាបដិបត្តិ ។
១០-ប្រព្រឹត្តទានសីលភាវនា ព្យាយាមម្ទីម្នាយ៉ាងម៉ឺងម៉ាត់
សិក្សាឱ្យយល់បរិយត្តិ ហើយបដិបត្តិនឹងផុតទុក្ខ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ក្នុងអដ្ឋកថា មនោរថបូរណី លោកពន្យល់ថា :

បទថា **ទេវទូតានិ** បានដល់ ទេវទូតទាំងឡាយ ។ ក៏ក្នុងបទថា **ទេវទូតានិ** នេះ មានអត្ថន័យរបស់ពាក្យដូចតទៅនេះ, មច្ចុ ឈ្មោះថា ទេវៈ, ទូតរបស់ទេវៈនោះ ឈ្មោះថា **ទេវទូត** អធិប្បាយថា មនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ ហៅថា ទេវទូត ព្រោះដូចជាដាស់តឿនថា

"**ឥទានិ តេ មច្ចុសមីបំ គន្តព្វំ** : ឥឡូវនេះ លោកកំពុងចូលទៅជិតសេចក្តីស្លាប់" ដោយសំដៅយកនឹងឱ្យកើតសេចក្តីសង្វេគ ។

មួយទៀត ឈ្មោះថា **ទេវទូត** ព្រោះសំដៅសេចក្តីថា ជាទូតដូចជាទេវតាខ្លះ ។ អធិប្បាយថា កាលទេវតាប្រដាប់តាក់តែងហើយឈរនិយាយនៅក្នុងអាកាសថា "**ត្វំ អសុកទិវសេ មរិស្សសិ** : លោកនឹងស្លាប់ក្នុងថ្ងៃឯណោះ" ពាក្យនិយាយរបស់ទេវតានោះ អ្នកត្រូវជឿ យ៉ាងណា សូម្បីមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ក៏ដូច្នោះដែរ កាលប្រាកដ ក៏ដូចជាដាស់តឿនថា "សូម្បីលោកក៏ជាយ៉ាងនេះជាធម្មតា" ក៏ពាក្យនិយាយនោះ របស់មនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ទាំងនោះ ក៏ដូចជាពាក្យព្យាករណ៍របស់ទេវតា ព្រោះមិនផ្លាស់ប្តូរទៅជាយ៉ាងដទៃឡើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ទេវទូត** ព្រោះជាទូត ដូចជាទេវតា ។

ម្យ៉ាងទៀត ឈ្មោះថា ជាទេវទូត ព្រោះជាទូតរបស់វិសុទ្ធិទេវៈក៏បាន, អធិប្បាយថា ព្រះពោធិសត្វគ្រប់អង្គឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួសប៉ុណ្ណោះ ក៏ដល់សេចក្តីសង្វេគ ហើយចេញបួស ។ មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួស ឈ្មោះថា **ទេវទូត** ព្រោះជាទូតរបស់វិសុទ្ធិទេវៈទាំងឡាយខ្លះ ដូចពោលមកនេះ ។

# ៨១_វាចាសុភាសិត

(សុត្តន្តបិដក ៤៥, ២៣១)

វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថា សុភាសិត មិនមែនជាទុព្ភាសិត ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញមិនគប្បីតិះដៀលផង ។ គឺ

**១_កាលេន ភាសិតា** វាចាដែលពោលប្រកបតាមកាល

**២_សច្ចា ភាសិតា** វាចាដែលពោលពិត

**៣_សណ្ហា ភាសិតា** វាចាដែលពោលទន់ភ្លន់

**៤_អត្ថសញ្ហិតា ភាសិតា** វាចាដែលពោលប្រកបដោយប្រយោជន៏

**៥_មេត្តចិត្តេន ភាសិតា** វាចាដែលពោលប្រកបដោយមេត្តាចិត្ត ។

## វាចាសុភាសិត (កំណាព្យ)

-សម្ដីពោលស្ដីសុភាសិត ដ៏ល្អវិសិដ្ឋប្រសើរណាស់
សម្ដីឥតទោសល្អត្រចះ គួររីករាយណាស់នៃអ្នកប្រាជ្ញ ។
-ទី១វាចាពោលតាមកាល ចេះអភិបាលមិនរហាច
គួរពោលគួរស្ងៀមចិត្តអង់អាច ជាមួយអ្នកប្រាជ្ញនិងជនា ។
-ទី២វាចាដែលពោលពិត ឥតមានប្រឌិតគ្រប់វេលា
មានការរិះគិតមុនពណ៌នា ឲ្យជនគ្រប់គ្នាបានត្រេកអរ ។

-ទី៣ វាចាពោលទន់ភ្លន់ ប្រសើរពេកពន់ដ៏បវរ
ទោះពាក្យរាក់ជ្រៅគួរអំណរ វាចាដ៏ល្អគួរចូលចិត្ត ។
-ទី៤វាចាប្រាប់ប្រយោជន៍ តិចច្រើនដោយហោចសែនវិចិត្រ
មានន័យខ្លឹមសារល្អប្រណិត វិសេសវិសិដ្ឋប្រសើរថ្កាន ។
-ទី៥ ពោលដោយចិត្តមេត្តា ព្រោះមានប្រាថ្នាការរាប់អាន
ចង់ផ្តល់ក្តីសុខណាកល្យាណ ឲ្យសត្វគ្រប់ប្រាណបានសួស្តី។
-អ្នកអើយដឹងចុះពោលវាចា គួរពិចារណាដឹងសេចក្តី
សឹមពោលចរចានិយាយស្តី ពោលដោយមេត្រីសុភាសិត ។

ថ្ងៃ ០៤ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៨២_អារាធនាធម៌ (ទី១)

( បទព្រហ្មគីតិ )

១-អហំ រីខ្ញុំម្ចាស់ សូមឱកាសអារាធនា
លោកម្ចាស់ពោលធម្មា ប្រាប់មាគ៌ាដ៏វិសិដ្ឋ ។
២-ព្រះពុទ្ធទ្រង់សម្តែង គ្រប់កន្លែងល្អវិចិត្រ
ធម៌នោះល្អប្រណិត សែនល្អល្អិតជាសច្ចៈ ។
៣-យើងខ្ញុំប្រាថ្នាស្តាប់ ធម៌ជាច្បាប់យ៉ាងប្រចក្ស
សូមយកចិត្តទុកដាក់ ស្តាប់សច្ចធម៌បវរ ។

៤-ហេតុនេះសូមលោកម្ចាស់ មានឱកាសវេលាល្អ
ពោលធម៌មិមានលំអ ខ្ញុំសាទរទទួលស្តាប់ ។

## ៨៣-អារាធនាធម៌ (ទី២)

១-ខ្ញុំមានចិត្តជ្រះថ្លា ពោលវាចាអារាធនា
លោកម្ចាស់ពោលធម្មា ក្នុងវេលាគ្រានេះឯង ។
២-សូមពោលធម៌វិន័យ ល្អប្រពៃគួរស្ទប់ស្ទែង
ដែលព្រះពុទ្ធសម្តែង សូមតាក់តែង ទោះវែងខ្លី ។
៣-ឱ្យខ្ញុំបានយល់ច្បាស់ ភ្លឺត្រចះធម៌បាលី
យល់អត្ថយល់សេចក្តី ខ្ញុំឃ្នាតខ្មីប្រព្រឹត្តល្អ ។
៤-ហេតុនេះសូមលោកម្ចាស់ មានឱកាសវេលាល្អ
ពោលធម៌មានលំអ ខ្ញុំសាទរទទួលស្តាប់ ។
៥-ម្យ៉ាងសូមពុទ្ធបរិស័ទ មេត្តាស្ងាត់បិទទូរស័ព្ទ
កុំមាត់គួរត្រងត្រាប់ លោកទេសប្រាប់ធម៌វិន័យ ។
សូមអារាធនា ! សូមអនុមោទនា ស្តាប់ព្រះធម៌ទេសនា !

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ៨៤_អារាធនាធម៌ (ទី៣)

( បទព្រហ្មគីតិ )

-សហម្បតីព្រហ្ម ចូលបង្គំព្រះភគវា
ក្រាបទូលអារាធនា ត្រាស់ធម្មាដោយករុណា ។
-កាលនោះព្រះពុទ្ធម្ចាស់ ទ្រង់ឃើញច្បាស់សត្វលោកា
សត្វខ្លះមានបញ្ញា ស្ដាប់ទេសនាអាចដឹងឆាប់ ។
-សត្វខ្លះមានអាល័យ គ្មាននិស្ស័យសែនយ៉ាកយ៉ាប់
ទោះបីបើបានស្ដាប់ មិនដឹងឆាប់នូវសច្ចៈ ។
-តែទ្រង់មានករុណា ត្រាស់គាថាយ៉ាងប្រចក្ស
ឲ្យសត្វបើកសោតៈ ស្ដាប់សច្ចធម៌ទេសនា ។
-នៅថ្ងៃ ១៥ កើត អាសាឍខ្នើតដើមវស្សា
កាលនោះព្រះសាស្ដា ត្រាស់ទេសនាដល់ឥសី ។
-គឺបញ្ចវគ្គីយ៍ ព្រះមុនីទ្រង់ឃ្នាតខ្ចី
ពន្យល់អត្ថសេចក្ដី ឲ្យឥសីឃើញធម្មា ។
-ឥឡូវខ្ញុំទាំងឡាយ សូមឱនកាយក្រាបវន្ទា
បញ្ចេញនូវសទ្ធា អារាធនាព្រះគុណម្ចាស់ ។
-សូមពោលធម៌វិន័យ ល្អប្រពៃដ៏ត្រចះ

ឲ្យយើងខ្ញុំបានច្បាស់ ក្នុងឱកាសពេលនេះហោង ។
សូមអារាធនា !!

ថ្ងៃ ០៨ កើត ខែបុស្ស ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

បញ្ជាក់ថា : ព្រះមានព្រះគាគ ទ្រង់យល់ព្រមដើម្បីនឹងសម្ដែងធម៌ហើយ ទ្រង់សម្ដែងជាបទគាថានេះនឹងសហម្បតិព្រហ្មថា :

**អបារុតា តេ អមតស្ស ទ្វារា យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ**
**វិហឹសសញ្ញី បគុណំ ន ភាសឹ ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។**

ទ្វារនៃព្រះនិព្វានទាំងនោះបើកហើយ សត្វទាំងឡាយណា មានសោតប្បសាទ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ ។ ម្នាលមហាព្រហ្ម តថាគតមានសេចក្ដីសម្គាល់ក្នុងការលំបាក បានជាមិនសម្ដែងធម៌ដ៏ឧត្ដម ដែលស្ទាត់ក្នុងសំណាក់មនុស្សទាំងឡាយ ។

ក្នុងអដ្ឋកថាព្រះវិន័យ ពន្យល់ថា :

ពីរបទថា **បរិវិតក្កោ ឧទបាទិ** សេចក្ដីថា សេចក្ដីរំពឹងនៃចិត្តនេះ ដែលព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់ប្រព្រឹត្តមកជាអាចិណ្ណៈ ( ប្រពៃណី) កើតឡើងដល់ព្រះមានព្រះភាគ លុះទ្រង់បានគង់ក្រោមម្លប់ដើមអជបាល-

និគ្រោធប៉ុណ្ណោះ ។ សួរថា ក៏ព្រោះហេតុអ្វីសេចក្តីរំពឹងនៃចិត្តនេះ ទើបកើតឡើងដល់ព្រះពុទ្ធគ្រប់ព្រះអង្គ ?

**ធម្មស្ស មហន្តភាវំ គរុភាវំ ភារិយភាវំ បច្ចវេក្ខណាយ ព្រហ្មុនា យាចិតេ ទេសេតុកាមតាយ ច :** ឆ្លើយថា "ព្រោះទ្រង់ពិចារណានូវភាវៈនៃព្រះធម៌ជាគុណធំ ជាគុណដ៏លើសលប់ ជារបស់ធ្ងន់ និងព្រោះទ្រង់ប្រាថ្នានឹងសម្តែងតាមពាក្យដែលព្រហ្មទូលអារាធនា" ។ មែនពិត ព្រះពុទ្ធទាំងឡាយ រមែងទ្រង់ជ្រាបថា កាលព្រះអង្គទ្រង់រំពឹងយ៉ាងនោះ ព្រហ្មនឹងមកទូលនិមន្តឱ្យសម្តែងធម៌ គ្រានោះ សត្វទាំងឡាយនឹងកើតសេចក្តីគោរពក្នុងធម៌ ព្រោះថា លោកសន្និវាសគោរពព្រហ្ម ។ សេចក្តីរំពឹងនេះ កើតឡើងព្រោះហេតុ ២ ប្រការនេះ ដោយប្រការដូច្នេះឯង ។

## ៨៥_សុខក្រោយស្តាប់ធម៌

១-សាធុ!សាធុ!ខ្ញុំបានភ្លឺច្បាស់ ដែលព្រះគុណម្ចាស់ជាអ្នកឈ្លាសវៃ
បានបើកបង្ហាញនូវធម៌វិន័យ ខ្ញុំបានយល់ន័យសន្តានជ្រះថ្លា ។
២-ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចគេប្រាប់ផ្លូវដ៏អស្ចារ្យ
ឱ្យបាត់វង្វេងក្នុងវដ្តសង្សារ តាំងក្នុងសម្មាបដិបត្តិប្រសើរ ។

៣-រសព្រះធម៌នេះពិតជាល្អល្អះ ឱ្យខ្ញុំយល់ច្បាស់ទៅតាមដំណើរ
មគ្គអង្គប្រាំបីជាផ្លូវប្រសើរ ញ៉ាំងសត្វអ្នកដើរឱ្យផុតចាកភ័យ ។
៤-អ្នកដែលប្រព្រឹត្តទានសីលភាវនា ឱ្យសម្រេចជាគុណបុណ្យបារមី
នេះជាកុសលនាំជនប្រុសស្រី ឆ្លងចាកភពបី មិនមានវិបរិត ។
៥-ព្រះពុទ្ធព្រះធម៌ព្រះសង្ឃបវរ ត្រៃរ័ត្ននេះល្អខ្ពង់ខ្ពស់ពេកពិត
រូបខ្ញុំសូមដល់អស់មួយជីវិត ខ្ញុំសូមប្រព្រឹត្តធម៌គួរដល់ធម៌ ។

ថ្ងៃ ០៥ រោច ខែ កត្តិក ព.ស. ២៥៥៦

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

នៅសម័យពុទ្ធកាល អ្នកដែលបានស្តាប់ធម៌ បានឃើញអរិយសច្ចធម៌ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបាច់ជឿស្តាប់ពាក្យបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដោយពាក្យថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ហើយនេះ ពីរោះណាស់ បុរសដែលផ្ងារឡើងនូវរបស់ដែលគេផ្កាប់ចុះ ឬបើកចេញនូវរបស់ដែលគេបិទបាំងទុក

ឬប្រាប់ផ្លូវដល់បុរសដែលវង្វេងផ្លូវ ឬទ្រោលបំភ្លឺនូវប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានចក្ខុនឹងឃើញរូបបានដោយងាយ មានឧបមាយ៉ាងណាមិញ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់ប្រកាសហើយដោយបរិយាយជាច្រើន ក៏មានឧបមេយ្យដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរលឹក សូមព្រះអង្គទ្រង់ជ្រាបនូវយើងខ្ញុំព្រះអង្គទាំងឡាយថាជាឧបាសក ដល់នូវទីរលឹកស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមទៅ” ។

## ៨៦_អានិសង្សនៃការស្តាប់ព្រះសទ្ធម្ម ៥ យ៉ាង

(សុត្តន្តបិដក ៤៥, ២៣៨)

**១_អស្សុតំ សុណាតិ** អ្នកស្តាប់តែងបានស្តាប់រឿងមិនទាន់បានស្តាប់

**២_សុតំ បរិយោទបេតិ** រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់ នឹងចូលចិត្តច្បាស់ឡើងបាន

**៣_កង្ខំ វិហនតិ** កំចាត់បង់សេចក្តីសង្ស័យចេញបាន

**៤_ទិដ្ឋឹ ឧជុំ ករោតិ** ធ្វើសេចក្តីឃើញឱ្យត្រង់

**៥_ចិត្តមស្ស បសីទតិ** ចិត្តអ្នកស្តាប់រមែងជ្រះថ្លា ។

## អានិសង្សស្តាប់ធម៌ ៥ យ៉ាង (កំណាព្យ)

-ព្រះធម៌ព្រះពុទ្ធទ្រង់ទេសនា ញ៉ាំងសព្វសត្តាឲ្យជាក់ច្បាស់
ដូចជាពន្លឺដ៏ត្រចះ គួររីករាយណាស់ណាម្ចាស់ថ្លៃ ។
-អ្នកស្តាប់ដោយល្អបានផលា មាន៥ប្រការប្រសើរក្រៃ
នាំបានសោយសុខជាកម្រៃ បានជាបច្ច័យរួចចាកទុក្ខ ។
-ទី១អ្នកស្តាប់តែងបានស្តាប់ រឿងមិនធ្លាប់ស្តាប់ជាប្រមុខ
ក៏បានចេះដឹងសន្សំទុក និស្ស័យទៅមុខប្រសើរណាស់ ។
-ទី២រឿងដែលធ្លាប់ស្តាប់ដែរ មិនយល់ស្រាប់តែបានជាក់ច្បាស់
ព្រោះស្តាប់រឿយៗឲ្យស្រឡះ យល់កាន់តែច្បាស់ធម៌បវរ ។
-ទី៣ កម្ចាត់ការសង្ស័យ ច្រើនឆ្នាំខែថ្ងៃជាបន្ត
អស់ការងឿងឆ្ងល់ភ្លឺស្វាងល្អ មានចិត្តអំណរពេកកន្លង ។
-ទី៤ ទិដ្ឋិក៏បានត្រង់ ឃើញតាមពុទ្ធអង្គឥតសៅហ្មង
ជឿកម្មជឿផលពិតតែម្តង គុណព្រះពុទ្ធផងដោយសទ្ធា ។
-ទី៥ អ្នកស្តាប់ធម៌ទេសនា មានចិត្តជ្រះថ្លារាល់វេលា
ព្រោះបានក្រេបរសព្រះធម្មា ដែលព្រះភគវាទ្រង់សម្តែង។
-អ្នកអើយដឹងចុះនេះផលា ស្តាប់ធម៌ទេសនាប្រាកដស្តែង
តាមកាលវេលានោះៗឯង កម្មនេះតាក់តែងសុខដល់អ្នក ។

-បញ្ចេញសទ្ធាដូចជាដៃ ទទួលធម៌ថ្លៃកុំស្ទើរស្ទាក់
ប្រព្រឹត្តតាមធម៌ឲ្យជាក់លាក់ នឹងនាំរូបអ្នកបានក្សេមក្សាន្ត ។

ថ្ងៃ ០៥ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៨៧_ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធាន

**១_ន សក្កច្ចំ ធម្មំ សុណន្តិ** (មិនស្តាប់ធម៌ដោយគោរព)

**២_ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ** (មិនរៀនធម៌ដោយគោរព)

**៣_ន សក្កច្ចំ ធម្មំ ធារេន្តិ** (មិនទ្រទ្រង់ (ចាំទុក) នូវធម៌ដោយគោរព)

**៤_ន សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** (មិនពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយ ដោយគោរព)

**៥_ន សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ** (ដឹងអត្ថ ដឹងធម៌ហើយ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ ដោយគោរព) ។

# ព្រះសទ្ធម្មសាបសូន្យដោយហេតុ ៥ យ៉ាង

១-រីព្រះសទ្ធម្មពុទ្ធសាសនា នៃព្រះសាស្ដាព្រះពុទ្ធម្ចាស់
ដែលមានលម្អដ៏ត្រចះ បរិបូរមិនខ្វះអត្ថព្យញ្ជនា ។
២-តែត្រូវសាបសូន្យព្រោះបរិស័ទ មិនបានប្រតិបត្តិដោយសទ្ធា
គោរពកោតក្រែងដោយហទយា បំពានបំពារឥតស្គាល់អ្វី ។
៣-មួយមិនគោរពដោយការស្ដាប់ ព្រះធម៌ជាច្បាប់ដែលជិនស្រី
ទ្រង់ត្រាស់សម្ដែងទោះវែងខ្លី សាវ័កប្រុសស្រីមិនកោតក្រែង។
៤-ពីរមិនគោរពដោយការរៀន ធម៌ព្រះទ្រង់ញាណបានតាក់តែង
បញ្ញត្តិទូន្មានគ្រប់កន្លែង មិនរៀននោះឯងដោយប្រពៃ ។
៥-បីមិនគោរពដោយទ្រទ្រង់ ចាំឲ្យគង់វង្សធម៌វិន័យ
ឡេះឡោះលេងសើចចិត្តមោះមៃ ឥតគិតលកលៃចងចាំទុក។
៦-បួនមិនគោរពពិចារណា នូវព្រះធម៌អាថ៌ជាប្រមុខ
ដែលខ្លួនបានចាំសន្សំទុក ពីនេះទៅមុខអត្ថយ៉ាងណា ។
៧-ប្រាំមិនគោរពដោយប្រតិបត្តិ តាមបរិយត្តិត្រៃសិក្ខា
ដែលបានទ្រទ្រង់ពិចារណា ដោយចិត្តជ្រះថ្លាដ៏បវរ ។
៨-ហេតុនេះបរិស័ទគប្បីដឹង ពិនិត្យសម្លឹងឲ្យល្អិតល្អ
នូវហេតុសាបសូន្យធម៌បវរ ពុទ្ធសាសន៍ដ៏ល្អកម្រមាន ។
៩-គួរតែគោរពចិត្តកោតក្រែង តាមព្រះសម្ដែងចិត្តអាចហាន
ប្រព្រឹត្តតាមធម៌មិនបំពាន ដែលទ្រង់ទូន្មានដោយសទ្ធា ។

១០-មានគុណតម្លៃប្រសើរណាស់ ឲ្យបានត្រចះគ្រប់វេលា
ញុំាងខ្លួននិងធម៌ព្រះភគវា ផ្សាយពេញពសុធាយូរអង្វែង ។

ថ្ងៃ ០៤ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៨៨-ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម ឋិតថេរ មិនសាបសូន្យ មិនអន្តរធាន

**១.សក្កច្ចំ ធម្មំ សុណន្តិ** (ស្តាប់ធម៌ដោយគោរព)

**២.សក្កច្ចំ ធម្មំ បរិយាបុណន្តិ** (រៀនធម៌ដោយគោរព)

**៣.សក្កច្ចំ ធម្មំ ធារេន្តិ** (ទ្រទ្រង់ធម៌ដោយគោរព)

**៤.សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** (ពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយ ដោយគោរព)

**៥.សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ** (ដឹងអត្ថ ដឹងធម៌ហើយ ប្រតិបត្តិធម៌ តាមសមគួរដល់ធម៌ដោយគោរព) ។

### ព្រះសទ្ធម្មឋិតថេរដោយហេតុ ៥ យ៉ាង

១-រីព្រះសទ្ធម្មដ៏ថ្កូរថ្កង់ នៃព្រះពុទ្ធអង្គដ៏អស្ចារ្យ
ទ្រង់ត្រាស់ទូន្មានដល់សត្តា ដោយធម៌ទេសនាល្អបវរ ។

២-ព្រះធម៌ទាំងនោះអាចឋិតនៅ យូរអង្វែងទៅជាបន្ត
ព្រោះពុទ្ធបរិស័ទចិត្តស្មោះសរ គោរពដោយល្អប្រឹងឃ្នាតខ្មី ។
៣-មួយចេះគោរពដោយការស្តាប់ ព្រះធម៌ជាច្បាប់ដែលជិនស្រី
ទ្រង់ត្រាស់សម្តែងទោះវែងខ្លី សាវ័កប្រុសស្រីចេះកោតក្រែង។
៤-ពីរចេះគោរពដោយការរៀន ធម៌ព្រះទ្រង់ញាណបានតាក់តែង
បញ្ញត្តិទូន្មានគ្រប់កន្លែង រៀនសូត្រនោះឯងដោយប្រពៃ ។
៥-បីចេះគោរពដោយទ្រទ្រង់ ចាំឲ្យគង់វង្សធម៌វិន័យ
គ្មានការលេងសើចឥតមោះមៃ ចិត្តគិតលកលៃចងចាំទុក។
៦-បួនចេះគោរពពិចារណា នូវព្រះធម៌អាថ៌ជាប្រមុខ
ដែលខ្លួនបានចាំសន្សំទុក ពីនេះទៅមុខអត្ថយ៉ាងណា ។
៧-ប្រាំចេះគោរពដោយប្រតិបត្តិ តាមបរិយត្តិត្រៃសិក្ខា
ដែលបានទ្រទ្រង់ពិចារណា ដោយចិត្តជ្រះថ្លាដ៏បវរ ។
៨-ហេតុនេះបរិស័ទគប្បីដឹង ពិនិត្យសម្លឹងឲ្យល្អិតល្អ
នូវហេតុឋិតថេរធម៌បវរ ពុទ្ធសាសន៍ដ៏ល្អកម្រមាន ។
៩-គួរតែគោរពចិត្តកោតក្រែង តាមព្រះសម្តែងចិត្តអាចហាន
ប្រព្រឹត្តតាមធម៌មិនបំពាន ដែលទ្រង់ទូន្មានដោយសទ្ធា ។
១០-មានគុណតម្លៃប្រសើរណាស់ ឲ្យបានត្រចះគ្រប់វេលា
ញុំាងខ្លួននិងធម៌ព្រះភគវា ផ្សាយពេញពសុធាយូរអង្វែង ។

ថ្ងៃ ០៤ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួងសុវណ្ណ

# ៨៩-ចិត្តអើយចិត្តនឹក

១-ចិត្តអើយចិត្តនឹក ទោះល្ងាចយប់ព្រឹក នឹកគ្មានពេលល្ហែ
ចង់ជួបព្រះពុទ្ធ ព្រះធម៌ផងដែរ ធ្វើម្ដេចបានក្បែរ
បានគាល់បម្រើ ។

២-ខ្ញុំនឹកព្រះសង្ឃ ជាបុត្រព្រះអង្គ សាវ័កប្រសើរ
លោកប្រព្រឹត្តល្អ ទៅតាមដំណើរ មគ្គដ៏ប្រសើរ
ជាផ្លូវដ៏ត្រង់ ។

៣-នឹកគ្រូអាចារ្យ មាតាបិតា មានចិត្តផូរផង់
លោកមានគុណធម៌ ប្រកបដោយអង្គ ប្រណិតផ្ចិតផ្ចង់
គួរឱ្យគោរព ។

៤-ចិត្តខ្ញុំសែននឹក ថែមទាំងរលឹក មិនថាថ្ងៃយប់
លោកមានគុណធ្ងន់ តែងបានជាម្លប់ ឱ្យខ្ញុំបានឈប់
ជ្រកដោយសុខសាន្ត ។

និគ្រោធវ័ន ថ្ងៃ ០៥រោច ខែកត្តិក ព.ស.២៥៥៦

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ៩០-សីលគុណ

១-សីលពិតមានគុណ ប្រសើរពេកពន់ យើងគួររក្សា
គប្បីប្រព្រឹត្ត ដោយឆន្ទតា និងការឧស្សាហ៍
កុំបីខានឡើយ ។
២-សីលគ្រឿងលំអ ជួយឱ្យបានល្អ អ្នកកុំកន្តើយ
កុំធ្វើលែនលន បណ្តែតបណ្តោយ គុណសីលនេះហើយ
ជាអលង្ការ ។
៣-សីលដ៏ត្រជាក់ ទោះបីលោកអ្នក ទៅដល់ទីណា
សីលផ្តល់ក្តីសុខ មិនឱ្យក្តៅផ្សា ត្រជាក់កាយា
និងចិត្តផងដែរ ។
៤-សីលមានលក្ខណៈ ទ្រទ្រង់រូបអ្នក ដ៏ខ្លាំងពូកែ
ម្យ៉ាងរួបរួមទុក កុសលផងដែរ ហេតុនេះត្រូវតែ
ខំរក្សាសីល ។
៥-សូម្បីធ្វើទាន ប្រសិនអ្នកមាន ចិត្តមិនខូចខិល
ពិតមានផលច្រើន ព្រោះអាស្រ័យសីល ចូលទៅផ្តាច់ផ្តិល
មន្ទិលទោសា ។

៦-សីលល្អប្រពៃ សមាធិនោះន័យ ប្រសើរថ្លៃថ្លា
ឡើងកាន់ត្រៃលក្ខណ៍ លើកវិបស្សនា បញ្ញាចាស់ក្លា
ត្រាស់ដឹងសច្ចៈ ។

និគ្រោធវ័ន ថ្ងៃ ០៦កើត ខែចែត្រ ព.ស.២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភ.ស.វ.

## ៩១-គុណសីលដ៏ល្អ

( បទពាក្យ ៨ )

១-គុណសីលដ៏ល្អមាន៥ ប្រការ តាមព្រះសាស្តាទ្រង់ត្រាស់សម្តែង
ប្រសើរខ្លាំងណាស់គួរយើងតាក់តែង គោរពកោតក្រែងផ្ចិតផ្ចង់ឱ្យស្អាត។
២-ទី១ មានភោគសម្បទច្រើន ទ្រព្យតែងកើតកើនព្រោះមិនប្រមាទ
មិនសម្លាប់សត្វជាដើមដាច់ខាត ខំប្រឹងសង្វាតរស់ដោយសប្បាយ។
៣-ទី២ មានកិត្តិស័ព្ទពីរោះ ផ្សាយមិនចំពោះក្នុងទីទាំងឡាយ
សូម្បីប្រាសខ្យល់តែងព្រួសខ្សាយ ទៅកាន់ទីឆ្ងាយឥតមានទើសទាក់ ។
៤-ទី៣ ចូលទៅកាន់បរិស័ទណា មានភាពក្លៀវក្លាដោយការជឿជាក់
ឥតមានអឹមអៀនតែងតែចេញភក្ត្រ ដោយសារខ្លួនអ្នកមានគុណសីលា។
៥-ទី៤ ស្លាប់មិនវង្វេងស្មារតី មិនបានឃើញអ្វីគួរខ្លាចឡើយណា
គ្មានការតក់ស្លុតភ័យអន្ទះសា ស្លាប់តាមធម្មតាត្រាច់ទៅតាមកម្ម ។

៦-ទី៥ ក្រោយពីបែកធ្លាយកាយា កើតមនុស្សទេព្តាសោយសុខប្រចាំ
បានសម្បត្តិទិព្វច្រើនសែនលានឆ្នាំ ដូច្នេះត្រូវចាំរក្សាសីលា ។
៧-គុណសីលល្អពិតនៅមានច្រើនទៀត ដែលព្រះលោកនាថទ្រង់ត្រាស់ទេសនា
សីលជាគ្រឿងលាបជាអលង្ការ សីលល្អអស្ចារ្យបានជាទីពឹង ។
៨-សីលគឺជាបាទជាគ្រឿងទ្រទ្រង់ មិនឱ្យលិចលង់ឱ្យបាននឹងធឹង
ឱ្យចិត្តតាំងមាំជាទីពំនឹង បានជាទីពឹងដល់វិបស្សនា ។
៩-គុណសីលបវរល្អពិតមែនហើយ ប្រឹងទៅអ្នកអើយដោយការឧស្សាហ៍
សមាទានឱ្យជាប់ដោយចិត្តចេតនា សីលដ៏ថ្លៃថ្លានាំឱ្យបរិសុទ្ធ ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ០៨រោច ខែមិគសិរ ព.ស.២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

នៅក្នុងវិនយបិដកមហាវគ្គ ទុតិយភាគ ៧ ទំព័រ ៣០៥ ព្រះមានព្រះភាគ ទ្រង់ត្រាស់អានិសង្សសីលមាន ៥ ប្រការ ។

១-បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្ដីមិនប្រមាទ ។

២-តែងមានកិត្តិស័ព្ទដ៏ពីរោះឮខ្ចរខ្ចាយទៅ ។

៣-ចូលទៅកាន់បរិស័ទណា ទោះបីជាខត្តិយបរិស័ទក្ដី ជាព្រាហ្មណបរិស័ទក្ដី ជាគហបតិបរិស័ទក្ដី ជាសមណបរិស័ទក្ដី ក៏ក្លៀវក្លាមិនឱនមុខចុះ គឺថាមិនក្រអឹមក្រអៀន ហើយដើរចូលទៅ ។

៤-លុះវេលាទៀបស្លាប់ ក៏មិនវង្វេងស្មារតីឡើយ

៥-លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក ។

* ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖

ធម្មោ រហទោ អកទ្ទមោ បាបំ សេទមលន្តិ វុច្ចតិ
សីលញ្ច នវំ វិលេបនំ តស្ស គន្ធោ ន កទាចិ ឆិជ្ជតិ ។

ធម៌ទុកជាស្រះមិនមានភក់ បាបលោកពោលថាជាញើស និងក្អែល សីលទុកជាគ្រឿងលាបដ៏ថ្មី ទាំងក្លិនរបស់សីលនោះ មិនដាច់ក្នុងកាលណាម្តង ។

* ក្នុងសីលវត្ថុគាថា លោកពោលថា ៖

សីលមេវិធ សិក្ខេថ អស្មឹ លោកេ សុសិក្ខិតំ
សីលំ ហិ សព្វសម្បត្តឹ ឧបនាមេតិ សេវិតំ ។

បុគ្គលគប្បីសិក្សានូវសីល ឲ្យជាសីលដែលខ្លួនសិក្សាល្អហើយក្នុងលោកនេះ ព្រោះថា សីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។

សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ
បសំសំ វិត្តិលាភញ្ច បេច្ច សគ្គេ បមោទនំ ។

ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាង គឺ សេចក្តីសរសើរ ១ ការបាននូវទ្រព្យ ១ ការលះលោកនេះហើយ រីករាយក្នុងស្ថានសួគ៌ ១ គួររក្សាសីល ។

* **សីលាលង្ការសទិសោ អលង្ការោ នត្ថិ:** គ្រឿងអលង្ការ ប្រាកដដូចជាគ្រឿងអលង្ការគឺសីល មិនមាន ។

* **សីលបុប្ផសទិសំ បុប្ផំ នត្ថិ** ៈ ផ្កាឈើប្រាកដដូចជា ផ្កាឈើ គឺសីល មិនមាន ។

* **សីលគន្ធសទិសោ គន្ធោ នត្ថិ** ៈ ក្លិនប្រាកដដូចជាក្លិន គឺសីល មិនមាន ។

# ៩២-សីលមានគុណពិត

-ត្រូវរក្សាសីល ដើម្បីផ្តាច់ផ្តិល ចាកអកុសល
ជម្រះកាយចិត្ត លះកាត់កង្វល់ សន្សំកុសល
ទុកក្នុងសន្តាន។
-រក្សាសីលា ដោយចិត្តចេតនា ធ្វើកុំខកខាន
ឧបោសថសីល ដ៏ប្រសើរថ្កាន ត្រូវអធិដ្ឋាន
ទៅតាមប្រក្រតី។
-សីលមានគុណពិត បើអ្នកប្រព្រឹត្ត នឹងបានសួស្តី
ចម្រើនភោគៈ សម្បត្តិលោកីយ៍ ញ៉ាំងជនប្រុសស្រី

ផុតការស្រេកឃ្លាន។
-កិត្តិយសកេរ្តិ៍ឈ្មោះ និងភាពខ្ពង់ខ្ពស់ ក្លៀវក្លាអាចហ៊ាន
ទាំងមានស្មារតី ឥតមានអឹមអៀន នេះមកពីមាន
នូវគុណសីលា។
-លុះបែកធ្លាយកាយ មិនទៅអបាយ កើតជាទេវតា
សោយសម្បត្តិទិព្វ តាមចិត្តប្រាថ្នា រួចចាកទុក្ខា
រហូតនិព្វាន ។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយសុវណ្ណជោតោ ភួង-សុវណ្ណ

## ៩៣-ឧបោសថសីលល្អវិសេសណាស់

ឧបោសថសីលល្អវិសេសណាស់ បរិស័ទក្មេងចាស់គប្បីដឹងថា
មានគុណដ៏ធំប្រសើរអស្ចារ្យ ដែលព្រះសាស្តាទ្រង់បញ្ញត្តហើយ។
រក្សាឲ្យជាប់តាមពេលវេលា ដោយចិត្តសទ្ធាកុំបីកន្តើយ
លះបង់តណ្ហាមិននៅកៀកកើយ កុសលនេះហើយនាំឲ្យបានក្សាន្ត។
នាំបានសម្បត្តិទាំង ៣ ប្រការ មនុស្សទេវតានិព្វានមិនខាន
ទទួលក្តីសុខសិរីថ្កើងថ្កាន សម្រេចសម្រាន្តគ្រប់ឥរិយាបថ ។
ព្រោះហេតុដូច្នោះគប្បីប្រឹងប្រែង សីលានេះឯងមានគុណប្រាកដ
ធ្វើឲ្យខ្ជាប់ខ្ជួនតាមកាលកំណត់ ឲ្យបានហ្មត់ចត់មានផលគាប់ហោង។

ព្រឹកថ្ងៃ ១០ កើត ខែជេស្ឋ ព.ស.២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ៩៤-អ្នកមានសទ្ធាជាដើម

១- អ្នកមានសទ្ធា ព្រមទាំងចាគា សុតៈបញ្ញា
តាំងក្នុងសីលគុណ បរិសុទ្ធថ្លៃថ្លា ឋិតក្នុងសម្មា-
ទិដ្ឋិដ៏ល្អ ។

២- ប្រាជ្ញាយល់ត្រូវ ដូចអ្នកនាំផ្លូវ ប្រសើរបវរ
អង្គមគ្គដទៃ ពិតជាបានល្អ ឋិតក្នុងធមិស
ខ្មាសខ្មើមបាបធមិ ។

៣- សីលទុកជាបាត ចិត្តក៏ថ្លាស្អាត បញ្ញាតាំងគភិ
ស្មារតីខ្ជាប់ខ្ជួន ឥតមានញាប់ញ័រ នៅក្នុងលោកធមិ
ចិត្តអស់កង្វល់ ។

៤- ប្រឹងប្រែងព្យាយាម គ្មានការទាក់ទាម ដោយការតម្កល់
ខ្លួនឱ្យប្រពៃ នៅក្នុងកុសល នឹងសម្រេចផល
ជាទីគាប់ចិត្ត ។

៥- ដឹងដូច្នេះហើយ គួរណាស់អ្នកអើយ ត្រូវសាងសុចរិត
មិនគួរបង្អង់ ខំតម្រង់ចិត្ត ឱ្យបានបង្ខិត
ចូលដល់ក្ដីស្ងប់ ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ០៧រោច ខែមិគសិរ ព.ស.២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៩៥-រស់ដោយបញ្ញា

១-ជីវិតសង្ខារ នៃសត្វលោកា ពិតជាមិនទៀង
ជរាគ្រាំគ្រា មិនអាចចៀសវាង ឯស្លាប់នោះទៀង
មិនវៀរសត្វណា ។
២-កើតចាស់ឈឺស្លាប់ នេះឯងជាច្បាប់ មានតាមធម្មតា
បើអវិជ្ជា ព្រមទាំងតណ្ហា នៅដរាបណា
ត្រូវកើតចាស់ស្លាប់ ។
៣-ព្រោះហេតុដូច្នេះ បើគ្មានតម្រិះ បញ្ញាអួអាប់
ត្រាច់ក្នុងវដ្ដៈ ពិតជាយ៉ាកយ៉ាប់ កើតចាស់ឈឺស្លាប់
មិនងាយរួចខ្លួន ។
៤-បើមានបញ្ញា បំពេញបុញ្ញា ឱ្យបានខ្ជាប់ខ្ជួន
អប់រំទានសីល ភាវនាមាំមួន នឹងអាចដោះខ្លួន
ផុតពីភពបី ។

និគ្រោធវ័ន ថ្ងៃ ០៩រោច ខែកត្ដិក ព.ស.២៥៥៦

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

**បញ្ញាជីវឹ ជីវិតមាហុ សេដ្ឋំ** ៖ បណ្ឌិតហៅជីវិតនៃអ្នករស់នៅដោយបញ្ញា ថាជាជីវិតដ៏ប្រសើរ ។

# ៩៦_ទសបុញ្ញកិរិយាវត្ថុ

១-ទសបុញ្ញកិរិយា- វត្ថុថ្លៃថ្លាគប្បីធ្វើ
ឱ្យបានហ្មត់ចត់កុំស្ទាក់ស្ទើរ ព្រោះជាអំពើនាំសុខា ។
២-ទានសីលភាវនា ជាកុសល គួរយើងតម្កល់ចិត្តចេតនា
អប់រំចម្រើនដោយឧស្សាហ៍ ព្រមដោយបញ្ញានិងស្មារតី ។
៣-ឯការគោរព ការបម្រើ ទៅតាមដំណើរដ៏ឃ្មាតខ្មី
តាមពុទ្ធឱវាទព្រះជិនស្រី បម្រើកែវបីត្រៃរតនា ។
៤-បត្តិទាន អនុមោទនា មានចិត្តសទ្ធាដ៏ឧឡារ
ឥតមានកំណាញ់មិនឥស្សា មានតែមេត្តាដល់សព្វសត្វ ។
៥-ស្ដាប់ព្រះសទ្ធម្មដោយគោរព ទោះព្រឹកថ្ងៃយប់ប្រឹងលះកាត់
កិច្ចការរវល់ច្រើនពេកក្ដាត់ ចូលកាន់ទីស្ងាត់មិនចរចា ។
៦-សម្ដែងធម្មាតាមចេះដឹង ដោយមិនសម្លឹងលាភឡើយណា
ព្រោះអនុគ្រោះនិងមេត្តា ឱ្យសត្វលោកាបានសុខសាន្ត ។
៧-តម្រង់ទិដ្ឋិឱ្យបានត្រង់ តាមព្រះពុទ្ធអង្គល្អថ្កើងថ្កាន
ប្រាជ្ញាយល់ត្រូវ ជាកល្យាណ ធម៌នេះពិតបានជាឧបការ ។
៨-សម្មាទិដ្ឋិជាប្រមុខ ស្ទុះទៅខាងមុខដ៏ហានក្លា
គួរមានជានិច្ចរាល់កិច្ចការ ត្រូវមានបញ្ញាយល់ត្រូវពិត ។

៩-កុសលទាំងឡាយគួរចម្រើន ឱ្យបានកើតកើនប្រឹងប្រព្រឹត្ត
សន្សំរឿយៗដោយពេញចិត្ត នាំបានសុខពិតសួគ៌និព្វាន ។
ថ្ងៃ ៣ រោច ខែស្រពណ៍ ព.ស.២៥៥៧ ដោយភិក្ខុ ភួង-សុវណ្ណ

## ៩៧-ល្អអើយល្អណាស់

( បទពាក្យ ៧ )

១-ល្អកាយវាចាល្អទាំងចិត្ត ល្អព្រោះសុចរិតមានចរិយា
ល្អនេះល្អពិតដ៏ថ្លៃថ្លា ទោះមនុស្សទេវតាតែងស្រឡាញ់ ។
២-ល្អចេះខ្វល់ខ្វាយរាល់កិច្ចការ មាតាបិតាមិត្រសម្លាញ់
ល្អចេះលះបង់មិនកំណាញ់ មិនឃើញតែអញចេះជួយគ្នា ។
៣-ល្អណាស់ល្អព្រោះមានចំណេះ ល្អមានតម្រិះផងនានា
ល្អចេះសិក្សារកវិជ្ជា ល្អខំម្ចីម្នាស្វែងរកទ្រព្យ ។
៤-ល្អចេះប្រើប្រាស់ចេះចាត់ចែង ល្អចេះសម្តែងការគួរគាប់
ល្អខំធ្វើបុណ្យទុកជាទ្រព្យ បុណ្យនេះនឹងជាប់ទៅបរលោក ។
៥-ល្អអើយល្អណាស់ចេះដឹងគុណ ប្រសើរពេកពន់នឹងមានជោគ
ចម្រើនកុសលឆ្លងចាកលោក នេះហៅមានជោគមានជម្នះ ។
វត្តវិសុទ្ធិមគ្គ ថ្ងៃ០១រោច ខែមិគសិរ ព.ស.២៥៥៨
ដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

# ៩៨-ល្អអ្វីល្អម្ល៉េះ

១-ល្អអ្វីល្អម្ល៉េះល្អពេកពន់ ល្អត្រង់មានគុណមានសីលា
ល្អមានសទ្ធាក្នុងសាសនា នេះឧបមាដូចជាដៃ ។
២-ល្អអ្វីល្អម្ល៉េះមានចាគា ល្អមានចិត្តជាចេះកែច្នៃ
លះបង់ទ្រព្យធនមានតម្លៃ ជានិច្ចរាល់ថ្ងៃធ្វើជាទាន ។
៣-ល្អអ្វីល្អម្ល៉េះមានសុតៈ យកចិត្តទុកដាក់ខំប្រឹងរៀន
មិនថាយប់ថ្ងៃឬស្រែកឃ្លាន ចំណេះនឹងមានប្រសើរណាស់ ។
៤-ល្អអ្វីល្អម្ល៉េះមានបញ្ញា ស្គាល់គ្រប់កិច្ចការដោយដឹងច្បាស់
យល់ហេតុយល់ផលយ៉ាងត្រចះ ឃើញប្រាកដណាស់គ្មានអ្វីបាំង ។
៥-ល្អអ្វីល្អម្ល៉េះល្អយ៉ាងនេះ បានជាជំនិះមានកម្លាំង
ទៅដល់ទីណាអ្នកនឹងខ្លាំង នេះជាកម្លាំងដ៏អស្ចារ្យ ។
៦-ល្អអ្វីល្អម្ល៉េះល្អប្រាកដ ល្អចេះអំណត់មានមេត្តា
ប្រើអ្វីគ្រប់យ៉ាងដោយបញ្ញា អាចជួយអាត្មាផុតទុក្ខភ័យ ។
៧-ល្អអ្វីល្អម្ល៉េះមានករុណា ជួយសត្វលោកាឆ្លងភពបី
ចិត្តអនុគ្រោះប្រោសប្រណី ដោយការពោលស្តីព្រះធម្មា ។
៨-ល្អអ្វីល្អម្ល៉េះត្រៃរតនៈ ខ្ញុំសូមស្មោះស្មគ្រក្រាបវន្ទា

ថ្វាយខ្លួនចំពោះព្រះភគវា ដើរតាមមាគ៌ាពុទ្ធបិតា ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ០៧រោច ខែមិគសិរ ព.ស.២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ៩៩-ល្អព្រោះប្រតិបត្តិ

១-ស្តាប់ច្រើនរៀនច្រើនកើនបញ្ញា នាំបានភ្លឺថ្លាក្នុងជីវិត
ត្រូវចេះគ្នេរគ្នាន់ដោយរិះគិត នឹងបានល្អពិតគ្មានមោះមៃ ។
២-គប្បីគ្រប់គ្រងកាយវាចា មានចិត្តសម្មាដ៏ប្រពៃ
សិក្សាឱ្យយល់ធម៌វិន័យ ហើយត្រូវលកលៃប្រតិបត្តិ ។
៣-បើគ្រាន់តែចេះគ្រាន់តែដឹង តែមិនខំប្រឹងប្រុងប្រយ័ត្ន
សង្រួមឱ្យល្អតាមបរិយត្តិ គ្មានការប្រតិបត្តិមានអ្វីល្អ ។
៤-ព្រោះហេតុដូច្នោះត្រូវទូន្មាន តាមការស្តាប់រៀនដោយបវរ
តាមធម៌វិន័យចិត្តស្មោះសរ ធ្វើឱ្យបានល្អជាទម្លាប់ ។
៥-កុំបីភ្លេចខ្លួនក្នុងកាមា លះបង់តណ្ហាមិនឱ្យជាប់
ដោយកុសលកម្មប្រសើរគាប់ អ្នកនឹងមានភ័ព្វបានក្សេមក្សាន្ត ។

ថ្ងៃ ០៥ កើត ខែវិសាខ ពុទ្ធសករាជ ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១០០_ការចេះស្គាល់ខ្លួន

-ការចេះស្គាល់ខ្លួនពិតជាសំខាន់ លះក្តីប្រកាន់តិចច្រើនដោយហោច
លោភៈទោសៈមោហៈជាខ្មោច មានក្លិនអសោចគប្បីវៀរបង់ ។
-សេចក្តីត្រិះរិះជាអកុសល វាតែងផុសផុលឱ្យកើតចំណង់
ទៅក្នុងកាមគុណចិត្តមិនធូរផង់ ត្រូវតែផ្តាច់បង់ឱ្យបានដាច់ខាត ។
-តាំងក្នុងកម្មដ្ឋានចម្រើនភាវនា ច្បាំងកិលេសមារតែងតែនាំអាទិ
ខំជម្រះចិត្តឱ្យបានល្អស្អាត ទៅតាមឱវាទនៃព្រះពុទ្ធម្ចាស់ ។
-បើអ្នកធ្វើបានអ្នកនឹងបរិសុទ្ធ ល្អប្រសើរផុតល្អក្រៃលែងណាស់
យល់ក្នុងសច្ចៈដោយបានដឹងច្បាស់ ឱព្រះគុណម្ចាស់ខ្ញុំសូមវន្ទា ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ០៧រោច ខែមិគសិរ ព.ស.២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១០១_ស្គាល់ពីធម្មជាតិ

១-មេឃខែវស្សា មិនសូវភ្លឺថ្លា ច្រើនតែអួអាប់
ពពកក្រាស់ឃ្មឹក ណែនណាន់តាន់តាប់ ដូចប្រកាសប្រាប់
ថាភ្លៀងឥឡូវ ។
២-មេឃខែរំហើយ ខ្យល់បក់មិនស្បើយ ត្រជាក់ពេកកូវ

សន្ទើមជោកជាំ ច្រើនណាស់ពេកទៅ ខុសពីរដូវ
ដទៃទនោះឯង ។
៣-ឯមេឃខែប្រាំង ពិតជាក្តៅខ្លាំង ក្តៅស្ទើរបែកផ្សេង
ធម្មជាតិក្រៀមស្វិត ដីបែកក្រហែង ហេតុដូច្នេះឯង
ងាប់ស្រូវងាប់ត្រី ។
៤-រដូវប្រួលប្រែ យើងមិនអាចកែ នេះជាប្រក្រតី
ជាបែបធម្មជាតិ កុំកើតទុក្ខអី ត្រូវមានស្មារតី
ស្គាល់ពីធម្មជាតិ ។

ថ្ងៃ ០៩ រោច ខែកត្តិក ព.ស. ២៥៥៦
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ធម្មជាតិប្រែប្រួល ព្រោះកិលេសរបស់មនុស្ស ។ គួរនាំគ្នាប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ។ ធម៌តែងរក្សាអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ តែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្ស ក្នុងធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌មិនដែលទៅកាន់ទុគ្គតិឡើយ ។

# ១០២_មេឃភ្លៀងមិនស្រាក់

១-មេឃភ្លៀងមិនស្រាក ប៉ប៉ុកប៉ប៉ាក់ ទឹកដក់ពេញដី
សើមស្បង់ចីវរ ហាលមិនស្ងួតអី ល្ងាចយប់ព្រឹកថ្ងៃ
នៅសើមដដែល ។

២-មេឃភ្លៀងរលឹម ងងឹតទោរទឹម ទឹកធ្លាក់ផែល១
ខ្យល់បក់បោកផាត់ រសាត់តោលតែល នៅភ្លៀងដដែល
ដូចមិនទំនេរ ។

៣-ទឹកក៏ជោរជន់ ជំនោរជំនន់ ពេញបឹងទន្លេ
ឡើងជាលំដាប់ តាមដងទន្លេ ឥតមានស្រកទេ
នាំឱ្យភ័យព្រួយ ។

៤-ខ្លាចលិចដំណាំ ដែលខិតខំដាំ នាំឱ្យរលួយ
ខ្លាចទឹកលិចផ្ទះ បានអ្នកណាជួយ ចិត្តគិតនឹកព្រួយ
ប្រយោជន៍នៃខ្លួន ។

៥-ឱណាជីវិត មិនឃើញសុខពិត ឋិតថេរមាំមួន
តិចតួចដោយហោច ថាឱ្យខ្ជាប់ខ្លួន នេះហើយមាសស្ងួន
ធម៌អនត្តា ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១០៣~សិក្សាពីការញញឹម

ពាក្យថា "ញញឹម" គឺសើចបិទមាត់មិនចេញសំឡេង : គ្រាន់តែញញឹម ។ ប្រើជាគុណ ក៏បាន : មុខញញឹម ស្រស់ញញឹម ។

ធម្មតាកាលដែលបុគ្គលអាចញញឹមបាន ទាល់តែមានហេតុ ។ ដូចព្រះសម្មាសម្ពុទ្ធ ព្រះអរហន្ត ឬក៏បុថុជ្ជនទាំងឡាយ ។ គ្រាន់តែការញញឹមនោះមានលក្ខណៈផ្សេងគ្នា ញញឹមមានហេតុ តែមិនប្រកបដោយកិលេស ឬប្រកបដោយកិលេសរបស់បុថុជ្ជនទាំងឡាយ ។ ញញឹមបញ្ជាក់ពីហេតុ របស់ព្រះអរហន្ត, ញញឹមបង្ហាញពីមេត្រី ញញឹមទទួលសេចក្ដីល្អ ញញឹមបវរឱ្យអភ័យ ញញឹមបូជា ញញឹមសង្គ្រោះគ្នា ញញឹមបញ្ចើច ញញឹមបង្ហាញពីចិត្តស្មោះជាដើម ។

## ១០៤~ញញឹមយកជ័យលើកិលេស

( បទផ្កាឈូករីក ពាក្យ ៧ )

១-ញញឹមទទួលយកការពិត ញញឹមប្រព្រឹត្តព្រះធម្មា
ញញឹមជានិច្ចគ្រប់វេលា ញញឹមចិត្តជាសុខក្សេមក្សាន្ត ។
២-ញញឹមដោយចិត្តដ៏ជ្រះថ្លា ញញឹមដូចផ្កាពិតកល្យាណ
ញញឹមដោយស្មោះពីសន្ដាន ញញឹមនេះបានសុខសួស្ដី ។

៣-ញញឹមមិនពិតមានអ្វីសម ញញឹមដោយខំគ្មានមេត្រី
ញញឹមបញ្ឆោតជនប្រុសស្រី ញញឹមធ្វើអ្វីគ្មានខ្លឹមសារ ។
៤-ញញឹមមិនស្មោះពីដួងចិត្ត ញញឹមនេះឋិតជិតមុសា
ញញឹមមិនស្រស់តាមធម្មតា ញញឹមឥតការណ៍ផ្កាសទទេ ។
៥-ញញឹមឱ្យពិតតាមសភាព ញញឹមយកលាភទាំងយើងគេ
ញញឹមប្រិមប្រិយដូចបំពេ ញញឹមមាសមេពិតមានន័យ ។
៦-ញញឹមទទួលសេចក្ដីល្អ ញញឹមបវរឱ្យអភ័យ
ញញឹមប្រព្រឹត្តធម៌វិន័យ ញញឹមយកជ័យលើកិលេស ។

ថ្ងៃ ០៤រោច ខែចែត្រ ពុទ្ធសករាជ ២៥៥
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១០៥_ញញឹមបវរញញឹមស្ងប់

១-ញញឹមយកលាភយកសួស្ដី ញញឹមឆ្នាំថ្មីស្រស់ថ្លៃថ្លា
ញញឹមទទួលពួកទេវតា ញញឹមចេតនាជាកុសល ។
២-ញញឹមធ្វើទានរក្សាសីល ញញឹមផ្ដាច់ផ្ដិលចិត្តកង្វល់
ញញឹមលះបាបសាងកុសល ញញឹមបានផលសុខក្សេមក្សាន្ដ ។
៣-ញញឹមដោយចិត្តដ៏រីករាយ ញញឹមពណ្ណរាយពីសន្ដាន

ញញឹមមេត្រីចិត្តប្រោសប្រាណ ញញឹមកល្យាណញញឹមហំ ។
៤-ញញឹមមានច្រើនប្រភេទណាស់ ញញឹមបែបខ្លះសែនល្អសម
ញញឹមចិត្តស្មោះញញឹមចំ ញញឹមដោយខំញញឹមប្រែ ។
៥-ញញឹមបញ្ឆើចញញឹមខូច ញញឹមហាក់ដូចជាល្អដែរ
ញញឹមបែបនេះកុំនៅក្បែរ ញញឹមគេចកែមានអ្វីល្អ ។
៦-ញញឹមទទួលនូវធម្មទាន ញញឹមដោយបានចេះស្មោះសរ
ញញឹមមិនខ្លាចសន្សំល្អ ញញឹមបវរញញឹមស្ងប់ ។

ថ្ងៃ ១០ រោច ខែចែត្រ ពុទ្ធសករាជ ២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១០៦-ញញឹមប្រាកដទទួលពរ

( បទផ្កាឈូករីក ពាក្យ ៧ )

១-ញញឹមរីករាយចូលឆ្នាំថ្មី ញញឹមប្រុសស្រីគិតសប្បាយ
ញញឹមជុំគ្នាលម្អកាយ ញញឹមខ្វល់ខ្វាយលេងច្រៀងរាំ ។
២-ញញឹមផឹកស្រាដល់កែវគ្នា ញញឹមលេងបៀយ៉ាងមុតមាំ
ញញឹមរួចភ័យព្រោះខ្មោចខ្មាំ ញញឹមធ្លាក់ជ្រាំវិនាសខ្លួន ។
៣-ញញឹមធ្វើតែអកុសល ញញឹមនេះដល់ទុក្ខផ្ទួនៗ

ញញឹមបែបនេះឱមាសស្ងួន ញញឹមលង់ខ្លួនក្នុងអបាយ ។

៤-ញញឹមចូលឆ្នាំដែលប្រពៃ ញញឹមលកលៃញ៉ាំងចិត្តកាយ

ញញឹមបម្រើឪពុកម្ដាយ ញញឹមឱនកាយថ្វាយវន្ទា ។

៥-ញញឹមជួបជុំញាតិបងប្អូន ញញឹមជួបជូនតានានា

ញញឹមសង្គ្រោះគ្នានឹងគ្នា ញញឹមបូជាព្រះត្រៃរ័ត្ន ។

៦-ញញឹមសន្សំសេចក្ដីល្អ ញញឹមស្មោះសរពិតប្រាកដ

ញញឹមមេត្រីចិត្តអំណត់ ញញឹមប្រាកដទទួលពរ ។

ថ្ងៃ ១០ រោច ខែចែត្រ ពុទ្ធសករាជ ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១០៧_ញញឹមសូមលាចាកភពបី

១-ញញឹមពេលព្រឹកយកសិរី ញញឹមឆ្នាំថ្មីតាមវេលា

ញញឹមធ្វើល្អទាំងអស់គ្នា ញញឹមបូជាអ្នកមានគុណ ។

២-ញញឹមសង្គ្រោះដល់ញាតិមិត្រ ញញឹមល្អពិតដ៏ស្រទន់

ញញឹមសង្គ្រោះកូនប្រពន្ធ ញញឹមទន់ភ្លន់មានមេត្តា ។

៣-ញញឹមថ្វាយទានដល់ព្រះសង្ឃ ញញឹមផ្ចិតផ្ចង់នូវសីលា

ញញឹមអង្គុយស្ដាប់ទេសនា ញញឹមជ្រះថ្លាក្នុងធម្មទាន ។

៤-ញញឹមមានពិតតាមហេតុការណ៍ ញញឹមមិនថ្លាព្រោះអឹមអៀន
ញញឹមស្រស់បស់ព្រោះអាចបាន ញញឹមខំរៀនព្រះធម៌អាថ៌។

៥-ញញឹមមានហេតុដូចជិនស្រី ញញឹមប្រិមប្រិយដូចអប្សរា
ញញឹមចិត្តស្មោះស្រស់ថ្លៃថ្លា ញញឹមមេត្តាញញឹមព្រហ្ម ។

៦-ញញឹមប្រព្រឹត្តធម៌សុចរិត ញញឹមសុខចិត្តព្រមលេងយំ
ញញឹមឱនកាយថ្វាយបង្គំ ញញឹមជួបជុំដោយចិត្តជា ។

៧-ញញឹមទទួលនូវធម្មរស ញញឹមឈប់ឈ្លោះព្រមព្រៀងគ្នា
ញញឹមដើរតាមព្រះភគវា ញញឹមសូមលាចាកភពបី ។

ថ្ងៃ ១២ រោច ខែចែត្រ ពុទ្ធសករាជ ២៥៥៨
ដោយភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១០៨-ញញឹមបានដល់ត្រើយសុខសាន្ត

( បទផ្កាឈូករីក ពាក្យ ៧ )

> ញញឹមពេលព្រឹកយកសិរី ញញឹមមេត្រីនឹងញាតិមិត្រ
ញញឹមពោលស្ដីចេះរិះគិត ញញឹមពិនិត្យគ្រប់កិច្ចការ ។

> ញញឹមពេលថ្ងៃដ៏រាក់ទាក់ ញញឹមដោយភក្ត្រដ៏ភ្លឺថ្លា
ញញឹមលះបង់ចិត្តឥស្សា ញញឹមករុណាដល់សព្វសត្វ ។

> ញញឹមពេលល្ងាចដ៏ស្រទន់ ញញឹមគយគន់ដោយប្រយ័ត្ន

ញញឹមជួបជុំមិនសូន្យបាត់ ញញឹមកម្ចាត់ក្តីកង្វល់ ។
> ញញឹមឲ្យពិតតាមសភាព ញញឹមយកលាភដោយកុសល
ញញឹមសង្ឃឹមទទួលផល ញញឹមបានដល់ត្រើយសុខសាន្ត។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១០៩-ញញឹមធ្វើទានរក្សាសីល

* ញញឹមធ្វើទានរក្សាសីល ញញឹមផ្តាច់ផ្តិលចិត្តកំណាញ់
ញញឹមមិនឃើញមានតែអញ ញញឹមស្រឡាញ់សេចក្តីល្អ ។
* ញញឹមសង្គ្រោះឬបូជា ញញឹមវន្ទាចិត្តបវរ
ញញឹមគោរពដោយស្មោះសរ ញញឹមត្រេកអរលះកិលេស ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១០-ញញឹមលះបង់អកុសល

* ញញឹមបូជាត្រៃរតនា ញញឹមជ្រះថ្លាក្នុងព្រះពុទ្ធ
ញញឹមស្តាប់ធម៌ចិត្តមោះមុត ញញឹមសូមផ្គត់ផ្គង់ព្រះសង្ឃ ។
* ញញឹមព្រោះបានយល់ធម្មា ញញឹមបូជាដោយផ្ចិតផ្ចង់
ញញឹមធ្វើទិដ្ឋិឲ្យត្រង់ ញញឹមលះបង់អកុសល ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១១-ញញឹមប្រាថ្នារួចចាកទុក្ខ

* ញញឹមធ្វើបុណ្យកឋិនទាន ញញឹមអាចហ៊ានលះកំណាញ់
ញញឹមមិនមែនឃើញតែអញ ញញឹមខំផ្លាញ់ចិត្តឥស្សា ។
* ញញឹមពោរពេញដោយសទ្ធា ញញឹមមិនរាក្នុងកុសលា
ញញឹមសន្សំតែបុញ្ញា ញញឹមប្រាថ្នារួចចាកទុក្ខ ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១២-ញញឹមបូជាដោយបរិសុទ្ធ

( បទផ្កាឈូករីក ពាក្យ ៧ )

* ញញឹមរៀបចំត្រៃចីវរ ញញឹមធ្វើល្អក្នុងព្រះសង្ឃ
ញញឹមតាក់តែងដោយផ្ចិតផ្ចង់ ញញឹមឱនអង្គថ្វាយបូជា ។
* ញញឹមពោលវេរដោយវាចា ញញឹមស្រស់ថ្លាដោយសទ្ធា
ញញឹមធ្វើបុណ្យទាំងអស់គ្នា ញញឹមបូជាដោយបរិសុទ្ធ ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៣-ញញឹមសុខាជាអមតៈ

( បទផ្កាឈូករីក ពាក្យ ៧ )

* ញញឹមធ្វើទានរក្សាសីល ញញឹមផ្តាច់ផ្តិលនូវលោភៈ
ញញឹមលះបង់ការជំពាក់ ញញឹមមិនទាក់ដោយទោសា ។

* ញញឹមចម្រើននូវភាវនា ញញឹមម្ទីម្នាក្នុងកុសលា
ញញឹមលះបង់នូវមោហា ញញឹមសុខាជាអមតៈ ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៤-ញញឹមប្រាថ្នាព្រះនិព្វាន

* ញញឹមប្រព្រឹត្តធម៌សុចរិត ញញឹមធ្វើចិត្តឲ្យផូរផង់
ញញឹមធ្វើល្អដោយស្មោះត្រង់ ញញឹមផ្ចិតផ្ចង់ក្នុងសិក្ខា ។
* ញញឹមសង្រួមដោយសទ្ធា ញញឹមខំវៀរអកុសលា
ញញឹមព្យាយាមដោយបញ្ញា ញញឹមប្រាថ្នាព្រះនិព្វាន ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៥-ញញឹមសុខាជានិរន្តរ៍

( បទផ្កាឈូករីក ពាក្យ ៧ )

> ញញឹមគោរពមិនបំពាន ញញឹមអាចហ៊ានព្រមលះបង់
ញញឹមធ្វើតាមព្រះពុទ្ធអង្គ ញញឹមផ្ចិតផ្ចង់នូវសិក្ខា ។
> ញញឹមពោរពេញដោយសទ្ធា ញញឹមមិនរាក្នុងកុសលា
ញញឹមសន្សំយកផលា ញញឹមសុខាជានិរន្តរ៍ ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៦-ញញឹមសេពគប់តែសប្បុរស

* ញញឹមព្រោះបានឃើញព្រះសង្ឃ ញញឹមឱនអង្គថ្វាយវន្ទា
ញញឹមឲ្យទានដោយសទ្ធា ញញឹមបូជាដោយគោរព ។
* ញញឹមជូនបុណ្យមិត្រកល្យាណ ញញឹមសូមបានសុខថ្ងៃយប់
ញញឹមសូមបានប្រាសចាកភព ញញឹមសេពគប់តែសប្បុរស។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៧-ញញឹមកម្ចាត់អវិជ្ជា

* ញញឹមទទួលនូវធម្មទាន ញញឹមប្រឹងរៀនដោយគោរព
ញញឹមធ្វើល្អទាំងថ្ងៃយប់ ញញឹមសូមឈប់សាងវេរា ។
* ញញឹមព្រោះស្គាល់ពីការពិត ញញឹមប្រព្រឹត្តព្រះធម្មា
ញញឹមជានិច្ចគ្រប់វេលា ញញឹមចិត្តជាបានសុខា ។
* ញញឹមទទួលនូវសំណាង ញញឹមស្អិតស្អាងកាយវាចា
ញញឹមធ្វើអ្វីដោយបញ្ញា ញញឹមមេត្តាដល់សព្វសត្វ ។
* ញញឹមវៀរចាករាល់បាបកម្ម ញញឹមចងចាំប្រុងប្រយ័ត្ន
ញញឹមធ្វើការដោយស្ងៀមស្ងាត់ ញញឹមកម្ចាត់អវិជ្ជា ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៨-ញញឹមសង្គ្រោះតាមវិន័យ

*ញញឹមប្រព្រឹត្តសេចក្តីល្អ ញញឹមបវរឲ្យអភ័យ
ញញឹមសង្គ្រោះតាមវិន័យ ញញឹមគិតលៃដោយតម្រិះ ។
*ញញឹមធ្វើចិត្តឲ្យស្អាតស្អំ ញញឹមខិតខំមិនប្រហែស
ញញឹមអរហន្តអស់កិលេស ញញឹមដូច្នេះស្អាតពេកណាស់ ។

ដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

## ១១៩-ញញឹមទូន្មានដោយព្រះធម៌

*ញញឹមធ្វើនូវសេចក្តីល្អ ញញឹមបវរគិតលកលៃ
ញញឹមរស់នៅមានវិន័យ ញញឹមប្រពៃចិត្តអាចហ៊ាន ។
*ញញឹមធ្វើតាមដោយផ្ចិតផ្ចង់ ញញឹមផូរផង់ចេះខ្មាសអៀន
ញញឹមចង់ចេះប្រឹងប្រែងរៀន ញញឹមទូន្មានដោយព្រះធម៌ ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១២០-ញញឹមសន្តោសជាមង្គល

*ញញឹមទទួលសេចក្តីល្អ ញញឹមបវរឲ្យអភ័យ
ញញឹមធ្វើតាមធម៌វិន័យ ញញឹមប្រពៃស្គាល់ការពិត ។
*ញញឹមដឹងច្បាស់ហេតុបច្ច័យ ញញឹមកែខៃចិត្តគំនិត
ញញឹមយល់ព្រមអាចប្រព្រឹត្ត ញញឹមមិនគិតក្នុងផ្លូវខុស ។

*ញញឹមមានន័យច្រើនបែបយ៉ាង ញញឹមស្អិតស្អាងទាំងស្រីប្រុស
ញញឹមតាមពិតញញឹមចុះ ញញឹមសន្តោសជាមង្គល ។
* ញញឹមទទួលនូវពរជ័យ ញញឹមលែងភ័យលែងកង្វល់
ញញឹមសង្ឃឹមលើកុសល ញញឹមបុណ្យផ្តល់ក្តីសុខសាន្ត ។
* ញញឹមទទួលនូវមេត្តា ញញឹមករុណាញាតិគ្រប់ប្រាណ
ញញឹមប្រណីមិត្រកល្យាណ ញញឹមសូមបានប្រាសចាករោគ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១២១-សួស្តីបវរល្អប្រសើរ

(បទពាក្យ៧ ជូនក្នុងឃ្លា)

-ពេលព្រឹកសួស្តីស្រីសុខា គ្រប់រូបអាត្មាណាកល្យាណ
កុំមានទុក្ខាផ្សាឈឺប្រាណ រស់ដោយសុខសាន្តក្សាន្តឧត្តម។
-ពេលថ្ងៃសួស្តីស្រីមង្គល កុំបីអំពល់រុលផ្សែផ្សំ
ធ្វើកិច្ចការអ្វីខ្មីខិតខំ ឲ្យបានស័ក្តិសមហំរូបរាង ។
-ពេលយប់សួស្តីស្រីថ្កើងថ្កាន ជុំញាតិសន្តានបានមិនឃ្លាង
ជុំទាំងបងប្អូនកូននួននាង មានការព្រមព្រៀងរៀងរាល់អង្គ។
-សួស្តីបវរល្អប្រសើរ លុះតែអ្នកដើរស្មើដោយផ្ទង់
តាមធម៌វិន័យលៃឲ្យត្រង់ នឹងបានផ្លូវផង់អង្គបរិសុទ្ធ ។

ថ្ងៃ ០៨ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩

និពន្ធដោយ សុវណ្ណជោតោ ភួងសុវណ្ណ

## ១២២-សួស្តីប្រាំវេលា

-អរុណសួស្តីសិរីអស្ចារ្យ ទៅនមស្ការថ្វាយបង្គំព្រះ
តាំងពីស្រាងៗអរុណទើបរះ ពិតមានតេជៈឥតមានចាលចាញ់ ។
-ព្រហាមសួស្តីសិរីសុខា ដល់ញាតិវង្សានិងមិត្រសម្លាញ់
សង្រ្គោះបូជាមិនឃើញតែអញ ផ្តល់ក្តីស្រឡាញ់ឲ្យដល់សព្វសត្វ។
-សាយ័ណ្ហសួស្តីសិរីភោគា ឧស្សាហ៍ម្ចីម្នាដោយប្រុងប្រយ័ត្ន
ធ្វើទានកាន់សីលដើម្បីលះកាត់ កិលេសឲ្យខ្ចាត់ពីចិត្តសន្តាន ។
-ព្រលប់សួស្តីសិរីជួបជុំ រស់អភិរម្យដោយចិត្តប្រោសប្រាណ
ដល់បុត្តភរិយាកុំឲ្យខកខាន ផ្តល់ក្តីសុខសាន្តក្នុងក្រុមគ្រួសារ ។
-រាត្រីសួស្តីសិរីសួគ៌ឋាន គ្មានការរំខានគ្មានការឡូឡា
គេងដោយស្ងប់ស្ងាត់ចម្រើនមេត្តា ដល់ខ្លួនអាត្មានិងដល់សព្វសត្វ។

ព្រឹកថ្ងៃ ០៩ រោច ខែអាសាឍ ពុទ្ធសករាជ ២៥៦០

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១២៣-សួស្តីបួនពេល

-ពេលព្រឹកសួស្តីសិរីថ្កើងថ្កាន សូមសម្រេចបានបំណងទាំងឡាយ
សុខដុមរមនាញាតិមិត្រជិតឆ្ងាយ កុំឲ្យប្រែក្លាយទៅជាមោះហ្មង។
-ពេលថ្ងៃសួស្តីសិរីសម្បត្តិ ចេះប្រុងប្រយ័ត្នពិតល្អកន្លង
ប្រព្រឹត្តសុចរិតឲ្យបានហ្មត់ហ្មង អ្នកនឹងបានឆ្លងផុតចាកអន្តរាយ។

-ពេលល្ងាចសួស្តីសិរីបវរ មានចិត្តស្មោះសរក្នុងកិច្ចទាំងឡាយ
ចាត់ចែងត្រឹមត្រូវមិនប្រទូសរ៉ាយ បានសុខសប្បាយគ្រប់គ្នាទាំងអស់។
-ពេលយប់សួស្តីសិរីមង្គល សូមបានឃើញយល់ព្រះធម៌សប្បុរស
បានដឹងការពិតទឹកមុខស្រស់បស់ ប្រសើរឥតខ្ចោះជានិច្ចនិរន្តរ៍។

ព្រឹកថ្ងៃ ១០ រោច ខែអាសាឍ ពុទ្ធសករាជ ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១២៤_ចិត្តអើយចិត្តនឹក

( បទពាក្យ ៧ )

-ចិត្តអើយចិត្តនឹកៗ ខ្លាំងណាស់ នឹកព្រះពុទ្ធម្ចាស់នឹកពុទ្ធស្ថាន
ទ្រង់ធ្លាប់ប្រើប្រាស់ទាំងប៉ុន្មាន ស្តាប់ធម៌កល្យាណចិត្តជ្រះថ្លា ។
-ស្ថានទីប្រសូតលុម្ពិនី បរិស័ទមួលមីរមនុស្សទេព្តា
សាលព្រឹក្សទាំងឡាយបញ្ចេញផ្កា កើតហេតុអស្ចារ្យគួរស្ញប់ស្ញែង ។
-ស្ថានទីត្រាស់ដឹងពុទ្ធគយា ក្រោយពីផ្ចាញ់មារគ្រានោះឯង
ទ្រង់ចម្រើនធម៌ត្រង់កន្លែង បល្ល័ង្កនោះឯងក៏ត្រាស់ដឹង ។
-វិសាខទៀបភ្លឺពេញបូណ៌មី ជាផលបារមីដែលទ្រង់ប្រឹង
បានសន្សំមកអ្នកត្រូវដឹង សាមសិបសុទ្ធសឹងជាគុណពិត ។
-បរិស័ទទាំងឡាយជ្រះថ្លាណាស់ ទាំងក្មេងទាំងចាស់សង្ឃបព្វជិត
ចម្រុះជាតិសាសន៍ចិត្តស្នេហ៍ស្និទ្ធ បានចូលទៅជិតក្រាបវន្ទា ។

-អ្នកខ្លះមានចិត្តសោមនស្សា ដោះអលង្ការផងនានា
ថ្វាយដោយចំពោះព្រះភគវា ដោយចិត្តសទ្ធាឥតបង្អង់ ។
-ខ្លះមានសំពត់មានភ្ញីផ្កា សូធ្យនមស្ការចិត្តឆ្ពោះត្រង់
រលឹកដល់គុណដ៏ផូរផង់ បូជាព្រះអង្គព្រះជិនស្រី ។
-ឥសិបតនមិគទាយវ័ន ជាច្រើនជំនាន់ពារាណសី
នគរចំណាស់ទីទឹកដី ឈ្មោះតាមប្រក្រតីពីបូរាណ ។
-ព្រះពុទ្ធទាំងឡាយត្រាស់ដឹងហើយ មិនបង្អង់ឡើយព្រះទ្រង់បាន
ស្ដេចយាងមកដល់ត្រង់ទីឋាន បល្ល័ង្កថ្កើងថ្កានជាអាសនា ។
-ព្រះអង្គទ្រង់គង់ដោយប្រើប្រាស់ រួចហើយក៏ត្រាស់ធម៌ទេសនា
ធម្មចក្កប្រសើរដ៏អស្ចារ្យ ញុំាងមនុស្សទេវតាឱ្យសម្រេច ។
-ព្រះកោណ្ឌញ្ញៈជាបឋម ព្រមទាំងពួកព្រហ្មឃើញអរិយសច្ច
១៨ កោដិបានសម្រេច រួចហើយទើបស្ដេចចប់ធម្មា ។
-ថ្ងៃពេញបូណ៌មីគ្រាចុងក្រោយ ឆ្នាំ ៨០ ហើយព្រះភគវា
កុសិនារាពេលរសៀល តាមដងមាគ៌ាស្ដេចយាងដល់ ។
-ព្រះអង្គទ្រង់ផ្ទំផ្ទៀងខាងស្ដាំ នេះអ្នកត្រូវចាំទ្រង់តម្កល់
ស្មារតីតាំងមាំជីវិតសល់ រួចហើយទ្រង់ផ្ដល់ព្រះឱវាទ ។
-បណ្ដាំចុងក្រោយវិសេសណាស់ បរិស័ទក្មេងចាស់ត្រូវសង្វាត

ចម្រើនកុសលកុំប្រមាទ ពិតជាឱវាទប្រសើរក្រៃ ។
-ចិត្តខ្ញុំសែននឹក១មិនភ្លេច ចងចាំជានិច្ចណាម្ចាស់ថ្លៃ
ដេកដើរអង្គុយចិត្តស្រមៃ ទោះយប់ឬថ្ងៃនឹកព្រះអង្គ ។
-ខ្ញុំសូមវន្ទានមស្ការ ដោយចិត្តជ្រះថ្លាដ៏ផូរផង់
សូមបុណ្យកុសលជួយតម្រង់ មានទិដ្ឋិត្រង់ជាសម្មា ។
-សូមឱ្យបានជួបនឹងសប្បុរស មានចិត្តស្ម័គ្រស្មោះក្នុងធម៌អាថ៌
ប្រតិបត្តិត្រូវក្នុងកុសលា ស្តាប់ធម៌ទេសនាបានត្រាស់ដឹង ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ 0៤ រោច ខែមិគសិរ ព.ស. ២៥៥៨

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១២៥-សំវេជនីយដ្ឋាន

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា ៖

ម្នាលអានន្ទ សំវេជនីយដ្ឋាន (ទីដែលគួរកើតសង្វេគ) ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធានេះ មាន ៤ កន្លែង ។

សំវេជនីយដ្ឋាន ៤ កន្លែង តើដូចម្តេច ?

ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះដូច្នេះ ១, ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមាន

សទ្ធា ដោយរលឹកឃើញថា ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះដូច្នេះ១, ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតបានសម្ដែងអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះ ១, ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្តអ្នកមានសទ្ធា ដោយរលឹកឃើញថា ព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះដូច្នេះ ១, ម្នាលអានន្ទ នេះឯងសំវេជនីយដ្ឋានដែលគួរឃើញ ៤ កន្លែង របស់កុលបុត្តអ្នកមានសទ្ធា ។

ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមានសទ្ធា នឹងមកដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះដូច្នេះក្ដី ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះដូច្នេះក្ដី ព្រះតថាគតបានសម្ដែងអនុត្តរធម្មចក្ក ក្នុងទីនេះដូច្នេះក្ដី ព្រះតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងទីនេះដូច្នេះក្ដី ម្នាលអានន្ទ ពួកជនណាមួយនឹងបានដើរមកកាន់ទីចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា បើប្រសិនជាធ្វើមរណកាលទៅ ពួកជនទាំងអស់នោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់ពីសេចក្ដីស្លាប់ នឹងចូលទៅកាន់លោក គឺមនុស្ស សុគតិ និងឋានសួគ៌ ។

# ១២៦-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (១)

-សទ្ធានាំមុខចេញចរយាត្រា ទៅនមស្ការតាមទីពុទ្ធស្ថាន
កត្តិក៣កើតណាមិត្រកល្យាណ ឥតមានខកខានដល់ក្រុងដៃល្លី។
-ជាដែនកុរុពីសម័យមុន ស្រស់ល្អពេកពន់អង្គព្រះមុនី
សម្តែងសតិប្បដ្ឋានព្រះធម្មី ផ្លូវល្អគ្មានពីរនាំរួចចាកទុក្ខ ។
-រាត្រីទៀបភ្លឺពេលព្រឹកព្រលឹម ញញឹមសង្ឃឹមដំណើរទៅមុខ
ក្រុងសាវត្ថីតាមការគ្រោងទុក ព្រះសង្ឃម៉ែពុកមានចិត្តស្រស់ថ្លា។
-គណ្ឌាម្ពព្រឹក្សស្វាយលាស់ស្រស់ខ្ចី អង្គព្រះជិនស្រីធ្វើបាដិហារ្យ
អាសាឍ១៥ កើតដ៏អស្ចារ្យ ផ្ចាញ់ពួកមិច្ឆាទិដ្ឋិទាំងឡាយ ។
-វត្តបុព្វារាមនៅខាងកើតក្រុង ជាទីបម្រុងគួរឲ្យសប្បាយ
ដែលវិសាខានាងបានចំណាយ ទ្រព្យសាងថ្វាយនៅក្នុងពុទ្ធសាសន៍។
-ជាទីគង់នៅនៃព្រះសាស្តា ប្រាំមួយវស្សាពិតប្រាដកណាស់
លោហប្រាសាទវិចិត្រល្អល្អះ មានសព្វមិនខ្វះបរិក្ខារទាំងឡាយ។
-វត្តជេតពនជាទីរីករាយ ស្រស់ល្អពណ្ណរាយជាទីសប្បាយ
ព្រះពុទ្ធមិនលះទោះស្តេចទៅឆ្ងាយ បរិស័ទថ្វាត់ថ្វាយបង្គំបូជា ។
-អានន្ទពោធិ៍ព្រះគន្ធកុដិ បិតនៅប្រាកដនៃព្រះភគវា
ដ៏ប្រសើរក្រៃបរិស័ទគ្រប់គ្នា តែងទៅវន្ទាដោយចិត្តជ្រះថ្លា ។
-នៅវេលាល្ងាចបរិស័ទទាំងឡាយ មានចិត្តសប្បាយចូលនមស្ការ
បូជាប្រទីបព្រមទាំងភ្ញីផ្កា ស្តាប់ធម៌ទេសនាតាំងអធិដ្ឋាន ។
-សូមបុណ្យកុសលបានជាបច្ច័យ ឧបនិស្ស័យដាក់ដល់ភូមិឋាន

ទីបរមសុខប្រសើរថ្កើងថ្កាន  បានសុខក្សេមក្សាន្តរួចចាកទុក្ខា ។

## ១២៧-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (២)

-មកដល់ទីក្រុងកបិលពស្តុថ្មី   វន្ទាចេតិយនៃព្រះសាស្តា
តម្កល់ព្រះធាតុ២នាឡិនោះណា ស្តាប់ធម៌ទេសនាដោយចិត្តស្ងប់ស្ងាត់។
-អរុណបានរះចាំងជះរស្មី    មកលើផែនដីបំភ្លឺសព្វសត្វ
ញុំាងដួងហាទ័យនៃពុទ្ធបរិស័ទ  ចូលទៅប្រតិបត្តិដល់ទីពុទ្ធស្ថាន។
-ឧទ្យានសាលវ័នឈ្មោះលុម្ពិនី   អង្គព្រះមុនីកាលនោះទ្រង់បាន
ប្រសូតចាកគភ៌មាតាកល្យាណ  ថ្ងៃនេះខ្ញុំបានចូលនមស្ការ ។
-ក្រុងកបិលពស្តុទ្រង់ធ្លាប់គង់នៅ  ប៉ុន្តែឥឡូវសល់តែសិលា
ស្មៅដុះជុំជិតមានអ្វីអស្ចារ្យ នេះហើយសង្ខារទាំងឡាយមិនទៀង។
-និគ្រោធារាមពួកញាតិសាងថ្វាយ  ក៏បានប្រែក្លាយសល់តែរូបរាង
គ្រឹះស្ថានអារាមសំឡេងស្ងូរសៀង ដីកាសំនៀងស្ងន្យស្ងាត់ពេកណាស់។
-ជាទីគង់នៅនៃព្រះសម្ពុទ្ធ     សាវ័កសុគតប្រសើរល្អល្អះ
២ម៉ឺនព្រះអង្គគួរជ្រះថ្លាណាស់  ឱព្រះគុណម្ចាស់បាត់ទៅណាហើយ។
-ទេវទហានគរមាតា       រាមគ្រាមអស្ចារ្យនៅមិនឆ្ងាយឡើយ
ទូលព្រះចេតិយស្រស់ល្អមែនហើយ ឥតមានកន្តើយគោរពបូជា។
-ស្តាប់ធម៌ទេសនាប្រវត្តិព្រះធាតុ  បញ្ជាក់ថែមទៀតចម្រើនសទ្ធា
រលឹកដល់គុណនៃព្រះភគវា  ក្រាបថ្វាយវន្ទាគោរពដោយស្មោះ ។

## ១២៨-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៣)

-ថ្ងៃប្រាំបីកើតដំណើរយាត្រា កុសិនារាគួរឲ្យអាឡោះ
អាល័យនឹកដល់ពុទ្ធអង្គកាលណោះ ទ្រង់ល្វិតល្វៃខ្សោះកម្លាំងព្រះកាយ។
-ចូលកាន់សាលវ័ននៃពួកមល្លក្សត្រ មិនសូន្យមិនស្ងាត់ភិក្ខុទាំងឡាយ
ដ៏ច្រើនរូបណាស់ជាប់តាមមិនឆ្ងាយ នៅជិតព្រះកាយនៃព្រះសាស្តា។
-បង្គាប់អានន្ទឲ្យឆាប់រួសរាន់ ប្រញាប់បន្ទាន់រៀបគ្រែអាសនា
ឱ្យមានសីសៈទៅខាងជើងណា ផ្ទំដោយសញ្ញាមិនក្រោកវិញទេ។
-ថ្ងៃពេញបូណ៌មីជាគ្រាចុងក្រោយ ឆ្នាំ ៨០ ហើយឱណាមាសមេ
ទ្រង់មានស្មារតីមិនតក់ស្លុតទេ រួចហើយរិះរេទ្រង់ផ្តល់ឱវាទ ។
-បណ្តាំចុងក្រោយល្អវិសេសណាស់ បរិស័ទក្មេងចាស់ត្រូវខំសង្វាត
ចម្រើនកុសលកុំបីប្រមាទ ពិតជាឱវាទដ៏ប្រសើរក្រៃ ។
-ចូលមកុដពន្ធនចេតិយ ហាក់ដូចថ្មីៗគិតនឹកស្រមៃ
បូជាព្រះសពព្រះចមក្សត្រថ្លៃ ជាគម្រប់ថ្ងៃទីប្រាំពីរហើយ ។
-បរិស័ទទាំងឡាយចូលមកបូជា ដល់ព្រះភគវាឥតមានកន្តើយ
មានទាំងមនុស្សទេវតាអ្នកអើយ កន្លែងនេះហើយមកុដពន្ធនៈ ។
-នៅក្នុងគ្រានោះហេតុអស្ចារ្យណាស់ មែនពិតយ៉ាងច្បាស់ច្រើនប្រាកដជាក់
ជុំដោយគ្រហស្ថព្រះសង្ឃសាវ័ក មានការជឿជាក់អង្គព្រះជិនស្រី។
-ប្រទក្សិណបីជុំរួចក៏បន្ត ដំណើរត្រាច់ចរតាមដងវិថី
ចូលទៅទៀបស្ទឹងហិរញ្ញវតី ដែលព្រះជិនស្រីទ្រង់បានឆ្លងកាត់។

## ១២៩-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៤)

-ក្រុងវេសាលីនៃស្តេចលិច្ឆវី អង្គព្រះមុនីទ្រង់បានកម្ចាត់
ភ័យ៣ប្រការឲ្យវិនាសបាត់ ញ៉ាំងរាស្ត្រនិងក្សត្របានសុខសួស្តី ។
-កូដាគារសាលាព្រៃមហាវ័ន មានរឿងពាក់ព័ន្ធនឹងភិក្ខុនី
បួសក្នុងសាសនានៃព្រះជិនស្រី ស្មោះស្ម័គ្រភក្តីក្នុងព្រហ្មចារ្យ ។
-លះបង់ពួកញាតិរស់នៅជួបជុំ និងភាពជាធំព្រមទាំងបរិវារ
លះកាមលោកីយ៍ឥតស្តាយទេណា មានចិត្តប្រាថ្នាតែក្នុងបព្វជ្ជា។
-ឯព្រះអានន្ទក៏ជួយអង្វរ ដោយចិត្តស្មោះសរឥតមានរួញរា
ក្រាបបង្គំទូលដល់ព្រះភគវា រហូតដល់គ្រាទ្រង់អនុញ្ញាតឲ្យ។
-ស្ត្រីបួសក្នុងព្រះពុទ្ធសាសនា នៅនាកូដាសាលានេះហើយ
មាន៥០០រូបពិតមិនតិចឡើយ កាលនោះឯងហើយគួរឲ្យជ្រះថ្លា។

## ១៣០-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៥)

-ថ្ងៃ១៥ កើត បិតក្នុងខែមាឃ ព្រះមានព្រះភាគទ្រង់បង្គាប់ថា
ឲ្យប្រជុំសង្ឃនៅក្នុងសាលា រួចទ្រង់ប្រាប់ការបរិនិព្វាន ។
-ទ្រង់ផ្តល់ឱវាទដល់ភិក្ខុសង្ឃ ជាច្រើនព្រះអង្គឥតមានលាក់លៀម
កុំឲ្យប្រមាទមានចិត្តអាចហាន ប្រព្រឹត្តសមាទានព្រហ្មចរិយ ។
-អម្ពបាលិវ័នក្រុងវេសាលី ទីតាំងចេតីយ៍ធាតុ២នាឡិជាក់
សទ្ធានាំមុខចិត្តឥតស្ទើរស្ទាក់ ឈានជើងបែរភក្ត្រចូលក្រាបវន្ទា។
-ក្រុងវេសាលីនៃស្តេចលិច្ឆវី អង្គព្រះមុនីនិងព្រះសង្ឃា
ទ្រង់ត្រាស់ព្រះសូត្ររម្ងាប់រោគា អមនុស្សនានាក៏បានចៀសឆ្ងាយ។

## ១៣១-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៦)

-បាតលិបុត្តអសោការាម ទីនេះបើតាមក្បួនច្បាប់ទាំងឡាយ
ជាទីមនោរម្យគួរឲ្យសប្បាយ ភិក្ខុទាំងឡាយធ្វើសង្គាយនា ។
-រួបរួមព្រះធម៌និងព្រះវិន័យ ដ៏ល្អប្រពៃនៃព្រះភគវា
ភិក្ខុមួយពាន់រូបសុទ្ធសឹងជា បដិសម្ភិទាញាណដ៏វិសេស។
-ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ គឺជាព្រះថេរដែលមានចំណេះ
ជាអធិបតីនាំដ៏ពិសេស លោកមានតម្រិះល្អប្រសើរណាស់។
-សង្គាយនានេះជាលើកទី៣ វេលានោះក្តី ៩ ខែឥតខ្វះ
សូម្បីផែនដីដ៏មានកម្រាស់ ញ័រក្រៃលែងណាស់ឲ្យសាធុការ។

## ១៣២-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៧)

-ទីក្រុងរាជគ្រឹះបញ្ចគិរី ក្រុងនេះជាទីព្រះពុទ្ធសាស្តា
ទ្រង់យាងចូលមកនិងអរហន្តា ស្តេចពិម្ពិសារមានចិត្តត្រេកអរ ។
-ភ្នំគិជ្ឈកូដមានព្រះគន្ធកុដិ ឋិតនៅប្រាកដគ្រឹះស្ថានបវរ
បរិស័ទក្មេងចាស់មានចិត្តត្រេកអរ រីករាយស្មោះសរឡើងនមស្ការ។
-សូករខាតាគឺជាគុហា ដែលព្រះភគវាវិសុទ្ធអស្ចារ្យ
ទ្រង់ធ្លាប់គង់នៅត្រាស់ធម៌ទេសនា ញ៉ាំងសព្វសត្តាត្រាស់ដឹងធម៌ថ្លៃ។
-ម្យ៉ាងទៀតជាទីគង់នៅប្រចាំ ព្រះសាវ័កស្តាំដ៏មានគុណក្រៃ
បរិស័ទចូលដល់បត់ជើងលើកដៃ ចិត្តនឹកស្រមៃថ្វាត់ថ្វាយបង្គំ ។

-ល្អាងព្រះមោគ្គល្លានឋិតនៅទីជិត ក្បែរនោះមែនពិតខាងក្រោមញកភ្នំ
ចូលនមស្ការក្រាបថ្វាយបង្គំ រួចហើយជួបជុំស្តាប់ធម៌វិន័យ ។
-វត្តអម្ពវ័នពេទ្យជីវកៈ មានចិត្តស្មោះស្ម័គ្រនៅក្នុងហាទ័យ
វេរថ្វាយព្រះសង្ឃបវរប្រពៃ ក្នុងធម៌វិន័យតាមចិត្តសទ្ធា ។
-សត្តបណ្ណល្អាងដ៏ស្ងប់ស្ងាត់ ភិក្ខុបរិស័ទមកជួបជុំគ្នា
រួមពុទ្ធវចនៈនៃព្រះភគវា ធ្វើសង្គាយនាព្រះធម៌វិន័យ ។
-សុទ្ធព្រះអរហន្តបានអភិញ្ញា បដិសម្ភិទាញាណដ៏ប្រពៃ
៥០០ព្រះអង្គគិតគូរលកលៃ សូម្បីផែនដីក៏បានញាប់ញ័រ ។
-វត្តវេឡុវ័នជាទីរីករាយ ដ៏ស្រស់ពណ្ណរាយទៅដោយព្រះធម៌
ភិក្ខុសាវ័កក៏មិនញាប់ញ័រ ព្រោះបានឃើញធម៌ត្រាស់ដឹងសច្ចៈ។
-ជាទីកន្លែងប្រជុំសាវ័ក សន្និបាតជាក់ពិតយ៉ាងប្រចក្ស
ព្រះខីណាស្រពមានគុណសមស័ក្តិ ត្រាស់ដឹងសច្ចៈអភិញ្ញា៦ ។
-ឥន្ទសាលគុហានៅឆ្ងាយ តែចិត្តសប្បាយឥតមានភ័យព្រួយ
ដើរដោយថ្មើរជើងឈានទៅមួយៗ ផលបុណ្យតាមជួយបានដល់ពុទ្ធស្ថាន។
-ទ្រង់ធ្លាប់គង់នៅដោះស្រាយបញ្ហា សក្កៈទេវតាទ្រង់ក៏ប្រោសប្រាណ
សាកសួរព្រះធម៌បវរកល្យាណ ចប់ស្រេចក៏បានត្រាស់ដឹងធម៌ថ្លៃ ។
-មហាវិទ្យាល័យនាលន្ទា សាលាធម្មាដ៏ប្រសើរក្រៃ
តែត្រូវមនុស្សបាបមានចិត្តព្រៃផ្សៃ ដុតគ្មានសំច័យនៅសល់តែគ្រឹះ។
-ឃ្លាំងទ្រព្យរាំងចាស់នៃព្រះរាជា សម្បូរហូរហៀរក្នុងក្រុងរាជគ្រឹះ
តែឥឡូវនេះមើលទៅគ្រប់ទិស សត្វស្វារពឹសរស់នៅពាសពេញ។

-សង្ខារទាំងឡាយមិនទៀងមែនពិត តែងតែវិបរិតកុំបីទុក្ខម្នេញ
អ្វីដែលកើតហើយតែងវិនាសវិញ គប្បីបំពេញតែសេចក្តីល្អ ។
-ភ្នំបណ្ឌវៈព្រះពោធិសត្វ ទ្រង់បានជួបក្សត្ររាជាបវរ
ព្រះពិម្ពិសារព្រះអង្គអង្វរ មានចិត្តត្រេកអរចែករាជ្យឲ្យសោយ។
-ព្រះពោធិសត្វមហាបុរស ទ្រង់មិនអាឡោះអាល័យសោះឡើយ
លះរាជសម្បត្តិគ្រប់យ៉ាងនោះហើយ ឥតមានកន្តើយរកពោធិញ្ញាណ។
-លដ្ឋិវនឧទ្យានសួនច្បារត្នោត ក៏ទីនេះសោតព្រះពុទ្ធទ្រង់ញាណ
ស្តេចយាងចូលដល់កាលគង់ធរមាន ទ្រង់ត្រាស់ទូន្មានដល់ពួកបរិស័ទ។
-អនុបុព្វីកថាសច្ចៈ ពិតយ៉ាងប្រចក្សដោយប្រុងប្រយ័ត្ន
ធម៌មានលម្អដើម្បីកម្ចាត់ កិលេសឲ្យបាត់ពីខន្ធសន្តាន ។

## ១៣៣-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៨)

-ទុក្ករកិរិយាជាផ្លូវអម កម្មជាដើមចមចេះតែរុញច្រាន
ឲ្យខំព្យាយាមនាំលំបាកប្រាណ ក្រោយមកទ្រង់បានរកឃើញផ្លូវត្រង់។
-អរិយមគ្គមានអង្គប្រាំបី ញ៉ាំងព្រះជិនស្រីឲ្យបានផូរផង់
ប្រតិបត្តិល្អដោយការផ្ចិតផ្ចង់ ដើរតាមផ្លូវត្រង់ទើបបានត្រាស់ដឹង។
-ថ្ងៃ ១៥ កើតវិសាខបុណ្ណមី ជាផលបារមី ៣០ ប៉ុណ្ណឹង
ជាគុណដ៏លើសនោះឯងសុទ្ធសឹង ទ្រង់បានត្រាស់ដឹងសម្ពោធិញ្ញាណ។
-វិសាខទៀបភ្លឺអរុណជិតរះ រស្មីចាំងជះមគ្គផលកើតមាន
ទ្រង់បានត្រាស់ដឹងសម្ពោធិញ្ញាណ ហេតុចម្លែកមានកើតប្រាកដច្បាស់។

-កក្រើកផែនដីពន្លឺភ្លឺស្វាង មិនមែនតែម្យ៉ាងដ៏ក្រៃលែងណាស់
ជាគុណតេជះព្រះពុទ្ធជាម្ចាស់ ពោរពេញមិនខ្វះបន្តិចឡើយណា។
-បរិស័ទទាំងឡាយមានចិត្តសទ្ធា គោរពវន្ទាថ្វាយនូវភ្ញីផ្កា
បាត្រពេជ្រចីវរនិងគ្រឿងបរិក្ខារ ដល់ព្រះសាស្តាឥតមានស្នាក់ស្ទើរ។

ឥណ្ឌា ថ្ងៃ ១៣ កើត ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣៩-ដំណើរយាត្រានមស្ការពុទ្ធស្ថាន (៩)
## ៧ សប្តាហ៍ក្រោយការត្រាស់ដឹង

-ស្ថានទីត្រាស់ដឹងពុទ្ធគយា បល្ល័ង្កភគវាក្រោមដើមឈើ
គួរអ្នកព្យាយាមដោយអើពើ ម្នីម្នាប្រឹងធ្វើការបូជា ។
-អនិម្មិសរតនចង្រ្កម ប្រសើរឧត្តមទីជិតគ្នា
បរិស័ទទាំងឡាយចូលវន្ទា ស្តាប់ព្រះធម្មាកើតជ្រះថ្លា ។
-ឯរតនឃរចេតិយ អង្គព្រះជិនស្រីពិចារណា
ធម៌អភិធម្មជ្រៅអស្ចារ្យ ពន្លឺភ្លឺថ្លាចេញពីកាយ ។
-សប្តាហ៍ទី៥ ទី៨ អង្គព្រះជិនស្រីយាងមិនឆ្ងាយ
អជបាលនិគ្រោធទីសប្បាយ គង់សម្រាកកាយសោយវិមុត្តិ ។
-សប្តាទី៦ ស្រះមុចលិន រីព្រះមុនិន្ទព្រះសុគត
គង់ក្រោមដើមរាំងនាគពេនពត់ ព័ទ្ធព្រះសុគតពីខាងក្រៅ។

-ឯរាជាយតនចេតិយ អង្គព្រះជិនស្រីទ្រង់សំដៅ
សប្តាហ៍ទី៧ គង់ខាងក្រៅ ដែលលោកដៅទីសប្បាយ ។
-យើងខ្ញុំគ្រប់គ្នាសូមគោរព មិនថាថ្ងៃយប់ឥតនឿយណាយ
សូមជ្រកក្រោមម្លប់ព្រះធម្មកាយ បង្គំថ្វាត់ថ្វាយត្រៃរតនា ។

ឥណ្ឌា ថ្ងៃ ១៣ កើត ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣៥-ស្ថានទីត្រាស់ដឹងពោធិព្រឹក្ស

*ស្ថានទីត្រាស់ដឹងពោធិព្រឹក្ស តាំងពីពេលព្រឹករហូតយប់
បរិស័ទទាំងឡាយមកមិនឈប់ ចូលមកគោរពព្រះភគវា ។
*មានទាំងគ្រហស្ថទាំងបព្វជិត ច្រើនណាស់មែនពិតខំម្នីម្នា
ខ្លះមានបុប្ផាគ្រឿងបូជា ប្រទីបផ្កាលាត្រៃចីវរ ។
*សង្រួមកាយចិត្តពោលវាចា សូធ្យនមស្ការចិត្តត្រេកអរ
សូធ្យហើយសូធ្យទៀតជាប់បន្ត ដោយចិត្តស្មោះសរក្នុងត្រៃរ័ត្ន។
*សូរស័ព្ទព្រះធម៌ពេញពុទ្ធស្ថាន ណាមិត្តកល្យាណជាក់ប្រាកដ
សូធ្យធម៌នមស្ការនិងធម៌បទ ឥតមានកំណត់អធ្យាស្រ័យ ។
*ខ្លះក៏សមាធិធ្វើកម្មដ្ឋាន ទូន្មានសន្តានលះអាល័យ
រលឹកដល់គុណចមក្សត្រថ្លៃ សន្សំនិស្ស័យបុណ្យបារមី ។
*សំឡេងគោះជួងនិងកូតទ្រ ព្រមទាំងវាយស្គរគ្មានប្រណី
ក៏បានលាន់ឮក្នុងទឹកដី វាយដើម្បីអ្វីឬបូជា ។

*ចម្រុះជាតិសាសន៍មកជួបជុំ ថ្វាត់ថ្វាយបង្គំដោយសទ្ធា
រលឹកដល់គុណព្រះភគវា ដែលទ្រង់ឈ្នះមារទីនេះឯង ។

ឥណ្ឌា ថ្ងៃ ១៤ កើត ខែកត្តិក ពុទ្ធសករាជ២៥៥៩

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣៦-អាទិត្តបរិយាយសូត្រ

-ឧរុវេលាសេនានិគម នៅលើខ្នងភ្នំឈ្មោះគយា
ទ្រង់ត្រាស់ទេសនាព្រះធម្មា ដល់ពួកសង្ឃាមួយពាន់អង្គ ។
-អាទិត្តបរិយាយសូត្រ គឺជាព្រះសូត្រដ៏ផូរផង់
ទ្រង់បានសម្ដែងដោយផ្ចិតផ្ចង់ ដល់ភិក្ខុសង្ឃកំពុងស្ដាប់ ។
-ចក្ខុសោតៈនិងឃានៈ ជិវ្ហាកាយៈទ្រង់បានប្រាប់
ថារបស់ក្ដៅអ្នកកុំចាប់ លះវៀរឲ្យឆាប់កុំប៉ះពាល់ ។
-ភិក្ខុទាំងឡាយបានយល់ច្បាស់ តាមពុទ្ធតម្រាស់ជាបន្ទាល់
លះការប្រកាន់មិនប៉ះពាល់ ក៏បានដឹងស្គាល់ឃើញអរិយសច្ច។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣៧-ឥន្ទសាលគុហា

ឥន្ទសាលគុហា ជិតភ្នំវេទិយកៈ តាំងនៅជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ។ ជាទីកន្លែងព្រះអង្គគង់ដោះស្រាយបញ្ហាដែល

សក្កទេវរាជសួរ, ព្រះអង្គដោះស្រាយព្រះធម៌ដែលមានសេចក្ដីពីរោះណាស់ ។ សក្កទេវរាជ ស្ដាប់ហើយក៏បានធម្មចក្ខុ (គឺសោតាបត្តិមគ្គ ) និងដល់ទេវតា ៨ ហ្មឺនឯទៀងផង ។

## កំណាព្យ ឥន្ទសាលគុហា

ឥន្ទសាលគុហានៅឆ្ងាយ តែចិត្តសប្បាយឥតមានភ័យព្រួយ
ដើរដោយថ្មើរជើងឈានទៅមួយៗ ផលបុណ្យតាមជួយបានដល់ពុទ្ធស្ថាន។
ឡើងថ្វាយបង្គំដល់ទីកន្លែង ព្រះពុទ្ធសម្ដែងព្រះធម៌កល្យាណ
ដោះស្រាយបញ្ហាដ៏ប្រសើរថ្កាន ដែលសក្កៈបានក្រាបទូលសាកសួរ។
គឺជាព្រះធម៌ជ្រាលជ្រៅមែនពិត ញុំាងអ្នកប្រព្រឹត្តតាមកាលសមគួរ
និងញុំាងព្រះឥន្ទដែលទ្រង់សាកសួរ ប្រព្រឹត្តសមគួរត្រាស់ដឹងសច្ចៈ។
ដល់ទេវតា ៨ ហ្មឺនទៀងផង បានឆ្លងកន្លងឃើញយ៉ាងប្រចក្ស
ធម្មចក្ខុត្រាស់ដឹងសច្ចៈ ឃើញយ៉ាងប្រចក្សអស់ក្ដីសង្ស័យ ។
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣៨-ហែព្រះបរមសារីរិកធាតុនៅពារាណសី

* កត្តិក១៥កើតពេញបូណ៌មី ពារាណសីហែសាស្ដា
ព្រះបរមធាតុដ៏អស្ចារ្យ បរិស័ទជ្រះថ្លាមិនកន្ដើយ ។
* ឈានទៅមួយៗដោយសទ្ធា ក្នុងព្រះភគវាអែបពីក្រោយ
កាត់សួនធម្មចក្កណាអ្នកអើយ ឥតបង្អង់ឡើយដល់ចេតិយ ។

* ក្រោមកំដៅថ្ងៃពេលរសៀល តែមិនរួញរាទាំងប្រុសស្រី
ព្រះសង្ឃសាវ័កចិត្តមេត្រី ស្មោះស្ម័គ្រភក្តីពុទ្ធបិតា ។
* សូមកុសលកម្មទាំងឡាយនេះ បានជាជំនិះឆ្លងសង្សារ
បានសោយសុខស្ងប់ជាអមតា ផុតចាកទុក្ខាទាំងពួងហោង ។
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៣៩-សួនធម្មចក្ក

* ឥសិបតនមិគទាយវ័ន មានរឿងពាក់ព័ន្ធព្រះជិនស្រី
ស្ដេចយាងមកដល់ពារាណសី ជួបពួកឥសីបញ្ចវគ្គីយ៍ ។
* ទ្រង់បានពន្យល់ឲ្យជឿជាក់ ឥសីប្រាំនាក់ស្ដាប់ធម្មី
ព្រះពុទ្ធដីកាព្រះមុនី ត្រាស់ព្រះធម្មីអរិយសច្ច ។
* ព្រះកោណ្ឌញ្ញៈជាបឋម ឃើញធម៌ឧត្តមបានសម្រេច
ព្រមទាំងពួកព្រហ្មឃើញអរិយសច្ច រួចហើយទើបស្ដេចចប់ទេសនា។
* បរិស័ទទាំងឡាយមានសទ្ធា បានចូលវន្ទានមស្ការ
លើកទង់ឆព្ណ៍រវែងអស្ចារ្យ បូជាសាស្ដាដោយគោរព ។
*ស្វាធ្យាយព្រះធម៌ព្រះធម្មចក្ក មានចិត្តស្មោះស្ម័គ្រជ្រកក្រោមម្លប់
ទទួលធម្មទានទល់ព្រលប់ រួចហើយក៏ឈប់ឧទ្ទិសផល ។
* សូមឲ្យសព្វសត្វអនុមោទនា ដោយចិត្តសទ្ធាក្នុងកុសល
សន្សំយកបុណ្យយកមគ្គផល សូមឲ្យបានដល់ក្ដីសុខា ។
* ម្យ៉ាងសូមឲ្យយើងខ្ញុំទាំងឡាយ ផុតពីអបាយចិត្តស្រស់ថ្លា

មានការយល់ត្រូវជាសម្មា ស្តាប់ធម៌ទេសនារួចចាកទុក្ខ ។

ឥណ្ឌា ថ្ងៃ ២ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៩០-ក្រុងកោសម្ពីឃោសិតារាម

-ក្រុងកោសម្ពីឃោសិតារាម វត្តនេះបើតាមសិក្សាមក
ឃោសកសេដ្ឋីបានលៃលក កសាងទុកមកដោយសទ្ធា ។
-ថ្វាយព្រះសាស្តានិងព្រះសង្ឃ ប្រណិតផ្ចិតផ្ចង់អារាធនា
ព្រះសង្ឃសាវ័កព្រះភគវា យាងមកក្នុងគ្រាសាងរួចស្រេច ។
-ចូលកាន់អារាមសសរស្តម្ភ រាជូបត្ថម្ភកាលនោះស្តេច
ព្រះធម្មាសោកឲ្យសម្រេច រួចហើយក៏ស្តេចប្រតិស្ឋាន ។
-បរិស័ទទាំងឡាយមានសទ្ធា គោរពវន្ទាត្រង់ទីឋាន
ទ្រង់ធ្លាប់គង់នៅទាំងប៉ុន្មាន ហាទ័យប្រោសប្រាណដល់សព្វសត្វ។

និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៩១-វាំងចាស់ព្រះបាទស្តេចឧទេន

-វាំងចាស់ព្រះបាទស្តេចឧទេន ឥឡូវមែនទែនវិនាសខ្ទាត់
សល់តែទីឋានស្តេចសូន្យបាត់ បរិស័ទខំស្កាត់ចូលទស្សនា ។
-ពេលដែលចូលដល់សែនរលឹក ហាទ័យគិតនឹកព្រះសាស្តា

ទ្រង់ធ្លាប់គង់នៅលើអាសនា ត្រាស់ធម៌ទេសនាអនុមោទនា ។
-ព្រះសង្ឃក៏គង់ដោយប្រើប្រាស់ ជាច្រើនរូបណាស់តាមវេលា
តាមការនិមន្តនៃរាជា ឆាន់នូវភោជនាដោយបញ្ញា ។
-យើងខ្ញុំទាំងឡាយរលឹកណាស់ ដល់ព្រះពុទ្ធម្ចាស់ទីនេះណា
សូមក្រាបបង្គំនមស្ការ ដោយចិត្តជ្រះថ្លាក្នុងត្រៃរ័ត្ន ។

ថ្ងៃ ៤ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

* ព្រះពាកុលៈ ប្រសូតមក បាន ៥ ថ្ងៃ ត្រូវត្រីលេប នៅស្ទឹងយមុនា អណ្តែតទៅដល់ពារាណសី, ភិរិយាសេដ្ឋីនៅ ពារាណសី ចិញ្ចឹមរក្សា ។ អាយុ ៨០ ឆ្នាំចេញបួស ។ បួសបាន ៨ ថ្ងៃ បានសម្រេចអរហត្ត ។

## ១៨២-ព្រះពាកុលៈ

-ស្ទឹងយមុនាដ៏វែងឆ្ងាយ មានរឿងទាំងឡាយគួរសិក្សា
ព្រះពាកុលៈនៅកុមារ ត្រូវសត្វមច្ឆាលេបយកទៅ ។
-អណ្តែតចុះដល់ពារាណសី ត្រូវអ្នកចាប់ត្រីចាប់លក់នៅ
មុខផ្ទះសេដ្ឋី ភរិយាទៅ ទិញមកលំនៅវះឃើញកូន ។
-ចិញ្ចឹមរក្សាដោយត្រេកអរ ប្រសើរបវរលើសបងប្អូន
ស្រឡាញ់ដោយស្នេហ៍ថាជាកូន ខ្លាចតែបាត់សូន្យមិនចង់ឃ្លាត។

-ក្រោយមកទៅបួសក្នុងសាសនា ព្រះពុទ្ធបិតាឥតរវាត
ព្យាយាមប្រឹងប្រែងបន្ថែមទៀត ក៏មិនឃ្លៀងឃ្លាតចាកមគ្គផល។

ថ្ងៃ ៤ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១៤៣-ដែនសង្កស្សអចលចេតិយ

* ដែនសង្កស្សអចលចេតិយ ព្រះពុទ្ធជិនស្រីទ្រង់ចាកឋាន
ទេវលោកតាវត្តិង្សប្រសើរថ្កាន បរិស័ទគ្រប់ប្រាណចាំទទួល ។
* អស្សុជ ១៥ ពេញបូណ៌មី ទាំងប្រុសទាំងស្រីបានស្រុះស្រួល
មានចិត្តជ្រះថ្លាឥតប្រែប្រួល រង់ចាំទទួលព្រះសាស្តា ។
* ព្រះពុទ្ធទាំងឡាយមិនលះបង់ ទ្រង់តែងចុះត្រង់ទីនេះណា
អចលចេតិយដ៏អស្ចារ្យ ទាំងមនុស្សទេវតាមកបូជា ។
* ថ្ងៃនេះយើងខ្ញុំមកដល់ហើយ ឥតបង្អង់ឡើយចូលវន្ទា
ទីឋានចេតិយព្រះភគវា ដោយចិត្តសទ្ធាដ៏ឧឡារ ។
* សូធ្យធម៌រំលឹកដល់ព្រះគុណ ដ៏ល្អលើសលន់សាស្តាចារ្យ
សូមបុណ្យកុសលដ៏ថ្លៃថ្លា រួចចាកទុក្ខាទាំងពួងហោង ។

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

# ១៩៤-សតិប្បដ្ឋានព្រះធម្មី

-សទ្ធានាំមុខចរយាត្រា ទៅនមស្ការដល់ពុទ្ធស្ថាន
ព្រះសង្ឃបរិស័ទមិត្តកល្យាណ ឥតមានខកខានក្រុងដៃល្លី ។
-ជាដែនកុរុសម័យមុន ស្រស់ល្អពេកពន់ព្រះមុនី
សម្តែងសតិប្បដ្ឋានព្រះធម្មី បរិស័ទសម្ដីស្តាប់ទេសនា ។
-ជាផ្លូវបរិសុទ្ធនៃសព្វសត្វ ប្រតិបត្តិកម្ចាត់នូវមោហា
លះបង់ទិដ្ឋិនិងតណ្ហា មិនមានសត្តាត្រឹមធម្មៈ ។
-កាយក្នុងកាយវេទនាក្នុងវេទនា ដែលព្រះភគវាទ្រង់បញ្ជាក់
ចិត្តក្នុងចិត្តធម៌ក្នុងធម្មៈ នេះប្រាកដជាក់ឥតមានសត្វ ។
-ភិក្ខុពិចារណាឃើញប្រក្រតី ទាំងមានស្មារតីគ្រឿងកម្ចាត់
អភិជ្ឈាទោមនស្សឲ្យសូន្យបាត់ ឥតមានឃើញសត្វបុគ្គលឡើយ។
-សតិប្បដ្ឋានជាផ្លូវតែមួយពិត គប្បីប្រព្រឹត្តកុំកន្តើយ
ឯកាយនៈណាអ្នកអើយ នាំសត្វដល់ត្រើយរួចផុតចាកទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

# ១៩៥-ស្ថានទីព្រះពុទ្ធមិនលះបង់

* ស្ថានទីព្រះពុទ្ធមិនលះបង់ ប្រសើរផូរផង់ទាំង ៤ ឋាន
ពោធិបល្ល័ង្កប្រសើរថ្កាន ទីដែលទ្រង់បានពោធិញ្ញាណ ។

* អចលបល្ល័ង្កសួនធម្មចក្ក ឋិតនៅប្រចក្សទ្រង់ទូន្មាន
ដល់បញ្ចវគ្គិយឲ្យអាចហ៊ាន រួចទ្រង់ទូន្មានធម៌ធម្មចក្ក ។
* ទ្រង់ចាកទេវលោកតាវត្តិង្ស នេះអ្នកត្រូវដឹងសង្កស្ស
អចលចេតិយនៅប្រចក្ស បរិស័ទស្មោះស្ម័គ្រចូលបូជា ។
* ទីដាក់ចុះជើងគ្រែទាំង៤ ឋិតថេរមាំមួនក្នុងវិហារ
ជេតពនអារាមព្រះភគវា ត្រាស់ព្រះធម្មាដោយករុណា ។
* ខ្ញុំសូមគោរពដល់ទីស្ថាន នេះទាំងប៉ុន្មានដោយជ្រះថ្លា
រលឹកដល់គុណព្រះសម្មា- សម្ពុទ្ធនោះណាគ្រប់ព្រះអង្គ ។
* សូមបុណ្យកុសលជាបច្ច័យ ឧបនិស្ស័យដ៏ផូរផង់
បានជួបសប្បុរសចិត្តស្មោះត្រង់ ស្តាប់ធម៌ពុទ្ធអង្គរួចចាកទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១៩៦-ព្រះធាតុព្រះសម្មាសម្ពុទ្ធ

* មកដល់ទីក្រុងញូដែល្ហី សារមន្ទីរនៃសាសនា
តម្កល់ព្រះធាតុព្រះសម្មា- សម្ពុទ្ធអស្ចារ្យពេកកន្លង ។
* បរិស័ទទាំងឡាយមានសទ្ធា បានចូលវន្ទាឥតមានហ្មង
ថ្វាត់ថ្វាយបង្គំភ្លាមតែម្តង ទៅតាមបំណងដោយជ្រះថ្លា ។
* ព្រះធាតុហែមកពីចេតិយ កបិលពស្តុថ្មីនោះឯងណា

បានតម្កល់ទុកថែរក្សា មន្ទីរនេះណាដោយផ្ចិតផ្ចង់ ។
* ខ្ញុំសូមកម្បង់ផ្គងអញ្ជលី លើកហត្ថទាំងពីរដ៏ផូរផង់
គោរពនឹកដល់ព្រះពុទ្ធអង្គ ដោយចិត្តស្មោះត្រង់ពុទ្ធបិតា ។
* សូមជ្រកក្រោមម្លប់ធម៌វិន័យ ដ៏ល្អប្រពៃព្រះសាស្តា
សូមមានទិដ្ឋិជាសម្មា ស្តាប់ធម៌ទេសនារួចចាកទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១៨៧-បូជាព្រះបរមសារីរិកធាតុ

* ខ្ញុំសែនមានចិត្តសោមនស្សា បូជាបុប្ផានិងចីវរ
ថ្វាយព្រះបរមធាតុចិត្តស្មោះសរ ប្រសើរបវរក្នុងមន្ទីរ ។
* ព្រះធាតុហែពីកបិលពស្តុថ្មី ចាកព្រះចេតិយព្រះមុនី
បរិស័ទទាំងឡាយខំសម្តី ចូលកាន់មន្ទីរដោយរីករាយ ។
* ក្រាបថ្វាយបង្គំនមស្ការ ស្តាប់ព្រះធម៌អាថ៌ឥតនិយាយ
ភាវនាស្ងប់ស្ងៀមមិនរាយមាយ មានចិត្តរីករាយដោយសទ្ធា ។
* ហាទ័យស្មោះស្ម័គ្រនិងមេត្រី ក្នុងព្រះជិនស្រីព្រះភគវា
រួចឧទ្ទិសបុណ្យទាំងអស់គ្នា អនុមោទនារួចចាកទុក្ខ ។

ថ្ងៃ០៧រោចខែកត្តិកពុទ្ធសករាជ២៥៥៩

ដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

ព្រះមានព្រះភាគ ត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលឥតជើងក្តី មានជើង ២ ក្តី មានជើង ៤ ក្តី មានជើងច្រើនក្តី មានរូបក្តី គ្មានរូបក្តី មានសញ្ញាក្តី គ្មានសញ្ញាក្តី មិនមែនជាមិនមានសញ្ញាក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរលើសជាងពួកសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វណាជ្រះថ្លាក្នុងព្រះពុទ្ធ ពួកសត្វទាំងនោះ ឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ផលដ៏ប្រសើរតែងមានដល់ពួកសត្វអ្នកជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ។

# ១៩៨-ព្រះពុទ្ធសម្តែងជយបរិត្ត

* ព្រះពុទ្ធសម្តែងជយបរិត្ត យើងខ្ញុំមានចិត្តសោមនស្សា
ព្យាយាមចូលទៅនមស្ការ កាត់តាមសួនច្បារក៏បានដល់ ។
* ទ្រង់ត្រាស់ពីនក្ខត្តឫក្សល្អ ប្រសើរបវរត្រង់តម្កល់
កាយកម្មជាដើមក្នុងកុសល នោះអ្នកនឹងដល់សុខសួស្តី ។
* មិនថាគ្រហស្ថឬបព្វជិត បើបានប្រព្រឹត្តធ្វើការអ្វី
បានពិចារណាដឹងសេចក្តី ធ្វើដោយឃ្លាតខ្ជីនឹងចម្រើន ។
*សុខក្នុងបច្ចុប្បន្ននិងបរលោក មានជ័យមានជោគកាន់តែច្រើន
ការងារត្រឹមត្រូវនាំកើតកើន ឲ្យសុខចម្រើនរួចចាកទុក្ខ ។

ថ្ងៃ ៥ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

* ព្រះពុទ្ធ ទ្រង់ត្រាស់ថា ៖

**សុនក្ខត្តំ សុមង្គលំ ។ល។**

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ ឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះល្អ ខណៈល្អ យាមល្អ (ទានដែល

បុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ, (ក្នុងថ្ងៃនោះ) កាយកម្ម ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន, សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន, បុគ្គលដែលបានធ្វើកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ។ ( បិដកលេខ ៥១ ទំព័រ៥៧៦)

* ព្រះពុទ្ធទ្រង់ត្រាស់ថា ៖

**នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា**

**អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។**

ប្រយោជន៍ រមែងកន្លងបង់នូវមនុស្សល្ងង់ ដែលរាប់អាននក្ខត្តឫក្ស (ព្រោះ) សេចក្តីចម្រើននៃប្រយោន៍ ឈ្មោះថា នក្ខត្តឫក្ស ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

អដ្ឋកថា ពន្យល់ថា ៖

ពាក្យថា **អត្ថោ អត្ថស្ស នក្ខត្តំ** (សេចក្តីចម្រើននៃប្រយោន៍ ឈ្មោះថា នក្ខត្តឫក្ស) សេចក្តីថា បុគ្គលត្រាច់ស្វែងរកប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថាជាឫក្សរបស់ប្រយោជន៍ ។

## ១៤៩-សេនាបតីសារីបុត្ត

-ទីកន្លែងកើតបរិនិព្វាន រឿងនេះកើតមានដល់ព្រះសាវ័ក
សេនាបតីសារីបុត្តជាក់ ច្បាប់បានបញ្ជាក់ខ្ញុំសូមវន្ទា ។
-រលឹកដល់គុណដ៏អស្ចារ្យ សាវ័កសាស្តាព្រះភគវា
មានគុណតេជះសីលភាវនា និងគុណធម្មាប្រសើរក្រៃ ។

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១៥០-អង្គុលិមាល

-អង្គុលិមាលចិត្តអង់អាច ឃោរឃៅកំណាចកាប់ប្រហារ
តែត្រូវព្រះពុទ្ធសាស្តាចារ្យ ឲ្យលះហិង្សាចូលបព្វជ្ជា ។
-មិនយូរប៉ុន្មានបានសម្រេច ប្រហារកាត់ផ្តាច់កិលេសមារ
កាច់សង្សារចក្កអវិជ្ជា គួរឲ្យបូជាយ៉ាងក្រៃលែង ។

និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១៥១-ឯករាជ្យសព្វសត្វតែងប្រាថ្នា

* ឯករាជ្យសព្វសត្វតែងប្រាថ្នា គឺតែងត្រូវការភាពជាធំ
មានសិទ្ធិសម្រេចក្នុងសង្គម រាល់កិច្ចតូចធំដោយខ្លួនឯង។
* ទោះក្នុងប្រទេសឬគ្រួសារ នេះជាធម្មតាពិតជាក់ស្តែង
ចង់ជាឥស្សរដោយខ្លួនឯង កែខៃតាក់តែងគ្រឿងការពារ។

* តែត្រូវដឹងចុះណាមាសស្ងួន សូម្បីតែខ្លួនណាពុំងា
តែងចាស់ទ្រុឌទ្រោមមានរោគា ថាតើគ្រប់គ្នាធំលើអ្វី។
* កុំចង់គ្រប់គ្រងលើលោកនេះ គួរតែត្រិះរិះដោយស្មារតី
ឃើញនូវទុក្ខទោសកាមលោកីយ៍ ចេញចាកភពបីទើបសុខស្ងប់។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៥២-វិហារផ្កាឈូក

វិហារផ្កាឈូកសាសនាបាហាយ បរិស័ទទាំងឡាយក៏បានចូលដល់
អង្គុយសមាធិលើកចិត្តតម្កល់ ឋិតក្នុងកុសលចម្រើនភាវនា។
ឥតមានប្រកាន់ជាតិសាសនាណា បើអ្នកប្រាថ្នាទៅតាមសទ្ធា
ចូលទៅអង្គុយចម្រើនភាវនា តាមពេលវេលាដែលបានកំណត់។
រលឹកដល់គុណពុទ្ធានុស្សតិ ធម្មានុស្សតិឲ្យបានប្រាកដ
សង្ឃានុស្សតិក៏ឲ្យហ្មត់ចត់ តាមទៅកំណត់គុណដ៏ថ្លៃថ្លា។
កាយស្ងប់ចិត្តស្ងប់ឆ្ងាយចាកបាបធម៌ កុំឲ្យញាប់ញ័រតាមតែតណ្ហា
អប់រំទូន្មានចិត្តឲ្យស្រស់ថ្លា ឋិតក្នុងកុសលានឹងបានសុខពិត។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ព្រះពុទ្ធគាថា ប្រារព្ធនាយទារុសាកដិកៈ

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា

យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណអស់កាលជានិច្ច ទាំងយប់ទាំងថ្ងៃ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រលឹកៗ ដោយប្រពៃសព្វកាល ។

## ១៥៣-ប្រវត្តិកោះលង្កា ជាប់ទាក់ទងនឹងព្រះពុទ្ធ

ដូចបានស្ដាប់មកថា ក្នុងអតីតកាល ទ្វីបនេះ (កោះលង្កា) មានឈ្មោះថា **ឱជទ្វីប** ។ ព្រះរាជាមានព្រះនាមថា **អភ័យ** ។ រាជធានី ឈ្មោះថា **អភយបុរៈ** ។ ចេតិយបព្វតៈ មានឈ្មោះថា **ទេវកូដបព្វតៈ** ។ ចូបារាម មានឈ្មោះថា **បដិយារាមៈ** ។ ព្រះមានព្រះភាគ ព្រះនាម កកុសន្ធៈ ត្រាស់ដឹងឡើងក្នុងលោក ទ្រង់យាងមកកាន់កោះនេះ មួយអន្លើដោយភិក្ខុ ៤០,០០០ រូប ដើម្បីរម្ងាប់រោគបជ្ជរកៈ និងសម្ដែងធម៌ប្រោស ធម្មាភិសម័យ បានមានដល់សត្វ ៨៤,០០០ ។ ព្រះមានព្រះភាគ បានប្រទានធម្មក្រកទុក ហើយស្ដេចជៀសទៅ ។ អ្នកក្រុងសាងព្រះចេតិយក្នុងបដិយារាម បញ្ចុះធម្មក្រកនោះទុកខាងក្នុង ។ ព្រះមហាទេវៈ បាននៅប្រៀនប្រដៅអ្នកកោះ។

ចំណែកក្នុងសម័យកាលព្រះមានព្រះភាគ **កោនាគមនៈ** ទ្វីបនេះ មានឈ្មោះថា វរទ្វីប ។ ព្រះរាជា មានព្រះនាមថា សមិទ្ធិ ។ រាជធានី ឈ្មោះថា វឌ្ឍមាន ។ ចេតិយបព្វតៈ មានឈ្មោះថា សុវណ្ណកូដ ។ ព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ ត្រាស់ដឹងឡើងក្នុងលោក ទ្រង់យាងមកកាន់កោះនេះ មួយអន្លើដោយភិក្ខុ ៣០,០០០ រូប ។ ដោយពុទ្ធានុភាព ភ្លៀងបានធ្លាក់ត្រូវតាមរដូវកាល។ ភិក្ខាហារក៏រកបានងាយ ។ ទ្រង់បានសម្តែងធម៌ប្រោស ធម្មាភិសម័យ បានមានដល់សត្វ ៨៤,០០០ ។ ព្រះមានព្រះភាគ ឃាត់ព្រះថេរព្រះនាមថា មហាសុមនៈ ដែលមានភិក្ខុ ១,០០០ រូប ជាបរិវារទុកឲ្យនៅក្នុងកោះ ។ បានប្រទានវត្ថពន្ធចង្កេះនោះទុកហើយស្តេចជៀសទៅ ។ ជនទាំងឡាយបានសាងព្រះចេតិយបញ្ចុះវត្ថពន្ធចង្កេះនោះទុកខាងក្នុង ។

ម្យ៉ាងទៀត ក្នុងកាលនៃព្រះមានព្រះភាគ ព្រះនាមថា កស្សបៈ កោះនេះមានឈ្មោះថា មណ្ឌទ្វីប ។ ព្រះរាជាមានព្រះនាមថា ជយន្ត ។ រាជធានី ឈ្មោះថា វិសាល ។ ភ្នំឈ្មោះ សុភកូដ ។ ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ត្រាស់ដឹងឡើងក្នុងលោក ទ្រង់យាងមកកាន់កោះនេះ មួយអន្លើដោយភិក្ខុ ២០,០០០ រូប ។ ស្តេចមករម្ងាប់វិវាទ ហើយសម្តែងធម៌ប្រោស ធម្មាភិសម័យ បានមានដល់សត្វ ៨៤,០០០ ។ ព្រះមានព្រះភាគ ទ្រង់ញាំងព្រះថេរព្រះនាមថា សព្វនន្ទី ដែលមានភិក្ខុ ១,០០០

រូប ជាបរិវារទុកឲ្យនៅក្នុងកោះនេះ ។ បានប្រទានឧទកសាដទុក ហើយស្ដេចជៀសទៅ ។ អ្នកកោះ បានសាងព្រះចេតិយបញ្ចុះឧទកសាដកនោះទុកខាងក្នុង ។ បរិភោគចេតិយ របស់ព្រះសម្មាសម្ពុទ្ធអង្គមុនៗ ព្រះអង្គប្រតិស្ឋាននៅហើយក្នុងថូបារាម ដោយប្រការដូច្នេះ ។

## ១៥៤-តម្ពបណ្ណិទ្វីប

( បទពាក្យ ៧ )

១-តម្ពបណ្ណិទ្វីបលង្កា ទ្វីបព្រះសាស្ដាធ្លាប់ប្រើប្រាស់
ជាច្រើនកន្លែងប្រាកដណាស់ មានពិតយ៉ាងច្បាស់ជាចេតិយ ។
២-ទី១ យាងមកទូន្មានយក្ខ ច្បាប់បានបញ្ជាក់ថាជិនស្រី
ទ្រង់ប្រទក្សិណទីទឹកដី អស់វារៈបីជុំមែនពិត ។
៣-ទី២ យាងមកទូន្មាននាគ ពួកក្មួយជានាគមិនប្រព្រឹត្ត
ស្រុះស្រួលសាមគ្គីគ្នាមូលមិត្រ ប្រុងចូលមកជិតប្រយុទ្ធគ្នា ។
៤-ទី៣ យាងមកជាមួយសង្ឃ ៥០០ ព្រះអង្គដោយឥទ្ធា
ចូលសមាបត្តិទីនានា ទីនោះបានជាចេតិយឋាន ។
៥-មហាចេតិយ-ថូបារាម ពិតជាអារាមដ៏ថ្កើងថ្កាន
មហាពោធិ-ព្រឹក្សទីឋាន ក៏ព្រះទ្រង់បានគង់ផងដែរ ។

៦-មុតិង្គណចេតិយផង ពិតល្អកន្លងមិនប្រួលប្រែ
គួរយើងបានឃើញក៏ប៉ុន្តែ មិនអាចបានក្បែរព្រោះហេតុអ្វី ។
៧-ឯចេតិយទីយវាបិ និងកល្យាណិព្រះជិនស្រី
ក៏ទ្រង់ប្រើប្រាស់ទីទឹកដី បានជាចេតិយគួរបូជា ។
៨-ម្យ៉ាងទីកោះនេះល្អពេកណាស់ ព្រះអង្គបានត្រាស់តាមធម្មា
សាសនាព្រះពុទ្ធព្រះភគវា ឋិតនៅយូរយារប្រាកដពិត ។
៩-ស្ថានទីទាំងឡាយគ្រប់កន្លែង គួរឱ្យស្ងប់ស្ងែងល្អប្រណិត
គឺជាស្ថានទីដ៏វិសិដ្ឋ គួរចម្រើនចិត្តជាកុសល ។
១០-ខ្ញុំសូមវន្ទានមស្ការ ទីឋាននេះណាឧទ្ទិសដល់
គុណព្រះសម្ពុទ្ធ សូមកុសល បានសម្រេចផលព្រះនិព្វាន ។

ថ្ងៃ ៥ រោច ខែផល្គុន ពុទ្ធសករាជ២៥៥៦
និពន្ធដោយភិក្ខុ ភួង-សុវណ្ណ

## ១៥៥-មហាអធិដ្ឋាន៥ប្រការរបស់ព្រះមានព្រះភាគ

ព្រះមានព្រះភាគ ទ្រង់ផ្ទំលើគ្រែបរិនិព្វាន ទ្រង់បានអធិដ្ឋានថា ៖

១- ដើម្បីត្រូវការឲ្យដើមមហាពោធិព្រឹក្ស ប្រតិស្ឋានក្នុងលង្កាទ្វីប ព្រះបាទអសោកមហារាជ នឹងស្ដេចមកទទួលដើម

មហាពោធិព្រឹក្ស ក្នុងវេលានោះ មែកមហាពោធិព្រឹក្ស ក្នុងទិសទក្សិណចូរដាច់ឯងតែម្តង ហើយប្រតិស្ឋាននៅក្នុងផើងមាស ។

២- ក៏ក្នុងវេលាប្រតិស្ឋាននៅក្នុងផើងមាសនោះ មហាពោធិព្រឹក្ស ចូរអណ្តែតចូលទៅកាន់ស្រទាប់ហិមវលាហកៈ (ពពកត្រជាក់) តាំងនៅ ។

៣- ក្នុងថ្ងៃទី ៧ ដើមមហាពោធិព្រឹក្ស ចូរអណ្តែតចុះមកអំពីស្រទាប់ហិមវលាហកៈ តាំងនៅក្នុងផើងមាស បញ្ចេញឆព្វណ្ណរង្សីអំពីស្លឹក និងផ្លែទាំងឡាយ ។

៤- ព្រះធាតុដងកាំបិតខាងស្តាំ ចូរធ្វើយមកបាដិហារ្យ ក្នុងថ្ងៃប្រតិស្ឋាន នៅឯព្រះចេតិយថូបារាម ។

៥- ព្រះធាតុរបស់យើងប្រមាណមួយទោណៈ (២ នាឡិ) ក្នុងកោះលង្កានេះឯង ក្នុងវេលាប្រតិស្ឋាននៅក្នុងមហាចេតិយចូរប្លែងភេទជាព្រះពុទ្ធ ហើយហោះឡើងកាន់អាកាស ធ្វើយមកបាដិហារ្យ ។ (ចាកអដ្ឋកថាព្រះវិន័យ ឈ្មោះសមន្តប្បាសាទិកា)

ក្នុងអដ្ឋកថា សមន្តប្បាសាទិកាដដែល បានបញ្ជាក់ថា ៖

បានឮមកថា ព្រះមានព្រះភាគ កាលទ្រង់នៅមានព្រះជន្មនោះឯង ទ្រង់បានអធិដ្ឋានថា

កាលតថាគតបរិនិព្វានហើយ យមកបាដិហារ្យចូរមានក្នុងថ្ងៃប្រតិស្ឋានព្រះធាតុដងកាំបិតខាងស្តាំរបស់យើង លើទី

តាំងបរិភោគចេតិយរបស់ព្រះពុទ្ធអង្គមុនៗ ៣ ព្រះអង្គ ខាងទិសទក្សិណនៃអនុរាធបុរី ក្នុងកោះតម្ពបណ្ណិទ្វី ដូច្នេះ ។

**ឯវំ អចិន្តិយា ពុទ្ធា ពុទ្ធធម្មា អចិន្តិយោ**
**អចិន្តិយេ បសន្នានំ វិបាកោ ហោតិ អចិន្តិយោ ។**

ព្រះពុទ្ធ ជាអចិន្ត្រៃយ៍ ព្រះធម៌របស់ព្រះពុទ្ធ ក៏ជាអចិន្ត្រៃយ៍ វិបាក (ផល) របស់ពួកជនអ្នកជ្រះថ្លាក្នុងព្រះពុទ្ធ និងព្រះគុណរបស់ព្រះពុទ្ធដែលជាអចិន្ត្រៃយ៍ ក៏ជាអចិន្ត្រៃយ៍ ដោយន័យដូចពោលមកដូច្នេះឯង ។

## ១៥៦-ព្រះពុទ្ធធ្លាប់យាងទៅកោះលង្កា

បានឮថា ព្រះសម្មាសម្ពុទ្ធ បានស្តេចយាងទៅកាន់កោះនេះ (កោះលង្កា) ៣ ដង សូម្បីក្នុងគ្រានៅមានព្រះជន្ម គឺក្នុងគ្រាដំបូងស្តេចមកតែមួយព្រះអង្គឯងប៉ុណ្ណោះ ដើម្បីទូន្មានយក្ខ គ្រាទូន្មានយក្ខហើយ ទ្រង់តាំងការរក្សាកោះតម្ពបណ្ណិទ្វីប ស្តេចប្រទក្សិណកោះ ៣ ជុំ តាំងព្រះទ័យថា កាលតថាគតបរិនិព្វានហើយ សាសនារបស់តថាគតនឹងប្រតិស្ឋាននៅលើកោះនេះ ។

គ្រាទី ២ ព្រះអង្គស្តេចយាងមកតែមួយព្រះអង្គឯងដូចគ្នា ដើម្បីត្រូវការទូន្មានស្តេចនាគ ដែលជាឪ និងក្មួយ គ្រាទូន្មាននាគទាំងនោះហើយ បានស្តេចយាងទៅ ។

គ្រាទី ៣ ព្រះអង្គស្តេចយាងមកជាមួយភិក្ខុ ៥០០ រូប ជាបរិវារ ប្រថាប់គង់ចូលនិរោធសមាបត្តិ ក្នុងទីតាំងមហាចេតិយ ទីតាំងថូបារាមចេតិយ ទីប្រតិស្ឋានមហាពោធិព្រឹក្ស ទីតាំងមុតិង្គណចេតិយ ទីតាំងទីឃវាបិចេតិយ និងទីតាំងកល្យាណិចេតិយ ។

ការមកដោយព្រះសរីរធាតុគ្រានេះ ជាលើកទី ៤ របស់ព្រះមានព្រះភាគអង្គនោះ។ ក៏ឯដែលឈ្មោះថា ឱកាសតិចតួចលើផែនដីកោះតម្ពបណ្ណិទ្វីប ដែលតំណក់ទឹកខ្ទាតខ្ទាយចេញចាកព្រះសរីរធាតុរបស់ព្រះមានព្រះភាគនោះ មិនពាល់ត្រូវមិនមានទេ ។ ព្រះសរីរធាតុរបស់ព្រះមានព្រះភាគអង្គនោះ ញុំាងកម្តៅរបស់ផ្ទៃផែនដីកោះតម្ពបណ្ណិទ្វីប ឲ្យស្ងប់រម្ងាប់ដោយគ្រាប់ភ្លៀងសម្តែងបាដិហារ្យដល់មហាជនហើយ ចុះប្រតិស្ឋានលើក្បាលរបស់ព្រះរាជា ដោយប្រការយ៉ាងនេះ ។ ព្រះរាជាទ្រង់សម្គាល់ការបានអត្តភាពជាមនុស្ស ដែលមានផល ទ្រង់ធ្វើសក្ការៈធំ ឲ្យបញ្ចុះព្រះធាតុហើយ ព្រមដោយការបញ្ចុះព្រះធាតុបានកើតមានការញាប់ញ័រផែនដី ។

# ១៥៧_ថូបារាមចេតិយ

( បទពាក្យ ៧ )

១-ថូបារាមចេតិយដ៏វិសិដ្ឋ យើងខ្ញុំមានចិត្តសោមនស្សា
ព្រោះជាកន្លែងព្រះសម្មា- សម្ពុទ្ធនោះណាធ្លាប់ប្រើប្រាស់ ។
២-ទីនេះជាទីព្រះចេតិយ នៃព្រះជិនស្រីប្រាកដណាស់
តាំងពីបូរាណយ៉ាងត្រចះ ប្រសើរល្អល្អះដ៏ឧឡារ ។
៣-តម្កល់ធម្មក្រកព្រះសម្ពុទ្ធ ជាព្រះសុគតសាស្តាចារ្យ
កកុសន្ធៈដ៏ថ្លៃថ្លា ទ្រង់ករុណាប្រទានឱ្យ ។
៤-តម្កល់កាយពន្ធព្រះមានជោគ ជាបរិភោគចេតិយហើយ
ពិតមានតម្លៃមិនតិចឡើយ យើងកុំតោះតើយត្រូវកោតក្រែង ។
៥-តម្កល់ឧទកសាដកៈ ពិតជាសមសក្តិគួរស្ញប់ស្ញែង
នៃព្រះកស្សបៈត្រង់នេះឯង តាមច្បាប់សម្តែងទីស្អាតល្អ ។
៦-តម្កល់ព្រះធាតុដងកាំបិត ឧត្តមប្រណិតដ៏បវរ
នៃព្រះគោតមវិសេសល្អ ចិត្តខ្ញុំត្រេកអរសូមវន្ទា ។
៧-បង្អោនកាយចិត្តពោលវាចា សូធ្យនមស្ការស្តាប់ធម្មា
បូជាភ្ញីផ្កាផងនានា ដោយចិត្តសទ្ធាក្នុងត្រៃរ័ត្ន ។

៨-សូមទូន្មានចិត្តឱ្យបានស្អាត តាមពុទ្ធឱវាទដោយហ្មត់ចត់
ព្យាយាមប្រឹងប្រែងដោយអំណត់ ឱ្យបានប្រាកដក្នុងកុសល ។
៩-វិការវន្ទានមស្ការ ទីឋាននេះណា ឧទ្ទិសដល់
គុណព្រះសម្ពុទ្ធ សូមកុសល បានសម្រេចផលព្រះនិព្វាន ។

ថ្ងៃ ៥ រោច ខែផល្គុន ព.ស.២៥៥៦ ដោយភិក្ខុ ភួង-សុវណ្ណ

## ១៥៨~សុមនកូដ

១-សុមនកូដា ភ្នំព្រះសាស្តា ទ្រង់ប្រតិស្ឋាន
នូវស្នាមព្រះបាទ ប្រសើរថ្កើងថ្កាន បរិស័ទតែងបាន
ឡើងនមស្ការ ។
២-មានការព្យាយាម ចិត្តឥតទាក់ទាម ហេតុតែជ្រះថ្លា
ចំពោះព្រះអង្គ ជាព្រះសម្មា- សម្ពុទ្ធអស្ចារ្យ
គួរឱ្យកោតក្រែង ។
៣-ក្រាបថ្វាយបង្គំ លើកដៃក្រពុំ ដោយការសម្តែង
នូវការគោរព ត្រង់ទីកន្លែង ព្រះបាទនោះឯង
នៃព្រះសម្ពុទ្ធ ។

៤-សូធ្យនមស្ការ បញ្ចេញវាចា ដោយចិត្តមោះមុត
ឱនកាយបន្ទន់ ឆ្ពោះព្រះសុគត ព្រះតថាគត
ទ្រង់ជាភគវា ។

៥-ដាក់នូវសីសៈ ដោយចិត្តស្មោះស្ម័គ្រ ទៀបព្រះបាទា
ម្តងហើយម្តងទៀត ឥតមានរួញរា ដោយចិត្តសទ្ធា
ព្រមដោយបញ្ញា ។

៦-សូធ្យធម៌រំលឹក គុណដ៏ពន្លឹក នៃព្រះសាស្តា
សូធ្យហើយសូធ្យទៀត ព្រោះមានប្រាថ្នា ឱ្យបានច្រើនសា
ច្រើនចប់នោះឯង ។

៧-ខ្ញុំសូមបូជា វត្ថុនានា ដោយការចាត់ចែង
សូម្បីតិចតួច ដើម្បីសម្តែង ទឹកចិត្តនេះឯង
គោរពវន្ទា ។

៨-មយ៉ាងការសិក្សា ក្នុងត្រៃសិក្ខា គ្រប់ពេលវេលា
ទោះជាយ៉ាងណា ខ្ញុំសូមបូជា ដល់ព្រះភគវា
ក្នុងគ្រានេះហោង ។

ថ្ងៃ ៤ រោច ខែផល្គុន ពុទ្ធសករាជ២៥៥៦
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៥៩-សូមជូនបុណ្យ

*ធម្មទានក្តីការគោរពក្តី បូជាជិនស្រីដោយចិត្តសទ្ធា
រលឹកដល់គុណនៃព្រះភគវា តាមទីនានាដែលជាពុទ្ធស្ថាន។
*សូមបុណ្យកុសលបានជាបច្ច័យ ឧបនិស្ស័យដាក់ដល់ភូមិឋាន
ទីបរមសុខប្រសើរថ្កើងថ្កាន បានសុខក្សេមក្សាន្តរួចចាកទុក្ខហោង។
*ម្យ៉ាងទៀតសូមឲ្យមនុស្សទេវតា និងញាតិវង្សាមិត្តសម្លាញ់ផង
សាធុទទួលដោយចិត្តហ្មត់ហ្មង បានឆ្លងកន្លងផុតចាកទុក្ខដែរ។

ដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

# ១៦០-សាធុ សាធុ ចិត្តត្រេកអរ

* សាធុសាធុ ចិត្តត្រេកអរ ដំណើរបវរតទៅមុខ
សាធុសាធុសន្សំទុក អាចរួចចាកទុក្ខព្រោះបុណ្យជួយ ។
* សាធុសាធុដោយរីករាយ ស្រស់ល្អពណ្ណរាយបំបាត់ព្រួយ
សាធុសាធុមិនតែមួយ បានជាជំនួយស្រីសួស្តី ។
* សាធុសាធុមិនអល់អែក គឺថាសូមចែកដោយមេត្រី
សាធុសាធុចិត្តភក្តី សូមបានសិរីពីបុញ្ញា ។
* សាធុសាធុយកកុសល សង្ឃឹមបានផលដូចប្រាថ្នា
សាធុសាធុឆ្លងសង្សារ រួចចាកទុក្ខាដល់និព្វាន ។

ថ្ងៃ ៧ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

ដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ១៦១-សាធុ សាធុ

>សាធុសាធុ អនុមោទនា　　មានចិត្តសទ្ធាដ៏ថ្លៃថ្លា
ខំប្រឹងសន្សំបុញ្ញកិរិយា　　សូមសាធុការអនុមោទនា ។
>សាធុសាធុ ដោយចិត្តបុណ្យ　　ប្រសើរពេកពន់ឥតគណនា
សាធុសាធុ ដោយសទ្ធា　　គ្រប់ពេលវេលាសុខចម្រើន។
>សាធុសាធុ ចិត្តត្រេកអរ　　ប្រសើរបវរនាំកើតកើន
ដោយចិត្តសោមនស្សខំក្រវើន　　ពិតនាំចម្រើនសុខសិរី ។
>សាធុសាធុចិត្តជ្រះថ្លា　　សាងបុញ្ញកិរិយាដោយលកលៃ
ទទួលយកបុណ្យដោយប្រពៃ　　ឥតមានមោះមៃមួយវេលា ។
>សាធុសាធុល្អខ្លាំងណាស់　　ដោយបានយល់ច្បាស់ក្នុងធម្មា
ខំសន្សំបុណ្យគ្មានលស់គ្រា　　ដើរតាមមាគ៌ានៃសប្បុរស ។
>សាធុសាធុ ចិត្តខ្ពស់ឯក　　គ្មានអ្វីចម្លែកចិត្តស្ម័គ្រស្មោះ
សាធុសាធុ យកទាំងអស់　　យកដោយចិត្តស្មោះនូវកុសល ។
>សាធុសាធុ គ្រប់កិច្ចការ　　ជាបុញ្ញកិរិយាគួរតម្កល់
ចិត្តជាសម្មាក្នុងកុសល　　នឹងទទួលផលសុខក្សេមក្សាន្ត ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៦២-សាធុសាធុ, ប្រពៃណាស់

>សាធុសាធុ,ប្រពៃណាស់　　ព្រោះបានយល់ច្បាស់បុញ្ញកិរិយា
ខំសាងសន្សំចិត្តជ្រះថ្លា　　សូមសាធុការអនុមោទនា។

>សាធុសាធុ,ប្រពៃណាស់ ចិត្តល្អត្រចះដោយសទ្ធា
លះទ្រព្យធនធានធ្វើបូជា ដើរតាមមាគ៌ានៃសប្បុរស ។
>សាធុសាធុ,ប្រពៃណាស់ ល្អឥតមានខ្វះល្អទាំងអស់
ឲ្យទានកាន់សីលធ្វើដោយស្មោះ ពុំមានអាឡោះអាល័យស្តាយ។
>សាធុសាធុ,ប្រពៃណាស់ នៅក្មេងមិនចាស់ចិត្តស្រស់ស្រាយ
សន្សំកុសលចិត្តសប្បាយ ឥតមាននឿយណាយសូមសាធុ។

ថ្ងៃ១៣ កើត ខែស្រាពណ៍ ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៦៣_សាធុសាធុ, ល្អប្រពៃ

-សាធុសាធុ! ល្អប្រពៃ អ្នកបានលកលៃសាងសន្សំ
នូវកុសលកម្ម ដោយខិតខំ ប្រសើរឧត្តម ដ៏ឧឡារ ។
-សូមកុសលធម៌ជួយទ្រទ្រង់ ឆ្លងផុតអន្លង់ ៤ ប្រការ
សូមជួបសប្បុរសដ៏ថ្លៃថ្លា មានចិត្តសម្មាយល់ត្រូវពិត ។
-សូមមានសទ្ធាមានបញ្ញា សូមបានចរចានឹងបណ្ឌិត
ស្តាប់ធម៌ទេសនាអាចប្រព្រឹត្ត ត្រាស់ដឹងធម៌ពិតរួចចាកទុក្ខ ។
-សូមឱ្យសព្វសត្វអនុមោទនា មានចិត្តសទ្ធាជាប្រមុខ
ត្រេកអរក្នុងបុណ្យសន្សំទុក បានរួចចាកទុក្ខទាំងពួងហោង ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ១០រោច ខែមិគសិរ ព.ស.២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៦៤-ពាក្យសាធុការ

>ពាក្យសាធុការជាពាក្យសប្បុរស ប្រពៃឥតខ្ចោះប្រកបដោយគុណ
សម្រាប់អ្នកឆ្លាតសន្តានទន់ភ្លន់ វាចាទោរទន់អនុមោទនា ។
>ពាក្យសាធុការពិតពីរោះណាស់ បញ្ជាក់យ៉ាងច្បាស់ពីចិត្តសទ្ធា
រីករាយក្នុងបុណ្យអនុមោទនា គ្រប់ពេលវេលានាំសុខចម្រើន។
>ពាក្យសាធុការជាបុញ្ញកិរិយា កុសលចេតនានាំឲ្យកើតកើន
បុណ្យបូកនិងបុណ្យគឺកាន់តែច្រើន ឲ្យសុខចម្រើនរួចផុតទុក្ខភ័យ។
>ពាក្យសាធុការមានដរាបណា នេះបញ្ជាក់ថាជាភាពប្រពៃ
មនុស្សសាងសុចរិតដោយការលកលៃ ចិត្តឥតមោះមៃក្នុងសេចក្តីល្អ។
>ពាក្យសាធុការបន្លឺឡើងហើយ អ្នកកុំកន្តើយមានចិត្តបវរ
ទទួលយកបុណ្យយកសេចក្តីល្អ ដោយចិត្តស្មោះសរនាំបានសុខស្ងប់។

ថ្ងៃ១៤ កើត ខែបឋមាសាឍ ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៦៥-បុណ្យបូកនិងបុណ្យ

* សម្រាប់អ្នកឆ្លាតពិតអាចហ៊ាន ប្រព្រឹត្តសមាទាននូវកុសលា
ធ្វើដោយខ្លួនឯងឬជ្រះថ្លា នូវបុញ្ញកិរិយាដែលគេឲ្យ។
* បុណ្យពិតមានគុណប្រសើរក្រៃ គឺមានតម្លៃមិនតិចឡើយ
ព្រោះហេតុដូច្នោះកុំកន្តើយ បើគេចែកឲ្យអនុមោទនា។

* កុំគិតថាវាមិនសំណំ ត្រូវចេះផ្សែផ្សំដោយសទ្ធា
បុណ្យបូកនិងបុណ្យផ្គុំចូលគ្នា បានពេញហូរហៀរប្រាកដណាស់។
* បុណ្យជួយឲ្យសុខឲ្យសប្បាយ ផុតចាកអបាយរួចស្រឡះ
ស្រស់ថ្លារុងរឿងភ្លឺត្រចះ នឹងបានជាក់ច្បាស់សច្ចធម៌។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៦៦-ចូលវិហារ

-ពេលព្រឹកឬល្ងាចចូលវិហារ បង្គំវន្ទាត្រៃរតនា
អង្គុយសមាធិផ្សាយមេត្តា សូមសព្វសត្តាបានសុខស្ងប់។
-កុំឲ្យមានពៀរកុំព្យាបាទ បៀតបៀនប្រមាថប្រទូស្តស្អប់
គំនុំក្នុងចិត្តសូមបញ្ចប់ សូមបានប្រសព្វសុខឥតទុក្ខ។
-គប្បីមានខ្លួនជាឧបមា ផ្សព្វផ្សាយមេត្តាជាប្រមុខ
ទិសតូចទិសធំតម្កល់ទុក ផ្សាយឥតរើសមុខជាធម្មតា។
-ព្រហ្មវិហារធម៌ប្រសើរពិត បើបានប្រព្រឹត្តចិត្តស្រស់ថ្លា
មេត្តាករុណាមុទិតា និងឧបេក្ខាមួយទៀតផង។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៦៧-ការចម្រើនមេត្តាចិត្ត

* គួរចម្រើនមេត្តាចិត្តចំពោះខ្លួនឯងជាមុន ថា < **អហំ សុខិតោ ហោមិ និទ្ទុក្ខោ:** សូមឲ្យអាត្មាអញ បានដល់នូវសេចក្តីសុខ កុំមានទុក្ខឡើយ > ដូច្នេះ ។

ឬចម្រើនថា < **អវេរោ អព្យាបជ្ឈោ អនីឃោ សុខី អត្តានំ បរិហារាមិ:** សូមឲ្យអាត្មាអញ ជាបុគ្គលគ្មានពៀរ គ្មានទុក្ខ គ្មានទោស ឲ្យមានតែសេចក្តីសុខ សូមរក្សាខ្លួនឲ្យបានយ៉ាងនេះជាដរាបទៅ > ដូច្នេះ ក៏បាន ។

* បន្ទាប់មកទៀត ចម្រើនមេត្តាចិត្តចំពោះបុគ្គលដែលគួរគោរព ថា < **ឯស សប្បុរិសោ សុខិតោ ហោតុ និទ្ទុក្ខោ:** សូម ឲ្យលោកជាសប្បុរសនោះ បានដល់នូវសេចក្តីសុខ កុំមានទុក្ខឡើយ > ដូច្នេះ ។

* បន្ទាប់មកទៀត គប្បីចម្រើនមេត្តាចិត្តចំពោះសព្វសត្វ ថា < **សុខិនោ វា ខេមិនោ ហោន្តុ សព្វេ សត្តា ភវន្តុ សុខិតត្តា:** សត្វទាំងឡាយទាំងពួង សូមឲ្យមានសេចក្តីសុខ ឲ្យមានសេចក្តីក្សេម ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ > ដូច្នេះ ។

# ១៦៨-អានិសង្សមេត្តាមាន ១១ ប្រការ

(វិនយបិដក ភាគ១៣ ទំព័រ១០៤)

មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឱ្យថ្មឹកហើយ ចម្រើនហើយ ធ្វើឱ្យក្រាស់ក្រែលហើយ ធ្វើឱ្យដូចជាយានជំនិះហើយ ធ្វើឱ្យជាទីនៅហើយ ឱ្យតាំងនៅញឹកញយហើយសន្សំទុកមិនឱ្យបាត់ ប្រារព្ធដោយល្អហើយ នឹងមានអានិសង្ស ១១ ប្រការ ជាពិតប្រាកដ គឺ

បុគ្គលនោះដេកលក់ជាសុខ ១ ភ្ញាក់ឡើងជាសុខ ១ មិនយល់សុបិនអាក្រក់ ១ ជាទីស្រឡាញ់របស់ពួកមនុស្ស ១ ជាទីស្រឡាញ់របស់ពួកអមនុស្ស ១ ពួកទេវតាតែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ក៏មិនប៉ះពាល់ដល់បុគ្គលនោះ ១ ចិត្តបុគ្គលនោះ រមែងចូលកាន់សមាធិដោយរួសរាន់ ១ បុគ្គលនោះ មានពណ៌សម្បុរមុខស្រស់បស់ ១ បុគ្គលនោះ មិនបានវង្វេងស្មារតីធ្វើមរណកាល ១ កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ទេ ជាអ្នកបានទៅកើតក្នុងព្រហ្មលោក ១ ។

# ១៦៩-បីតិក្នុងធម៌

* បីតិក្នុងធម៌ពិតល្អប្រសើរ គឺជាដំណើររបស់សប្បុរស
ចង់សិក្សាស្ដាប់លើសអ្វីទាំងអស់ ទឹកមុខស្រស់បស់ព្រោះយល់ធម្មា។
* សិក្សាស្ដាប់ហើយប្រឹងប្រតិបត្តិ តាមបរិយត្តិដោយចិត្តសទ្ធា
សតិបញ្ញាចិន្តាម្ទីម្នា តាមពេលវេលានឹងបានសម្រេច ។
* មគ្គផលនិព្វាននៅមិនឆ្ងាយទេ ប្រសិនមាសមេព្យាយាមកាត់ផ្ដាច់
តណ្ហាមានះទិដ្ឋិបានដាច់ នោះនឹងសម្រេចមគ្គផលនិព្វាន ។
* កើតចាស់ឈឺស្លាប់មានតាមធម្មតា ព្រោះតែតណ្ហាអវិជ្ជានៅមាន
ត្រូវរងទុក្ខសោកលំបាកស្រែកឃ្លាន ផ្ទុយពីនិព្វានគឺជាអមតៈ ។

ថ្ងៃ ០៦រោច ខែអស្សុជ ព.ស.២៥៥៩

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៧០-ជីវិតរស់នៅដោយបញ្ញា

* ជីវិតរស់នៅដោយបញ្ញា ប្រព្រឹត្តធម៌អាចពិតប្រសើរ
យល់ស្គាល់ការពិតតាមដំណើរ មានចិត្តស្មោះស្មើជាប្រក្រតី ។
* ទោះមានឬក្រក៏ដោយចុះ បើចេះសន្ដោសទាំងប្រុសស្រី
មានចិត្តមេត្តាប្រោសប្រណី ស្មោះស្ម័គ្រភក្ដីកើតមង្គល ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៧១-ព្រះពុទ្ធវចនៈគ្មានអ្វីស្មើ

*គម្ពីរបិដកអដ្ឋកថា មានន័យខ្លឹមសារដ៏ជ្រាលជ្រៅ
គួរពុទ្ធបរិស័ទប្រឹងប្រែងទៅ សិក្សាស្គាល់ផ្លូវប្រតិបត្តិ ។
*ព្រះពុទ្ធវចនៈធម៌វិន័យ ដ៏ល្អប្រពៃជាបរិយត្តិ
បើអ្នកយល់ដឹងអាចកម្ចាត់ មោហៈឲ្យខ្ចាត់ពីសន្តាន ។
*រៀនច្រើនស្តាប់ច្រើនកើនបញ្ញា ស្មារតីភ្លឺថ្លាជាក់ពុំខាន
ប្រាជ្ញាយល់ត្រូវពិតកល្យាណ ធ្វើអ្វីក៏បានល្អប្រសើរ ។
*ដូច្នេះគប្បីខំសិក្សា បិដកដីកាតាមដំណើរ
ព្រះពុទ្ធវចនៈគ្មានអ្វីស្មើ មគ្គដ៏ប្រសើរផ្លូវផុតទុក្ខ ។

ល្ងាចថ្ងៃ ១០ កើត ខែជេស្ឋ ព.ស.២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៧២-សិក្សាគាថា

១-សិក្សាគាថា តាមព្រះសាស្តា ទ្រង់ត្រាស់សម្តែង
ពិតជាព្រះធម៌ គួរឱ្យស្ងប់ស្ងែង គ្រប់ទីកន្លែង
ក្រុងនិងជនបទ ។

២-ត្រាស់ដល់ជនណា មនុស្សទេវតា ត្រាស់យ៉ាងហ្មត់ចត់
សុទ្ធមានលំអ គ្រប់បាទគ្រប់បទ ត្រាស់ដឹងប្រាកដ

នូវព្រះធម៌ថ្លៃ ។

៣-ធម៌បរិសុទ្ធ គួរយើងលំអុត រៀនសូធ្យរាល់ថ្ងៃ
ប្រព្រឹត្តតាមធម៌ ពិតមានតម្លៃ បានជាបច្ច័យ
នៃក្តីសុខពិត ។

៤-ធម៌តែងរក្សា ដល់លោកអ្នកណា ជាអ្នកប្រព្រឹត្ត
ធម៌គួរដល់ធម៌ មិនឱ្យវិបរិត នឹងបានសុខពិត
គឺសេចក្តីស្ងប់ ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៧៣-វិសុទ្ធិមគ្គ

ក្នុងគម្ពីរវិសុទ្ធិមគ្គ បានសម្តែងពីវិសុទ្ធិមគ្គ (ផ្លូវនៃសេចក្តីបរិសុទ្ធ) ដោយលើកយកព្រះពុទ្ធដីកាដែលព្រះអង្គសម្តែងពីវិសុទ្ធិមគ្គ ដោយន័យផ្សេងៗ ដោយអំណាចនៃគុណជាតមានកម្មជាដើម ។

ដូចទ្រង់សម្តែងថា :

**កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ**
**ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា ។**

សត្វទាំងឡាយ រមែងបរិសុទ្ធដោយគុណជាតនេះ គឺ កម្ម ១ វិជ្ជា ១ ធម៌ ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធដោយគោត្រ ឬដោយទ្រព្យទេ ។

ត្រង់កន្លែងខ្លះ ព្រះអង្គសម្តែងដោយអំណាចនៃគុណមានសីលជាដើម, ដូចទ្រង់សម្តែងថា

**សព្វទា សីលសម្បន្នោ បញ្ញវា សុសមាហិតោ**
**អារទ្ធវីរិយោ បហិតត្តោ ឱឃំ តរតិ ទុត្តរំ ។**

បុគ្គលបរិបូរណ៍ដោយសីលសព្វកាល មានបញ្ញា មានចិត្តតាំងមាំប្រពៃ មានព្យាយាមប្រារព្ធហើយ មានខ្លួន (ចិត្ត) បញ្ជូនទៅហើយ រមែងឆ្លងនូវឱឃៈ (ជំនន់កិលេស) ដែលគេឆ្លងបានដោយកម្រ ។

ត្រង់កន្លែងខ្លះ ព្រះអង្គសម្តែងដោយអំណាចធម៌ មានការត្រេកអរក្នុងសេចក្តីមិនប្រមាទជាដើម, ដូចទ្រង់ត្រាស់ទុកថា :

**អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា**
**អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។**

ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។

# ១៧៤_អស្សុសូត្រ

(សុត្តន្តបិដក ភាគ៣២ ទំព័រ៨១)

ទ្រង់គង់នៅក្រុងសាវត្ថី ។ល។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតគេមិនអាចដឹងបាន គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមានអវិជ្ជាជារនាំង មានតណ្ហាជាចំណង អន្ទោលទៅ ត្រាច់រង្គាត់ទៅមិនប្រាកដឡើយ" ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច គឺត្រង់ដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅកន្ទក់កន្ទេញ ទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលជាអង្វែងនេះ ទឹកភ្នែកដែលហូរស្រក់ហើយនឹងទឹកក្នុងមហាសមុទ្រទាំង ៤ តើបណ្តាទឹកទាំងពីរនោះទឹកណាច្រើនជាង ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ យល់ច្បាស់នូវធមិតាមដែលព្រះមានព្រះភាគសម្តែងហើយ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ កន្ទក់កន្ទេញទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលជាអង្វែងនេះ ទឹកភ្នែកដែលហូរស្រក់ទៅហើយ

ច្រើនអនេក ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនច្រើនជាងឡើយ ។

ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ច្បាស់នូវធម៌ តាមដែលតថាគតសម្តែងហើយយ៉ាងនេះ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ កន្ទក់កន្ទេញ ទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលជាអង្វែងនេះ ទឹកភ្នែកដែលហូរស្រក់ទៅហើយច្រើនអនេក ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនច្រើនជាងមែន ។ល។

ម្នាលភិក្ខុទាំងឡាយ ហេតុនេះ អ្នកទាំងឡាយ គួរនឿយណាយ គួរធុញទ្រាន់ គួរជិនឆ្អន់ ក្នុងសង្ខារទាំងពួងដោយពិត ។

## ១៧៥-វដ្តសង្សារជាផ្លូវឆ្ងាយ

-វដ្តសង្សារជាផ្លូវឆ្ងាយ ដែលសត្វទាំងឡាយតែងត្រាច់ចរ
អាស្រ័យតណ្ហានៅបន្ត ឲ្យល្អក់កករមិនប្រសើរ។
-ឯអវិជ្ជាក៏រាំង ប្រៀបដូចរនាំងស្ទាក់ដំណើរ
មិនឲ្យឃើញមគ្គដ៏ប្រសើរ ក៏ចេះតែដើរក្នុងផ្លូវឆ្ងាយ។
-មគ្គអង្គប្រាំបីជាផ្លូវត្រង់ ដែលព្រះពុទ្ធអង្គទ្រង់បរិយាយ
ឲ្យឃើញនិព្វានផុតអបាយ រីឯផ្លូវឆ្ងាយក៏បានដល់។

-ហេតុនេះប្រសិនអ្នកប្រាថ្នា កាត់វដ្តសង្សារត្រូវតម្កល់
សម្មាទិដ្ឋិក្នុងកុសល នឹងសម្រេចផលព្រះនិព្វាន។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖

**ឧជុកោ នាម សោ មគ្គោ អភយា នាម សា ទិសា**
**រថោ អកុជ្ជនោ នាម ធម្មចក្កេហិ សំយុត្តោ ។**

ផ្លូវគឺអដ្ឋង្គិកមគ្គនោះ ឈ្មោះថា ជាផ្លូវត្រង់ ទិសគឺព្រះនិព្វាននោះ ឈ្មោះថា ជាទិសគ្មានភ័យ រថគឺអដ្ឋង្គិកមគ្គ ឈ្មោះថា ជារថមិនឮសូរ ប្រកបដោយកង់គឺធម៌ បានដល់សេចក្តីព្យាយាមដោយកាយនិងចិត្ត ។ល ។

អដ្ឋង្គិកមគ្គ គឺធម៌ដូចជាផ្លូវមានអង្គ ៨ ដ៏ប្រសើរនេះឯង (ហៅថា សេចក្តីប្រតិបត្តិជាកណ្តាល)

**១.សម្មាទិដ្ឋិ** (ប្រាជ្ញាយល់ឃើញត្រូវ)
**២.សម្មាសង្កប្បោ** (សេចក្តីត្រិះរិះត្រូវ)
**៣.សម្មាវាចា** (សម្តីត្រូវ)
**៤.សម្មាកម្មន្តោ** (ការងារត្រូវ)
**៥.សម្មាអាជីវោ** (កិរិយាចិញ្ចឹមជីវិតត្រូវ)
**៦.សម្មាវាយាមោ** (ព្យាយាមត្រូវ)

**៧.សម្មាសតិ** (សេចក្ដីរឭកត្រូវ)

**៨.សម្មាសមាធិ** (កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ) ។

## ១៧៦-មគ្គអង្គប្រាំបីដ៏ប្រពៃ

-មគ្គអង្គប្រាំបីដ៏ប្រពៃ គប្បីលកលៃចិត្តអាចហ៊ាន
អប់រំកុសលខំសមាទាន ផ្លូវទៅនិព្វានផុតទុក្ខា។
-កាមគុណមានអ្វីគួរត្រេកអរ ពិតមិនបវរសោះឡើយណា
ញុំាំងសត្វឲ្យជាប់ក្នុងសង្សារ មិនដឹងថ្ងៃណាបានរួចខ្លួន។
-បើមិនសេពគប់នូវសប្បុរស នៅតែឡេះឡោះឱមាសស្ងួន
នឹងទទួលរងទុក្ខផ្ទួនៗ មិនអាចរួចខ្លួនបានសុខស្ងប់។
-ដូច្នេះគប្បីមានស្មារតី តាមព្រះជិនស្រីអាចបញ្ចប់
ព្រោះឃើញនិព្វានទីសុខស្ងប់ ពិតមិនត្រឡប់ជាអមតៈ ។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៧៧-ឆ្លងសង្សារ

-វដ្ដសង្សារដ៏ធំធេង សត្វតែងវង្វេងដោយមោហា
ជំពាក់នៅក្នុងកាមតណ្ហា មិនដឹងថ្ងៃណាអាចស្រាយរួច។
-រឹងរឹតប្រាថ្នាក្រៃលែងណាស់ មិនបានដឹងច្បាស់អ្វីតិចតួច

ជាប់ចិត្តនឹងកាមចៀសមិនរួច កិលេសតែងផ្ដួចផ្ដើមជានិច្ច។
-ងងឹតងងល់មិនភ្លឺថ្លា រស់ឥតបញ្ញាវង្វេងភ្លេច
កំដៅកាមគុណដុតជានិច្ច បានសុខបន្តិចមិនទៅណា។
-ហេតុនេះដឹងចុះមិត្រកល្យាណ បើអ្នកចង់បានឆ្លងសង្សារ
ត្រូវតែលះបង់នូវកាមា ប្រព្រឹត្តធម៌អាថ៌ទើបឆ្លងរួច។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៧៨_សមុទ្រ ៤ ប្រការ

-អហំ សុវណ្ណជោតោសមណា សូមលើកប៉ាកកាចារចែងរ៉ាយរ៉ាប់
រៀបរាប់ធម៌អាថ៌ទុកបានជាច្បាប់ ដែលព្រះត្រាស់ប្រាប់អំពីសមុទ្រ។
-រីសមុទ្រនេះមានន័យជ្រាលជ្រៅ ធំទូលាយទៅដែលព្រះសម្ពុទ្ធ
ទ្រង់ត្រាស់ប្រៀបធៀបស្ដីពីសមុទ្រ ន័យជ្រៅបំផុតក្នុងធម៌វិន័យ ។
-គប្បីជ្រាបចុះសមុទ្រនេះណា មាន ៤ ប្រការគួរយើងលកលៃ
សិក្សាឱ្យចេះឱ្យបានយល់ន័យ ខំប្រឹងរំពៃគិតគួរឱ្យជ្រៅ ។
-ទី១ នេះគឺសមុទ្រសង្សារ សត្វមានតណ្ហាតែងអន្ទោលទៅ
ធ្លាក់ក្នុងវដ្ដៈទុក្ខច្រើនពេកកូវ តែងអន្ទោលទៅគ្មានទីបំផុត ។

-ទី២ ក៏គឺជលសាគរ គឺជាគំនរនៃទឹកសមុទ្រ
ទឹកច្រើនពេកណាស់ផ្ទៃធំបំផុត សំដៅសមុទ្រដែលមានទឹកប្រៃ ។
-ទី៣ នេះមិញនយសាគរ គឺជាគំនរនៃព្រះធម៌ថ្លៃ
មានន័យជ្រាលជ្រៅមិនងាយឧបមេយ្យ ហួសពីវិស័យយើងគិតពិចារណ៍ ។
-ទី៤ ក៏គឺញាណសាគរ ខ្វះខ្វាយទូទ័រម៉ឺនសែនចក្រវាល
នេះជាព្រះញាណនៃព្រះសាស្តា ជាព្រះសម្មាសម្ពុទ្ធជិនស្រី ។
-សាគរទាំង ៤ ប្រការនេះឯង ដូចបានសម្ដែងសង្ខេបយ៉ាងខ្លី
សាគរប្រសើរលើសសាគរបី ញាណព្រះជិនស្រីពិតប្រសើរជាង ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៧៩_សមុទ្រ ១៦ ប្រការ

-សមុទ្រសង្សារសមុទ្រទឹកប្រៃ សមុទ្រធម៌ថ្លៃមានន័យជ្រាលជ្រៅ
សមុទ្រព្រះញាណធំទូលាយទៅ ដឹងចុះណាពៅគ្មានអ្វីរាំងបាន ។
-សមុទ្រចក្ខុសោតៈឃានៈ ជិវ្ហាកាយៈដែលជាអង្គប្រាណ
រឹងមនោក្នុងធម៌កល្យាណ ក៏ព្រះទ្រង់បានត្រាស់ថាសមុទ្រ ។
-រូបសំឡេងក្លិនរសផោដ្ឋព្វៈ ធម្មារម្មណ៍ជាក់ក៏ជាសមុទ្រ
ដែលព្រះលោកនាថប្រសើរបំផុត ត្រាស់ថាសមុទ្រក្នុងធម៌វិន័យ ។

-ទឹកភ្នែកនិងឈាមទឹកដោះមាតា មួយៗប្រការច្រើនហួសឧបមេយ្យ
ជាងទឹកសមុទ្រយើងត្រូវយល់ន័យ គួរឱ្យស្លុតភ័យគួរខ្លាចរអា ។
-គួរឱ្យសង្វេគគួរឱ្យនឿយណាយ ជួបហើយឃ្លាតឆ្ងាយនៅក្នុងសង្សារ
ទួញយំសោយសោកច្រើនបែបប្រការ ព្រោះតែតណ្ហានិងអវិជ្ជា ។
-គួរខំប្រឹងស្រាយខំប្រឹងលះបង់ ដើរក្នុងផ្លូវត្រង់ គឺមជ្ឈិមា
សិក្សាប្រព្រឹត្តនូវព្រះធម្មា តាមព្រះភគវាពិតរួចចាទុក្ខ ។

ថ្ងៃ ១៣ រោច ខែផល្គុន ព.ស. ២៥៥៥
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៨០-ឆ្លងសមុទ្រ

ជិះទូកកាត់សមុទ្រធំវែងឆ្ងាយ ចិត្តគិតនឿយណាយរឿងសង្សារ
កើតចាស់ឈឺស្លាប់ទុក្ខក្រៃណា ដោយផលបុញ្ញាសូមឆ្លងផុត។
សមុទ្រទឹកដោះទឹកឈាមទឹកភ្នែក តែងតែហូរជ្រែកគួរតក់ស្លុត
វីកុសលកម្មដ៏បរិសុទ្ធ សូមបានឆ្លងផុតទុក្ខទាំងពួង ។

ថ្ងៃ១៥រោច ខែភទ្របទ ពុទ្ធសករា២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៨១-ចង់ឆ្លងសមុទ្រត្រូវតែខំប្រឹង

-ចង់ឆ្លងសមុទ្រត្រូវតែខំប្រឹង ពិនិត្យសម្លឹងសិក្សាធម្មា
ប្រព្រឹត្តត្រឹមត្រូវតាមព្រះភគវា គ្រប់ពេលវេលាដោយមិនប្រមាទ។
-សេចក្ដីត្រិះរិះក៏ដោយប្រពៃ គិតគូរលកលៃធ្វើអ្វីឲ្យស្អាត
វៀរចាកបាបកម្មឲ្យបានដាច់ខាត ត្រូវតែសង្វាតនៅក្នុងកុសល។
-កុំឡើយទម្រន់ឡេះឡោះលេងសើច តិចច្រើនដោយហោចគប្បីតម្កល់
កាយកម្មជាដើមតែក្នុងកុសល អ្នកនឹងឆ្លងដល់ត្រើយនាយប្រាកដ។
-ត្រើយនាយសុខសាន្តឥតភ័យអន្តរាយ ផ្សេងពីអបាយគ្មានការនឿយហត់
គ្មានការស្រេកឃ្លានគ្មានអ្វីត្រូវអត់ ឥតមានកម្សត់គ្រប់គ្រាន់សុខស្ងប់។

កំពង់សោម ថ្ងៃ ៦ កើត ខែវិសាខ ពុទ្ធសករា២៥៥៩

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៨២-រឿងក្នុងវដ្ដៈគួរនឿយណាយ

រឿងក្នុងវដ្ដៈគួរតែនឿយណាយ មិនគួរសប្បាយទៅតាមតណ្ហា
គួរមានស្មារតីរស់ដោយបញ្ញា សិក្សាធម៌អាថ៌រលាស់ខ្លួនចេញ ។
កុំចង់បានសុខនៅក្នុងកាមគុណ នាំរងទុក្ខធ្ងន់គ្មានបានចំណេញ
សិក្សាប្រតិបត្តិរលាស់ខ្លួនចេញ ទើបបានចំណេញរួចផុតចាកទុក្ខ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៨៣-សប្បុរិសធម៌ ៧ យ៉ាង

១-ធម្មញ្ញូ ( ជាអ្នកដឹងនូវធម៌ គឺសុត្តៈ ។ល។ វេទល្លៈ)

២-អត្ថញ្ញូ ( ដឹងនូវអត្ថ របស់ធម៌ )

៣-អត្តញ្ញូ ( ដឹងខ្លួន )

៤-មត្តញ្ញូ ( ដឹងនូវប្រមាណក្នុងភោជន )

៥-កាលញ្ញូ ( ដឹងកាលគួរ )

៦-បរិសញ្ញូ ( ដឹងបរិស័ទ )

៧-បុគ្គលបរោបរញ្ញូ (ដឹងបុគ្គលដែលគួរគប់រក) ។

## កំណាព្យ សប្បុរិសធម៌

*រីសប្បុរសដឹងនូវធម្មៈ សុត្តៈគេយ្យៈជាដើមមែនពិត
ដឹងអត្ថនោះៗរបស់ភាសិត លោកអាចប្រព្រឹត្តដ៏ល្អប្រពៃ ។
*ជាអ្នកដឹងខ្លួននិងដឹងប្រមាណ ត្រេកអរតាមបានតាមធម៌វិន័យ
លោកប្រាថ្នាតិចចេះគិតលកលៃ ចិត្តឥតមោះមៃប្រសើរថ្លៃថ្លា។
*លោកដឹងកាលគួរនិងដឹងបរិស័ទ គួររៀនបរិយត្តិឬគួរសាកថ្លា
ពេលចូលទៅរកបរិស័ទណាៗ ចេះដឹងវាចានិយាយស្ដីស្មៀម ។
*លោកដឹងបុគ្គលដែលគួរគប់រក ស្និទ្ធស្នាលទៅមកឥតមានលាក់លៀម
ព្រោះស្រឡាញ់ធម៌ទៅតាមទំនៀម បូជាពួកព្រាហ្មណ៍ព្រះអរិយៈ។

* បើអ្នកចង់បានជាសប្បុរស ធ្វើធម៌ទាំងអស់ឲ្យប្រាកដជាក់
មាននៅក្នុងខ្លួនរបស់លោកអ្នក នេះប្រសើរជាក់ពិតជាសប្បុរស។

ថ្ងៃ១២ រោច ខែភទ្របទ ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៨៩-លោកធម៌ ជាអនត្តា

-ម្សិលមិញថ្ងៃនេះផ្សេងខុសគ្នា ព្រោះពេលវេលាតែងប្រែប្រួល
ជូនសុខសប្បាយជូនមិនស្រួល ចិត្តបានទទួលដឹងអារម្មណ៍ ។
-សុខទុក្ខសង្ខារបានតាក់តែង ព្រះធម៌សម្ដែងច្បាស់ចំៗ
កុំគិតថាវាមិនសំណំ ព្រោះខ្ញុំបានខំប៉ុណ្ណឹងហើយ ។
-មានលាភឥតលាភក៏ដូចគ្នា ដឹងចុះពុំងាមិនទៀងឡើយ
មិនថាថ្ងៃនេះឬថ្ងៃក្រោយ ព្រះអង្គត្រាស់ហើយជាលោកធម៌ ។
-សរសើរនិន្ទាយសអត់យស ពីរោះទ្រគោះ កុំញាប់ញ័រ
ដូចបានបញ្ជាក់ជាលោកធម៌ ពុំគួរញាប់ញ័រភ្លេចធម្មា ។
-ទោះសម្គាល់ថានោះជាអញ នោះរបស់អញគ្រប់វេលា
ដោយពិតគ្រប់យ៉ាងព្រះភគវា ត្រាស់ថាគឺជាអនត្តា ។

ថ្ងៃ ១៤ រោច ខែភទ្របទ ពុទ្ធសករា២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

អ្នកគប្បីដឹងថា ៖

ម្សិលមិញផ្សេងថ្ងៃនេះផ្សេង គ្រប់យ៉ាងមានការប្រែប្រួលជានិច្ច មិននៅក្នុងអំណាចរបស់បុគ្គលណាម្នាក់ទេ គឺថាតែងមានការប្រែប្រួល បែកធ្លាយជាធម្មតា ទុកជាខំប្រកាន់ថា អញ របស់អញ ជាខ្លួនអញ ក៏នៅតែមិនជាអញ របស់អញ ជាខ្លួនអញ ដដែល ។ ព្រោះថា សង្ខារទាំងពួងទាំងឡាយ មិនទៀង ជាទុក្ខ, ធម៌ទាំងពួងទាំងឡាយ ជាអនត្តា ។

## ១៨៥-កាយប្រែប្រួល

អាកាសធាតុប្រែប្រួលកាយប្រែប្រួល នាំឲ្យមិនស្រួលឈឺសព្វកាយ
ព្រឺក្តៅរងាមិនសប្បាយ ពិតគ្រុនផ្តាសសាយប្រាកដណាស់។
តែទោះយ៉ាងណាត្រូវអត់ទ្រាំ តាំងចិត្តឲ្យមាំចាំឲ្យច្បាស់
មានរូបមានទុក្ខនេះពិតណាស់ ដូចពុទ្ធតម្រាស់ទ្រង់ទេសនា។
ពេលសេចក្តីទុក្ខកើតប្រាកដ គប្បីកំណត់ដោយបញ្ញា
នេះជាសច្ចតាមធម្មតា មិនមានអ្នកណាអាចជៀសបាន។
គប្បីដឹងចុះទាំងអស់គ្នា កាលទុក្ខវេទនាកើតក្នុងប្រាណ
ជាផលវិបាកដែលយើងបាន សាងធ្វើប៉ុន្មានជាអកុសល។
តែទោះយ៉ាងណាត្រូវរក្សា កុំឡើយអាងថាកម្មឲ្យផល
ប្រយោគបច្ចុប្បន្នត្រូវតម្កល់ ប្រពៃអាចផ្តល់សុខសួស្តី។

ថ្ងៃ ៨ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៨៦-ជំងឺឈឺថ្កាត់ពិតរំខាន

-ជំងឺឈឺថ្កាត់ពិតរំខាន ឲ្យលំបាកប្រាណខាតការងារ
ខាតទាំងទ្រព្យធនពេលវេលា សុខភាពជានាត្រូវប្រែប្រួល។
-ថមថយកម្លាំងពីធម្មតា ធ្ងន់ទាំងកាយាពិតមិនស្រួល
ចាក់ថ្នាំប្រើថ្នាំទ្រាំទទួល គិតចង់ឲ្យស្រួលបានសះជា។
-ដូច្នេះគួរអ្នកប្រុងប្រយ័ត្ន កុំឲ្យឈឺថ្កាត់មានរោគា
ត្រូវចេះសំអាតក្នុងគ្រឹហា អាហារនានាជាដើមផង។
-ហេតុកើតជំងឺមានច្រើនយ៉ាង មិនមែនតែម្យ៉ាងទេស្នេហ៍ស្នង
ជួនកើតពីកម្មនោះតែម្តង មិនអាចអ្នកផងរក្សាបាន។
-ដូច្នេះត្រូវធ្វើអំពើល្អ ដែលជាកម្មសដ៏កល្យាណ
នោះអ្នកនឹងចៀសពីរោគបាន មិនអាចរំខានសុខសួស្តី។

ថ្ងៃ ៩ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៨៧-ត្រូវការពរជ័យពីញាតិមិត្រ

-ត្រូវការពរជ័យពីញាតិមិត្រ ពីទិសឆ្ងាយជិតសូមជួយផ្តល់
កម្លាំងដ៏ខ្លាំងនៃកុសល សូមឲ្យបានដល់ស្រីសួស្តី។
-ដ្បិតខ្ញុំពេលនេះដូចជាខ្សោយ ឱណាអ្នកអើយមិនប្រក្រតី
សូមមេត្តាជួយដោយមេត្រី ទឹកចិត្តប្រណីដ៏បវរ។

-ត្រូវដឹងចុះកម្លាំងចិត្តក្តី កម្លាំងបុណ្យក្តីពិតជាល្អ
ជាគុណប្រយោជន៍គួរត្រេកអរ ប្រសើរបវរអាស្រ័យអ្នក។
-យល់ពីធម្មជាតិហេតុបច្ច័យ ជាប្រចាំថ្ងៃឲ្យបានជាក់
លះការប្រកាន់ជាប់ជំពាក់ នឹងឲ្យរូបអ្នកបានសុខស្ងប់។

ថ្ងៃ ៩ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៨៨-ការចាយទ្រព្យដោយកម្មដ៏សមគួរ៤ យ៉ាង

ព្រះពុទ្ធ ទ្រង់ត្រាស់ថា ៖

ម្នាលគហបតី អរិយសាវ័ក ក្នុងសាសនានេះ ញុំាងខ្លួនឱ្យសុខ ឱ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមាតាបិតាឱ្យសុខ ឱ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងកូនប្រពន្ធនិងបុរសជាទាសកម្មករ ឱ្យសុខ ឱ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមិត្តអមាត្យ ឱ្យសុខ ឱ្យឆ្អែត រក្សាសុខដោយប្រពៃ ដោយភោគៈទាំងឡាយ ដែលបានមកដោយសេចក្តីព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង សន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជារបស់ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី១ ដែលអរិយសាវ័កនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី ប្រការមួយទៀត សេចក្តីអន្តរាយណា ដែលកើត អំពីភ្លើងក្តី អំពីទឹកក្តី អំពីស្តេចក្តី អំពីចោរក្តី អំពីបុគ្គលមិនជាទីស្រលាញ់ក្តី អំពីអ្នកទទួលមរតកក្តី អរិយសាវ័ក ក៏ការពារទប់ទល់ចំពោះអន្តរាយមានសភាពដូច្នេះបាន ដោយភោគៈទាំងឡាយ ធ្វើខ្លួនឱ្យដល់នូវសួស្តីបាន ក៏ដោយភោគៈទាំងឡាយ ដែលបានមកដោយសេចក្តីព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី២ ដែលអរិយសាវ័កនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី ប្រការមួយទៀត អរិយសាវ័កធ្វើពលិកម្មទាំង ៥ គឺញាតិពលី ១ អថិតិពលី ១ បុព្វបេតពលី ១ រាជពលី ១ ទេវតាពលី ១ ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមក ដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី៣ ដែលអរិយសាវ័កនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី ប្រការមួយទៀត ពួកសមណព្រាហ្មណ៍ណា វៀរចាកសេចក្តីវង្វេង និងសេចក្តីប្រមាទ ឋិតនៅក្នុងខន្តិ និងសោរច្ចៈ ទូន្មានតែខ្លួនមួយ រម្ងាប់កិលេសចំពោះខ្លួនមួយ ញ៉ាំងតែខ្លួនមួយឱ្យបរិនិព្វាន អរិយសាវ័ក រមែងញ៉ាំងទក្ខិណាទាន មានផលដ៏ខ្ពស់ប្រសើរ នាំឱ្យទៅកើតក្នុងស្ថានសួគ៌ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ឱ្យប្រតិស្ឋាននៅក្នុងពួកសមណព្រាហ្មណ៍ មានសភាពដូច្នោះ បានដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី៤ ដែលអរិយសាវ័កនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយដោយទំនងដ៏សមគួរ ។

ម្នាលគហបតី អរិយសាវ័កនោះឯង ជាអ្នកធ្វើកម្មដ៏សមគួរទាំង ៤ ប្រការនេះបាន ដោយភោគៈទាំងឡាយដែលបានមកដោយព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណាមួយ តែវៀរលែងចាកកម្ម ដ៏សមគួរទាំង ៤ ប្រការចេញហើយ រមែងដល់នូវការអស់ទៅ ម្នាលគហបតី ភោគៈទាំងឡាយនេះ ហៅថា មិនដល់នូវហេតុដ៏សមគួរ មិនបានសម្រេច

មិនបានបរិភោគដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណា អស់ទៅដោយកម្មដ៏សមគួរទាំង ៤ នេះ ម្នាលគហបតី ភោគៈទាំងនេះ ហៅថា ដល់នូវហេតុដ៏សមគួរ បានសម្រេច បានបរិភោគដោយទំនងដ៏សមគួរ ។ (សុត្តន្ត. ៤២, ១៦៦)

## ១៨៩-មានទ្រព្យត្រូវប្រើដោយបញ្ញា

-មានទ្រព្យត្រូវប្រើដោយបញ្ញា កាន់យកខ្លឹមសារដោយប្រពៃ
ឲ្យទានបរិច្ចាគគិតលកលៃ តាមធម៌វិន័យដ៏បវរ។
-ទំនុកបម្រុងពុទ្ធសាសនា មាតាបិតាឲ្យបានល្អ
សង្គ្រោះញាតិមិត្រអ្នកទាល់ក្រ អស់ទៅដោយល្អមានប្រយោជន៍។
-ចិញ្ចឹមខ្លួនឯងនិងគ្រួសារ និងពួកទាសានោះដោយហោច
ធ្វើពលិកម្មកុំលេងសោច យុំគ្រងប្រយោជន៍បានសុខជា។
-ព្រោះហេតុដូច្នោះត្រូវតែច្នៃ ឲ្យមានតម្លៃក្នុងទ្រព្យា
សម្រាប់ខ្លួនឯងនិងជនា សុខទាំងអស់គ្នាគ្រប់សន្តាន។

ថ្ងៃ ៩ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៩០-អ្នកមានសទ្ធាទឹកចិត្តបវរ

-អ្នកមានសទ្ធាទឹកចិត្តបវរ មានរបស់ល្អតែងនឹកព្រះសង្ឃ
មាតាបិតាមានចិត្តឱនអង្គ គាត់តែងផ្ចិតផ្ចង់ថ្វាយដោយជ្រះថ្លា។
-ជីវិតរស់នៅមិនឃើញតែអញ លះក្តីកំណាញ់ព្រមទាំងឥស្សា
លោភៈទោសៈនិងចិត្តមោហា សាងតែកុសលាសន្សំក្តីសុខ ។
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ថ្ងៃ ៩ រោចខែកត្តិក ពុទ្ធសករាជ២៥៥៩ នេះ បានប្រគេនចង្ហាន់ដល់ព្រះសង្ឃនៅវត្តខ្មែរកុរុរដ្ឋ ក្រុង New Delhi ដើម្បី ឧទ្ទិសទានជូនញោមឧបាសក ឃឹម-ប៊ិន ដែលបានធ្វើមរណៈ- កាលទៅកាន់បរលោក សូមបានអនុមោទនា បានសេចក្តីសុខ រួចផុតចាកទុក្ខទាំងពួង ។

## ១៩១-ថ្វាយទានដល់សង្ឃឧទ្ទិសផល

-ថ្វាយទានដល់សង្ឃឧទ្ទិសផល សូមឲ្យបានដល់ញាតិវង្សា
សាច់សាលោហិតជីដូនតា សូមលោកជ្រះថ្លាអនុមោទនា។
-សូមឲ្យបានសុខស្រីសួស្តី បាននំចំណីទឹកភោជនា
រួចចាកស្រេកឃ្លាននិងរោគា ផុតទុក្ខវេទនាដល់សួគ៌ឋាន។
-ម្យ៉ាងទៀតសូមឲ្យជាបច្ច័យ ឧបនិស្ស័យប្រសើរថ្កាន
ឃើញព្រះធម្មាល្អកល្យាណ សូមសម្រេចបានស្រីសុខា។

-និងមិត្តសម្លាញ់ក៏ដូចគ្នា អនុមោទនាដោយជ្រះថ្លា
សូមបុណ្យកុសលជាឧបការ រួចចាកទុក្ខាដល់និព្វាន។

ថ្ងៃ ៩ រោច ខែកត្តិក ពុទ្ធសករា២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៩២-ឱកម្មវាសនា

-ឱកម្មវាសនា មិនអាចទៅណា តាមចិត្តបំណង
ព្រោះមាននាទី នាមជាកូនបង សង្គ្រោះញាតិផង
ប្អូនៗកល្យាណ។
-ឱកិច្ចការងារ រកតែដកឃ្លា សឹងតែមិនបាន
រវល់រហូត មិនអាចខកខាន ទោះម៉ោងប៉ុន្មាន
ក៏ត្រូវតែធ្វើ។
-ឱណារូបកាយ គិតគូរខ្វល់ខ្វាយ នឹងវាមិនស្មើរ
ប្រដាប់តាក់តែង ពីក្រោមដល់លើ បើមិនអើពើ
ខ្លាចវាមិនល្អ។
-ឱណាទានសីល ក៏ខំផ្ដាច់ផ្ដិល ដោយចិត្តបវរ
លះក្ដីស្រឡាញ់ ចង់តែស្រស់ល្អ មានចិត្តស្មោះសរ
នៅក្នុងគុណធម៌។

ថ្ងៃ ៥ កើត ខែអស្សុជ ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ១៩៣-កម្មតាក់តែង

-ឱកម្មវាសនា នៃសត្វលោកា ពិតមិនដូចគ្នា
ទាំងរឿងលាភយស សុខទុក្ខវេទនា សរសើរនិន្ទា
នេះកម្មតាក់តែង ។
-កម្មចាស់កម្មថ្មី ដែលជនប្រុសស្រី សាងដោយខ្លួនឯង
វាតែងឲ្យផល តាមព្រះសម្តែង តាមកាលនោះឯង
បើមានឱកាស ។
-កម្មខ្មៅឬស អាក្រក់ឬល្អ មានពិតយ៉ាងច្បាស់
ឲ្យផលផ្សេងគ្នា ផ្សេងខុសស្រឡះ ឥតមានផ្តេសផ្តាស់
ទេណាមិត្រណា ។
-បើអ្នកបានដឹង ពិនិត្យសម្លឹង ទៅដោយបញ្ញា
លះនូវទោមនស្ស ទិដ្ឋិមោហា សន្តានស្រស់ថ្លា
រស់ដោយសុខសាន្ត ។

រាត្រីថ្ងៃ ១៤ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

*ក្នុងអយ្យិកាសូត្រ ព្រះអង្គទ្រង់ត្រាស់នូវពាក្យនេះថា :*

សត្វទាំងអស់មុខជានឹងស្លាប់ ព្រោះថា ជីវិត (របស់សត្វ) មានសេចក្តីស្លាប់ជាទីបផុត សត្វទាំងឡាយ ទទួលយកផលបុណ្យ

ផលបាបហើយ នឹងទៅតាមយថាកម្ម គឺអ្នកធ្វើបាប តែងទៅកាន់នរក ចំណែកខាងអ្នកធ្វើបុណ្យ តែងទៅកាន់សុគតិភព ព្រោះហេតុនោះ បុគ្គលគួរតែធ្វើបុណ្យដែលនាំទៅក្នុងបរលោកឱ្យចម្រើន (ព្រោះថា) បុណ្យទាំងឡាយ ជាទីពឹងរបស់ពួកសត្វក្នុងបរលោក ។

## ១៩៤-រឿងរ៉ាវកំបាំង

-រឿងរ៉ាវកំបាំងពិតមានច្រើនណាស់ យើងមិនដឹងច្បាស់និងគិតមិនដល់
បើអ្នកចង់ដឹងចិន្តាខ្វាយខ្វល់ រសាប់រសល់នៅមិនសប្បាយ ។
-រឿងទឹករឿងដីអាកាសចក្រវាល រឿងមនុស្សទេព្តាប្រទេសជិតឆ្ងាយ
ទន្លេសមុទ្រសុខទុក្ខទាំងឡាយ រឿងជុំវិញកាយកំណត់មិនបាន ។
-រឿងរ៉ាវទាំងឡាយមានហេតុបច្ច័យ កុំចង់កែខៃខុសសមុដ្ឋាន
បើអ្នកមិនយល់ដោះស្រាយមិនបាន រស់មិនសុខសាន្តគ្មានយសសិរី ។
-រឿងដែលសំខាន់ប្រាជ្ញាយល់ត្រូវ សិក្សាស្គាល់ផ្លូវគប្បីឃ្មាតខ្មី
សាងសេចក្តីល្អដោយចិត្តមេត្រី សន្តោសប្រណីដើរតាមបណ្ឌិត ។
-សេពគប់សប្បុរសសិក្សាធម៌អាថ៌ ចម្រើនបញ្ញាគ្មេរគ្មាន់រិះគិត
ឲ្យបានដឹងច្បាស់ហើយខំប្រព្រឹត្ត ត្រាស់ដឹងធម៌ពិតសោយរសវិមុត្តិ ។

ថ្ងៃ ១១ កើត ខែវិសាខ ពុទ្ធសករាជ២៥៥៨

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

រឿងរ៉ាវកំបាំង ដែលយើងមិនដឹង ឬគិតមិនដល់ មានច្រើនរឿងណាស់ អ្វីដែលត្រូវដឹង គប្បីសិក្សាឲ្យដឹង អ្វីដែលមិនចាំបាច់ដឹង មិនដឹងក៏បាន មិនគួរកើតទុក្ខកន្ទក់កន្ទេញអ្វីទេ ។ អ្វីដែលកើតឡើងហើយ ត្រូវចេះដោះស្រាយដោយបញ្ញា ប្រកបដោយធម៌ ដែលសំខាន់មានបញ្ញាយល់ត្រូវ សិក្សាធម៌ ប្រព្រឹត្តធម៌ សាងសេចក្តីល្អ ចម្រើនក្នុងចិត្ត ។

រឿងរ៉ាវកំបាំងខ្លះ ដែលអ្នកមិនបានដឹងច្បាស់ មិនយល់ អ្នកអាចគិតខុស យល់ខុស ធ្វើឲ្យអ្នកមិនស្រឡាញ់ មិនចូលចិត្ត កើតទុក្ខទោមនស្ស អន់ចិត្តជាដើម ។ ប៉ុន្តែពេលដែលអ្នកដឹងយល់ច្បាស់ វាទៅជារឿងដែលគួរឲ្យអាណិត គួរឲ្យស្រឡាញ់ ជ្រះថ្លាជាដើមទៅវិញក៏មាន ។ ហេតុដូច្នេះត្រូវសិក្សាឲ្យបានដឹងច្បាស់ យល់ច្បាស់ជាមុនសិន មុននឹងស្អប់ ឬស្រឡាញ់ជាដើម កុំចេះតែខឹងទាស់ ស្រឡាញ់ស្អប់នោះ ត្រូវឲ្យមានហេតុផលច្បាស់លាស់ផង និងត្រូវចេះឲ្យអភ័យ ។

ព្រះពុទ្ធគាថា ទ្រង់ប្រារព្ធធីតាជាងតម្បាញ

អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ
សកុន្តោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្ដាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះ ដោយអំណាចអនិច្ចលក្ខណៈជាដើម) ជនតិចគ្នាដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (ដែលជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ដែលរួចអំពីសំណាញ់ ដូច្នោះ ។

## ១៩៥-លោកីយ៍មហាជនងងឹតណាស់

>លោកីយ៍មហាជនងងឹតណាស់ មិនបានដឹងច្បាស់នូវត្រៃលក្ខណ៍
ប្រកាន់តួខ្លួនយ៉ាងមាំជាក់ ច្រើនណាស់តែងធ្លាក់ក្នុងអបាយ ។
>មិនងាយគេចផុតបានរួចខ្លួន ជួបទុក្ខផ្ទួនៗភ័យអន្តរាយ
ព្រោះតែតណ្ហាត្រូវខ្វល់ខ្វាយ ទិដ្ឋិទាំងឡាយទាញទម្លាក់ ។
>គិតស្មានបានសុខក្នុងកាមគុណ ខំរែកខំពុននូវភារៈ
តែត្រូវកិលេសដូចអន្ទាក់ អូសទាញឲ្យធ្លាក់ក្នុងសង្សារ ។
>រស់គ្មានស្មារតីមិនដឹងច្បាស់ ងងឹតខ្លាំងណាស់មិនភ្លឺថ្លា
សាងតែបាបកម្មគ្មានមេត្តា មិនដឹងថ្ងៃណាបានផុតទុក្ខ ។
>ឱប៉ុណ្ណឹងហើយនៅមិនដឹង នៅតែខំប្រឹងពេញបន្ទុក
សម្លាប់លួចប្លន់លបលាក់ទុក តែងតែរងទុក្ខមិនសប្បាយ ។
>ហេតុនេះគួរវៀរចាកបាបកម្ម កុំនៅត្រងត្រាំវៀរឲ្យឆ្ងាយ
សាងកុសលកម្មចិត្តនឿយណាយ តម្រង់ចិត្តកាយឲ្យបានស្អាត។

>សិក្សាប្រព្រឹត្តព្រះធម្មា តាមព្រះភគវាទ្រង់ឱវាទ
លះបាបសាងបុណ្យខំសង្វាត ធ្វើចិត្តឲ្យស្អាតបានបរិសុទ្ធ ។

ព្រឹកថ្ងៃ ១០ កើត ខែជេស្ឋ ព.ស.២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ១៩៦-សុរាមានរសមិនធម្មតា

-សុរាមានរសមិនធម្មតា ផឹកចូលកាលណាបែបមិនស្រួល
នាំជ្រួញចិញ្ចើមចិត្តប្រែប្រួល ធ្វើឲ្យក្តៅឆ្លួលដល់រាងកាយ។
-សុរាមានរសមិនធម្មតា នាំឲ្យហានក្លាប្រទូសរ៉ាយ
លែងស្គាល់ប្រពន្ធកូនទាំងឡាយ និងឪពុកម្តាយត្រូវរងកម្ម។
-សុរាមានរសមិនធម្មតា នាំឈ្លោះឡូឡាកើតក្តីក្តាំ
គ្រួសារមិនសុខត្រូវប្រេះស្រាំ នេះអ្នកត្រូវចាំទោសវេរា។
-សុរាមានរសមិនធម្មតា កើតរោគឈឺផ្សាខាតការងារ
អស់ទ្រព្យរបស់ពេលវេលា បើអ្នកមិនវៀរត្រូវលង់លិច។
-សុរាមានរសមិនធម្មតា នាំខ្សោយបញ្ញាវង្វេងភ្លេច
ធ្លាក់អបាយភូមិមិនអាចគេច រងទុក្ខជានិច្ច ទៅតាមកម្ម ។
-សុរាមានរសមិនធម្មតា ដូចដែលបានចារជាបណ្តាំ
ត្រូវវៀរឲ្យឆ្ងាយចាកបាបកម្ម រាល់ថ្ងៃខែឆ្នាំសុខក្សេមក្សាន្ត។

ល្ងាចថ្ងៃ ១៣ កើត ខែភទ្របទ ព.ស.២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

អ្នកគប្បីដឹងថា ៖

បើអ្នកស្រឡាញ់ខ្លួន ស្រឡាញ់គ្រួសារ ស្រឡាញ់សេចក្តីសុខ ចង់រួចចាកទុក្ខទាំងពួង សូមវៀរឲ្យឆ្ងាយពីសុរាមេរ័យ ។

នៅក្នុងសុត្តន្តបិដក សុត្តនិបាត ព្រះអង្គសម្តែងពីទោសនៃការផឹកទឹកស្រវឹង គឺសុរាមេរ័យ ថា ជាគ្រឿងបណ្តាលឲ្យ កើតបាប នាំឲ្យឆ្កួត នាំឲ្យវង្វេង ទាំងនាំឲ្យល្ងង់ ។

អដ្ឋកថាពន្យល់ថា នាំឲ្យឆ្កួតក្នុងលោកខាងមុខ នាំវង្វេងក្នុងលោកនេះ ។ ព្រោះដូច្នោះ បើអ្នកមិនចង់វង្វេង មិនចង់ឆ្កួត មិនចង់ល្ងង់ទេ ត្រូវវៀរឲ្យឆ្ងាយពីសុរាមេរ័យ ។

សុរាមានរសមិនធម្មតា វាតែងប្រហារបញ្ញាស្មារតី
នាំឲ្យវង្វេងនៅក្នុងលោកីយ៍ ដឹងចុះប្រុសស្រីកុំចង់សប្បាយ។
សុរាមានរសមិនធម្មតា បែកធ្លាយកាយាទៅកាន់អបាយ
ឆ្កួតក្នុងបរលោកអស់កាលវែងឆ្ងាយ ដឹងចុះឆោមឆាយកុំចង់សាកអី។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

ព្រះពុទ្ធគាថា ប្រារព្ធចំពោះព្រះសម្មជ្ជនត្ថេរ ៖

យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុំាងខន្ធាទិលោកនេះឲ្យភ្លឺស្វាង ដូចព្រះចន្ទ្ររះផុតចាកពពក ។

## ១៩៧-សុរាមានទោសច្រើន

-ញញឹមញញែមដាក់កែវស្រា ស្រស់ស្រីសង្ហាភក្ត្រពព្រាយ
ឆាប់លើកយកមកដោយរីករាយ ញញឹមពព្រាយផឹកសប្បាយ។
-ថែមហើយថែមទៀតមិនចេះចប់ ជួនស្ទើរសន្លប់ធ្ងន់អស់កាយ
បាត់បង់ស្មារតីចិត្តប្រែក្លាយ អស់ពីសប្បាយជួបទុក្ខព្រួយ ។
-ទំនាស់មិត្រញាតិប្រពន្ធកូន តែងត្រូវសាបសូន្យមិនតែមួយ
លំបាកកែខែលៃលកជួយ ឲ្យផុតទុក្ខព្រួយបានក្សេមក្សាន្ត។
-ខាតពេលវេលាទ្រព្យសម្បត្តិ បញ្ញាបង់បាត់ពិតមិនថ្កាន
ព្រោះតែសុរាចូលរំខាន អ្វីដែលត្រូវបានគឺសោកា ។
-សុរាមានទោសច្រើនពេកពិត អ្នកចូររិះគិតដោយបញ្ញា
តាមព្រះពុទ្ធម្ចាស់ទ្រង់ត្រាស់ថា ធ្លាក់សោយទុក្ខាក្នុងអបាយ ។
-សេសសល់ផលកម្មកើតជាមនុស្ស ដោយផលកម្មនោះក៏ប្រែក្លាយ
ឆ្កួតខូចស្មារតីផងទាំងឡាយ នេះព្រោះសប្បាយនឹងសុរា ។

-ហេតុនេះត្រូវរៀរដោយដាច់ខាត កុំឡើយប្រមាទព្រោះកាមា
សិក្សាប្រព្រឹត្តព្រះធម៌អាថ៌ ជីវិតស្រស់ថ្លាជួបមង្គល ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

១៩៨-កុំដែលប្រពៃគឺកុំផឹក

-កុំចង់លលេងនឹងសុរា កុំឡើយគិតថាវាមិនអី
កុំផឹកសាងមិត្រថាមិនថ្វី កុំនេះកើតក្តីនាំមោះហ្មង ។
-កុំដែលប្រពៃគឺកុំផឹក កុំឲ្យប្រមឹកនោះតែម្តង
កុំឲ្យដាច់សីលនាំសៅហ្មង កុំឲ្យអ្នកផងគេតិះដៀល ។
-កុំឲ្យវិនាសទ្រព្យសម្បត្តិ កុំឲ្យវិបត្តិមានរោគា
កុំកកើតកម្មពៀរវេរា កុំទាំងនេះជាការប្រពៃ ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

អ្នកគប្បីដឹងថា ៖

* អ្វីដែលកើតគឺវាកើតទៅហើយ ដែលសំខាន់នោះត្រូវចេះដោះស្រាយបញ្ហាដោយបញ្ញា ប្រកបដោយធម៌។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា សេចក្ដីទុក្ខ មានកាមជាហេតុ សេចក្ដីទុក្ខ កើតពីសេចក្ដីស្រឡាញ់ ។ កាលបុគ្គលមានវត្ថុជាទីស្រឡាញ់ ១០០ ក៏មានសេចក្ដីទុក្ខ ១០០, មានវត្ថុជាទីស្រឡាញ់ ១ ក៏មានសេចក្ដីទុក្ខ ១ ដែរ, បើមិនមានវត្ថុជាទីស្រឡាញ់សោះ ក៏មិនមានសេចក្ដីទុក្ខដែរ ។

សេចក្ដីសោកក្ដី សេចក្ដីខ្សឹកខ្សួលក្ដី ណាមួយ ឬសេចក្ដីទុក្ខជាច្រើនយ៉ាងក្នុងលោក ធម៌ទាំងនោះ រមែងកើតឡើងព្រោះអាស្រ័យសត្វនិងសង្ខារជាទីស្រឡាញ់ កាលបើមិនមានសត្វនិងសង្ខារជាទីស្រឡាញ់ ធម៌ទាំងនោះក៏រមែងមិនមាន ។

ព្រោះហេតុនោះ បុគ្គលណា មិនមានសត្វនិងសង្ខារជាទីស្រឡាញ់ ក្នុងលោកណាមួយទេ បុគ្គលនោះ ទើបមានសេចក្ដីសុខ ប្រាសចាកសេចក្ដីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្ដីមិនសោក និងការប្រាសចាកធូលី គឺកិលេស មិនគប្បីធ្វើសត្វនិងសង្ខារឲ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ ។

## ១៩៩-តើឃំព្រោះអ្វី

-ឃំព្រោះរឿងអ្វី ឃំព្រោះរឿងស្រី ឃំព្រោះរឿងប្រុស

ឃំព្រោះមិនបាន នូវទ្រព្យរបស់ ឃំព្រោះអាឡោះ

អាល័យសោកស្តាយ ។
-យំព្រោះមិនគាប់ យំព្រោះរឿងជាប់ ក្នុងកាមទាំងឡាយ
យំព្រោះស្នេហា យំព្រោះឃ្លាតឆ្ងាយ យំព្រោះអត់បាយ
បរិភោគពិសា ។
-យំព្រោះព្រាត់ប្រាស យំព្រោះរឿងចាស់ យំឈឺកាយា
យំគ្មានគេថៃ គេយល់ចិន្តា យំខ្វះដុល្លារ
ចាយវាយសប្បាយ ។
-យំព្រោះបងប្អូន យំព្រោះរឿងកូន យំព្រោះរឿងម្តាយ
យំព្រោះរឿងឪ យំព្រោះនឿយណាយ យំដូចបរិយាយ
តើយំព្រោះអ្វី ?
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២០០-ទឹកភ្នែកហូរស្រក់ចាកនេត្រា

ទឹកភ្នែកហូរស្រក់ចាកនេត្រា នេះបញ្ជាក់ថាមានទុក្ខព្រួយ
ដួងចិត្តក្រៀមក្រំសូមអ្នកជួយ តម្កើងលើកស្ទួយឲ្យធូរស្បើយ ។
ទឹកភ្នែកហូរស្រក់ចាកនេត្រា អួលណែនឱរ៉ាយូរណាស់ហើយ
គ្រាំគ្រាដួងចិត្តមិនតិចឡើយ ឱណាអ្នកអើយឱណាអ្នក ។
ទឹកភ្នែកហូរស្រក់ចាកនេត្រា ហួសពីវាចាប្រាប់បញ្ជាក់
រៀបរាប់ពណ៌នាដល់លោកអ្នក ឲ្យបានយល់ជាក់អស់សេចក្តី។

ទឹកភ្នែកហូរស្រក់ចាកនេត្រា ស្មើរខ្យ័យជីវាចាកលោកីយ៍
តើខ្ញុំត្រូវរស់ដើម្បីអ្វី សូមអ្នកប្រណីមេត្តាផង ។
ទឹកភ្នែកហូរស្រក់ចាកនេត្រា មកពីកាមាខុសបំណង
បើអ្នកមិនជាប់មិនប៉ុនប៉ង គ្មានអ្វីសៅហ្មងរស់សុខសាន្ត ។

ថ្ងៃ ៥ រោច ខែអស្សុជ ពុទ្ធសករា២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២០១-តើអ្នកស្ដាយអ្វី

-តើអ្នកស្ដាយអ្វី ស្ដាយទឹកស្ដាយដី ស្ដាយព្រៃព្រឹក្សា
ស្ដាយកោះសមុទ្រ ទន្លេបព្វតា ប្រាសាទសិលា
សម្បត្តិដ៏ល្អ ។
-ស្ដាយវត្តព្រះសង្ឃ ប្រណិតផ្ចិតផ្ចង់ ពិតស្រស់បវរ
ស្ដាយធម៌វិន័យ ដ៏មានលំអ ល្អអើយសែនល្អ
ជាពុទ្ធឱវាទ ។
-ស្ដាយពុកស្ដាយម៉ែ ស្ដាយមិនបានថៃ ស្ដាយការប្រមាទ
ស្ដាយកាយវាចា ធ្វើមិនបានស្អាត ចិត្តគិតប្រមាទ
ដល់អ្នកមានគុណ ។
-ស្ដាយបុណ្យកុសល មិនបានតម្កល់ ទុកក្នុងកាលមុន
ស្ដាយការខឹងក្រោធ មិនបានអត់ធន់ ស្ដាយភាពទន់ភ្លន់

ដែលមិនបានធ្វើ ។
-ស្តាយប្រុសចិត្តជា ស្តាយស្រីពុំងា ស្តាយមិនអើពើ
ស្តាយចិត្តភក្តី ស្តាយរាល់ទង្វើ បានធ្វើទៅលើ
ព្រោះមិនដឹងច្បាស់ ។
-ស្តាយទ្រព្យរបស់ ស្តាយបាត់សម្រស់ ស្តាយប្រែជាចាស់
ស្តាយភាពជានា ស្តាយខ្លាំងពេកណាស់ ស្តាយមិនស្រឡះ
តាមការចង់បាន ។
-ស្តាយនូវលាភយស ស្តាយភាពខ្ពង់ខ្ពស់ ស្តាយមិត្រកល្យាណ
ស្តាយអ្នកមានគុណ ស្តាយញាតិសន្តាន ស្តាយចាកភូមិឋាន
ដែលធ្លាប់រស់នៅ ។
-ស្តាយមានច្រើនពិត អោះឱណាមិត្រ អ្នកស្តាយអ្វីទៅ
តែទោះយ៉ាងណា ដឹងចុះណាពៅ អ្វីកន្លងទៅ
គឺជាធម្មៈ ។
-អ្នកគប្បីដឹង សិក្សាសម្លឹង ឲ្យបានយល់ជាក់
ស្គាល់ហេតុបច្ច័យ តាមសភាវៈ ត្រឹមជាធម្មៈ
អ្នកនឹងរួចខ្លួន ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២០២-តើចង់បានអ្វី

-ចង់ឃើញចង់ស្គាល់ ចង់បានប៉ះពាល់ ចង់បានកៀកកើយ
ចង់បាននៅជិត មិនចង់ឃ្លាតឡើយ ឱណាអ្នកអើយ
រឿងកាមលោកីយ៍ ។
-ចង់ស្តាប់សូរសៀង សំណើចសំនៀង ដោយចិត្តមេត្រី
ចង់បានចរចា ទាក់ទងសម្តី សន្តោសប្រណី
ដោយចិត្តមេត្តា ។
-ចង់បានរបស់ ដ៏ល្អឥតខ្ចោះ នៅក្នុងលោកា
យកមកប្រើប្រាស់ ឲ្យស្រស់សង្ហា ឡានផ្ទះវីឡា
សម្បត្តិភោគទ្រព្យ ។
-ចង់បានជាធំ ចង់បានជួបជុំ ចង់បានគួរគាប់
ចង់បានឯករាជ្យ មិនចង់នៅជាប់ រស់ក្រោមបង្គាប់
នៃអ្នកណាម្នាក់ ។
-ចង់សោយសុខស្ងប់ ចង់បានប្រសព្វ និងអរិយមគ្គ
ចង់ឃើញនិព្វាន ចង់រួចអន្ទាក់ ឱណាឱអ្នក
តើចង់បានអ្វី ។
-ចង់បានកាមគុណ នឹងរងទុក្ខធ្ងន់ នៅក្នុងលោកីយ៍
ធ្លាក់អបាយភូមិ វិលក្នុងភពបី ទោះយ៉ាងណាក្តី
ក្តីសុខតិចណាស់ ។

-ចង់រួចចាកទុក្ខ នេះជាប្រមុខ នឹងឲ្យជាក់ច្បាស់
កុសលបារមី បរិបូរណ៍មិនខ្វះ រួចផុតស្រឡះ
បានសុខក្សេមក្សាន្ត ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២០៣-ចង់បានចិត្តស្មោះ

-ចង់បានចិត្តស្មោះ លើសអ្វីទាំងអស់ ជាមួយគ្រួសារ
មិនចង់ជួបទេ មនុស្សចិត្តសាវា មិនគិតគ្រួសារ
ប្រពន្ធកូនស្ងួន។

-សម្បត្តិលាភយស កិត្តិយសកេរ្តិ៍ឈ្មោះ និងភាពមាំមួន
ក៏ចង់បានដែរ ថ្នាក់ថ្នមថែថួន តែថាមាសស្ងួន
សូមមានចិត្តស្មោះ។

-អ្វីៗគ្រប់យ៉ាង អ្នកមានសំណាង អាចបានទាំងអស់
អាស្រ័យលើបុណ្យ សន្សំឥតខ្ចោះ គ្រប់យ៉ាងទាំងអស់
កើតពីបច្ច័យ។

-បើមានចំណង់ ត្រូវខំផ្ចិតផ្ចង់ លៃលកកែខៃ
សន្សំសុចរិត ជាប្រចាំថ្ងៃ នេះជាបច្ច័យ
នៃក្តីសុខសាន្ត។

ថ្ងៃ ៧ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩

ពី សុវណ្ណជោតោ ភួង-សុវណ្ណ

## ២០៤-សលាកភត្ត

-ខែស្រាពណ៍១រោចនៅពេលព្រឹក ចិត្តនឹករលឹកគុណសង្ឃា
រៀបចំទេយ្យធម៌ផងនានា ថ្វាយដោយសទ្ធាស្លាកអាហារ ។
-មានទាំងសៀវភៅត្រៃចីវរ ពណ៌ដ៏ស្រស់ល្អគ្រឿងបរិក្ខារ
បាយទឹកផ្លែឈើនិងភីហ្សា មានចិត្តចេតនាថ្វាយដល់សង្ឃ ។
-បវារណាបច្ច័យតាមវិន័យ ចាត់ចែងលកលៃដោយផ្ចិតផ្ចង់
រួចឧទ្ទិសបុណ្យមិនបង្អង់ ទានថ្វាយដល់សង្ឃអនុមោទនា ។
-សូមពុទ្ធបរិស័ទសាធុចុះ ឲ្យដោយចិត្តស្មោះដោយសទ្ធា
តាមធម៌វិន័យព្រះភគវា អនុមោទនារួចចាកទុក្ខ ។

ថ្ងៃ ១ រោច ខែស្រាពណ៍ ពុទ្ធសករាជ ២៥៥៩
ដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

## ២០៥-ធ្វើបុណ្យភ្ជុំបិណ្ឌ

-វេលាកាន់បិណ្ឌមាន ១៤ ថ្ងៃ ពិតល្អពេកក្រៃសាងបុញ្ញកិរិយា
ឥឡូវ ១៥ ប្រសើរថ្លៃថ្លា បងប្អូនយាយតាធ្វើបុណ្យភ្ជុំបិណ្ឌ ។
-ចាស់ទុំបុរាណលោកបានលៃលក ប្រព្រឹត្តធ្វើមកលោកប្រសប់ប៉ិន
ឲ្យរាស្ត្រប្រជាធ្វើបុណ្យភ្ជុំបិណ្ឌ ផ្អាកកិច្ចការសិនចូលវត្តធ្វើល្អ ។
-កាមគុណឲ្យសត្វរវល់ពេកណាស់ ពីក្មេងដល់ចាស់ឲ្យល្អក់កករ
គ្មានពេលធ្វើបុណ្យសាងសេចក្តីល្អ នេះហៅកម្រកើតចិត្តសទ្ធា។
-ហេតុនេះបរិស័ទទាំងឡាយអើយ ឱកាសមានហើយព្យាយាមម្ទីម្ទា

ធ្វើទានកាន់សីលគោរពបូជា  តាមពេលវេលាកុំបីខកខាន ។
-ឱកាសធ្វើបុណ្យរកបានដោយក្រ  ព្រោះទឹកចិត្តល្អមិនងាយរកបាន
សទ្ធាកើតហើយក្នុងចិត្តសន្តាន  សាងក្តីសុខសាន្តដោយមិនប្រមាទ។

ថ្ងៃ១៥រោច ខែភទ្របទ ពុទ្ធសករា២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២០៦-អស្សុជ ១៥ កើត (១)

*អស្សុជ១៥កើតគួរឲ្យជ្រះថ្លា  ព្រះពុទ្ធសាស្តាទ្រង់បានយាងចុះ
ចាកទេវលោកនាយក្នុងកាលឯណោះ បរិស័ទស្ម័គ្រស្មោះរង់ចាំទទួល។
*អស្សុជ១៥កើតមហាគន្ធកុដិ  បរិស័ទលំអុតមានចិត្តស្រុះស្រួល
ធ្វើបុណ្យកឋិនឥតមានប្រែប្រួល  ព្រមព្រៀងទទួលនូវធម្មទាន។
*អស្សុជ ១៥ កើត សង្ឃបវារណា  វិន័យសិក្ខាតាមព្រះទូន្មាន
បរិស័ទរីករាយមានចិត្តអាចហ៊ាន  ព្រមសមាទានសីលឧបោសថ។
*អស្សុជ១៥កើតប្រសើរខ្លាំងណាស់ បរិស័ទក្មេងចាស់មានចិត្តបរិសុទ្ធ
ស្តាប់ធម៌ទេសនានៅមហាគន្ធកុដិ  បានបុណ្យប្រាកដទុកជាទីពឹង ។

## ២០៧-អស្សុជ ១៥ កើត (២)

*អស្សុជ ១៥ កើតពេញបូណ៌មី  សាវ័កជិនស្រីត្រូវបវារណា
ព្រោះគ្រប់បីខែខាងក្នុងវស្សា  ព្រះពុទ្ធបិតាទ្រង់អនុញ្ញាត ។
*១៥ កន្លង ១ រោចចូលដល់  គប្បីតម្កល់ចិត្តឲ្យបានស្អាត
ធ្វើកឋិនទានព្យាយាមសង្វាត ដោយមិនប្រមាទនៅក្នុងកុសល។

*សទ្ធាចម្រើននៅក្នុងចិត្តហើយ កុំបង្អង់ឡើយកុំនៅខ្វាយខ្វល់
ខ្លាចក្រែងត្រូវស្លាប់ខានធ្វើកុសល សូន្យចាកមគ្គផលពិតគួរឲ្យស្ដាយ។
*សម្បត្តិគ្រប់យ៉ាងទោះមនុស្សទេវតា និព្វានអស្ចារ្យផុតភ័យអន្តាយ
ជាផលសម្រេចនៃបុណ្យទាំងឡាយ ដូច្នេះសប្បាយបំពេញបុណ្យចុះ។

ថ្ងៃ ២ រោច ខែអស្សុជ ពុទ្ធសករា២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២០៨-ព្រះសង្ឃស្រែបុណ្យ

-ខ្ញុំសូមគោរពក្រាបនមស្ការ ដល់ព្រះសាស្ដា ព្រះពុទ្ធជាម្ចាស់
ព្រះធម៌ព្រះសង្ឃប្រសើរល្អល្អះ ល្អក្រៃលែងណាស់ខ្ញុំសូមវន្ទា ។
-នៅក្នុងថ្ងៃមួយរីព្រះសាស្ដា ទ្រង់ព្រះចិន្ដា តាមដោយធម្មា
បានអនុញ្ញាតកឋិនក្នុងគ្រា សាវ័កភគវា ចេញវស្សាហើយ ។
-កាលនោះកាលនេះបរិស័ទទាំងឡាយ មានចិត្តសប្បាយមិនបានកន្ដើយ
ពេញចិត្តនឹងបុណ្យមិនបង្អង់ឡើយ ក្នុងខែនេះហើយចុងរដូវភ្លៀង ។
-អស្សុជ រនោច មាន ១៤ ថ្ងៃ កត្តិកថ្លាថ្លៃ ១៥ ដ៏ទៀង
បូករួម ២៩ ថ្ងៃនេះកុំឃ្លាង រៀបចំប្រិតប្រៀងចីវរបរិក្ខារ ។
-វេរថ្វាយដល់សង្ឃលះដាច់ស្រឡះ បញ្ជាក់យ៉ាងច្បាស់បញ្ចេញវាចា
ឥតមានទាក់ទាមតិចតួចឡើយណា កុសលចេតនាប្រសើរកន្លង ។

-ព្រះសង្ឃសាវ័កទ្រទ្រង់ដោយគុណ សែនល្អពេកពន់ឥតមានសៅហ្មង
វៀរចាកបាបធម៌ លះកាត់ចំណង បរិសុទ្ធកន្លងទក្ខិណេយ្យា ។
-ព្រះសង្ឃស្រែបុណ្យ គប្បីបូជា មិនអាចគណនារាប់ដោយផលា
នាំបានសម្បត្តិប្រសើរថ្លៃថ្លា តាមចិត្តប្រាថ្នាដែលបានតាំងទុក ។

និគ្រោធវ័ន ០៥កើត ខែអស្សុជ ព.ស.២៥៥៨

ដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

## ២០៩_ថ្ងៃកឋិនកាល

-ថ្ងៃកឋិនកាលបានមកដល់ហើយ អ្នកកុំកន្តើយប្រុងប្រៀបរៀបចំ
ចំពត់ចីវរបរិក្ខាររួមផ្សំ ប្រសើរឧត្តមប្រណិតផ្ចិតផ្ចង់ ។
-លើកត្រៃចីវរដាក់លើសិរសា ព្រោះតែជ្រះថ្លាចំពោះព្រះសង្ឃ
ដើរប្រទក្សិណមិនបានបង្អង់ ឆ្ពោះមុខតម្រង់ចូលខណ្ឌសីមា ។
-ដាក់ចុះតម្កល់លើកដៃក្រពុំ ក្រាបថ្វាយបង្គំព្រះត្រៃរតនា
ឧទ្ទិសចំពោះលើកដាក់ហត្ថា បញ្ចេញវាចាសូមថ្វាយដល់សង្ឃ ។
-រួចស្តាប់គាថាអនុមោទនា ដោយចិត្តសទ្ធា ប្រសើរផូរផង់
ហើយឧទ្ទិសទានមិនបានបង្អង់ ទានថ្វាយដល់សង្ឃ អនុមោទនា ។

-ដោយកុសលនេះខ្ញុំសូមសច្ចា ជួបព្រះសម្មាសម្ពុទ្ធភគវា
សូមឱ្យបានស្ដាប់នូវព្រះធម្មា យល់ដឹងមគ្គាត្រាស់ដឹងសច្ចៈ ។

និគ្រោធវ័ន ១០រោច ខែកត្តិក ព.ស.២៥៥៦

ដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

# ២១០-ឧទ្ទិសបុណ្យនិងសច្ចាធិដ្ឋាន

-ខ្ញុំសូមគោរពក្រាបនមស្ការ ដល់ព្រះសាស្ដា ព្រះពុទ្ធជាម្ចាស់
ព្រះធម៌ព្រះសង្ឃ ប្រសើរល្អល្អះ ល្អក្រៃលែងណាស់ខ្ញុំសូមវន្ទា ។
-រលឹកដល់គុណមានចិត្តជ្រះថ្លា ប្រគេនអាហារបរិក្ខារនានា
ចំពោះព្រះសង្ឃគ្រប់ព្រះអង្គា សូមឆាន់ភោជនាតាមមានតាមបាន។
-សូមឧទ្ទិសបុណ្យកុសលចេតនា ដល់ញាតកាកើតគ្រប់ទីឋាន
សព្វសត្វទេវតាដល់សង្ឃកល្យាណ សូមឱ្យលោកបានអនុមោទនា។
-ដោយកុសលនេះខ្ញុំសូមសច្ចា ជួបព្រះសម្មាសម្ពុទ្ធភគវា
សូមឱ្យបានស្ដាប់នូវព្រះធម្មា យល់ដឹងមគ្គាត្រាស់ដឹងសច្ចៈ ។

និគ្រោធវ័ន ០៧កើត ខែអស្សុជ ព.ស.២៥៥៨

ដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

## ២១១-ជូនកុសល

១-អស្សុជរនោចក្នុងថ្ងៃ ១៤ បរិស័ទជួបជូនស្តាប់ធម៌ទេសនា
ព្រះសង្ឃសាវ័កគ្រូធម្មាចារ្យ គង់លើអាសនាប្រកាសសម្តែង ។
២-ដង្ហែព្រះធាតុបូជាភ្ញីផ្កា ដោយចិត្តជ្រះថ្លាគោរពកោតក្រែង
សាកច្ឆាធម៌នឹងសង្ឃគម្តែង កុសលនេះឯងសូមជូនដល់អ្នក ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២១២-សូមបានពរជ័យ

* សូមបានពរជ័យ ផុតចាកទុក្ខភ័យ រស់នៅជួបជុំ
ក្នុងក្រុមគ្រួសារ និងក្នុងសង្គម តែសូមជួបជុំ
ដោយព្រះធម៌អាចិ។

* ពរពិតអាចជួយ ឲ្យផុតទុក្ខព្រួយ ដល់រូបជនណា
ធ្វើអំពើកម្ម បរិសុទ្ធថ្លៃថ្លា ទាំងកាយវាចា
ព្រមទាំងផ្លូវចិត្ត។

* ដឹងចុះបាបធម៌ នាំឲ្យញាប់ញ័រ ក្នុងផ្លូវទុច្ចរិត
សាងកម្មវេរា នាំសៅហ្មងចិត្ត សញ្ញាវិបរិត
មានអ្វីជួយបាន។

* វៀរចាកបាបកម្ម សាងកុសលកម្ម ពិតប្រសើរថ្កាន

នាំបានពរជ័យ សិរីសុខសាន្ត រហូតដល់បាន
សោយនូវសុខស្ងប់។

ថ្ងៃ ៦ រោច ខែកត្តិក ពុទ្ធសករាជ២៥៥៩
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២១៣-សំណាងល្អបវរសុខស្ងួស្តី

-សំណាងល្អបវរសុខស្ងួស្តី នៅនាលោកីយ៍មានអ្វីគាប់
បានជាសត្វលោកតែងតែជាប់ សម្បត្តិភោគទ្រព្យយសថ្កើងថ្កាន។
-បើតាមពិតទៅត្រូវសិក្សា អ្វីក្នុងលោកាទាំងប៉ុន្មាន
ត្រូវចោលទាំងអស់មិនអាចបាន ជាប់ទៅតាមប្រាណបន្តិចឡើយ។
-ស្ងួម្បីបច្ចុប្បន្នមិនប្រាកដ បានតាមកំណត់យើងទៅហើយ
ទម្រាំបរលោកនោះអ្នកអើយ ថានឹងផ្តល់ឲ្យសុខម្តេចទៅ ។
-អ្វីទាំងប៉ុន្មានក្នុងលោកនេះ សម្រាប់លោកនេះដឹងចុះពៅ
មានតែកុសលដែលបិតនៅ ជាប់ក្នុងចិត្តទៅកាន់បរលោក ។
-បញ្ជូនតៗជាប់មិនដាច់ នាំឲ្យសម្រេចនូវជ័យជោគ
ក្តីសុខយសសក្តិសម្បត្តិភោគ នាំឆ្លងចាកលោកដល់ត្រើយនាយ។

ថ្ងៃ ២ រោច ខែអស្សុជ ពុទ្ធសករា២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២១៩-ដូចបានសង្ឃឹម

អស្សុជ១៤រោចពេលព្រឹកព្រលឹម ដូចបានសង្ឃឹមគិតទុករួចហើយ
ទៅបុណ្យកឋិនឱណាអ្នកអើយ មិនបង្អង់ឡើយចេញចរយាត្រា។
យន្តហោះៗឡើងយ៉ាងលឿនរហ័ស ក្នុងផ្ទៃអាកាសកណ្តាលវេហា
ផុតគេហដ្ឋានព្រៃបព្វតា មិនយូរឡើយណាដល់ខេត្តសៀមរាប។
យន្តហោះបត់បែនលើដងទន្លេ ហោះមិនខ្ពស់ទេក៏បានបន្ទាប
ចុះដល់ព្រលាននាខេត្តសៀមរាប ដោយសុវត្ថិភាពសិរីសួស្តី ។
បន្តដំណើរឥតបានបង្អង់ ឆ្ពោះមុខតម្រង់ដោយការឃ្មាតខ្មី
ទៅកាន់អារាមសាវ័កជិនស្រី ចូលដងវិថីវិសុទ្ធិមគ្គ ។
វត្តនៅក្នុងព្រៃជាទីមនោរម្យ បរិស័ទជួបជុំមានចិត្តជឿជាក់
ធ្វើបុណ្យកឋិនឥតមានទើសទាក់ ល្ងាច១៤ជាក់ ១កើតក៏ច្រើន។
គោរពបូជាព្រះរតនត្រ័យ ស្តាប់ព្រះធម៌ថ្លៃនាំបានចម្រើន
សតិបញ្ញាក្រវើនក្រតើន សន្សំឲ្យច្រើនទុកក្នុងសន្តាន ។
ឱកាសមានហើយចិត្តមិនប្រមាទ ខំប្រឹងសង្វាតត្រូវធ្វើឲ្យបាន
អប់រំកុសលមិនឲ្យខកខាន សាងក្តីសុខសាន្តក្នុងសេចក្តីល្អ ៕

ថ្ងៃ១៤រោច ខែអស្សុជ ពុទ្ធសករាជ២៥៦៩
ដោយ សុវណ្ណជោតោ ភួង សុវណ្ណ

# ២១៥-ដឹងសព្វដឹងគ្រប់

១-ជីវិតវេលា សុខភាពជានា សំខាន់ខ្លាំងណាស់
ដូច្នេះគ្រប់គ្នា ត្រូវចេះប្រើប្រាស់ ឲ្យបានជាក់ច្បាស់
នូវផលប្រយោជន៍ ។

២-ដឹងនូវកាលគួរ ឲ្យឬទទួល តិចច្រើនដោយហោច
ត្រូវពិចារណា កុំគិតលេងសើច នាំខូចប្រយោជន៍
ដែលខ្លួនគួរបាន ។

៣-ដឹងកិច្ចការងារ ព្យាយាមស្មុះស្មា កុំឲ្យខកខាន
ធ្វើពេញកម្លាំង ទោះម៉ោងប៉ុន្មាន ត្រូវធ្វើឲ្យបាន
ទាន់នៅស្រួលបួល ។

៤-ដឹងពេលសម្រាក ដែលគប្បីផ្អាក កុំឲ្យមិនស្រួល
ក្រែងបាក់កម្លាំង ឈឺចុករមួល កាយត្រូវប្រែប្រួល
នាំលំបាកប្រាណ ។

៥-ដឹងពេលលំហែ ជួបជុំពុកម៉ែ ញាតិមិត្តកល្យាណ
និងកូនប្រពន្ធ ស្វាមីថ្កើងថ្កាន នៅគេហដ្ឋាន
ឬនៅទីណា ។

៦-ដឹងតួនាទី គប្បីសម្តី តាមពុទ្ធដីកា
ក្នុងនាមជាកូន មាតាបិតា ឬគ្រូអាចារ្យ
ជាដើមផងដែរ ។

៧-ដឹងពេលធ្វើល្អ ទឹកចិត្តបវរ រៀងរាល់ថ្ងៃខែ
ធ្វើទានកាន់សីល ជួយកិច្ចពុកម៉ែ ចិញ្ចឹមមើលថែ
គោរពដឹងគុណ ។
៨-ដឹងត្រៃរតនា ចាស់ព្រឹទ្ធាចារ្យ ត្រូវចេះទន់ភ្លន់
ឱនកាយវន្ទា នេះល្អពេកពន់ នឹងបានជាគុណ
យសសុខសិរី ។
៩-ដឹងសព្វដឹងគ្រប់ ដឹងចេះសេពគប់ នឹងមិត្តប្រុសស្រី
ដឹងធម៌សប្បុរស មគ្គអង្គប្រាំបី ដឹងប្រឹងឃ្លាតខ្ចី
នាំរួចចាកទុក្ខ ។

១០ រោច ខែមិគសិរ ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង សុវណ្ណ

## ២១៦-កុំចង់តែឆ្ងាញ់

-កើតជាសត្វត្រី អស់ជនប្រុសស្រី គេតែងត្រូវការ
យកធ្វើប្រហុក ស្លជាអាហារ តាមចិត្តប្រាថ្នា
គួរឲ្យអាណិត ។
-ជួនត្រូវគេអាំង ម្ទូរស្វាយក្រសាំង បេះជាចំណិត
ជួនចៀនជួនស្ងោរ លាយជាមួយផ្សិត តាមគេចូលចិត្ត
ឱណាឱអ្នក ។
-តែទោះយ៉ាងណា សូមញាតកា ចូរចាំឲ្យជាក់

វៀរការសម្លាប់ កុំឡើយលបលាក់ បរិភោគក៏អ្នក
ត្រូវពិចារណា ។
-កុំចង់តែឆ្ងាញ់ គិតតែពីអញ គប្បីឧបមា
ទាំងសត្វទាំងយើង សុទ្ធតែប្រាថ្នា ចង់មានជីវា
រស់ដោយសុខសាន្ត ។
ដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២១៧-លះបាបដោយកម្មកល្យាណ

-សត្វមានជីវិត គួរយើងពិនិត្យ ឲ្យបានគ្រប់ប្រាណ
សុទ្ធចង់រស់រាន ទោះលំបាកប្រាណ សូមមិត្តកល្យាណ
មានចិត្តមេត្តា ។
-ទោះតូចឬធំ ចង់រស់ជួបជុំ ក្នុងក្រុមគ្រួសារ
បងប្អូនកូនចៅ មាតាបិតា និងញាតកា
មិត្តសម្លាញ់ផង ។
-ចូរកុំគិតថា វាជាអាហារ តាមដោយចិត្តប៉ង
មិនមែនដូច្នោះ ទេណាប្អូនបង នេះទោសសៅហ្មង
ដែលសត្វបានធ្វើ ។
-បាបតែងឲ្យផល រមែងតែងផ្តល់ ទៅតាមទង្វើ
មានអាយុខ្លី នេះមកពីធ្វើ សម្លាប់ទៅលើ

ជីវិតនៃសត្វ ។

-ដូច្នេះត្រូវរៀរ កុំឲ្យមានពៀរ គួរតែប្រយ័ត្ន

កុំសាងបាបកម្ម ជាមួយសព្វសត្វ តែត្រូវកម្ចាត់

កិលេសក្នុងខ្លួន ។

-លោភៈទោសៈ ព្រមទាំងមោហៈ ដឹងចុះមាសស្ងួន

គឺជាសត្រូវ បិតនៅក្នុងខ្លួន នាំទុក្ខផ្ទួនៗ

គប្បីលះបង់ ។

-បើអ្នកលះបាន ដោយកម្មកល្យាណ ប្រណិតផ្ចិតផ្ចង់

ផុតចាកទុក្ខភ័យ ពិតល្អផូរផង់ ដើរក្នុងផ្លូវត្រង់

បានសុខក្សេមក្សាន្ត ។

ថ្ងៃ ០៩កើត ខែមិគសិរ ពុទ្ធសករាជ២៥៥៩

ដោយ សុវណ្ណជោតោ ភួង សុវណ្ណ

## ២១៨-ឱត្រីអើយត្រី

-ឱត្រីអើយត្រី គេចំហុយឆី ធ្វើជាអាហារ

ជួបជុំញាតិមិត្រ និងក្រុមគ្រួសារ គេនិយាយថា

មានរស់ឆ្ងាញ់ណាស់ ។

-សូមជនប្រុសស្រី មានចិត្តប្រណី ទាំងក្មេងទាំងចាស់

ត្រូវឲ្យអភ័យ កុំគិតតែផ្គាស ថាវាឆ្ងាញ់ណាស់

សម្លាប់វានោះ ។

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

> ផលនៃការសម្លាប់សត្វ នាំឲ្យធ្លាក់ទៅសោយទុក្ខ
ក្នុងនរក, ផលដ៏ស្រាល កើតជាមនុស្ស អាយុខ្លី ។
> ផលនៃការវៀរចាកការសម្លាប់សត្វ កើតជាមនុស្ស
មានអាយុវែង ។

## ២១៩-អ្នកបួស

-អ្នកបួសរស់បានដោយអ្នកស្រុក ទោះញាំប្រហុកឬស្ងោរស្ពៃ
ឆាន់ពិចារណាតាមវិន័យ ចិត្តគិតលកលៃចេញចាកកាម ។
-ស្វែងរកទទួលនិងបរិភោគ តាមព្រះមានជោគមិនជិតដាម
ប្រកបដោយធម៌កុំញៀនញ៉ាម ត្រូវប្រព្រឹត្តតាមធម៌វិន័យ ។
-ពិចារណាកំណត់ដឹងបច្ច័យ ជាប្រចាំថ្ងៃមិនមោះមៃ
លះនូវទោមនស្សមិនរំពៃ ចិន្តាលកលៃដោយបញ្ញា ។
-ជីវិតរស់បានព្រោះបច្ច័យ ត្រូវតែកែច្នៃឲ្យភ្លឺថ្លា
ខំរៀនខំស្តាប់ព្រះធម៌អាថ៌ ញុំាងត្រៃសិក្ខាឲ្យដល់ព្រម ។

ព្រឹកថ្ងៃ ១២ រោច ខែមិគសិរ ពុទ្ធសករាជ២៥៥៩

ដោយ សុវណ្ណជោតោ ភួង សុវណ្ណ

## ២២០-ក ខ ។ល។

ក កើតមកហើយមានរូបកាយ ខ ខំខ្វល់ខ្វាយសន្សំល្អ
គ គិតធ្វើអ្វីដោយស្មោះសរ ឃ ឃុំគ្រងល្អដោយវិន័យ ។
ង ងក់ឱនចុះព្រោះគោរព ច ចេះបញ្ឈប់គិតលកលៃ
ឆ ឆាប់យល់ការណ៍ដោយប្រពៃ ជ ជួយដោះភ័យសត្វទាំងឡាយ។
ឈ ឈានទៅមុខដោយស្មារតី ញ ញុំាងប្រុសស្រីឲ្យសប្បាយ
ដ ដឹងស្គាល់ទុក្ខចិត្តនឿយណាយ ឋ ឋិតមិនឆ្ងាយពីធម្មា ។
ឌ ឌិនមាសប្រាក់ត្រូវសម្តី ឍ ឍលភេរីព្រះធម្មា
ណ ណាយចាកកាមព្រោះចិត្តជា ត តែងម្នីម្នាក្នុងកុសល ។
ថ ថែរក្សាខ្លួនឲ្យល្អ ទ ទៅបន្តប្រឹងតម្កល់
ធ ធម៌វិន័យចូលឲ្យដល់ ន នាំបានផលសុខក្សេមក្សាន្ត ។
ប បាបទាំងពួងគប្បីវៀរ ផ ផលសម្បទាប្រសើរថ្កាន
ព ព្រោះធ្វើល្អចិត្តប្រោសប្រាណ ម មានតែបានស្រីមង្គល ។
យ យូរណាស់ហើយម្តេចមិនភ្ញាក់ រ រួចអន្ទាក់កុំអំពល់
ល ល្មមឆាប់ឡើងណានិមល វ វឹងទប់ទល់ពួកកិលេស ។
ស សូមបញ្ឈប់កាមតណ្ហា ហ ហើយប្រាថ្នារកចំណោះ
ឡ ឡើងឲ្យដល់ដោយតម្រិះ អ អស់កិលេសដោយអរិយមគ្គ ។

វត្តនិគ្រោធវ័ន ថ្ងៃ ១ កើត ខែបុស្ស ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ( ភួង-សុវណ្ណ )

# ២២១-កុំ ១២ យ៉ាង

-កុំគិតថាវាមិនសម កុំចង់សុំពីវាសនា
កុំគិតឲ្យដូចប្រាថ្នា កុំតវ៉ានឹងកម្មផល ។
-កុំគិតតែពីខ្លួនឯង កុំសម្តែងនូវកិច្ចកល
កុំធ្វើអ្វីតក់ក្រហល់ កុំបន្ទស់កម្មវេរា ។
-កុំគិតដោះខុសបញ្ហា កុំចរចាខុសវេលា
កុំសេពគប់នឹងពួកមារ កុំរួញរាក្នុងកុសល ។

ថ្ងៃ ០៨ រោច ខែបុស្ស ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួងសុវណ្ណ

# ២២២-មនុស្សលោក

មនុស្សលោកមិនងាយយល់ចិត្តទេ កុហករៀចវេរទុកចិត្តមិនបាន
ខំគិតថាល្អបវរថ្កើងថ្កាន តែការគិតស្មានបានត្រឹមតែខក ។
មើលទៅដូចជាត្រឹមត្រូវខ្លាំងណាស់ តែដល់ស្គាល់ច្បាស់មានតែសម្បក
ខ្លឹមគុណគ្មានទេដូចសត្វចចក បានត្រឹមតែខកខូចខាតប្រយោជន៍។
ហេតុនេះមុននឹងសេពគប់ជាមិត្រ គប្បីពិនិត្យយូរឆាប់ដោយហោច
ឲ្យបានដឹងសិនមិនត្រូវលេងសើច កុំឲ្យអសោចជ្រុលជ្រួសហួសកែ។
បើបានស្គាល់ច្បាស់ឃើញថាល្អហើយ ដឹងចុះអ្នកអើយត្រូវចូលទៅក្បែរ
សេពគប់ជាមិត្រកុំបីប្រួលប្រែ រៀងរាល់ថ្ងៃខែនឹងបានប្រយោជន៍។

កោះរ៉ុង ថ្ងៃ ៦ កើត ខែវិសាខ ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

ព្រះគាថា ទ្រង់ប្រារព្ធចំពោះរឿងនាងចិញ្ចាមាណវិកា

**ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ**

**វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។**

បុគ្គលប្រព្រឹត្តកន្លង (ពាក្យសច្ចៈ) ដែលជាធមិឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថា មិនធ្វើអំពើបាបមិនមានឡើយ ។

## ២២៣-ពរជ័យស្រីសុខសាន្ត

-គេមានមាត់គេក៏ថា គួសវាសអក្ខរាតាមការគិត
ជួនក៏ត្រឹមត្រូវជាការពិត ទៅតាមគំនិតការយល់ឃើញ ។
-ជួនក៏មិនត្រូវខុសស្រឡះ គិតតែផ្តេសផ្តាសគិតលេងៗ
ព្រោះតែមិនដឹងឬមិនឃើញ ដូចភ្ញាក់ពីគេងឥតយល់ការណ៍ ។
-ហេតុនេះកុំបីទុក្ខម្នោម្នេញ កន្ទក់កន្ទេញតាមវាចា
ទោះបីបើគេពោលយ៉ាងណា ខុសត្រូវមេត្តាអោយអភ័យ ។
-បើមិនប្រកាន់មិនទំនាស់ គ្មានការឈ្លោះទាស់ពិតប្រពៃ
អប់រំតាមធម៌និងវិន័យ នាំបានពរជ័យស្រីសុខសាន្ត ។

ថ្ងៃ ៦ កើត ខែវិសាខ ពុទ្ធសករាជ ២៥៥៩

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២២៤-ពាក្យកុហក ពាក្យពិត

ពាក្យកុហកឡេះឡោះលេងសើច  តិចច្រើនដោយហោចកុំបីពោលស្តី
នាំឲ្យដាច់សីលទោះប្រាំៗបី  អស់ញាតិប្រុសស្រីគេមិនទុកចិត្ត។
ពាក្យពោលញុះញង់ទ្រគោះបោះបោក ជាសម្តីថោកជាពាក្យទុច្ចរិត
អ្នកផងទាំងពួងតែងមិនចូលចិត្ត  ដូច្នេះត្រូវបិទសង្រួមវាចា ។
ពាក្យពិតទៀងត្រង់មានរសផ្អែមឆ្ងាញ់ ជនាស្រឡាញ់ចូលចិត្តត្រូវការ
ពាក្យប្រាប់ប្រយោជន៍មានន័យខ្លឹមសារ ជាសម្តីផ្កាប្រសើរបវរ ។
ហេតុនេះអ្នកអើយមុននឹងពោលស្តី  ត្រូវស្គាល់សម្តីអាក្រក់ឬល្អ
កុំចេះតែពោលនាំល្អក់កករ  បើសម្តីសស្អូមពោលទៅចុះ ។

វត្តនិគ្រោធវ័ន ថ្ងៃ ៨ កើត ខែវិសាខ ពុទ្ធសករាជ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២២៥-ដីនៅតែដីមនុស្សស្លាប់អស់

-ខំធ្វើសង្គ្រាមចង់យកឈ្នះ  បង្ហាញតេជះឫទ្ធិអំណាច
កុហកសម្លាប់មិនកោតខ្លាច មានចិត្តកំណាចគួរភិតភ័យ ។
-សង្គ្រាមកើតឡើងត្រូវហិនហោច មនុស្សស្លាប់ជាខ្មោចក្រុងជាព្រៃ
នាំគ្នាដណ្តើមយកទឹកដី  ដីនៅតែដីមនុស្សស្លាប់អស់ ។
-ទោះខំប្រកាន់ថាជាអញ  ហួងហែងស្រឡាញ់សព្វរបស់
តែទីបញ្ចប់ត្រូវសូន្យសោះ  គួរឲ្យស្រណោះពេកកន្លង ។

-ហេតុនេះត្រូវដឹងតាមធម្មា ត្រូវមានចិត្តជាកុំមោះហ្មង
មេត្តាអាណិតសព្វសត្វផង សុទ្ធតែចង់ឆ្លងចាកទុក្ខា ។

ថ្ងៃ ១៣ រោច ខែវិសាខ ពុទ្ធសករាជ ២៥៦០ / ឆ្នាំ២០១៦

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២២៦-សូមផ្តល់ក្តីសុខដល់មនុស្សសត្វផង

សង្គ្រាមកើតឡើងក្នុងទីណា ត្រូវមានទុក្ខាដល់មនុស្សសត្វ
និរាសព្រាត់ប្រាសស្លាប់បង់បាត់ ធម្មជាតិវិបត្តិពីប្រក្រតី ។
សង្គ្រាមកើតឡើងព្រោះកិលេស ដុតរោលឆាបឆេះលែងស្គាល់អ្វី
បាត់បង់មនុស្សធម៌សូន្យស្មារតី វក់កាមលោកីយ៍វង្វេងភ្លេច ។
វិវាទមានមូលទាំងដប់ពីរ ជនជាមុនីចាំជានិច្ច
មិនត្រូវបង្កគប្បីគេច ក្នុងមួយរំពេចកុំបណ្តោយ ។
ត្រូវគ្រប់សង្កត់ត្រូវលះបង់ មានចិត្តស្មោះត្រង់ប្រគល់ឲ្យ
សុខដល់មនុស្សសត្វជាអំណោយ លុះដល់ខាងក្រោយបានក្សេមក្សាន្ត។

ថ្ងៃ ០២ រោច ខែជេស្ឋ ពុទ្ធសករាជ ២៥៦០ / ឆ្នាំ ២០១៦

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

ព្រះពុទ្ធគាថា ទ្រង់ប្រារព្ធចំពោះនាងកុណ្ឌលកេសីថេរី

**យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា**

**ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ៗ**

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ ហើយរមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែ ១ បទ ក៏ឈ្មោះថាប្រសើរជាង ។

**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**

**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ៗ**

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់ ១ ពាន់ៗ ដង គឺ ១ លាន ចំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។

## ២២៧-ឈ្នះដែលប្រសើរឈ្នះខ្លួនឯង

-មហាកំពែងនៃរាជា ធ្វើឡើងការពារជនសត្រូវ

មិនឲ្យឱកាសបិទច្រកផ្លូវ មិនឲ្យសត្រូវលុកលុយបាន ។

-ពង្រឹងអំណាចកើនកម្លាំង ដើម្បីខ្លួនខ្លាំងប្រសើរថ្កាន

តែទោះយ៉ាងណាសត្វគ្រប់ប្រាណ ពិតមិនអាចបានឈ្នះមច្ចុរាជ។

-រក្សាដែលល្អរក្សាខ្លួន ធ្វើឲ្យមាំមួនយប់ព្រឹកល្ងាច
ក្នុងកុសលធម៌កុំឲ្យរៀច បានជាឯករាជលើកិលេស ។
-ឈ្នះដែលប្រសើរឈ្នះខ្លួនឯង ព្រះពុទ្ធសម្ដែងយ៉ាងដូច្នេះ
ហេតុនេះគួរយើងមានតម្រិះ ប្រហារកិលេសដោយអរិយមគ្គ ។

ថ្ងៃ ០៤ រោច ខែវិសាខ ពុទ្ធសករាជ ២៥៦០

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២២៨-ធ្វើជាមនុស្សត្រូវចេះគិត

-ធ្វើជាមនុស្សត្រូវចេះគិត ត្រិះរិះពិនិត្យដោយបញ្ញា
កុំចេះតែធ្វើតាមប្រាថ្នា កិលេសតណ្ហាអូសទាញទៅ ។
-ត្រូវគិតដល់ខ្លួនប្រពន្ធប្ដី និងកូនប្រុសស្រីផងណាពៅ
មាតាបិតាដែលឋិតនៅ ស្គាល់ការរាក់ជ្រៅទាំងក្នុងក្រៅ ។
-ធ្វើការជំនួញស្រែចម្ការ ត្រូវតែសិក្សាកុំល្ងង់ខ្លៅ
ចេះដឹងប្រាកដឆ្ពោះសំដៅ លះបង់កម្មខ្មៅសាងកម្មស ។
-មិនធ្វើទុច្ចរិតដោយដាច់ខាត ខំប្រឹងសង្វាតជាបន្ត
ការងារត្រឹមត្រូវបរិសុទ្ធល្អ មានចិត្តស្មោះសរជានិរន្តរ៍ ។
-កុំចេះតែហ៊ានហួសកម្លាំង ក្រែងលោមិនខ្លាំងបែរជាអន់
ធ្លាក់ខ្លួនដុនដាបជួបអាសន្ន វិនាសទាន់ហាន់ណាមាសមេ ។
-មិនដឹងមិនយល់ទៅរកប្រាក់ ជឿខ្ចីបណ្ដាក់ជំពាក់គេ

ស្មានថាវាស្រួលឥតរិះរេ អត់អីសងគេការជាដើម ។
-លំបាកដល់ខ្លួនប្រពន្ធប្ដី និងកូនប្រុសស្រីរកដង្ហើម
ខ្វល់ខ្វាយសងគេយ៉ាងសម្បើម សឹងផុតដង្ហើមចាកលោកីយ៍ ។
-ហេតុនេះត្រូវតែប្រុងប្រយ័ត្ន កុំឡើយបង់បាត់ភ្លេចស្មារតី
លោភលន់ហួសហេតុលែងស្គាល់អ្វី គិតគ្គីធ្វើក្តីដោយបញ្ញា ។
-ព្រះពុទ្ធជាម្ចាស់ត្រាស់បញ្ជាក់ ពិតប្រាកដជាក់ពុទ្ធដីកា
ជីវិតរស់នៅដោយបញ្ញា ប្រសើរអស្ចារ្យសុខក្សេមក្សាន្ត ។

ថ្ងៃ ០៨ កើត ខែអាសាឍ ពុទ្ធសករាជ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២២៩_នជីរតិសូត្រ

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

**រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ រាគោ ឧប្បថោតិ វុច្ចតិ ។**

**លោភោ ធម្មានំ បរិបន្ថោ វយោ រត្តិន្ទិវក្ខយោ**
**ឥត្ថី មលំ ព្រហ្មចរិយស្ស ឯត្ថាយំ សជ្ជតេ បជា**
**តបោ ច ព្រហ្មចរិយញ្ច តំ សិនានមនោទកំ ។**
**ឆ លោកស្មឹ ឆិទ្ទានិ យត្ថ ចិត្តំ ន តិដ្ឋតិ**
**អាលស្យញ្ច បមាទោ ច អនុដ្ឋានមសំយមោ**
**និទ្ទា តន្ទី ច តេ ឆិទ្ទេ សព្វសោ តំ វិវជ្ជយេ ។**

រូបរបស់សត្វទាំងឡាយ រមែងចាស់ជរា នាមនិងគោត្ត មិនចាស់

ជរាឡើយ, រាគៈហៅថា ផ្លូវខុស ។ លោភៈ ជាសេចក្ដីអន្តរាយនៃធមិ ទាំងឡាយ វ័យអស់ទៅតាមយប់និងថ្ងៃ ស្ត្រី ជាមន្ទិលរបស់ព្រហ្មចរិយៈ ប្រជាជនទាំងនេះ រមែងជាប់ចំពាក់នូវនឹងស្ត្រីទាំងនោះ តបធមិ ឬ ព្រហ្មចរិយធមិ ជាធម្មជាតិសម្រាប់លាងជម្រះនូវមន្ទិលនោះ មិនចាំបាច់ មានទឹកឡើយ ។ ចិត្ត រមែងមិនឋិតនៅក្នុងច្រកទាំងឡាយណា ច្រក ទាំងនោះមាន ៦ យ៉ាង ក្នុងលោក គឺសេចក្ដីខ្ជិលច្រអូស ១ សេចក្ដីធ្វេសប្រហែស ១ សេចក្ដីមិនព្យាយាម ១ ការមិនសង្រួម ១ ការលក់ ១ សេចក្ដីខ្ជិល ១ ជនគប្បីវៀរបង់នូវច្រកទាំងនោះ ដោយ ប្រការទាំងពួងចុះ ។ (បិដក ២៩, ១១២)

## ២៣០-រូបចាស់ រូបថ្មី

-រូបចាស់តែក្មេងជាងឥឡូវ      រូបថ្មីសក់ស្កូវប្រែរូបរាង
នេះហើយសង្ខារធមិមិនទៀង មិនអាចជៀសវាងចាស់ឈឺស្លាប់។
-ថ្ងៃនេះថ្ងៃស្អែកមានប្រាកដ      ដែលលោកសន្មតពោលស្ដីប្រាប់
នឹងឆ្លងកន្លងតាមលំដាប់      អស់ទៅយ៉ាងឆាប់មិនបង្អង់ ។
-រូបកាយជីវិតមិនខុសគ្នា      តែងមានជរាមិនផូរផង់
ទោះបីខំថែដោយផ្ចិតផ្ចង់      រីឯរូបអង្គនៅតែចាស់ ។
-មិនថាគ្រហស្ថឬបព្វជិត      ពាលឬបណ្ឌិតប្រាកដណាស់
សត្វកើតមកហើយតែងតែចាស់ វាត្រូវប្ដូរផ្លាស់តាមធម្មតា ។

-ហេតុនេះដឹងចុះមិត្តកល្យាណ  កុំឲ្យខកខានត្រូវសិក្សា
ព្រះធម៌វិន័យត្រៃសិក្ខា  ចម្រើនកុសលាដោយព្យាយាម ។
-ប្រព្រឹត្តប្រពៃតាមធម្មា  ដោយចិត្តសទ្ធាឥតទាក់ទាម
កម្ចាត់មន្ទិលឥតលាក់លៀម  ធ្វើបានភ្លាមៗដោយប្រតិបត្តិ។
-អ្នកមានគុណធម៌ទោះស្លាប់ទៅ តែកេរ្តិ៍ឈ្មោះនៅមិនសូន្យបាត់
បានជាគំរូដល់សព្វសត្វ  យកមកប្រតិបត្តិបានសុខសាន្ត ។

និគ្រោធវ័ន ថ្ងៃ ១ រោច ខែអាសាឍ ពុទ្ធសករាជ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៣១-ចម្រើននូវផ្លូវសន្តិភាព

-ទិវាកន្លងចូលរាត្រី  បាត់បង់រស្មីនៃសុរិយា
ព្រះចន្ទ្រចូលមកអមតារា  ឯសត្វលោកាក៏សម្រាក ។
-ជំនោរត្រជាក់ក៏បក់ផាត់  បានជួយបំបាត់ការលំបាក
រវល់មួយថ្ងៃមិនសូវស្រាក  តែត្រូវបានផ្អាកពេលរាត្រី ។
-ខ្លះរស់ជួបជុំក្រុមគ្រួសារ  សាច់ញាតិវង្សាប្រពន្ធប្តី
កូនស្ងួនថ្នាក់ថ្នមថៃបមបី  ខ្លះក៏គ្មានអ្វីរស់ម្នាក់ឯង ។
-កិច្ចការសព្វសត្វតែងប្រព្រឹត្ត  តាមការនឹកគិតហួសសម្តែង
លើកមករៀបរាប់ចារតាក់តែង  មិនងាយនឹងថ្លែងឲ្យអស់បាន ។
-រីអង្គបព្វជិតគិតខំប្រឹង  ពិនិត្យសម្លឹងចិត្តសន្តាន
អប់រំចម្រើនព្រះកម្មដ្ឋាន  ដោយកម្មកល្យាណល្អប្រពៃ ។

-សង្រួមរវាំងដោយប្រយ័ត្ន ខំប្រឹងប្រតិបត្តិធម៌វិន័យ
ប្រាជ្ញាយល់ត្រូវគិតលកលៃ បង្អោនព្រះទ័យក្នុងធម្មា ។
-ចម្រើននូវផ្លូវសន្តិភាព ល្អគ្មានអ្វីប្រៀបហួសពណ៌នា
ដែលព្រះសុគតព្រះភគវា ទ្រង់ត្រាស់មាគ៌ាព្រះនិព្វាន ។
-ញ៉ាំងត្រៃសិក្ខាឲ្យផូរផង់ ដោយការផ្ចិតផ្ចង់ចិត្តអាចហ៊ាន
មិនធ្វើកន្លងដោយបំពាន មានការខ្មាសអៀនខ្ពើមបាបធម៌ ។
-បើមិនដូច្នោះមានអ្វីល្អ ចិត្តមិនបវរសែនញាប់ញ័រ
វឹកវរក្នុងកាមស្អិតដូចជ័រ ជាប់នឹងលោកធម៌មិនទៅណា ។
-វង្វេងវង្វាន់ភ្លេចស្មារតី នៅក្នុងភពបីសោយសោកា
ព្រោះតែចំណង់កាមតណ្ហា ឥតមានបញ្ញានឹងដោះខ្លួន ។
-ហេតុនេះកុំនៅដោយប្រមាទ ត្រូវតែសង្វាតឲ្យមាំមួន
សិក្សាអប់រំទូន្មានខ្លួន ឲ្យបានស៊ប់សួនពិតប្រសើរ ។
-អរិយមគ្គបរិសុទ្ធដ៏ផូរផង់ មានមុខឆ្ពោះត្រង់តាមដំណើរ
នឹងបានសម្រេចផលប្រសើរ គាប់ល្អណាស់តើគួរបូជា ។

និគ្រោធវ័ន ថ្ងៃ ១៤ រោច ខែអាសាឍ ពុទ្ធសករាជ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៣២-សុរិយារះពីទិសខាងកើត

-សុរិយារះពីទិសខាងកើត មនុស្សមានកំណើតដោយកុសល
ដូច្នេះត្រូវតែចូលឲ្យដល់ ដោយការតម្កល់ខ្លួនឲ្យល្អ ។

-កម្មបានតាក់តែងនូវអត្តភាព ទោះខ្ពស់ឬទាបខ្មៅឬស
រូបរាងសណ្ឋានល្អមិនល្អ អ្នកត្រូវត្រេកអរទទួលយក ។
-មិនអាចបន្ទោសដល់ជនណា មាតាបិតាបង្កើតមក
នេះជាផលកម្មបានរត់រក តាក់តែងលៃលកតាមការពិត ។
-បើបានសិក្សាធម៌វិន័យ ឃើញច្បាស់ប្រពៃមិនប្រឌិត
គ្រប់យ៉ាងគឺជាសច្ចៈពិត ជនជាបណ្ឌិតរមែងដឹង ។

ថ្ងៃ ០៦ កើត ខែស្រាពណ៍ ពុទ្ធសករាជ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៣៣-រដូវត្រជាក់

-រដូវត្រជាក់ រងាចង់ញាក់ លំបាកងូតទឹក
មិនថាពេលល្ងាច ឬក៏ពេលព្រឹក គ្រាន់ប៉ះត្រូវទឹក
រងាតែម្តង ។
-ផ្សំគ្រុនផ្តាសសាយ រឹតមិនសប្បាយ ខ្លាំងពេកកន្លង
ឈឺក្បាលក្តៅខ្លួន ព្រមទាំងក្អកផង តែកាយសៅហ្មង
ត្រូវងូតជម្រះ ។
-តែទោះយ៉ាងណា សម្រួលកាយា អ្នកត្រូវជម្នះ
លុបលាងរួចរាល់ ដោយការជម្រះ នោះអ្នកនឹងឈ្នះ
ស្រទ្បះខ្លួនប្រាណ ។
-គប្បីរក្សា ការពារអាត្មា ឲ្យបានសុខសាន្ត

កុំឲ្យឈើថ្កាត់ នាំឲ្យរំខាន ខ្លួននិងសន្តាន
សូមសុខសួស្តី ។
ដោយ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៣៤_វត្តនិគ្រោធវ័ន

១-វត្តនិគ្រោធវ័នគល់ទទឹង មានដីសន្ទឹងជិត ១៦ ហិតា
មានទាំងស្រះទឹកព្រៃសួនច្បារ ចំប៉ីចម្ប៉ាបូជាព្រះ ។
២-មានពោធិព្រឹក្សនិងចេតិយ ក្មេងចាស់ប្រុសស្រីមកសំពះ
ក្រាបនមស្ការបោសជម្រះ ពិតមានតេជះដ៏អស្ចារ្យ ។
៣-ព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ មានគុណផូរផង់ឥតឧបមា
ដែលព្រះគុណម្ចាស់រាល់រូបា សិក្សាសិក្ខា ធម៌វិន័យ ។
៤-ប្រតិបត្តិប្រពៃបានត្រឹមត្រង់ ឱ្យសីលផូរផង់នាំផុតភ័យ
តាមព្រះសាស្តាជាជិនស្រី បញ្ញត្តិវិន័យនិងធម្មា ។
៥-មែនពិតព្រះសង្ឃ តា ដូនជី ជួបជុំមូលមីគ្រប់ៗគ្នា
សិក្សាបដិបត្តិព្រះធម្មា ដែលជាមាគ៌ាដ៏បរិសុទ្ធ ។
៦-មានបណ្ណាល័យ ព្រះវិហារ ធម្មសភា និងមហាកុដិ
សាលាអរិយទ្រព្យល្អបំផុត សាងដោយហ្មត់ចត់ដ៏ផ្ចិតផ្ចង់ ។

៧-មានទាំងសាលាសតិប្បដ្ឋាន សិក្សាកម្មដ្ឋានតាមព្រះអង្គ
អប់រំទូន្មានចិត្តឱ្យត្រង់ ប្រសើរផ្លូវផង់ក្នុងសាសនា ។
៨-និងមានសាលាបរិយត្តិ សិក្សាស្វៀមស្វាត់នឹងអាចារ្យ
រៀនពីសីលសមាធិបញ្ញា ដែលព្រះសាស្តាត្រាស់ទុកហើយ ។
៩-ម្យ៉ាងមានវិទ្យុផ្សាយព្រះធម៌ ផ្សព្វផ្សាយដោយល្អមិនកន្តើយ
មិនថាបរិស័ទក្មេងចាស់ឡើយ មានបំណងឱ្យបានសុខស្ងប់ ។
១០-អហំ សុវណ្ណជោតោសមណោ បានលើកប៊ិកចារតែមិនសព្វ
ដោយសង្ខេបខ្លីសូមបញ្ចប់ ការថ្លែងពីវត្តនិគ្រោធវ័ន ។
១១-សូមពុទ្ធបរិស័ទបានក្តីសុខ បណ្តាញស្មាញស្មុគកុំជាប់ព័ន្ធ
ដើរតាមផ្លូវមគ្គដោយរួសរាន់ សាសនាប្រាំពាន់កុំប្រមាទ ។

វត្តនិគ្រោធវ័ន ថ្ងៃ ១០ កើត ខែវិសាខ ព.ស. ២៥៥២
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៣៥_និគ្រោធវ័នទីជម្រក

១-និគ្រោធវ័នទីជម្រក បរិស័ទចូលជ្រកជាប្រចាំ
តែងសាងសន្សំកុសលកម្ម រាល់ថ្ងៃខែឆ្នាំជាបន្ត ។
២-និគ្រោធវ័នជាអារាម ដែលសិក្ខាកាមដ៏បវរ
គ្រហស្ថបព្វជិតចិត្តស្មោះសរ មានទឹកចិត្តល្អមកសិក្សា ។

៣-និគ្រោធវ័នជាវិហារ ផ្តល់នូវវិជ្ជាព្រះធម៌អាថ៌
កុលបុត្របំពេញត្រៃសិក្ខា ហាថ័យស្រស់ថ្លាគ្មានកង្វល់ ។
៤-និគ្រោធវ័នទីមនោរម្យ បរិស័ទជួបជុំតែងបានផល
ទទួលធម្មទានជាកុសល ចិត្តក៏តម្កល់ជាសម្មា ។
៥-និគ្រោធវ័នមានរតនៈ ពិតយ៉ាងប្រចក្សដ៏អស្ចារ្យ
ព្រះពុទ្ធព្រះធម៌ដ៏ថ្លៃថ្លា ព្រមទាំងសមណាសង្ឃគម្តែង ។
៦-និគ្រោធវ័នវត្តនេះណា ដូចខ្ញុំបានចារដោយថ្លាថ្លែង
មានហេតុច្រើនទៀតតែមិនថែង ចប់ប៉ុណ្ណេះឯងសាធុការ ។
៧-បើអ្នកចង់ដឹងសូមមកចុះ ទោះស្រីឬប្រុសបើប្រាថ្នា
ធ្វើទានកាន់សីលស្តាប់ទេសនា ចម្រើនកុសលារួចចាកទុក្ខ ។

ថ្ងៃ ០៧ រោច ខែមិគសិរ ព.ស.២៥៥៨
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៣៦ វិសុទ្ធិមគ្គ

-វិសុទ្ធិមគ្គ អារាមប្រពៃ ឋិតនៅក្នុងព្រៃដ៏ស្រស់អស្ចារ្យ
មានឈើតូចធំជាច្រើនហិតា គួរឱ្យជ្រះថ្លាជាទីមនោរម្យ ។
-វិសុទ្ធិមគ្គ អារាមសង្ឃពិត កើតដោយទឹកចិត្តសទ្ធារួមផ្តុំ
ព្រមដោយបញ្ញាប្រសើរឧត្តម រួបរួមផ្សេងផ្សំបូជាត្រៃរ័ត្ន ។

-វិសុទ្ធិមគ្គ អារាមសង្ឃា គួរឱ្យបូជាយ៉ាងពិតប្រាកដ
ព្រោះក្នុងទីនេះមានព្រះត្រៃរ័ត្ន គោរពបហ្មត់ចត់ចម្រើនបុញ្ញា ។
-វិសុទ្ធិមគ្គ នៅក្នុងព្រៃជ្រៅ មិនមែនលំនៅគ្រហស្ថឡើយណា
ផុតពីភូមិស្រុកសំឡេងខ្សៀវខ្សារ គ្មានការឡូឡាឈ្លោះទាស់ទែងគ្នា ។
-វិសុទ្ធិមគ្គ មានធម៌វិន័យ សិក្សាប្រពៃតាមកុដិវិហារ
ក្រោមឈើតូចធំទាបខ្ពស់នានា ចម្រើនវិជ្ជាក្នុងពុទ្ធសាសនា ។
-វិសុទ្ធិមគ្គ មានព្រះចេតិយ នៅកណ្ដាលព្រៃគួរឱ្យជ្រះថ្លា
តម្កល់ព្រះធាតុនៃព្រះសម្មា- សម្ពុទ្ធនោះណាប្រសើរឧត្ដម ។
-វិសុទ្ធិមគ្គ មានពោធិព្រឹក្ស ថែទាំស្រោចទឹកដោយការខិតខំ
បម្រើបូជាឱ្យបានសក្ដិសម វត្ដនោះឧត្ដមវិសេសថ្លៃថ្លា ។
-វិសុទ្ធិមគ្គ មាននូវព្រះសង្ឃ ជាច្រើនព្រះអង្គបុត្រព្រះសាស្ដា
រៀនធម៌វិន័យតាមត្រៃសិក្ខា ចម្រើនបញ្ញាសម្មាទិដ្ឋិ ។
-វិសុទ្ធិមគ្គ ជាទីស្ងប់ស្ងាត់ អ្នកចង់លះកាត់អប់រំសតិ
ញ៉ាំងសទ្ធាសីលហើយនឹងហិរិ សម្មាទិដ្ឋិស្ទុះទៅខាងមុខ ។
-វិសុទ្ធិមគ្គមានន័យខ្លាំងណាស់ ដែលព្រះពុទ្ធម្ចាស់ទ្រង់បានត្រាស់ទុក
សីលសមាធិបញ្ញានាំមុខ នឹងរួចចាកទុក្ខព្រោះដើរផ្លូវនេះ ។

វិសុទ្ធិមគ្គ ល្ងាចថ្ងៃ ៧ កើត ខែជេស្ឋ ព.ស.២៥៥៥

និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៣៧-អារាមវិសុទ្ធិមគ្គ

( មេពាក្យ ៦ និង ៨ )

១-អារាមវិសុទ្ធិមគ្គ ប្រសូតឡើងជាក់នាកណ្តាលព្រៃ
ដោយសារគុណធម៌វិន័យ ដ៏ល្អប្រពៃកាត់ថ្លៃមិនបាន ។
២-អារាមវិសុទ្ធិមគ្គ សូមប្រាប់លោកអ្នកនៅសព្វទីឋាន
ភូមិឃុំស្រុកខេត្តប៉ុន្មាន អ្នកតាំងសន្តានស្តាប់ដោយហ្មត់ចត់ ។
៣-អារាមវិសុទ្ធិមគ្គ មានប្រាកដជាក់នូវព្រះត្រៃរ័ត្ន
ពិតណាស់យ៉ាងច្បាស់ប្រាកដ គុណព្រះត្រៃរ័ត្ន ជាទីជ្រះថ្លា ។
៤-អារាមវិសុទ្ធិមគ្គ មានព្រះធាតុជាក់នៃព្រះសម្មា-
សម្ពុទ្ធវិសុទ្ធអស្ចារ្យ ដោយគុណករុណាទ្រង់អធិដ្ឋាន ។
៥-អារាមវិសុទ្ធិមគ្គ មានព្រះធម្មៈប្រសើរថ្កើងថ្កាន
បិដកដែលព្រះពុទ្ធបាន ទ្រង់ប្រតិស្ឋានបញ្ញត្តសម្តែង ។
៦-អារាមវិសុទ្ធិមគ្គ មានសង្ឃសាវ័កពិតសង្ឃគម្ដែង
សិក្សាប្រព្រឹត្តកោតក្រែង ដើម្បីសម្តែងនូវការគោរព ។
៧-អារាមវិសុទ្ធិមគ្គ ត្រៃរ័ត្ននេះជាក់ពិតបានជាម្លប់
ចូលជ្រករាល់ពេលថ្ងៃយប់ ដើម្បីបញ្ឈប់កិលេសតណ្ហា ។
៨-អារាមវិសុទ្ធិមគ្គ មានព្រៃត្រជាក់ជាច្រើនហិតា
ស្ងប់ស្ងាត់គ្មានការឡូឡា សំឡេងខ្សៀវខ្សាវឈ្លោះទាស់ទែងគ្នា ។

៩-អារាមវិសុទ្ធិមគ្គ ព្រះសង្ឃសាវ័កនៃព្រះភគវា
សិក្សានូវព្រះធម្មា ចម្រើនវិជ្ជាតាមព្រះសាស្តា ។
១០-អារាមវិសុទ្ធិមគ្គ ដូចបានបញ្ជាក់បងប្អូនយាយតា
ប្រសិនបើលោកប្រាថ្នា លះកាត់តណ្ហាមកទីនេះចុះ ។

វត្តវិសុទ្ធិមគ្គ ព្រឹកថ្ងៃ ១១ រោច ខែជេស្ឋ ព.ស. ២៥៥៥
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៣៨-អារាមវិសុទ្ធិមគ្គ ព្រៃតបោវ័ន

( មេពាក្យ ៦ និង ៨ )

១-អារាមវិសុទ្ធិមគ្គ ជាទីពំនាក់របស់សមណា
អប់រំទូន្មានចិន្តា ក្រោមដើមរុក្ខាចិត្តឥតពាក់ព័ន្ធ ។
២-អារាមវិសុទ្ធិមគ្គ មានព្រៃត្រជាក់ឈ្មោះតបោវ័ន
កុដិតូចជាប់ដីឥតជាន់ ចិត្តលោកគ្រប់គ្រាន់រស់ដោយសន្តោស ។
៣-អារាមវិសុទ្ធិមគ្គ សមណៈស្មោះស្ម័គ្រហាទ័យផុលផុស
លះបង់ស្ត្រីបុរស និងទ្រព្យរបស់គ្មានការទាក់ទាម ។
៤-អារាមវិសុទ្ធិមគ្គ ដូចបានបញ្ជាក់មិនមានលាក់លៀម
ពេលខ្ញុំចូលមកដល់ភ្លាម ឃើញលោកស្ងប់ស្ងៀមដួងចិត្តជ្រះថ្លា ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ ១១ រោច ខែកត្តិក ព.ស.២៥៥៨
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៣៩-វិសុទ្ធិមគ្គទីជម្រក

១-វិសុទ្ធិមគ្គទីជម្រក បរិស័ទចូលជ្រកជាប្រចាំ
តែងសាងសន្សំកុសលកម្ម រាល់ថ្ងៃខែឆ្នាំជាបន្ត ។
២-វិសុទ្ធិមគ្គជាអារាម ដែលសិក្ខាកាមដ៏បវរ
គ្រហស្ថបព្វជិតចិត្តស្មោះសរ មានទឹកចិត្តល្អមកសិក្សា ។
៣-វិសុទ្ធិមគ្គជាវិហារ ផ្តល់នូវវិជ្ជាព្រះធម៌អាថ៌
កុលបុត្របំពេញត្រៃសិក្ខា ហឫទ័យស្រស់ថ្លាគ្មានកង្វល់ ។
៤-វិសុទ្ធិមគ្គទីមនោរម្យ បរិស័ទជួបជុំតែងបានផល
ទទួលធម្មទានជាកុសល ចិត្តក៏តម្កល់ជាសម្មា ។
៥-វិសុទ្ធិមគ្គមានរតនៈ ពិតយ៉ាងប្រចក្សដ៏អស្ចារ្យ
ព្រះពុទ្ធព្រះធម៌ដ៏ថ្លៃថ្លា ព្រមទាំងសមណាសង្ឃគម្ពែង ។
៦-វិសុទ្ធិមគ្គវត្តនេះណា ដូចខ្ញុំបានចារដោយថ្លាថ្លែង
មានហេតុច្រើនទៀតតែមិនថែង ចប់ប៉ុណ្ណេះឯងសាធុការ ។
៧-បើអ្នកចង់ដឹងសូមមកចុះ ទោះស្រីឬប្រុសបើប្រាថ្នា
ធ្វើទានកាន់សីលស្តាប់ទេសនា ចម្រើនកុសលារួចចាកទុក្ខ ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ ១១ រោច ខែកត្តិក ព.ស. ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៤០-នឹកឃើញទាំងអស់

១-ប៉ុន្មានថ្ងៃទៀតត្រូវឃ្លាតឆ្ងាយ   សមណទាំងឡាយគ្រប់រូបា
ព្រោះតែរវល់ក្នុងកិច្ចការ   ឃ្លាតតែកាយាចិត្តអាល័យ ។
២-នឹកឃើញទាំងអស់នឹកដល់គ្រា   សិក្សាធម្មារៀងរាល់ថ្ងៃ
ក្នុងព្រៃត្រជាក់ដ៏ធំក្រៃ   ចិត្តគិតស្រមៃធ្លាប់ជួបជុំ ។
៣-នឹកឃើញទាំងអស់អង្គសមណា   ជួយធ្វើកិច្ចទោះតូចធំ
នៅក្នុងទីស្ងាត់ទីប្រជុំ   ក្រាបថ្វាយបង្គំសូមបម្រើ ។
៤-នឹកឃើញទាំងអស់ពេលបូជា   ដល់ព្រះភគវាដ៏ប្រសើរ
រៀងរាល់ថ្ងៃសីលតាមដំណើរ   គ្មានអ្វីប្រៀបស្មើព្រះសាស្តា ។
៥-នឹកឃើញទាំងអស់ពេលសន្ទនា   វិន័យធម្មាដ៏អស្ចារ្យ
សាកសួរដោះស្រាយនូវបញ្ហា   ដោះដោយបញ្ញាការចេះដឹង ។
៦-នឹកឃើញទាំងអស់សីតវ័ន   និងតបោវ័នលោកខំប្រឹង
ដុះខាត់កិលេសចិត្តសម្លឹង   មិនធូរមិនតឹងមជ្ឈិមា ។
៧-នឹកឃើញទាំងអស់គ្រប់អ្វីៗ   ចិត្តប្រោសប្រណីដោយធម្មា
គ្រហស្ថបព្វជិតផងនានា   តែខ្ញុំត្រូវលាមួយពេលហោង ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ ១១ រោច ខែកត្តិក ព.ស. ២៥៥៨

ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៩១-ឱគិរីរម្យជំរំចិត្ត

* ឱគិរីរម្យជំរំចិត្ត រូបខ្ញុំស្នេហ៍ស្និទ្ធនឹងអ្នកណាស់
តាំងពីចូលដល់ចិត្តស្រឡះ នៅក្នុងឱកាសបុណ្យមួយគ្រា ។
* មានខ្យល់ត្រជាក់ប៉ះកាយា ក្រោមដើមរុក្ខាផងនានា
ដុះសងខាងផ្លូវជាប់តគ្នា តាមដងមាគ៌ាចូលអារាម ។
* ព្រះសង្ឃសាវ័កអង្គសមណា ស្ងប់ស្ងាត់សិក្សាសិក្ខាកាម
ខំប្រឹងប្រព្រឹត្តប្រតិបត្តិតាម ចង់ចេញចាកកាមផុតទុក្ខភ័យ ។
* គោតមចេតិយខ្ពស់ត្រដែត ហាក់ដូចអណ្ដែតនភាល័យ
បរិស័ទទាំងឡាយតែងលកលៃ បង្អោនហទ័យថ្វាយវន្ទា ។
* ហេតុនេះសូមចិត្តអ្នកមេត្តា ចូលអារាមាព្រះសង្ឃា
គោរពកោតក្រែងព្រះភគវា កុំសាងវេរានឹងត្រៃរ័ត្ន ។
* ព្រះពុទ្ធព្រះធម៌និងព្រះសង្ឃ អ្នកត្រូវឱនអង្គដោយហ្មត់ចត់
ធ្វើអ្វីគ្រប់យ៉ាងឲ្យប្រាកដ ឲ្យមានបែបបទធម៌វិន័យ ។
* កុំឡើយប្រមាទធ្វើបំពាន ដោយមិនខ្មាសអៀនឥតគិតអ្វី
ឃើញតែលាភយសកាមលោកីយ៍ នាំធ្លាក់អវីចីទុក្ខខ្លោចផ្សា ។
* បើអ្នកមិនចង់ធ្លាក់អបាយ ចង់សុខសប្បាយផុតទុក្ខា
ត្រូវសាងសន្សំនូវកុសលា នឹងបានផលាសោយសុខស្ងប់ ។

ថ្ងៃ ៧ រោច ខែអស្សុជ ពុទ្ធសករាជ២៥៥៩
និពន្ធដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៤២-ក្រោយពេលភ្លៀងមេឃក៏ស្រឡះ

*ក្រោយពេលភ្លៀងមេឃក៏ស្រឡះ ទាំងផ្ទៃអាកាសក៏ភ្លឺថ្លា
ធម្មជាតិស្រស់ខ្ចីគួរទស្សនា បក្សីបក្សាក៏សប្បាយ ។
*រឿងរ៉ាវផ្សេងៗដែលមានមក នាំគ្នាលៃលកគិតដោះស្រាយ
ដោះដោយបញ្ញាធម៌ទាំងឡាយ ឲ្យបានសប្បាយទាំងអស់គ្នា។
* មិនមានចាក់ដោតមិនព្យាបាទ និងមិនប្រមាទចងកម្មពៀរ
សូមឲ្យបានសុខទាំងអស់គ្នា ផុតទុក្ខវេទនាព្រួយកង្វល់ ។
* សម្លឹងមើលគ្នាដោយមេត្រី ករុណាប្រណីចំពោះដល់
ជួបជុំសាមគ្គីសាងកុសល ចាប់យកមគ្គផលបានសុខស្ងប់ ។

ថ្ងៃ ៩ រោច ខែអស្សុជ ពុទ្ធសករាជ២៥៥៩
ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៤៣-គិរីរម្យចាស់

-ចូលដងវិថីគិរីរម្យចាស់ ហាប្ញទ័យស្រឡះពេកកន្លង
ខ្យល់បក់ត្រជាក់សព្វតែម្តង នាំចិត្តមួហ្មងរសាត់ឆ្ងាយ ។
-ក្រឡេកមើលទៅឃើញចេតិយ នៃព្រះជិនស្រីចិត្តសប្បាយ
ចង់ថ្វាយបង្គំបន្ទន់កាយ សូធ្យធម៌ទាំងឡាយរំលឹកគុណ ។
-អារាមស្ងប់ស្ងាត់នៃសមណា សិក្សាធម៌អាថ៌ល្អលើសលន់
អប់រំសមាធិចិត្តទន់ភ្លន់ ចម្រើនដោយគុណប្រសើរក្រៃ ។

-មានកុដិតូចៗតាមមាត់ទឹក ទឹកហូរសន្សឹកទាំងយប់ថ្ងៃ
លោកគង់ព្យាយាមកាត់អាល័យ មិនថាយប់ថ្ងៃតាមវេលា ។
-សូមចិត្តអ្នកផងកុំរំខាន ធ្វើនូវភូមិឋានព្រះសង្ឃា
ឲ្យវិនាសខូចបែកបាក់គ្នា កើតទុក្ខវេទនាមិនសុខស្រួល ។
-ត្រូវតែជួយថែទាំឲ្យល្អ ដោយចិត្តស្មោះសរកុំប្រែប្រួល
បម្រើការពារដូចជាឈ្នួល អ្នកនឹងទទួលសុខខាងក្រោយ ។

គិរីរម្យចាស់ ០៦ រោច ខែវិសាខ ពុទ្ធសករាជ ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៤៤-តំបន់ព្រៃភ្នំរមណីយដ្ឋាន

-តំបន់ព្រៃភ្នំរមណីយដ្ឋាន ផ្ដល់ក្ដីសុខសាន្តដល់ជនា
ធម្មជាតិត្រជាក់គ្រប់វេលា ទីនោះគឺជាគិរីរម្យ ។
-មានទាំងអារាមព្រះសមណា លោកគង់សិក្សាក្នុងព្រៃភ្នំ
ស្ងប់ស្ងាត់គួរដល់ការអប់រំ វត្តគិរីរម្យមហាវ័ន ។
-គល់ឈើព្រៃស្ងាត់ពីសំឡេង ប្រុសស្រីចាស់ក្មេងឥតពាក់ព័ន្ធ
ឡើងទៅឲ្យដល់មហាវ័ន ចិត្តអ្នកគ្រប់គ្រាន់ប្រសើរក្រៃ ។
-ឯកុដិតូចៗតាមមាត់ទឹក ទឹកហូរសន្សឹកទាំងយប់ថ្ងៃ
លោកគង់ព្យាយាមកាត់អាល័យ មិនថាយប់ថ្ងៃតាមវេលា ។

-គួរនៅសម្រាកដោយស្ងប់ស្ងាត់ ខំប្រតិបត្តិព្រះធម្មា
លះកាត់កង្វល់ក្នុងការងារ អ្នកអាចដកឃ្លាគិតរិះរេ ។
-ប្រសិនបើអាចពិតជាល្អ ប្រសើរបវរខំគ្នាន់គ្នេរ
សិក្សាអប់រំមិនទំនេរ នឹងមិនទទេចាកប្រយោជន៍ ។

គិរីរម្យចាស់ ០៦ រោច ខែវិសាខ ពុទ្ធសករាជ ២៥៦០ ឆ្នាំ២០១៦
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៤៥-សួស្តីគិរីរម្យចាស់

-ពេលព្រឹកសួស្តីគិរីរម្យចាស់ ហាប្ញទ័យស្រឡះត្រជាក់កាយា
មេឃភ្លៀងរលឹមធ្លាក់តាមធម្មតា ក្នុងព្រៃព្រឹក្សាអារាមព្រះសង្ឃ។
-ពេលថ្ងៃសួស្តីគិរីរម្យចាស់ ពន្លឺភ្លឺច្បាស់ត្រចះត្រចង់
មានព្រះរត្នត្រ័យទាំងពផូរផង់ គួរឲ្យឱនអង្គក្រាបប្រណិប័តន៍ ។
-ព្រលប់សួស្តីគិរីរម្យចាស់ មេឃមីរដេរដាសពពករសាត់
ជំនោរត្រជាក់ក៏បានបក់ផាត់ ហាក់ជួយបំបាត់នូវទុក្ខកង្វល់ ។
-រាត្រីសួស្តីគិរីរម្យចាស់ ចិត្តមិនប្តូរផ្លាស់ក្នុងការកុសល
ព្រះសង្ឃយាយតាសន្សំមគ្គផល សូមឲ្យបានដល់សេចក្តីសុខស្ងប់ ។

ថ្ងៃ ០៧ រោច ខែវិសាខ ពុទ្ធសករាជ ២៥៦០ ឆ្នាំ២០១៦
ដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៤៦-អារាមព្រះសង្ឃគិរីរម្យចាស់

-អារាមព្រះសង្ឃគិរីរម្យចាស់ ស្រស់ល្អត្រចះពេកកន្លង
មានខ្យល់ត្រជាក់សព្វតែម្តង នាំចិត្តមួហ្មងរសាត់ឆ្ងាយ ។
-ដើមស្រល់ធំៗខ្ពស់ស្រឡះ ជាច្រើនដេរដាសគួរសប្បាយ
ទាំងខាងឯនាយខាងឯអាយ ធម្មជាតិទាំងឡាយស្រស់បំព្រង។
-ទឹកជ្រោះហូរចុះតាមលំដាប់ មិនមានភក់ល្បាប់តាមជ្រលង
ព្រៃអមសងខាងជាគន្លង ហាក់មានទាក់ទងយូរណាស់ហើយ ។
-ព្រះសង្ឃសាវ័កគង់អាស្រ័យ ជាប្រចាំថ្ងៃមិនតិចឡើយ
គួរចូលបូជាកុំកន្តើយ ថ្ងៃនេះថ្ងៃក្រោយបានសុខសាន្ត ។
-មានទាំងចេតិយខ្ពស់ត្រដែត ដូចជាអណ្តែតប្រសើរថ្កាន
និងពោធិព្រឹក្សស្រស់កល្យាណ សូមញាតិសន្តានចូលវន្ទា ។

ដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៤៧-ស្ពានកាត់អាល័យ

-ស្ពានកាត់អាល័យនិស្ស័យខ្ពស់ សម្រាប់ឆ្លងជ្រោះឆ្ពោះឡើងភ្នំ
ចូលក្នុងព្រៃជ្រៅស្ងាត់ជ្រងំ គួរអភិរម្យក្នុងកម្មដ្ឋាន ។
-ឈានជើងដើរទៅដោយស្មារតី មានចិត្តឃ្មាតខ្មីប្រសើរថ្កាន
សិក្សាប្រតិបត្តិតាមលំអាន ដែលព្រះពុទ្ធបានបង្ហាញប្រាប់ ។

-ស្មុះស្មារសរាន់មិនបង្អង់ ធ្វើទិដ្ឋិត្រង់តាមលំដាប់
អរិយមគ្គផ្លូវផង់មិនអួអាប់ នឹងអាចសម្លាប់កិលេសបាន ។

ថ្ងៃ ០៧ រោច ខែវិសាខ ពុទ្ធសករាជ ២៥៦០
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

## ២៤៨_បុណ្យបូជាព្រះរតនត្រ័យ

-អរុណបានរះចាំងជះរស្មី មកលើផែនដីនាថ្ងៃពសុធា
បរិស័ទទាំងឡាយជ្រះថ្លាគ្រប់គ្នា នាំគ្នាមិម្នាដង្ហែព្រះធាតុ ។
-ចាកផ្ទះចូលវត្ត តាមដងមាគ៌ា ដោយចិត្តសទ្ធាឥតមានរវាត
រីករាយខ្លាំងណាស់ដង្ហែព្រះធាតុ ចិត្តឥតបែកឃ្លាតចាកអំពើល្អ ។
-ថ្ងៃ ១១ កើតនេះពិតប្រពៃ ផល្គុននេះនៃនាំសុខបវរ
ព្រោះសាធុជនមានចិត្តដ៏ល្អ មូលមិរកុះករបំពេញកុសល ។
-ធ្វើសង្ឃគតាទក្ខិណា ជាទានថ្លៃថ្លាឥតមានកង្វល់
មានចិត្តរីករាយដោយការតម្កល់ ឧទ្ទិសឆ្ពោះដល់ព្រះសង្ឃសាវ័ក ។
-ថ្វាយបង្គំព្រះដោយចិត្តជ្រះថ្លា បូជាភ្ញីផ្កាព្រោះតែជឿជាក់
ក្នុងបុណ្យកុសលក្នុងទីព្រះភក្ត្រ ព្រះសម្ពុទ្ធជាក់ទ្រង់ជាភគវា ។
-ស្តាប់ព្រះសទ្ធម្មប្រគេនចង្ហាន់ និមន្តលោកឆាន់គ្រប់ព្រះអង្គា
មានបាយមានម្ហូបលើកមកមិម្នា ស្រូតរូតគ្រប់គ្នាប្រគេនភ្លាមៗ ។

-រួចឧទ្ទិសបុណ្យដល់ពពួកញាតិ ដែលស្លាប់បែកឃ្លាតឥតមានទាក់ទាម
ចង់ឱ្យបានសុខផុតទុក្ខភ្លាមៗ ទៅតាមទំនៀមក្នុងព្រះសាសនា ។
-ជូនបុណ្យកុសលដល់គ្នានឹងគ្នា ដោយចិត្តសទ្ធាតាមពុទ្ធដីកា
មិនមានកំណាញ់លាក់លៀមឡើយណា ព្រោះមានប្រាថ្នាឱ្យសុខបវរ ។
-សាធុទទួលនូវបុណ្យទាំងឡាយ ដែលគេបានផ្សាយដោយចិត្តដ៏ល្អ
រីករាយនឹងបុណ្យដោយចិត្តស្មោះសរ សាធុត្រេកអរដើម្បីសុខស្ងប់ ។

យប់ថ្ងៃ ១០ កើត ខែផល្គុន ព.ស.២៥៥៥

ដោយភិក្ខុ ភួង-សុវណ្ណ សុវណ្ណជោតោ

# កំណាព្យតាមបុណ្យនានា

## ២៤៩_បុណ្យដង្ហែព្រះធាតុ

(ទៅកម្ពុជាក្រោម)

-ថ្ងៃ ១៣ កើតខ្នើតខែវិសាខ បរិស័ទសម្រាកពីកិច្ចការងារ
ចាកគេហដ្ឋានភូមិឋាននានា នាំគ្នាម្នីម្នាឡើងជិះលើឡាន ។
-អរុណបានរះចាំងជះរស្មី គ្រប់រូបឃ្មាតខ្មីញ៉ាំងចិត្តសន្ដាន
ព្រមដោយសទ្ធាប្រសើរថ្កើងថ្កាន ព្រោះហេតុតែបានដង្ហែព្រះធាតុ ។
-កម្ពុជាក្រោមស្រុកខ្មែរពីដើម នាំគ្នាផ្ដួចផ្ដើមឥតមានរវាត
ចូលរួមហែហមព្រះបរមធាតុ ដែលត្រូវបែកឃ្លាតឆ្ងាយពីស្រុកខ្មែរ ។
-ពិទូឃោសរង្សីវិហារ មានព្រះសង្ឃាយាយតាផងដែរ
រង់ចាំទទួលនឹងរួមដង្ហែ ឥតមានបែកបែរងាករេថយក្រោយ ។
-ថ្ងៃ ១៤ កើតខ្នើតខែវិសាខ ក្រោយពីសម្រាកចិត្តមិនកន្ដើយ
រៀបសក្ការៈរួចស្រេចបាច់ហើយ មិនបង្អង់ឡើយក៏ឆ្ពោះសំដៅ ។
-ព្រះសង្ឃដូនជីក្មេងចាស់ប្រុសស្រី ខ្លះកាន់ខ្លះបីនៅក្រោមកំដៅ
សូរ្យសែងស្រទន់មិនសូវជាក្ដៅ ភ្ញីផ្កាសំដៅបូជាសាស្ដា ។
-បានយាងព្រះអង្គជាព្រះមុនី និងព្រះសង្ឃជីល្អអ៊ីម្ល៉េះណា
តាមកម្រាលព្រំប្រសើរថ្លៃថ្លា បូជាភ្ញីផ្កាបាំងក្លស់លើកទង់ ។

-តម្រង់ចំពោះឡើងលើវិហារ ហទ័យល្អជាងង្ហែតាមទ្រង់
ដោយចិត្តសោមនស្សដូចចតុរង្គ ព្រះសង្ឃលោកគង់ក្រាបថ្វាយវន្ទា ។
-រួចនមស្ការថ្វាយបង្គំព្រះ លើកដៃសំពះឱនកាយគ្រប់គ្នា
សូធ្យធម៌រំលឹកព្រះគុណនានា នៃព្រះភគវាអរហន្តា ។
-រួចហើយអញ្ជើញគ្រូកែវវិមុត្តិ ជាសាវ័កពុទ្ធឡើងថ្លែងវាចា
ចំណាប់អារម្មណ៍និងពោលធម៌អាថ៌ គួរឱ្យជ្រះថ្លានៅក្នុងពិធី ។
-បន្តបន្ទាប់ខ្ញុំភ្លួងសុវណ្ណ ចាប់មេក្រូកាន់មានចិត្តសម្ដី
រៀបរាប់រាយរ៉ាប់នៅក្នុងពិធី ដំណើរមុនីព្រះបរមធាតុ ។
-ខ្ញុំបានទទួលយកមកបូជា ដោយចិត្តសទ្ធាខ្ញុំមិនចង់ឃ្លាត
ក្រាបថ្វាយបង្គំម្ដងហើយម្ដងទៀត ហាក់មិនចង់ឃ្លាតពីព្រះពុទ្ធម្ចាស់ ។
-ថ្ងៃ ១៥ កើតវិសាខបុណ្ណមី បរិស័ទឃ្មាតខ្ចីទាំងក្មេងទាំងចាស់
ធ្វើការគោរពដោយក្រៃលែងណាស់ ព្រោះជឿជាក់ច្បាស់គុណព្រះត្រៃរ័ត្ន ។
-ហែប្រទក្សិណដោយចិត្តជ្រះថ្លា តាមព្រះសាស្ដាបានដើរព័ទ្ធព័ទ្ធ
នៅលើវិហារមានជួរបន្ទាត់ មិនបានស្ងាត់មាត់សូធ្យធម៌បូជា ។
-ក្រាបថ្វាយបង្គំហើយនមស្ការ ចាត់ចែងភ្ញីផ្កាលំអិតនានា
ក្បូរក្បាច់រចនាដោយចិត្តសទ្ធា វេរថ្វាយបូជាឱ្យបានសក្ដិសម ។

-ប្រកាសវិសាខបញ្ជាក់យ៉ាងច្បាស់ ថ្ងៃព្រះពុទ្ធម្ចាស់ប្រសើរឧត្តម
ប្រសូតត្រាស់ដឹងដោយការខិតខំ បំពេញផ្សៃផ្សំបារមីអស្ចារ្យ ។
-មយ៉្យាងទៀតជាថ្ងៃដែលព្រះទ្រង់ញាណ បរិនិព្វាននៅកុសិនារា
ខាងក្នុងសាលវ៉ិនរបស់ក្សត្រា គ្រប់គ្រងរក្សាដោយស្ដេចមល្លក្សត្រ ។
-នៅក្នុងពេលនោះបរិស័ទទាំងឡាយ មានចិត្តសោកស្ដាយជុំជិតតាន់តាប់
ចូលមកបូជាដោយការលះកាត់ កម្ចាយកម្ចាត់បាបអកុសល ។
-ល្ងាច ១៥ កើតវិសាខបុណ្ណមី បរិស័ទប្រុសស្រីមានចិត្តតម្កល់
លះបង់លុយកាក់ដោយមិនខ្វាយខ្វល់ បំពេញកុសលដោយការលកលៃ ។
-សង្វរពោធិញ្ញាណនោះផងណា អារាមលោកតាស្រស់ល្អប្រពៃ
មានសង្ឃយាយតាបងប្អូនប្រុសស្រី មានភក្ត្រប្រិមប្រិយទទួលរាក់ទាក់ ។
-ល្ងាចថ្ងៃ ១ រោចក្នុងខែវិសាខ ក្រោយពីសម្រាកពំនឹងពំនាក់
ស្រូតរូតឡើងយានទឹកចិត្តត្រជាក់ មិនមានស្ទើរស្ទាក់ទៅវត្តមួយទៀត ។
-សិរីមង្គលសាគរបារាច គ្រប់គ្នាអង់អាចឥតមានរវាត
បំពេញបុញ្ញាម្ដងហើយម្ដងទៀត ដោយមិនបានឃ្លាតឆ្ងាយពីកុសល ។
-កសាងព្រះពុទ្ធបរិនិព្វាន បានជាធម្មយានឈានរកមគ្គផល
ដោយចិត្តជ្រះថ្លាឥតមានកង្វល់ ស្ងប់អកុសលចម្រើនកុសលា ។
-អហំ រីខ្ញុំនាម ភួង សុវណ្ណ បានលើកប៊ិកកាន់ចារជាអក្ខរា

និយាយរៀបរាប់ទៅតាមហេតុការណ៍ ឥឡូវអាត្មាបញ្ចប់ប៉ុណ្ណេះ ។
-សូមឱ្យបរិស័ទព្រះពុទ្ធទាំងឡាយ មានចិត្តសប្បាយដោយផលពិសេស
កើតពីបូជាប្រមាណប៉ុណ្ណេះ រួចចាកកិលេសបាននូវសុខា ។

កម្ពុជាក្រោម ថ្ងៃ១៥ កើត ខែវិសាខ ព.ស.២៥៥៤
ដោយភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៥០-បុណ្យនៅភ្នំបូកគោ

-ព្រឹកថ្ងៃប្រាំរោចរនោចខែជេស្ឋ ចេញចាកនិវេសន៍បវរភូមិឋាន
ដួងចិត្តរីករាយប្រពៃកល្យាណ ឡើងទៅក្នុងឡានចេញចរយាត្រា ។
-អរុណក៏រះចាំងជះរស្មី តាមដងវិថីទៅតាមធម្មតា
ដំណើរទៅមុខតាមចិត្តប្រាថ្នា ព្រះសង្ឃយាយតាឥតមានកន្តើយ ។
-តាកែវកំពតដល់តាមលំដាប់ ស្រូតរូតប្រញាប់មិនសូវឈប់ឡើយ
ចូលអាហារដ្ឋានបរិភោគរួចហើយ ឱណាអ្នកអើយរៀបចំរៀបខ្លួន ។
-បន្តដំណើរឡើងភ្នំបូកគោ មានខ្យល់ជំនោរបោក់ដូចអង្រួន
សទ្ធាជ្រះថ្លាសតិមាំមួន ដើម្បីថែថួនសូធ្យធម៌បវរ ។
-ខ្លះសូធ្យបានច្រើនខ្លះសូធ្យបានតិច នេះធ្វើដូចម្តេចព្រោះចាំមិនល្អ
រថយន្តលឿនទៅកាត់គ្រោះកាត់ថ្ម កាត់លើស្ពានថ្មអ្នកបើកប្រឹងទប់ ។

-កាត់ចន្លោះព្រៃខាងលើខ្នងភ្នំ ឃើញពុទ្ធរូបធំចិត្តបានតាំងស៊ប់
បានត្រឹមជ្រះថ្លាព្រោះឡានមិនឈប់ មុនពេលព្រលប់ដល់កាស៊ីណូ ។
-ឡើងដល់ខាងលើមើលឃើញសមុទ្រ គួរឱ្យតក់ស្លុតរឿងទឹកភ្នែកហូរ
តណ្ហាអវិជ្ជាវិលវល់ផ្លាស់ប្ដូរ ញុំាងទឹកភ្នែកហូរស្រក់លើផែនដី ។
-រួចធ្វើដំណើរស្រូតរូតឆ្ពោះទៅ កាន់វត្តសំពៅប្រាំស្រស់ប្រិមប្រិយ
កសាងលើភ្នំបូកគោប្រពៃ នៅនាទឹកដីនៃខេត្តកំពត ។
-រថយន្តតូចធំចូលចតពាសពេញ ចិត្តមិនទោម្នេញរួចហើយដើរទត
វិហារសាលាថ្មភ្នំកំពត ឡើងចុះដើរទតឃើញព្រះពុទ្ធម្ចាស់ ។
-នៅវេលាល្ងាចខ្យល់បក់ត្រជាក់ ពពកក៏ធ្លាក់រសាត់មកប៉ះ
ញុំាងដួងហឫទ័យឱ្យត្រេកអរណាស់ ឱ្យបានស្រឡះផុតចាកទុក្ខា ។
-ចូលកាន់សាលាសន្សំកុសល មានចិត្តតម្កល់ក្នុងត្រៃរតនា
ក្រាបថ្វាយបង្គំសូធ្យធម៌នមស្ការ សមាទានសីលាដោយចិត្តសទ្ធា ។
-ស្ដាប់ព្រះបរិត្តអភិសេកថ្វាយផ្កា ស្រែកសាធុការលាន់ឮខ្ទរខ្ទារ
រលឹកដល់គុណនៃព្រះភគវា ដែលទ្រង់ឈ្នះមារស្ងប់ក្នុងព្រះទ័យ ។
-បន្ទាប់បន្ទាប់រៀបគ្រែទេសនា ដោយចិត្តជ្រះថ្លាឧបាសិកាន័យ
ឈ្មោះហាវសារុធចិត្តល្អប្រពៃ និងញោមដទៃជួយរៀបចាត់ចែង ។
-រីឯអាចារ្យមានតួនាទី ប្រញាប់សម្ដីខិតខំតាក់តែង

និមន្តលោក ៣ រូបឱ្យលោកសម្តែង វែកញែកថ្លាថ្លែងនូវព្រះធម្មា ។
-ពេលចប់ទេសនាក៏ឧទ្ទិសផល ចែកជូនទៅដល់សព្វសត្វគ្រប់គ្នា
ទោះមនុស្សទេព្តាឬជាព្រហ្មា ដោយចិត្តសទ្ធាក្នុងត្រៃរតនៈ ។
-ព្រះពុទ្ធព្រះធម៌ព្រមទាំងព្រះសង្ឃ បរិសុទ្ធផូរផង់ដ៏យ៉ាងប្រចក្ស
មានគុណក្រៃលែងគួរអស់លោកអ្នក មានចិត្តស្មោះស្ម័គ្រគ្រប់ពេលវេលា ។
-នៅពេលរាត្រីសម្ងួស្សត្រជាក់ ព្រោះពពកធ្លាក់រងាអង្គា
ព្រះសង្ឃច្រើនពេកសិងជិត១គ្នា ដោះទាល់មួយគ្រាមួយយប់ទៅចុះ ។
-ឯសាធុជនជាពុទ្ធបរិស័ទ គ្នាច្រើនពេកក្តាត់សសៀរសសោះ
ចូលទៅសម្រាន្តទោះជាកៀនកោះ បើមានប្រឡោះនឹងអាងចូលជ្រក ។
-រាត្រីត្រជាក់ទៅដោយសំណើម ខ្យល់និងសន្សើមលាយដោយពពក
សែនត្រជាក់ខ្លាំងមិនធ្លាប់ជួបមក នាំគ្នាលែលកសម្រួលកាយា ។
-ដល់ពេលជិតភ្លឺអរុណបានរះ រស្មីចាំងជះពេញអាកាសា
ញ៉ាំងភាពងងឹតបាត់ទៅធម្មតា បរិស័ទយាយតារៀបចំចង្ហាន់ ។
-នៅម៉ោងប្រាំបួនរៀបចំទទួល ព្រមព្រៀងស្រុះស្រួលដោយមិនប្រកាន់
រង់ចាំលោកគ្រូដែលគាត់មកកាន់ ភិក្ខុរស់ចាន់ក៏បានថ្លាថ្លែង ។
-ម៉ោងប្រាំបួនជាងគាត់ក៏មកដល់ បរិស័ទខ្វាយខ្វល់ប្រញាប់ចាត់ចែង

អញ្ជើញលោកគ្រូឱ្យគាត់សម្តែង និយាយថ្លាថ្លែងនូវព្រះធម្មា ។

-នៅម៉ោងដប់ជាងព្រះធមិបានចប់ ហឫទ័យក៏ស្ងប់សាយសព្វច្រើនគ្នា

ព្រោះបានក្រេបផឹកនូវរសឱជា ដែលគ្រូធម្មាចារ្យគាត់សម្តែង ។

-រួចហើយដឹកនាំវេរនូវគម្ពីរ បិដកធម្មីដល់សង្ឃគម្តែង

ដោយចិត្តរីករាយក្នុងគ្រានោះឯង គោរពកោតក្រែងក្នុងត្រៃរតនៈ ។

-បន្តបន្ទាប់រៀបចំចង្ហាន់ និមន្តលោកឆាន់នៅលើអាសនៈ

ធ្វើដោយផ្ចិតផ្ចង់សន្តានស្មោះស្ម័គ្រ ក្នុងសង្ឃសាវ័កនៃព្រះភគវ៉ា ។

-អហំ រីខ្ញុំឈ្មោះភួង-សុវណ្ណ លើកប៉ាកកាកាន់ហើយចារពណ៌នា

និយាយរៀបរាប់នូវហេតុនានា រីការពណ៌នាខ្ញុំសូមបញ្ចប់ ។

-លើសលស់ខ្វះខាតខ្ញុំសូមអភ័យ សូមបានប្រពៃប្រសើរគួរគាប់

ដោយបុណ្យកុសលបន្តបន្ទាប់ ជួយឱ្យមានភ័ព្វផុតចាកទុក្ខា ។

ភ្នំបូកគោ ថ្ងៃ ០៦ រោច ខែជេស្ឋ ព.ស.២៥៥៣ ឆ្នាំ២០០៩

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៥១-បុណ្យប្រតិស្ឋានពោធិព្រឹក្ស

ព្រឹកថ្ងៃ ១០ កើតខ្នើតខែអាសាឍ ទឹកចិត្តថ្លាស្អាតរីករាយត្រេកអរ

ស្រុះស្រួលស្រស់ស្រាយក្នុងសេចក្តីល្អ ប្រសើរបវរនាំបានសុខជា ។

អរុណពណ៌មាសនាទិសខាងកើត   រស្មីល្អឆើតពេញផ្ទៃពសុធា
យានចេញដំណើរតាមដងមាគ៌ា    បរិស័ទគ្រប់គ្នាមានចិត្តស្មោះសរ ។
ផុតក្រុងភ្នំពេញនិងខេត្តកណ្ដាល  តាមផ្លូវត្រកាលដោយការត្រាច់ចរ
ធម្មជាតិទាបខ្ពស់ដ៏ស្រស់បវរ     ដុះដាលបន្តតាមជួរគន្លង ។
កាត់កំពុងចាមចូលកំពង់ធំ         ឆ្លងផុតស្ពានធំទៅវត្តបាគង
ចាត់ចែងចង្ហាន់ថ្វាយដល់សង្ឃហោង ចិត្តមិនសៅហ្មងរីករាយស្រស់ស្រាយ ។
រួចហើយរៀបចំទេយ្យធម៌នានា    បរិស័ទគ្រប់គ្នាមានចិត្តសប្បាយ
បានវេរដល់សង្ឃសាវ័កទាំងឡាយ  ជាង ១០ អង្គប្លាយគង់នៅប្រចាំ ។
រួចស្រេចបន្តដំណើរទៅទៀត    អ្នកបើកឈ្លាសឆ្លៀតប្រកាន់ខាងស្ដាំ
តាមកាលកំណត់ដែលលោកបានផ្ដាំ   ថាបរិស័ទចាំទទួលនៅវត្ត ។
រថយន្តលឿនលយចូលខេត្តសៀមរាប បរិស័ទបានរៀបជាជួរបន្ទាត់
ឈរជារបងនៅខាងក្នុងវត្ត       មិនបានហាមឃាត់មានចិត្តរីករាយ ។
សុវណ្ណមុនីសោភ័ណស្រស់ល្អ      បរិស័ទកុះករមានតាមានយាយ
ព្រះសង្ឃច្រើនអង្គនៅអាយនៅនាយ ប្រសើរពណ្ណរាយមានចិត្តជាបុណ្យ ។
នៅម៉ោងបីជាងបរិស័ទគ្រប់ថ្នាក់  មានចិត្តស្មោះស្ម័គ្រត្រជាក់ស្រទន់
ចូលកាន់សាលាសាងសន្សំបុណ្យ   ចិត្តក៏ទោរទន់ក្រាបនមស្ការ ។

សមាទានសីលស្តាប់លោកសូធ្យធម៌ ត្រៃអរសាទរមនោជ្រះថ្លា
ធ្វើអភិសេកបូជាដោយផ្កា ថ្វាយសាធុការថ្វាយព្រះពរជ័យ ។
បន្តបន្ទាប់រៀបត្រៃទេសនា ដោយចិត្តជ្រះថ្លាឧបាសិកាន័យ
នាមហាវសារុធចិត្តល្អប្រពៃ និងញោមដទៃជួយរៀបចាត់ចែង ។
រីឯអាចារ្យមានតួនាទី ប្រញាប់សម្ពីខិតខំតាក់តែង
និមន្តលោក ៣ រូបឱ្យលោកសម្តែង វែកញែកថ្លាថ្លែងនូវព្រះធម្មា ។
ពេលចប់ទេសនាក៏ឧទ្ទិសផល ចែកជូនទៅដល់សព្វសត្វគ្រប់គ្នា
ទោះមនុស្សទេព្តាឬជាព្រហ្មា ដោយចិត្តសទ្ធាក្នុងត្រៃរតនៈ ។
ព្រះពុទ្ធព្រះធម៌ហើយនិងព្រះសង្ឃ បរិសុទ្ធផូរផង់ដ៏យ៉ាងប្រចក្ស
មានគុណក្រៃលែងគួរអស់លោកអ្នក មានចិត្តស្មោះស្ម័គ្រព្រមដោយសទ្ធា ។
រួចហើយស្រូតរូតបន្តកម្មវិធី បរិស័ទមូលមីរជុំអារាធនា
ព្រះពោធិព្រឹក្សដែលគួរបូជា អង្គព្រះភគវាទ្រង់ត្រាស់ដឹង ។
នាប៉ែកខាងខ្មែតវិសាខបុណ្ណមី ប្រសើរថ្លាថ្លៃនៅក្នុងថ្ងៃហ្នឹង
ក៏គឺជាថ្ងៃដែលទ្រង់ត្រាស់ដឹង ១៥ កើតហ្នឹងជាព្រះភគវា ។
រីឯពោធិព្រឹក្សដែលត្រូវប្រតិស្ឋាន គឺពូជពោធិ៍បានពីពុទ្ធគយា
ដែលពួកសាវ័កបានអារាធនា រហូតនៅនាកោះស្រីលង្កា ។
បន្តបន្ទាប់មកដល់ស្រុកខ្មែរ ញាតិញោមបានថែដោយសោមនស្សា

គោរពក្នុងគុណប្រសើរអស្ចារ្យ    បូជាថ្វាយផ្កាចំប៉ាចំប៉ី ។
ឥឡូវអារាធនាមកប្រតិស្ឋាន    ប្រសើរថ្កើងថ្កានបានជាចេតិយ
សុវណ្ណមុនីសោភ័ណប្រពៃ    សាវ័កប្រុសស្រីគោរពបូជា ។
នៅពេលរាត្រីភ្លៀងក៏បានធ្លាក់    សម្មស្សត្រជាក់នាំឱ្យរងា
រកកន្លែងជ្រកគ្រប់ៗអង្គា    វិការបូជាបញ្ចប់តែម្តង ។
ខ្លះចូលសាលាខ្លះចូលវិហារ    ខ្លះក៏ម្នីម្នាដើរដោយត្រសង
ប្រញាប់ប្រញាល់មានរត់ខ្លះផង    ទៅតាមចិត្តប៉ងកាន់ទីនានា ។
សន្សើមត្រជាក់នៅពេលរាត្រី    ក៏បានឃ្មាតខ្មីចងមុងគ្រប់គ្នា
ដេកលក់ជាសុខក្នុងអវិជ្ជា    ឱសត្វគ្រប់គ្នាប្រមាទដល់ណា ។
អវិជ្ជាតណ្ហាឧបាទាន    កម្មក៏នៅមានញ៉ាំងសត្វលោកា
កើតចាស់ឈឺស្លាប់គ្រប់ៗអាត្មា    មិនងាយអ្នកណានឹងអាចគេចផុត ។
នាពេលជិតភ្លឺពន្លឺស្វាងស្វៃ    អរុណោទ័យដ៏ស្អាតបរិសុទ្ធ
ញ៉ាំងភាពងងឹតឱ្យសូន្យរលត់    បរិស័ទមោះមុតរៀបចំចង្ហាន់ ។
រួចហើយបន្តកម្មវិធីទៀត    ដោយការខ្មីឃ្មាតឆ្ពោះមុខទៅកាន់
ខ្លះសែងខ្លះទ្រខ្លះក៏បានកាន់    ដោយមិនប្រកាន់ព្រោះប្រាថ្នាបុណ្យ ។
ដង្ហែពោធិព្រឹក្សនិងព្រះគម្ពីរ    ដែលជាធម្មីដ៏មានគុណធ្ងន់

ប្រតិស្ឋានព្រះពោធិ៍ប្រសើរពេកពន់ អ្នកមានចិត្តបុណ្យមកនមស្ការ ។
រួចហើយជួបជុំបើកការសន្ទនា នូវព្រះធម្មានៃព្រះសាស្តា
ដោយសាវ័កទ្រង់វិសុទ្ធថ្លៃថ្លា កបដោយបញ្ញាព្រមដោយសទ្ធា ។
នៅម៉ោងជិត១០ព្រះធមិបានចប់ ហឫទ័យក៏ស្ងប់សាយសព្វច្រើនគ្នា
ព្រោះបានក្រេបផឹកនូវរសឱជា ដែលព្រះសង្ឃាដោះស្រាយសម្តែង ។
រួចហើយក៏បានវេរនូវគម្ពីរ ព្រះធមិធម្មីដល់សង្ឃគម្តែង
ប្រសើរខ្ពង់ខ្ពស់ឧត្តមក្រៃលែង ព្រះអង្គសម្តែងថាជារតនៈ ។
មិនតែប៉ុណ្ណោះមានទៀនវស្សា តម្កល់ត្រៀបត្រាសាដកឧទកៈ
ដាក់នៅខាងមុខចំពោះព្រះភក្ត្រ ព្រះសង្ឃសាវ័កជាស្រែបុណ្យជាក់ ។
បន្តបន្ទាប់រៀបចំចង្ហាន់ និមន្តលោកឆាន់នៅលើអាសនៈ
រៀបចំចាត់ចែងដោយចិត្តស្មោះស្ម័គ្រ ដល់សង្ឃសាវ័កនៃព្រះភគវា ។
អហំ វីខ្ញុំនាមភួងសុវណ្ណ បានលើកប៊ិកកាន់ហើយចារពណ៌នា
និយាយរៀបរាប់នូវហេតុនានា វីការពណ៌នាស្ទេរសូមបញ្ចប់ ។
លើសលស់ខ្វះខាតសូមញាតិអភ័យ ព្រោះខ្ញុំខំលៃក្រែងមិនគួរគាប់
ដោយបុណ្យកុសលបន្តបន្ទាប់ ជួយឱ្យមានភ័ព្វផុតចាកទុក្ខា ។

សៀមរាប ថ្ងៃ១០-១១កើត ខែអាសាឍ ព.ស.២៥៥៣

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៥២-បុណ្យដង្ហែអដ្ឋកថាទៅមណ្ឌលគិរី

-ថ្ងៃ ១២រោច រនោចខែបុស្ស ក្មេងចាស់ស្រីប្រុសចាកគេហដ្ឋាន
ព្រះសង្ឃបរិស័ទប្រសើរថ្កើងថ្កាន ឡើងជិះលើឡានឆ្ពោះទៅកាន់ខេត្ត ។
-មណ្ឌលគិរីស្ថិតនៅសែនឆ្ងាយ បរិស័ទទាំងឡាយមានចិត្តត្រដែត
ទៅសន្សំបុណ្យកាត់ស្រុកកាត់ខេត្ត ជាហេតុឱ្យឆ្អែតឱ្យបានសុខា ។
-អរុណពណ៌មាសចាំងជះរស្មី មកលើផែនដីដងព្រៃព្រឹក្សា
បរិស័ទទាំងឡាយមានចិត្តជ្រះថ្លា ហើយនមស្ការរលឹកដល់គុណ ។
-ព្រះពុទ្ធព្រះធម៌ហើយនិងព្រះសង្ឃ វិសុទ្ធផូរផង់គួរយើងអត់ធន់
តាំងចិត្តបូជាសទ្ធាជាទុន វិសេសលើសលន់នាំបានបញ្ញា ។
-ពេលព្រឹកព្រលឹមរៀបចំចង្ហាន់ និមន្តលោកឆាន់តាមចិត្តប្រាថ្នា
ព្រោះមានសទ្ធាព្រមដោយបញ្ញា កុសលចេតនាប្រកបដោយអង្គ ។
-ពេលឆាន់រួចហើយចេញដំណើរទៀត សង្វាតខ្មីឃ្មាតព្រមដោយព្រះសង្ឃ
ស្រូតរូតឡើងយានឆ្ពោះមុខតម្រង់ ឥតមានបង្អង់ទៅតាមចិត្តប៉ង ។
-មណ្ឌលគិរីសម្បូរព្រៃភ្នំ មានតូចមានធំឈើដុះត្រសង
មានជ្រោះមានអូរទឹកហូរកាត់ឆ្លង សូរស័ព្ទគឹកកងលាន់ឮឈ្ងូឆរ ។
-ផ្កាកប៉ុណ្ណោះសិនមិនទាន់បញ្ចប់ កាត់ព្រៃកាត់ដុបឡានបើកបន្ត

ដល់សែនមនោរម្យវត្តសង្ឃបវរ រៀបចំស្រស់ល្អព្រោះមានពិធី ។
-ហៃពោធិព្រឹក្សអដ្ឋកថា គម្ពីរដីកាថេរៈសម្ដី
បានចាររៀបរាប់នូវព្រះធម៌ ដែលព្រះមុនីទ្រង់ត្រាស់សម្ដែង ។
-អធិប្បាយកែខែពន្យល់អត្ថ ដោយប្រុងប្រយ័ត្នយ៉ាងច្បាស់ជាក់ស្ដែង
នូវពុទ្ធដីកាព្រះអង្គសម្ដែង ទោះខ្លីឬវែងលៃឱ្យងាយយល់ ។
-នេះក៏ជាគុណរបស់ព្រះសង្ឃ ជាបុត្រព្រះអង្គដែលលោកបានផ្ដល់
គិតគូរខ្វល់ខ្វាយហើយបានបន្សល់ គួរយើងតម្កល់កុំបីប្រែប្រួល ។
-វត្តសែនមនោរម្យជាទីរីករាយ ព្រះសង្ឃតាយាយបានមកទទួល
យាងមុខសាលាចិត្តឥតប្រែប្រួល ចេញមកទទួលជួយគ្នាចាត់ចែង ។
-នៅវេលាល្ងាចមានកម្មវិធី លើកនូវធម៌យកមកសម្ដែង
វែកញែករៀបរាប់ចោទឆ្លើយថ្លាថ្លែង ដោយសង្ឃគម្ដែងចំនួន៤ អង្គ ។
-រួចហើយនឹងវេរអដ្ឋកថា គម្ពីរដីកា ដ៏ល្អផូរផង់
មានទាំងវត្ថុរៀបចំផ្ចិតផ្ចង់ បូជាដល់សង្ឃពេលចប់ទេសនា ។
-រួចហើយញោមញាតិផងទាំងឡាយ មានចិត្តស្រោះស្រាយបំពេញកុសលា
ខ្លះក៏ចាត់ចែងនូវគ្រែទេសនា មិនមានតវ៉ានាំគ្នាសម្អី ។
-នាំយកក្រណាត់ពីថង់ពីទៃ រវៀសរវៃក្បួរក្បាច់ផ្កាភ្ញី
ភ្ជាប់អាសនៈបូជាធម៌ ដោយញោមទាំងពីរញោមយ៉េកញោមវុធ ។

-ដល់ពេលវេលាចូលកាន់សាលា   លោកយាយលោកតានាំគ្នាប្រយុទ្ធ
ច្បាំងនឹងកិលេសដោយចិត្តមោះមុត ខំប្រឹងតយុទ្ធមិនបានរួញរា ។
-នមស្ការនិងសមាទានសីល        ដើម្បីផ្តាច់ផ្តិលកិលេសមារ
លោភៈទោសៈមោហៈមាយា      និងអវិជ្ជាមានះតណ្ហា ។
-ស្តាប់ព្រះសង្ឃសូធ្យនូវព្រះបរិត្ត   ដោយការផ្ចង់ចិត្តស្ងាត់សព្ទវាចា
រួចនិមន្តធម្មកថិកទេសនា        សាកសួរធម៌អាថ៌ចរចាដោះស្រាយ ។
-លោកម្ចាស់ឃឹម-ទូច ជាធម្មធរ   បុច្ឆាបន្ត ឱ្យអធិប្បាយ
នូវអត្ថសេចក្តីជិតខ្លីវែងឆ្ងាយ   យកមកចែកចាយកុំឱ្យសេសសល់ ។
-ខ្ញុំភួង-សុវណ្ណ និងសុខ-សុផៃ      មេត្តាកែខៃមិនបានកង្វល់
នាំគ្នាបកស្រាយបំបាត់ចម្ងល់      ភ្លាមៗឱ្យដល់តាមធម៌វិន័យ ។
-ប្រយោជន៍កសាងអដ្ឋកថា        គម្ពីរដីកា ចូលក្នុងទានអ្វី
រីឯមេត្តា តាមអធ្យាស្រ័យ        ពេញចិត្តធម៌ថ្លៃបញ្ជាក់ធម្មៈ ។
-ពេលចប់ទេសនាភិក្ខុរស់ច័ន្ទ        ចាប់មេក្រូកាន់មិនបានស្ងៀវស្ងាក់
ជួយរៀបចាត់ចែងដោយចិត្តស្មោះស្ម័គ្រ ខ្លះកាន់ខ្លះដាក់ខាងមុខព្រះសង្ឃ ។
-បញ្ចេញវាចាបញ្ជាក់យ៉ាងច្បាស់   ពិតប្រាកដណាស់រាល់រូបរាល់អង្គ
សូមថ្វាយបូជាចំពោះព្រះសង្ឃ     វិសុទ្ធផូរផង់ទាំងប្រាំមួយវត្ត ។

-រីឯញោមវុធលើកពោធិព្រឹក្ស ដើមត្រង់ដុះស្លឹកដូចជាបន្ទាត់
ប្រគេនភិក្ខុដែលគង់ក្នុងវត្ត ហេតុតែរូបគាត់មានចិត្តសទ្ធា ។
-ចំណែកញោមវ៉ាង និងអ្នកឯទៀត មានចិត្តឆ្លាសឆ្លៀតក៏បានម្ចីម្ចា
លើកនូវគម្ពីរក្បួនច្បាប់សោភា វត្ថុនានាថ្វាយសង្ឃផងទៀត ។
-រួចហើយស្រេចបាច់ក៏ឧទ្ទិសផល ចែកជូនទៅដល់ពពួកនៃញាតិ
ទោះនៅជិតឆ្ងាយឬស្លាប់បែកឃ្លាត និងសត្វផ្សេងទៀតឱ្យបានសុខជា ។
-ពេលចប់ពិធី រីបរិស័ទ រសាយរសាត់កាន់ទីនានា
ខ្លះផ្ទះសំណាក់ខ្លះសណ្ឋាគារ អាត្មានៅនាងវត្តលោកតា ។
-នៅពេលរាត្រីសន្សើមត្រជាក់ រងាញ័រញាក់មិនមែនធម្មតា
ដណ្ដប់ចីវរតែក៏មិនថា រីឯមេត្តាលោកដណ្ដប់ព្រហ្ម ។
-ចំណែកញោមខ្លះមិនដឹងយ៉ាងណា គេងលើសាលាដ៏ទាបហើយធំ
ផ្ទៃវាលស្រឡះត្រសាយត្រសុំ ដែលសង្ឃឧត្តមចាត់ចែងផ្ដួចផ្ដើម ។
-ពេលព្រឹកព្រលឹមចេញចរយាត្រា ទៅតាមធម្មតាកាត់ទឹកសន្សើម
កាត់ក្រួសកាត់ថ្មដែលមានសំណើម ញាតិញោមចាប់ផ្ដើមនិមន្តលោកឆាន់ ។
-រួចហើយទៅវត្តព្រហ្មសីមារាម គឺជាអារាមរបស់អង្គច័ន្ទ
ដែលយើងបានដឹងនិងធ្លាប់ប្រកាន់ ថារូបអង្គច័ន្ទធ្លាប់នៅទីនោះ ។
-មិនយូរប៉ុន្មានបានវិលត្រឡប់ ព្រោះបានបញ្ចប់ក្នុងមួយសន្ទុះ

ធ្វើអធិដ្ឋានដើម្បីចាក់ធ្លុះ ទម្លាយទម្លុះក៏បានបែកឃ្លាត ។
-ខេត្តមណ្ឌលគិរីឃុំប៊ូស្រា ស្រុកពេជ្រាដា សម្បូរជនជាតិ
មានព្រៃមានភ្នំតូចធំប្រច្រៀត តាមបែបធម្មជាតិដុះដាលបន្ត ។
-តំបន់ទឹកធ្លាក់ទឹកជ្រោះប៊ូស្រា សួរស័ព្ទឈូឆា ក្មេងចាស់ត្រេកអរ
ងូតលេងសប្បាយទឹកធ្លាក់លើថ្ម ថតរូបល្អៗញញឹមប្រិមប្រិយ ។
-ឯរមណីយដ្ឋានទឹកធ្លាក់- មនោរម្យជាក់ឈើដុះស្រស់ខ្ចី
ហៅដំណាក់ស្ដេចស្រស់ល្អប្រពៃ ញោមខ្លះលកលៃងូតលេងសប្បាយ ។
-ទៅសមុទ្រឈើ ភ្នំដោះក្រមុំ ត្រសាយត្រសុំ មើលគួរឱ្យណាយ
វាយោត្រជាក់បក់ផាត់ត្រូវកាយ ខ្លះក៏សប្បាយទៅតាមចិត្តប៉ង ។
-រួចហើយស្រួតទៅមណ្ឌលបុរី- កុមារប្រុសស្រី រង់ចាំត្រសង
លោកគ្រូអ្នកគ្រូជាអ្នកចម្លង បីបាច់ត្រកង ដូចម្ដាយទីពីរ ។
-ព្រះសង្ឃតាយាយមានចិត្តមេត្តា និងករុណា ផ្ដល់ជាធម្មី
លើកជាឱវាទដោយចិត្តសម្ដី រួចមានពិធី ចែកសៀវភៅថ្មី ។
-ណ្ហើយប៉ុណ្ណឹងចុះខ្ញុំសូមបញ្ចប់ បើមិនគួរគាប់ សុំញាតិប្រណី
លើសលស់ខ្វះខាតនូវអត្ថសេចក្ដី ទោះវែងឬខ្លីចារបានប៉ុណ្ណោះ ។
-សូមសត្វទាំងឡាយបាននូវសុខជា ចូរព្រមព្រៀងគ្នាហើយកុំប្រហែស

សិក្សាធមិអាថិឱ្យមានចំណេះ ញ៉ាំងគុណវិសេសឱ្យកើតមានហោង ។

ខេត្តមណ្ឌលគិរី ថ្ងៃ ១២ រោច ខែបុស្ស ព.ស.២៥៥៣

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

## ២៥៣_កឋិនទាននៅមណ្ឌលគិរី

១-មណ្ឌលគិរី ខេត្តនេះជាទី គួរឲ្យមនោរម្យ
មានព្រៃទាបខ្ពស់ មានជ្រោះមានភ្នំ ទាំងតូចទាំងធំ
ច្រើនអ្វីម្ល៉េះណា។

២-ដង្ហែចីវរ មានពណ៌ស្រស់ល្អ ព្រះសង្ឃយាយតា
ក្មេងចាស់តូចធំ ស្រែកសាធុការ ដោយចិត្តជ្រះថ្លា
អនុមោទនា ។

៣-ចិត្តជាកុសល ដែលបានតម្កល់ ក្នុងព្រះភគវា
ព្រះធមិឧត្តម និងព្រះសង្ឃា ត្រៃរ័ត្ននេះជា
រតនៈអស្ចារ្យ ។

៤-ទូលត្រៃចីវរ បរិស័ទសាទរ ញ៉ាំងចិត្តចេតនា
ដើរប្រទក្សិណ រួចចូលសាលា បញ្ចេញវាចា
វេរថ្វាយដល់សង្ឃ ។

៥-ដឹកនាំពិធី ក្រុមពួកសង្ឃជី មានលោកមួយអង្គ
នាមរស់សុច័ន្ទ មានចិត្តតម្រង់ មិនបានបង្អង់

ទៅទាំងទើសទាក់ ។

៦-រួចឧទ្ទិសបុណ្យ ប្រកាសទ្រព្យធន សម្រាប់ទុកដាក់
ហៅសង្កត់ត្រៃ ឲ្យបានប្រចក្ស មានទាំងទឹកប្រាក់
ខ្មែរនិងដុល្លារ ។

៧-គ្រាន់តែចប់ភ្លាម រវៀសរវាម ចេញចាកសាលា
រកទីសម្រាក រៀងៗអាត្មា ឱអនិច្ចា
នេះរឿងរូបកាយ។

៨-ទឹកជ្រោះប៊ូស្រា ស្រុកពេជ្រាដា ជនជាតិទាំងឡាយ
ទៅទស្សនា ដោយចិត្តសប្បាយ ស្កាត់ពីជិតឆ្ងាយ
ចង់ឃើញចង់ស្គាល់។

៩-ទឹកជ្រោះហូរចុះ ញុាំងចិត្តស្រីប្រុស ហាក់ឲ្យញាប់ញ័រ
ចង់ចុះងូតលេង ចង់ទៅប៉ះពាល់ ព្រោះតែបានស្គាល់
ឃើញទឹកហូរខ្លាំង។

១០-ទឹកធ្លាក់មិនឈប់ ទាំងថ្ងៃទាំងយប់ ដូចមានកម្លាំង
ឮសូរឈ្ងូឆរ ធ្លាក់ចាកមាត់ច្រាំង ពិតជាហូរខ្លាំង
តាមជាន់តាមថ្នាក់។

១១-ទឹកជ្រោះប៊ូស្រា គ្រាន់ជាសម្មតា មានយ៉ាងប្រចក្ស
តំបន់ជនជាតិ ហើយលោកបានដាក់ នេះជាលក្ខណៈ
ធម្មជាតិប្រណិត។

១២-ជ្រោះព្រៃទាំងឡាយ ទោះល្អឆើតឆាយ ជាទីគាប់ចិត្ត
តែទោះយ៉ាងណា វាតែងវិបរិត មិនអាចថេរឋិត
នៅតាមសភាព ។
១៣-សុជន់គិរី មានព្រមទាំងពីរ មួយខ្ពស់មួយទាប
នៅសងខាងផ្លូវ ដូចគេតម្រៀប ហាក់មានរបៀប
ក៏លោកសន្មត។
១៤-ឯសមុទ្រឈើ សម្លឹងពីលើ ឃើញយ៉ាងប្រាកដ
វែងឆ្ងាយសន្លឹម មិនអាចកំណត់ ចាស់ទុំសន្មត
សាគររុក្ខា។
១៥-អ្វីៗក្នុងលោក មានច្រើនគរគោក មនុស្សទេវតា
ទន្លេសមុទ្រ សុជន់បព្វតា ទឹកជ្រោះប៊ូស្រោ
គ្រាន់តែជានាម។
១៦-ចក្ខុសោតា ឮឃើញរូបា ចាប់ប្រកាន់ភ្លាម
មិនបានពិចារណា ដោយនូវទំនៀម មិនស្គាល់រូបនាម
ជាលោកវោហារ។
១៧-អហំ រីខ្ញុំ ប្រមូលរួមផ្តុំ ចារជាអក្ខរា
និយាយរៀបរាប់ នូវព្រឹត្តិការណ៍ ដំណើរយាត្រា
ចប់ប៉ុណ្ណេះចុះ ។
មណ្ឌលគិរី ១២ រោច ខែអស្សុជ ពុទ្ធសករាជ ២៥៥៦
និពន្ធដោយ ភិក្ខុសុវណ្ណជោតោ ភួង-សុវណ្ណ

ព្រះពុទ្ធគាថា ទ្រង់ប្រារព្ធចំពោះឧបាសិកាវិសាខា

**យថាបិ បុប្ផរាសិម្ហា  កយិរា មាលាគុណេ ពហូ**

**ឯវំ ជាតេន មច្ចេន  កត្តព្វំ កុសលំ ពហុំ ៕**

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា (ផ្សេងៗគ្នា) ឱ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឱ្យច្រើនយ៉ាងនោះ ។

## ២៥៤-កៀនស្វាយជាស្រុកកំណើត (ទី១)

-ឱស្រុកកៀនស្វាយជាស្រុកកំណើត កន្លែងធ្លាប់កើតធ្លាប់នៅរួមរស់
ធ្លាប់នៅធ្វើការរៀនសូត្រធម៌បួស ចេញសាងព្រះផ្នួសក្នុងពុទ្ធសាសនា។
-វត្តកៀនស្វាយក្នុងជ្រោយអម្ពិលចាស់ បានផ្តល់ឱកាសឲ្យខ្ញុំសិក្សា
មជ្ឈិមវ័ននិគ្រោធវ័នផងណា  នៅរៀនធម៌អាថ៌សិក្ខាវិន័យ ។
-ខ្ញុំចាំមិនភ្លេចនូវរឿងទាំងឡាយ  តាំងពីលាម្តាយចិត្តល្អប្រពៃ
ដើម្បីសាងផ្នួសក្នុងធម៌វិន័យ  ចង់រួចចាកភ័យក្នុងវដ្តសង្សារ ។
-រឿងទុក្ខលំបាកជួបច្រើនណាស់ហើយ ឱណាអ្នកអើយនេះជាធម្មតា
ចង់ឆ្លងឱឃៈត្រូវប្រឹងសិក្សា  បំពេញសិក្ខាទើបរួចចាកទុក្ខ ។

ថ្ងៃ ១៤ កើត ខែបុស្ស ពុទ្ធសករាជ ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

# ២៥៥-កៀនស្វាយជាស្រុកកំណើត (ទី២)

-ឱស្រុកកៀនស្វាយជាស្រុកកំណើត កន្លែងធ្លាប់កើតធ្លាប់នៅរួមរស់
ធ្លាប់នៅរៀនសូត្រធ្វើការផតមោះ រកចម្អែតពោះដោយចិត្តត្រេកអរ។
-វត្តកៀនស្វាយក្នុងវត្តកៀនស្វាយក្រៅ ភូមិព្រែកក្របៅទាំងដូនស
ក្បាលកោះព្រែកធំធម្មជាតិស្រស់ល្អ អ្នកទៅទេសចរមានចិត្តមេត្រី។
-ធម្មជាតិខៀវស្រស់បន្លែបង្ការ ទាំងមូលផលាក៏សម្បូរធើ
ផ្លែស្វាយផ្លែមៀនច្រើនមិនខ្វះអី បង្អួតប្រុសស្រីតាមរដូវកាល ។
-តែទោះយ៉ាងណាសូមចិត្តអ្នកចុះ ទាំងស្រីទាំងប្រុសបានទៅក្រសាល
រក្សាវប្បធម៌ធម្មជាតិគ្រកាល ជួយអភិបាលឲ្យល្អប្រសើរ ។

ថ្ងៃ ១០ រោច ខែមិគសិរ ពុទ្ធសករាជ ២៥៥៩
និពន្ធដោយភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ

# ២៥៦-មិនគួរប្រាថ្នាកាមលោកីយ៍

>កែបកំពតជាប់កំពង់សោម ទេសភាពរូបឆោមស្រស់ប្រិមប្រិយ
ហាក់ដូចប្រលោមជនប្រុសស្រី ជាប់កាមលោកីយ៍ចង់ទស្សនា។
>បើអ្នកបានឃើញនិងបានគិត ដឹងពីការពិតដោយបញ្ញា
គួរសង្វេគក្នុងវដ្តសង្សារ មិនគួរប្រាថ្នាកាមលោកីយ៍ ។

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ២៥៧-ទឹកដីសៀមរាប

( បទពាក្យ ៧ )

១-ទឹកដីសៀមរាបប្រសើរណាស់ ជាទីក្រុងចាស់ពីបូរាណ
មានប្រាង្គប្រាសាទល្អច្រើនថ្កាន ដែលស្ដេចទ្រង់បានសាងបូជា ។
២-អង្គរធំតូចដ៏អស្ចារ្យ ក្បូរក្បាច់រចនាបែបនានា
មានព្រះពុទ្ធរូបព្រះភគវា បរិស័ទគ្រប់គ្នានមស្ការ ។
៣-រូបព្រហ្មរូបនាគបង្អួតរាង ព្រមទាំងរូបនាងទេពកញ្ញា
ពត់ជើងពត់ដៃកាយវិការ មើលទៅភក្រ្តាល្អសមណាស់ ។
៤-នៅតាមជញ្ជាំងមានចម្លាក់ ដែលលោកបានឆ្លាក់ប្រវត្តិសាស្ត្រ
រឿងរ៉ាវទាំងឡាយច្រើនពេកណាស់ តែងតែប្តូរផ្លាស់តាមសម័យ ។
៥-ប្រាសាទបន្ទាយស្រីដ៏ប្រណិត ចម្លាក់វិចិត្រជាស្នាដៃ
ពួកជាងបូរាណបានកែច្នៃ រហូតសព្វថ្ងៃជាមាតិា ។
៦-ប្រាសាទតូចធំច្រើនបែបយ៉ាង ដែលបានកសាងដោយរាជា
ច្រើនជំនាន់មកតៗគ្នា បរទេសនានាកោតស្ញប់ស្ញែង ។
៧-ឯភ្នំគូលេនល្អណាស់ដែរ ស្ដេចបូរាណខ្មែរបានចាត់ចែង
កសាងពុទ្ធរូបត្រង់កន្លែង កំពូលនោះឯងព្រះអង្គធំ ។

៨-ទឹកជ្រោះហូរខ្លាំងហូរមិនឈប់ ទាំងថ្ងៃទាំងយប់ឮរងំ
តាមជាន់តាមថ្នាក់ខ្សែតូចធំ ក្មេងចាស់ជួបជុំងូតសប្បាយ ។
៩-ខាងលើជិតជ្រោះមានប្រាសាទ រូបរាងស្អាតបាតតែប្រែក្លាយ
បាក់បែកទ្រុឌទ្រោមថ្មខ្ចាត់ខ្ចាយ ឈើព្រៃទាំងឡាយដុះព័ន្ធព័ទ្ធ ។
១០-អោះឱ! សង្ខារមិនទៀងពិត គឺតែងវិបរិតតែងប្រាសព្រាត់
របស់គ្រប់យ៉ាងមិនទៀតទាត់ គ្មានអ្វីអាចឃាត់ជាធម្មជាតិ ។
១១-វត្តព្រះអង្គជប់នៅមិនឆ្ងាយ បួនពាន់ម៉ែត្របួយគប្បីឆ្លៀត
ទៅថ្វាយបង្គំកុំអាលឃ្លាត ជួបព្រះពុទ្ធទៀតក្រាបវន្ទា ។
១២-ទឹកជប់ត្រជាក់ទៀបព្រះបាទ មើលទៅថ្លាស្អាតមានឱជា
ក្រេបផឹកបំបាត់ទុក្ខវេទនា សូធ្យធម៌បូជាចម្រើនគុណ ។
១៣-ដើមឈើធំៗម្លប់ត្រជាក់ ចម្ប៉ាជ្រុះធ្លាក់ចិត្តទោរទន់
បិទភ្នែកភាវនាលែងគយគន់ រលឹកដល់គុណព្រះពុទ្ធម្ចាស់ ។
១៤-សូមចប់ប៉ុណ្ណេះលែងរាប់រៀប គ្រាន់ឱ្យអ្នកជ្រាបហេតុខ្លះៗ
ព្រោះនៅមានរឿងច្រើនទៀតណាស់ បើចង់ដឹងច្បាស់ចូរទៅចុះ ។

ថ្ងៃ ១៤កើត ខែបុស្ស ពុទ្ធសករាជ ២៥៥៨

ដោយ សុវណ្ណជោតោ ភួង-សុវណ្ណ

# ទ្រង់ប្រារព្ធចំពោះឆត្តបាណិឧបាសក

**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ**

**ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ឲ**

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌(ល្អ) តែគ្មានក្លិន (ក្រអូបរមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាម ដូច្នោះ ។

**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ**

**ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោឲ**

ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្តេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពជាធម្មទាន

សូមអនុមោទនា កុសលចេតនាប្រកបដោយសទ្ធា និងបញ្ញា

របស់ពុទ្ធបរិស័ទ ក្នុងការចូលរួមបោះពុម្ពជាធម្មទា

-លោកម្ចាស់គ្រូ សាន សប្បាយ 100$ + 200,000 រៀល

-ភិក្ខុ សុមនា 100$ + 200,000 រៀល -ភិក្ខុ ស៊ិន ផល្លា 20$

-ឧបាសក គួច គួងឡេង ឧបាសិកា តាំង យូគាង និងកូនចៅ ២០០ ដុល្លារ

-ឧបាសក ជាម ហួរហុង ឧបាសិកា សុខ គាង និងកូនចៅ ២០០ ដុល្លារ

-ឧបាសក មាស ខេង ឧបាសិកា មួរ រួច និងកូនចៅ ១០០ ដុល្លារ

-ឧបាសក គួច ប៊ុនលី និង អ៊ឹង ម៉េងសាង និងបុត្រ ១០០ ដុល្លារ

-លោក រស់ ថារិទ្ធ និងលោកស្រី សេង សុខពិសី ហៅ ពេជ្យ ព្រមទាំងកូន

កញ្ញា រស់ កែវសោភ័ណ កញ្ញា រស់ សែនប្រសើរដួង ១០០ ដុល្លារ

-ឧបាសក អោក បូរ៉ា និងឧបាសិកា សួន សុគន្ធា ព្រមទាំងបុត្ត ១០០ ដុល្លារ

-ឧបាសិកា ច័ន្ទ បុប្ផាណា និងបុត្រ ១០០ ដុល្លារ

-ក្រុមវេនថ្ងៃ ១០ កើត វត្តនិគ្រោធវ័ន ៧០ ដុល្លារ

-ឧបាសក ដៀប នួច និងឧបាសិកា ចាប សុម៉ាលី និងកូនចៅ 200,000 រៀល

-ឧបាសិកា យាន ច័ន្ទលី និងក្មួយ ឧបាសិកា យាន ថារី និងឧបាសក

យាន សុភ័ក្រ 50$ -ឧបាសិកា កៅ យក់ឡាយ 50$

-ឧបាសក គឹម គិន ឧបាសិកា ចែម ស្រី ព្រមទាំងកូនចៅ 50$

-ឧបាសិកា គឹម នាង និងស្វាមី 50$ -ឧបាសិកា ឡុង ថាច 50$

-ឧបាសិកា មាស ពិសី 30$ -ឧបាសិកា គួច ភិនគាង 20$

-ឧបាសក សាក់ ម៉ូនី ឧបាសិកា ង៉ា ពៅ និងបុត្រ 25$

-ឯកឧត្តម ជា លីស្រ៊ុន លោកជំទាវ សាក់ ម៉ូនីឡារ៉ូ និងបុត្រ 25$

-ឧបាសក ខៀវ កូឡា ឧបាសិកា លឿង លៀងហួរ និងកូនចៅ 20$

-ឧបាសិកា ហេ្គច ហួយ និងស្វាមី និងកូនចៅ 20$

-ឧបាសិកា ខេង លាភារី (អាភា) និងអ្នកម្តាយ 20$

-លោក សា សារ៉ា ឧបាសិកា គី ស្រីថា និងកូន ២០ ដុល្លារ
-ឧបាសក ប៊ុន សុខខឿន ៨០,០០០រៀល
-ពុទ្ធបរិស័ទ នៅទឹកថ្លា ៦០,០០០ រៀល
-ឧបាសិកា ជា គឹមហៀប និងបុត្រ 15$
-ឧបាសិកា លីម ផិចហៀង និងកូនចៅ 15$
-ឧបាសិកា អ៊ិត សោភ័ណ និងស្វាមី និងកូន 10$ + 20,000 រៀល
-ឧបាសិកា អ៊ឹម ប៊ុនលី ឧបាសិកា អ៊ឹម ធានី ឧបាសិកា សំ សុខ 50,000 រៀល
-ឧបាសិកា តារា តូច និងមិត្ត 55,000 រៀល
-លោកស្រី ជុំ ណារ៉ា និងបងប្អូន 50,000 រៀល
-ឧបាសក ដាំ កុយ ឧបាសិកា សុខ ពៅ និងកូនចៅ 40,000 រៀល
-ឧបាសិកា អ៊ូ សុខសាន្ត និងកូនចៅ 40,000 រៀល
-ឧបាសក឵ ឃី លាងឈុន ឧបាសិកា សុខ ជិនថា និងកូនចៅ 40,000 រៀល
-ឧបាសិកា ស៊យ សារឿន 40,000 រៀល -ឧបាសិកា សុគន សុ៊ីនួន 40,000 រៀល
-លោក ប៊ុន រ៉េត ឧបាសិកា សាក់ ម៉ូនីរ័ត្ន និងបុត្រ 10$
-ឧបាសក អ៊ុក សំណាង ឧបាសិកា ប៉ាល់ ធីតា និងកូនចៅ 10$
-ឧបាសិកា អ៊ុន ញ៉ូ និងកូនចៅ 10$ -ឧបាសិកា អ៊ុន ហ៊ន និងកូនចៅ 10$
-ឧបាសិកា តា យូអេង និងកូនចៅ 10$ -ឧបាសិកា សុខ ជី 10$ តា តា 10$
-ឧបាសក អោ សុភ័ក្ត្រ និងមាតាបិតា 10$ -ឧបាសិកា អូន ហោមរ៉ា 10$
-ឧបាសិកា ហេង ស៊ីវខេង និងបងប្អូន 10$ -ឧបាសក ភិន ញ៉ក់ 10$
-ឧបាសិកា សៀង គីមអេង និងបុត្រ 10$ -ឧបាសិកា ខឹម ស៊ាងហៃ 10$
-ឧបាសក ធន ច័ន្ទសុជាតិ និងមាតាបិតា 10$ - អ៊ី មួយគា 10$
-ឧបាសិកា ជា សុផល និងក្រុមគ្រួសារ 10$ -ឧបាសិកា ផុន អ៊ាងលន 10$
-ឧបាសិកា ហ្សួត សាអ៊ឹត និងកូនចៅ 10$ -ឧបាសក តាំង ហៃថាំង 10$
-ឧបាសិកា ជូ គីមស្រាយ និងស្វាមី និងកូនចៅ 10$
-ឧបាសក ទ្រី ហេង ឧបាសិកា លាង មន្ថា និងកូនចៅ 10$

-ឧបាសិកា សៀក លាងជាវ និងស្វាមី ឆាវ និងកូនចៅ 10$
-ឧបាសិកា ឡាយ គឹមលាង ឧបាសិកា ឡេង សុគន្ធ 10$
-ឧបាសក ហ៊ឹ អ៊ុនសេង និងឧបាសិកា ហ៊ឹម ស៊ីមណៃ និងកូនចៅ 10$
-ឧបាសិកា ញូង អ៊ាង ហៅ លន និងស្វាមី និងកូនចៅ 10$
-ឧបាសិកា សេង ដាវី 30,000 រៀល -ឧបាសិកា ផុន យឿន 30,000 រៀល
-លោក អ៊ុច ជយោ និងអ្នកស្រី នូ សារ៉េម និងបុត្រ 20,000 រៀល
-ឧបាសិកា សេង ចិន្តា និងកូនចៅ ២០០០០ រៀល
-ឧបាសិកា ស្រេង យាន និងស្វាមី និងកូនចៅ 20,000 រៀល
-ឧបាសិកា ម៉ៅ ថេង និងស្វាមី និងកូន 20,000 រៀល
-ឧបាសិកា មាស ស្រីទូច 20,000 រៀល
-ឧបាសិកា ហែម ណាវី និងបុត្រ 20,000 រៀល
-ឧបាសិកា តាំង គីមណៃ និងបុត្រ 20,000 រៀល
-អ្នកនាង តាំង ស្រីនីន និងស្វាមី 20,000 រៀល
-ឧបាសិកា រស់ សុីមន ឧបាសិកា ពៅ និងកូនចៅ 20,000 រៀល
-ឧបាសក លឹម គុណអាន និងក្រុមគ្រួសារ 20,000 រៀល
-ឧបាសក ហេង ប៉ូ និងក្រុមគ្រួសារ 20,000 រៀល
-ឧបាសិកា សៀ ចាន់ណា និងកូនចៅ 20,000 រៀល
-ឧបាសិកា ឡាយ គុយហួង និងកូនចៅ 20,000 រៀល
-ឧបាសិកា ហួត គឹមហេន 20,000 រៀល -ឧបាសិកា ជី ប៉េង 20,000 រៀល
-ឧបាសិកា សេង វណ្ណី 20,000 រៀល -ឧបាសិកា អុន អ៊ុក 20,000 រៀល
-ឧបាសិកា អ៊ុក សៅនក និងស្វាមី និងកូនចៅ 05$
-ឧបាសិកា ឡាំង ស៊ីវម៉េង និងកូនចៅ 05$ -ឧបាសិកា កេង ណៃ 05$
-យុវជន ប្រាក់ ពិសិដ្ឋ និងមាតាបិតា 10,000 រៀល
-ឧបាសិកា ប៉ា ស៊ីណាត 10,000 រៀល
-ឧបាសិកា ប៊ូយ គឹមស៊ុន 10,000 រៀល

-ឧបាសិកា ឈុន ចំណាន និងកូនចៅ 10,000 រៀល

-ឧបាសិកា ឈឹម សុខុម និងកូនចៅ 10,000 រៀន

-ឧបាសិកា ឆៃ លីន និងបុត្រ 10,000 រៀល

-ឧបាសក នៅ ប៊ូអេង និងភរិយា កូនចៅ 10,000 រៀល

-ឧបាសិកា មូល វណ្ណថេត 10,000 រៀល -ឧបាសិកា ប៊ួយ គឹមស

-ឧបាសិកា អ៊ាង ពត 10,000 រៀល

-ឧបាសិកា សេក សារុន និងញាតិ 10,000 រៀល

-ឧបាសិកា ប៉ែន ស៊ីហ៊ាង 10,000 រៀល

-ឧបាសិកា តាំង មុយហ្គេច និងស្វាមី កូនចៅ 10,000 រៀល

-ឧបាសក ហេង កុកលី និងក្រុមគ្រួសារ 02$

=> ដោយអានុភាពនៃបុណ្យធម្មទាន សូមបានសេចក្ដីសុខ កុំមានទុក្ខឡើយ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ជាឧបនិស្ស័យនៃបញ្ញា មានសម្មាទិដ្ឋិ ប្រតិបត្តិប្រពៃ បានត្រាស់ដឹងសច្ចធម៌ រួចផុតចាកទុក្ខទាំងពួង ។